ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



- តើសហរដ្ឋអាមេរិកគួរតែផ្ដល់មូលនិធិហិរញ្ញវត្ថុដោយផ្ទាល់ដល់សាលាក្ដីខ្មែរក្រហមឬទេ?
- សាលាក្ដីខ្មែរក្រហមមានសារសំខាន់ចំពោះសហគមន៍អន្តរជាតិ

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ៩៧ ខែមករា ឆ្នាំ២០០៨

## ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

## មាតិកា


◆ សំបុត្រ ៖ តើសហរដ្ឋអាមេរិកគួរតែផ្ដល់មូលនិធិហិរញ្ញវត្ថុ....................១

**ផ្នែកឯកសារ**

◆ ៣០ឆ្នាំក្រោយមក ....................................................................៣

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ គុកខ្មែរក្រហម ........................................................................៨

◆ ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ..........................................១៥

◆ ធម្មយាត្រាដើម្បីយុត្តិធម៌និងសន្តិភាព ..........................................២២

◆ ត្រៀមខ្លួនស្វែងរកយុត្តិធម៌ ......................................................២៦

◆ តម្លៃនៃការនិយាយពីជម្លោះអតីតកាល .......................................២៨

**ផ្នែកច្បាប់**

◆ នៅចំពោះមុខអង្គបុរេជំនុំជម្រះនៃអង្គជំនុំជម្រះវិសាមញ្ញ ..............៣២

◆ ការិយាល័យរដ្ឋបាលរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ..៤២

◆ សាលាក្ដីខ្មែរក្រហមមានសារសំខាន់ចំពោះសហគមន៍ ...................៤៥

**វេទិកាពិភាក្សាសាធារណៈ**

◆ ការកែប្រែរចនាសម្ព័ន្ធតុលាការកូនកាត់ ....................................៤៨

◆ ការស្លាប់ដោយការអត់អាហារក្នុងរបបកម្ពុជាប្រជាធិបតេយ្យ.........៥៤

**ទំព័រស្រាវជ្រាវរកក្រួសារ**

◆ ខ្ញុំចង់រំឭក ខ្ញុំចង់ឃើញ ខ្ញុំចាំមើល ...........................................៦០








## រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ ០២៩១ពម/៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩


រូបថតឯកសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង


**ស្នេរលេខនេះ ៖** ឌី ខាំបូលី, ផេង ពង្សរ៉ាស៊ី, ប៉ាង ពីវ័ន, ដឺទីល ក្រូដឹម, ដេវីដ សេហ៊ុរ, អែន ហេនដែល, អេតែល ហ៊ីហ្គូនេត, សូឡូម៉ុន បាសុិ, តុងរ៉ា
**អ្នកនិពន្ធនិងស្រាវជ្រាវ ៖** គាត លក្ខិណា, សោម ប៊ុនថន **អ្នកបកប្រែ ៖** ព្រាំ ផល្លា និង ជា ផល្លា **និពន្ធនាយកទូទៅ៖** ឆាំង យុ **ជំនួយការនិពន្ធនាយក ៖** លី សុផល
**ក្រាហ្វិក កុំព្យូទ័រ ៖** ស៊ឹម សុភ័ក្ត្រ **គ្រប់គ្រងការចែកផ្សាយ ៖** រ័ត្ន តារាពិដោរ Email: dccam@online.com.kh, Homepage: www.dccam.org

*សំបុត្រ :*

# តើសហរដ្ឋអាមេរិកគួរតែផ្តល់មូលនិធិហិរញ្ញវត្ថុដោយផ្ទាល់ដល់សាលាក្តីខ្មែរក្រហមដែរឬទេ?

*លោកឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំនៅកម្ពុជា ចូសេហ្វ មូសូមេលី និងសហការីរបស់លោកយល់ឃើញថា អង្គជំនុំជម្រះវិសាមញ្ញកំពុងតែមានដំណើរការត្រឹមត្រូវនិងសមតែទទួលបាននូវការគាំទ្រដោយផ្ទាល់ពីសហរដ្ឋអាមេរិក ។ ខ្ញុំជឿជាក់ថា ជំនួយដោយផ្ទាល់ពីសហរដ្ឋអាមេរិកដល់សាលាជំនុំជម្រះក្តីនេះគឺជាបញ្ហាសមហេតុផល ក្នុងករណីដែលអង្គជំនុំជម្រះវិសាមញ្ញយល់ស្របទៅនឹងកំណែទម្រង់សំខាន់ៗមួយចំនួនដើម្បីឲ្យសាលាជំនុំជម្រះក្តីនេះស្ថិតនៅលើគន្លងដ៏ត្រឹមត្រូវ ។*

***១) ការប្តេជ្ញាប្រឆាំងនឹងអំពើពុករលួយៈ*** *លក្ខខណ្ឌមួយសំខាន់នោះគឺថា អង្គជំនុំជម្រះវិសាមញ្ញត្រូវអនុម័តការគ្រប់គ្រងដែលប្រឆាំងនឹងអំពើពុករលួយឲ្យបានតឹងរ៉ឹង ។ ចាប់តាំងពីការបញ្ចេញជាសាធារណៈនូវរបាយការណ៍សវនកម្មរបស់កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិកាលពីប៉ុន្មានខែកន្លងទៅនេះ សាលាជំនុំជម្រះក្តីបានចាត់វិធានការតិចតួចណាស់ក្នុងការទប់ស្កាត់អំពើពុករលួយដែលទទួលរងនូវការចោទប្រកាន់ ។ អង្គជំនុំជម្រះវិសាមញ្ញត្រូវតែចាត់តាំងបង្កើតនូវគណៈកម្មាធិការមួយជាបន្ទាន់ដើម្បីស៊ើបអង្កេតរាល់ការចោទប្រកាន់ និងត្រូវចាត់វិធានការចំពោះបុគ្គលិកទាំងឡាយណាដែលត្រូវបានរកឃើញថាបានជាប់ពាក់ព័ន្ធនឹងការប្រព្រឹត្តសកម្មភាពមិនស្មោះត្រង់ ។ អង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាត្រូវតែប្តេជ្ញាជាសាធារណៈប្រកាន់យកវិធានការតឹងរ៉ឹង ។ សំខាន់បំផុតនោះ ការជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហមនេះគឺជាឱកាសមួយដើម្បីបង្ហាញប្រជាជនកម្ពុជាអំពីរបៀបក្នុងការស្វែងរកយុត្តិធម៌ ហើយបញ្ហាពុករលួយនេះអាចធ្វើឲ្យដំណើរការនេះមានឥទ្ធិពលអាក្រក់ឬមិនអាចបន្តទៅទៀតបាន ។*

***២) រយៈពេលប្រតិបត្តិការជាក់លាក់ៈ*** *អង្គជំនុំជម្រះវិសាមញ្ញចាំបាច់ត្រូវតែកំណត់ឲ្យបានច្បាស់លាស់នូវរយៈពេលនៃការបញ្ចប់កិច្ចការរបស់ខ្លួន ។ វាមានសារសំខាន់ណាស់ក្នុងការរៀបចំដំណើរការជំនុំជម្រះដោយប្រុងប្រយ័ត្ននិងចេញសាលក្រមត្រឹមត្រូវ ប៉ុន្តែប្រសិទ្ធភាពការងារក៏សំខាន់ណាស់ដែរ ។ ប្រជាជនកម្ពុជាបានរង់ចាំមើលយុត្តិធម៌អស់រយៈពេល៣០ឆ្នាំមកហើយ ដូច្នេះដំណើរការដែលចំណាយពេលច្រើនដោយមិនចាំបាច់នឹងទំនងជាបង្កឲ្យមានការមិនពេញចិត្តពីសាធារណជន ។*

*ប្រសិនបើអង្គជំនុំជម្រះវិសាមញ្ញត្រូវចំណាយពេលវេលាយូរអង្វែងដូចជាសាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ឬរ៉្វាន់ដានោះ ចុងចោទដែលជាអតីតមេដឹកនាំខ្មែរក្រហមទាំងអស់ប្រហែលជាត្រូវបាត់បង់ជីវិតអស់ដោយមិនបានជំនុំជម្រះឡើយ ។*

***៣) គម្រោងហិរញ្ញវត្ថុដែលអាចទុកចិត្តបានៈ*** *អង្គជំនុំជម្រះវិសាមញ្ញចាំបាច់ត្រូវរៀបចំនូវផែនការហិរញ្ញវត្ថុច្បាស់លាស់ ។ ការណ៍ដែលថា អង្គជំនុំជម្រះនេះបានស្នើថវិកាបន្ថែម ហើយនោះគឺជារឿងគួរឲ្យព្រួយបារម្ភដែរ ។ តុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូនបានចាប់ផ្តើមដោយថវិកាចំនួន៥៦លានដុល្លារ និងកំណត់រយៈពេលបីឆ្នាំដូចអង្គជំនុំជម្រះវិសាមញ្ញដែរ ប៉ុន្តែឥឡូវនេះបានចំណាយពេលអស់ប្រាំឆ្នាំ និងថវិកាប្រមាណ១៥០លានដុល្លារ និងថែមទាំងមិនដឹងថានឹងត្រូវបញ្ចប់នៅពេលណាទៀតផង ។ សាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសយូហ្គោស្លាវីនិងរ៉្វាន់ដា មកទល់នឹងពេលនេះបានចំណាយថវិកាអស់ជាង២ពាន់លានដុល្លារ ។ នៅពេលខ្លះសាលាជំនុំជម្រះក្តីបានជំរុញឲ្យប្រទេសម្ចាស់ជំនួយផ្តល់ថវិកាបន្ថែម ដោយទទូចថាយុត្តិធម៌មិនអាចកើតមានបានទេប្រសិនបើមិនមានការជួយឧបត្ថម្ភបន្ថែមផ្នែកហិរញ្ញវត្ថុ ។ នៅពេលខ្លះការអះអាងបែបនេះគឺសមរម្យ ប៉ុន្តែយើងចាំបាច់ត្រូវផ្តល់ចំណាប់អារម្មណ៍ឲ្យបានគ្រប់គ្រាន់ទៅលើបញ្ហានេះ ។ ការិយាល័យធិបតេយ្យអាចកើតមានគ្រប់ពេលវេលា*

ហើយការិយាល័យធិបតេយ្យមិនលើកលែងទោសសម្រាប់សាលាជំនុំជម្រះក្តីទាំងនេះ ។ អង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាប្រហែលជាមើលឃើញថា ជោគជ័យខ្លះៗរហូតមកដល់ពេលនេះរបស់អង្គជំនុំជម្រះវិសាមញ្ញ ជាមធ្យោបាយដើម្បីស្វែងរកថវិកាបន្ថែម ប៉ុន្តែថវិកាបន្ថែមនេះគួរតែផ្តល់ឲ្យនៅក្នុងករណីដែលអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាប្តេជ្ញាប្រកាន់យកមធ្យោបាយដែលមានប្រសិទ្ធភាព ដូចជាប្រើប្រាស់ធនធានក្នុងស្រុកនិងប្រើឲ្យអស់លទ្ធភាពនូវតួនាទីរបស់ខ្លួនតាមដែលអាចធ្វើទៅបាន ។

**៤) ការចូលរួមដោយសង្គមស៊ីវិលៈ** លក្ខខណ្ឌមួយទៀតសម្រាប់ការផ្តល់ជំនួយដោយផ្ទាល់របស់សហរដ្ឋអាមេរិកដែលទាក់ទងទៅនឹងលក្ខខណ្ឌខាងលើនោះគួរតែរួមបញ្ចូលនូវការចូលរួមដោយសង្គមស៊ីវិលនៅក្នុងការត្រួតពិនិត្យមើលយូរៗម្តងនូវប្រតិបត្តិការនិងថវិការបស់អង្គជំនុំជម្រះវិសាមញ្ញ ។ សំឡេងពីខាងក្រៅអាចជួយដល់អង្គជំនុំជម្រះវិសាមញ្ញក្នុងការលៃលកធនធានមានប្រសិទ្ធភាពជាងជួយដោះស្រាយឧបសគ្គនយោបាយនិងផ្តល់នូវតួនាទីឃ្លាំមើលដ៏មានប្រយោជន៍ ។ ការផ្តល់កន្លែងជាផ្លូវការមួយនៅក្នុងវេទិកាត្រួតពិនិត្យមើលបែបនេះនឹងធ្វើឲ្យយើងអាចត្រួតពិនិត្យមើលនិងឆ្លើយតបទៅនឹងដំណើរការនេះបានដោយប្រសិទ្ធភាពជាង ។

កំណែទម្រង់ខាងលើនេះនឹងមិនអាចលុបបំបាត់នូវរាល់ភាពប្រថុយប្រថានរបស់សាលាជំនុំជម្រះក្តីនេះទេ ប៉ុន្តែអង្គជំនុំជម្រះវិសាមញ្ញចាំបាច់ត្រូវធ្វើកំណែទម្រង់ទាំងនេះ ប្រសិនបើចង់បំពេញតួនាទីរបស់ខ្លួនឲ្យមានប្រសិទ្ធភាព ។ ជំនួយរបស់សហរដ្ឋអាមេរិកប្រហែលជាមិនសូវសំខាន់ខាងផ្នែកហិរញ្ញវត្ថុសម្រាប់អង្គជំនុំជម្រះវិសាមញ្ញទេ ប៉ុន្តែអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជានឹងមើលឃើញការចូលរួមរបស់សហរដ្ឋអាមេរិកគឺមានសារសំខាន់ខាងផ្នែកនយោបាយនិងជានិមិត្តរូប ។ រដ្ឋាភិបាលសហរដ្ឋអាមេរិកគួរតែប្រើប្រាស់ឱកាសនេះដើម្បីជំរុញឲ្យមានការកែទម្រង់តាមរយៈធ្វើការយ៉ាងជិតស្និទ្ធជាមួយប្រទេសជប៉ុនដើម្បីប្រមូលយកការគាំទ្រឆ្ពោះទៅរកការសម្រេចគោលដៅកំណែទម្រង់នេះ ។

បន្ថែមទៅលើការជួយឲ្យអង្គជំនុំជម្រះវិសាមញ្ញមានដំណើរការបានតទៅទៀត ជំនួយរបស់សហរដ្ឋអាមេរិកដែលមានដាក់លក្ខខណ្ឌត្រឹមត្រូវនឹងជួយធានាថារដ្ឋាភិបាលសហរដ្ឋអាមេរិកនឹងទទួលបាននូវការសរសើរសមរម្យចំពោះកិច្ចការនាំយកមេដឹកនាំខ្មែរក្រហមទៅជំនុំជម្រះទោស ។ អ្នកចូលរួមដទៃទៀតនៅក្នុងដំណើការនេះមានឆន្ទៈចង់ដឹកនាំអង្គជំនុំជម្រះវិសាមញ្ញនេះនិងចង់បានគុណសម្បត្តិចំពោះកិច្ចការនេះដែរ ប៉ុន្តែការជំនុំជម្រះក្តីនេះនឹងមានប្រសិទ្ធភាពបំផុតជាមួយនឹងការបន្តការដឹកនាំគាំទ្រដោយសហរដ្ឋអាមេរិក ។ ប្រសិនបើរដ្ឋាភិបាលសហរដ្ឋអាមេរិកផ្តល់ជំនួយដល់អង្គជំនុំជម្រះវិសាមញ្ញដោយមានដាក់លក្ខខណ្ឌត្រឹមត្រូវ ខ្ញុំជឿជាក់ថា ថវិកានេះនឹងចំណាយយ៉ាងត្រឹមត្រូវ ហើយជាប្រយោជន៍ដល់ជនរងគ្រោះទៀតផង ។

**ឆាំង យុ**



ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា

# ៣០ឆ្នាំក្រោយមក

របបកម្ពុជាប្រជាធិបតេយ្យដែលចាប់ផ្តើមពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ បានបណ្តាលឲ្យប្រជាជនកម្ពុជាស្លាប់អស់ប្រមាណជាង ១,៧លាននាក់ ។ គ្រួសារមួយចំនួនធំត្រូវបានសម្លាប់ស្ទើរផុតពូជ ហើយបន្សល់ទុកនូវស្ត្រីមេម៉ាយនិងកុមារកំព្រាជាច្រើន ។ កុមារខ្លះមានឱកាសបានវិលត្រឡប់ទៅស្រុកកំណើតរស់នៅជួបជុំញាតិសន្តាន ប៉ុន្តែកុមារមួយចំនួនមិនអាចវិលត្រឡប់ទៅស្រុកកំណើតវិញដោយសារតែមិនចាំស្រុកកំណើតនិងប្រវត្តិក្រុមគ្រួសារច្បាស់លាស់ ។ សេក សាយ ជាអតីតកុមារីរងគ្រោះម្នាក់នៅក្នុងរបបនេះ ហើយដែលបានបែកពីក្រុមគ្រួសារសាច់ញាតិតាំងពីអាយុប្រហែល ១២ឆ្នាំគឺចាប់តាំងពីរបបវាលពិឃាតនេះដួលរលំនៅឆ្នាំ ១៩៧៩ ។ សេក សាយ ត្រូវបងប្រុសជីដូនមួយខាងឪពុកឈ្មោះ សេក សារ៉ុន កំពុងស្វែងរកគ្រប់ទីកន្លែង ។ សារុន បានចុះផ្សាយដំណឹងអំពីការបាត់ខ្លួនរបស់ សាយ នៅក្នុងអត្ថបទមួយដែលមានចំណងជើងថា «និរសារតំបន់២៥» នៅក្នុងទស្សនាវដ្តីស្វែងរកការពិត ។ តាមរយៈអត្ថបទនេះ សារ៉ុន បានទទួលដំណឹងថា សាយ កំពុងរស់នៅក្នុងខេត្តកំពង់ស្ពឺ ។ ចំណែក សាយ ក៏កំពុងស្វែងរកដំណឹងឪពុកម្តាយបងប្អូននិងសាច់ញាតិអស់រយៈពេល៣០ឆ្នាំដែរ ហើយអ្វីដែល សាយ ទទួលបានគឺដំណឹងអំពីការស្លាប់របស់ឪពុកម្តាយនិងរូបថតម្តាយថតជាមួយប្អូនប្រុសមួយសន្លឹក ។

យោងតាមការរៀបរាប់របស់ សាយ បានឲ្យដឹងថាៈ

សេក សាយ ហៅ សេក សុធី មានបងប្អូនបីនាក់ ។ សាយ ជាកូនស្រីច្បងដែលមានឪពុកឈ្មោះ សេក សាត ហៅ ប្រាក់ និងម្តាយឈ្មោះ ចាន់ គឹមស្រ៊ុន ហៅ សាង ។ អ្នកទាំងពីរបានបម្រើការជាកងទ័ពខ្មែរក្រហមតាំងពីមុនខ្មែរក្រហមឡើងកាន់អំណាចទាំងស្រុង ។ ក្រោយពីកងទ័ពខ្មែរក្រហមពីវាយដណ្តើមបានជ័យជម្នះពីរបបសាធារណរដ្ឋខ្មែរនៅថ្ងៃទី១៧មេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានប្តូរឈ្មោះរបបនេះថាជា «កម្ពុជាប្រជាធិបតេយ្យ» ។ សេក សាត ហៅ សេក ប្រាក់ បានទទួលតំណែងជាលេខាតំបន់២៥ ហើយ ចាន់ គឹមស្រ៊ុន មានតួនាទីជាប្រធានរោងចក្រតម្បាញនៅតំបន់២៥ ។ នៅខែឧសភា ឆ្នាំ១៩៧៨ ប្រាក់ ត្រូវអង្គការចាប់ខ្លួនបញ្ជូនមកមន្ទីរស-២១ជាមួយប្រពន្ធព្រមទាំងកូនប្រុសពៅដែលមានវ័យមិនដល់មួយឆ្នាំផង ។ ក្រោយមក អ្នកទាំងបីត្រូវអង្គការបញ្ជូនទៅសម្លាប់ចោល ។ ចំណែក សាយ និងប្អូនស្រី ព្រមទាំងសាច់ញាតិទាំងអស់ដែលពាក់ព័ន្ធត្រូវបានបញ្ជូនទៅកាន់មន្ទីរលត់ដំដៃជ្រអូរញ្ញោ ។ ក្រុមគ្រួសារអ៊ឹមាមីងខាងឪពុកភាគច្រើនរបស់ សាយ មានសំណាង



សេក សាយ ហៅ សេក សុធី

បានវិលត្រឡប់ទៅកាន់ស្រុកកំណើតវិញ លើកលែងតែក្រុមគ្រួសាររបស់ សាយ ដែលត្រូវនិរាសព្រាត់ប្រាសគ្នា ។ ប្អូនស្រីរបស់ សាយ បានស្លាប់ដោយសារជំងឺគ្រុនក្តៅលើលនៅពេលរត់ចេញពីមន្ទីរសន្តិសុខ ជ្រៃអូរញ៉ោជាមួយម្តាយមីងទៅកាន់ស្រុកកៀនស្វាយ ។ ចំណែក សាយ រត់ចេញពីមន្ទីរសន្តិសុខជ្រៃអូរញ៉ោ ធ្លាក់មកនៅខេត្តកំពង់ស្ពឺ ។

រំឭកដល់កុមារភាពរបស់ខ្លួន សាយ អាចចងចាំបាននូវហេតុការណ៍មួយចំនួននិងអនុស្សាវរីយ៍ដ៏តិចតួចក្នុងខណៈពេលរស់នៅជាមួយឪពុកម្តាយនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ។

នៅខណៈពេលដែលឪពុកម្តាយរបស់ សាយ បម្រើការនៅស្រុកត្រាំខ្នារក្នុងខេត្តតាកែវ សាយ ត្រូវបានជីដូនយកទៅចិញ្ចឹមនៅឯខេត្តកំពង់ស្ពឺ ។ យូរៗទើបឪពុកទៅយកមកលេងផ្ទះម្តង ។

សាយ រំឭកថា ពេលគាត់ទៅលេងផ្ទះនៅខេត្តតាកែវម្តងៗ គាត់តែងឃើញម្តាយគាត់ធ្វើសៀងយ៉ាងច្រើនសម្រាប់ផ្គត់ផ្គង់កងទ័ព ។ ចំណែកឪពុករបស់គាត់ចេញទៅធ្វើការបាត់ៗតាំងពីព្រលឹមពេលល្ងាចទើបត្រឡប់មកផ្ទះវិញ ។

មានពេលមួយ សាយ បានធ្លាក់ខ្លួនឈឺធ្ងន់ ហើយជីដូនបានបញ្ជូនទៅព្យាបាលនៅមន្ទីរពេទ្យក្រុងកំពង់សោម ។ ពេលដឹងថា សាយ សម្រាកនៅមន្ទីរពេទ្យ សាង បានយក សាយ មកសម្រាកព្យាបាលនៅមន្ទីរពេទ្យភ្នំពេញវិញ ដែលមានទីតាំងនៅក្បែរស្ពានព្រះមុន្នីវង្ស ។ ពេលបានជាសះស្បើយ សាយ បានសុំម្តាយត្រឡប់ទៅរស់នៅជាមួយជីដូននៅខេត្តកំពង់ស្ពឺវិញ ។

នៅពេលចុងក្រោយនេះ(មិនចាំឆ្នាំ) ឪពុកម្តាយរបស់ សាយ បានផ្លាស់ប្តូរទីលំនៅមករស់នៅទីក្រុងតាខ្មៅវិញ ហើយអ្នកទាំងពីរបានយក សាយ មករស់នៅជាមួយដែរ ។ សាយ នៅចាំបានថា ពេលគាត់ទៅដល់ គាត់បានឃើញម្តាយរបស់គាត់បង្កើតបានកូនប្រុសម្នាក់ទៀត ។ រយៈពេលពីរ-បីខែពេលរស់នៅផ្ទះក្រុងតាខ្មៅ សាយ មិនហ៊ានទៅបើករបបហូបទៀងទាត់ទេ ព្រោះគាត់មិនបានទៅធ្វើការដូចគេ ។ ដោយឃើញដូច្នេះ ឪពុកម្តាយរបស់ សាយ ក៏បានយកគាត់ទៅផ្ញើនៅរោងសិប្បកម្មតម្បាញមួយរយៈដើម្បីឲ្យគាត់មានការងារធ្វើនឹងគេនិងទទួលបានរបបហូបដូចគេឯង ។ ក្រោយមកអ្នកទាំងពីរបានយក សាយ ទៅផ្ញើនៅមន្ទីរពេទ្យសំប៉ាន វិញ ។

## មន្ទីរពេទ្យសំប៉ាន

មន្ទីរពេទ្យសំប៉ានមានទីតាំងនៅក្នុងខេត្តកណ្តាលជាកន្លែងផលិតថ្នាំនិងជាកន្លែងសម្រាប់ព្យាបាលកងទ័ពរបួសដាច់ដៃជើងនៅសមរភូមិ ។ អ្នកទាំងពីរបានយក សាយ ទៅផ្ញើនៅខាងផ្នែកផលិតឱសថគ្រាប់នៅមន្ទីរពេទ្យសំប៉ាន ពីព្រោះថានៅក្នុងផ្នែកនេះមានកុមារីធ្វើការប្រហែលជា៣០នាក់និងគ្រូពេទ្យចំណាស់ៗ៤-៥នាក់ជាអ្នកមើលការខុសត្រូវលើកុមារនិងការផលិតថ្នាំគ្រាប់ ។ មីងរបស់ សាយ ម្នាក់ឈ្មោះ វន ក៏ធ្វើការនៅទីនោះដែរ ។ ក្នុងចំណោមកុមារទាំងនោះ សាយ មានអាយុតិចជាងគេ ។ ពេលថ្ងៃ សាយ និងកុមារីផ្សេងទៀតនាំគ្នាសែងសំបកដបទៅលាងទឹកទន្លេ ។ ភារកិច្ចរបស់ សាយ គឺគ្រាន់តែឈរចាំចុចយកគ្រាប់ថ្នាំឲ្យធ្លាក់ចេញពីម៉ាស៊ីនសង្កត់ថ្នាំ បន្ទាប់មកប្រមូលយកគ្រាប់ថ្នាំដែលផលិតបានទៅហាលថ្ងៃឲ្យស្ងួត ។ នៅពេលទំនេរពីការងារ សាយ យកបន្លែទៅលាងឲ្យចុងភៅ ។ នៅទីនោះ សាយ ទទួលបានរបបបាយហូបគ្រប់គ្រាន់ ។

ចាប់តាំងពីធ្វើការនិងស្នាក់នៅក្នុងមន្ទីរពេទ្យនេះមក សាយ មិនដែលមានឱកាសទៅលេងឪពុកម្តាយនៅក្រុងតាខ្មៅឡើយ ។ សាយ ធ្វើការនៅមន្ទីរពេទ្យនេះរហូតដល់ថ្ងៃអង្គការបញ្ជូនមកសន្តិសុខជ្រៃអូរញ៉ោ ។ ធ្វើការនៅទីនោះបានរយៈពេលយូរបន្តិច ថ្ងៃមួយនៅពេលបាក់រសៀលម៉ោងប្រហែល៥ល្ងាច បុរសម្នាក់បានមកទទួល សាយ ចេញពីមន្ទីរពេទ្យ ។ សាយ ស្គាល់ច្បាស់ថាបុរសម្នាក់នោះឈ្មោះ ខន ជាអ្នកបើករថយន្តឲ្យឪពុកម្តាយរបស់ខ្លួន ។ ខន បានប្រាប់ សាយ ថាអង្គការឲ្យទៅលេងម៉ែនៅស្រុកថ្មីភូមិថ្មី ដូច្នេះមិនបាច់យកមុងភួយទៅទេ ប៉ុន្តែ សាយ នៅតែជម្នះយកអីវ៉ាន់ដែលខ្លួនមានទៅជាមួយតាមបណ្តាំរបស់ម្តាយដែលផ្តែផ្តាំថា «*ពេលទៅណាវេចទៅឲ្យអស់*» ។ ខន បានទទួលបញ្ជាពីថ្នាក់លើឲ្យនិយាយដូច្នេះដើម្បីលួងលោមឲ្យ សាយ ឡើងរថយន្ត ។ សាយ ត្រូវបានដឹកទៅកាន់គុកជ្រៃអូរញ៉ោទាំងយប់ដោយឆ្លងកាត់ផ្ទះនៅក្រុងតាខ្មៅដែល សាយ ស្គាល់ច្បាស់ថាជាផ្ទះរបស់ខ្លួន ។ សាយ បានសុំ ខន ដាក់គាត់ចុះ ប៉ុន្តែ ខន ប្រាប់ថា ឪពុកម្តាយរបស់គាត់នៅភូមិថ្មីឯណោះ ។ «គេទៅយកខ្ញុំនៅពេទ្យសំប៉ានមកដល់តាខ្មៅ ខ្ញុំសុំគេចុះ គេថាកុំចុះទៅ ម៉ែៗនៅស្រុកថ្មីភូមិថ្មីឯណោះ ។ ខ្ញុំថា

*អត់ទេ ហួសផុះខ្ញុំហើយ តែគេអត់ឲ្យចុះ»។*

## មន្ទីរសន្តិសុខជ្រៃអូរញ៉ោ

ជ្រៃអូរញ៉ោជាឈ្មោះភ្នំដែលអ្នកស្រុកនិយមហៅតាំងពីដើមរៀងមក។ មន្ទីរសន្តិសុខជ្រៃអូរញ៉ោបង្កើតឡើងដោយគណៈភូមិភាគនិរតីឈ្មោះ «ម៉ុក» នៅចុងឆ្នាំ១៩៧៦។ ក្នុងបរិវេណភ្នំជ្រៃអូរញ៉ោភ្នំនេះស្ថិតនៅក្នុងឃុំវាល ស្រុកគងពិសីខេត្តកំពង់ស្ពឺ។ គោលបំណងនៃការបង្កើតមន្ទីរនេះឡើងគឺដើម្បីអប់រំកែប្រែប្រជាជនដែលធ្លាប់មាននិន្នាការនយោបាយពីសង្គមចាស់និងអ្នកដែលនៅមានគំនិតសួនតួ។ មន្ទីរនេះគ្រប់គ្រងដោយ តាខុន ពិការដៃម្ខាងដែលមានតួនាទីជាប្រធាន និង តាបែន ជាអនុប្រធាន។ អ្នកទោសភាគច្រើនរងគ្រោះដោយសារប្តី ឬសាច់ញាតិបងប្អូនដែលត្រូវ«បដិវត្តន៍កម្ទេច»និងចាប់យកមកពីតំបន់២៥ ព្រមទាំងកងទ័ពពីភូមិភាគបូព៌ាទៀតផង។ នៅជុំវិញ បរិវេណមន្ទីរសន្តិសុខជ្រៃអូរញ៉ោមានសុទ្ធតែជារណ្តៅសម្រាប់កប់សាកសពអ្នកទោសរបស់មន្ទីរនេះ។

សាយនិងប្រជាជនជាច្រើនទៀតបានទៅដល់មន្ទីរសន្តិសុខជ្រៃអូរញ៉ោប្រហែលម៉ោង៩យប់។ អ្នកគ្រប់គ្រងនៅទីនោះបានឲ្យ សាយ ហូបបាយនិងរកកន្លែងសម្រាក រង់ចាំរហូតដល់ព្រឹកដើម្បីទៅរកឪពុកម្តាយ។ នៅទីនោះ សាយ បានជួបប្អូនស្រីនិងសាច់ញាតិខាងឪពុកចំនួន៤គ្រួសារ។ អ្នកទាំងអស់ត្រូវបានបញ្ជូនមកមន្ទីរនេះពីរថ្ងៃមុន សាយ ទៅដល់។ អ្នកទាំងអស់ត្រូវអង្គការបែងចែកឲ្យទៅធ្វើការនៅកងផ្សេងគ្នានៅជាប់ជើងភ្នំខាងស្រុកជុំគិរី។ យូរម្តងៗ សាយ បានសុំប្រធានកងទៅលេងអ៊ំនិងម្តាយមីងដែលនៅធ្វើការខាងជើងភ្នំ។ ចំណែកប្អូនស្រីរស់នៅក្នុងកងកុមារ។ សាយ បានសួរអ្នកនៅទីនោះស្ទើរគ្រប់គ្នាអំពីដំណឹងឪពុកម្តាយគាត់។ សាយ ក៏បានសួរ តាខុន ដែរ ប៉ុន្តែ តាខុន មិនបាននិយាយអ្វីច្រើនទេ គ្រាន់តែប្រាប់ សាយ ថា «ដើររកទៅរកឃើញហើយ»។ តាខុន មិនបានយកទោសពៃរ៍ចំពោះការដើរគ្មានវិន័យរបស់ សាយ ឡើយ ព្រោះយល់ថា សាយ នៅក្មេង ហើយថែមទាំងបានអនុញ្ញាតឲ្យ សាយ ដើររកឪពុកម្តាយតាមចិត្តទៀតផង។ សាយ តាមរកឪពុកម្តាយស្ទើរគ្រប់កន្លែងនៃបរិវេណមន្ទីរនេះ ប៉ុន្តែគ្មាននរណាម្នាក់ដឹងថាអ្នកទាំងពីរនៅទីណានោះទេ ហើយក៏មិនដឹងស្រុកថ្មីភូមិថ្មីនៅកន្លែងណាដែរ។ សាយ ដើររកអស់ចិត្តនៅតែមិនឃើញ ក៏បោះបង់ការព្យាយាមមួយរយៈ ហើយវិលត្រឡប់ទៅធ្វើការក្នុងកងកុមារវិញ។ សាយ មិនដឹងថា ជ្រៃអូរញ៉ោ ជាកន្លែងលត់ដំនោះទេ ពេលឃើញអ៊ំរែកដី សាយ បានសួរថា «អ៊ំៗពីណាឲ្យអ៊ំរែកដី ខ្ញុំមិនឃើញអ៊ំរែកដីទេ ឃើញតែអ៊ំស្រោចទឹកកញ្ឆាយ»។ អ៊ំរបស់ សាយ បានត្រឹមតែនិយាយណែនាំក្មួយថា «កុំសួរអ៊ំអី ខំធ្វើការទៅ»។ សាយ បានប្រាប់អ៊ំរបស់ខ្លួនថាៈ គេឲ្យមកលេងម៉ែនៅស្រុកថ្មី ភូមិថ្មី ហើយគេមិនឲ្យយកសម្លៀកបំពាក់មកជាមួយទេ ដល់ពេលនេះខ្ញុំដើររកតែរកមិនឃើញសោះ។ អ្នកគ្រប់គ្រងនៅទីនោះគេឲ្យខ្ញុំដើររកឲ្យអស់ចិត្តទៅ។ អ៊ំរបស់ សាយ ក៏មិនអាចផ្តល់ចម្លើយនេះបានដែរ។ ចម្ងល់របស់សាយនៅតែស្ថិតក្នុងសញ្ញាសួរដដែល។

## «សុភាពរាបសារ កូនអង្គការអត់ម៉ែអត់ឪ»

នេះជាប្រយោគមួយដែល សាយ តែងឮកុមាររបស់អង្គការច្រៀងនៅពេលដើរដេញចាប។ ពេលស្រែកច្រៀងម្តងៗកុមារទាំងនេះសម្លឹងមើលមុខ សាយ ជានិច្ច។ សាយ ចេះតែឆ្ងល់ ហើយក៏បានទៅសួរអ៊ំរបស់គាត់ ប៉ុន្តែអ៊ំរបស់ សាយ មិនហ៊ានបកស្រាយឡើយ ព្រោះខ្លាចអង្គការឮនឹងនាំឲ្យមានផលវិបាកដល់ខ្លួន។ អ៊ំរបស់ សាយ បានត្រឹមតែណែនាំថា «ក្មួយកុំមាត់កុំក គេឲ្យធ្វើអីធ្វើហ្នឹងទៅ»។ សាយ ត្រូវបានចាត់តាំងឲ្យបេះសណ្តែកដីធ្វើស្មៅជីឡូងមីនិងធ្វើការងារផ្សេងទៀតដោយមិនរើសមុខ។

នៅទីនោះ សាយ បានទទួលការយកចិត្តទុកដាក់ពីស្ត្រីម្នាក់ឈ្មោះ វ៉ាន់ ដែលបម្រើការនៅក្នុងមន្ទីរនេះ និងបុរសម្នាក់ឈ្មោះ ខន។ វ៉ាន់ ធ្លាប់មើលថែនិងបីព សាយ តាំងពីនៅតូច។ វ៉ាន់ ដឹងថា សាយ ជាក្មេងពិបាកក្នុងការហូបចុកនិងខស្សរាហ៍ឈឺ ដូច្នេះរាល់ពេលបើករបបអាហារម្តងៗ វ៉ាន់ តែង ផ្តាំចុងភៅឲ្យយកម្ហូបដែល សាយ អាចហូបបានប៉ុណ្ណោះ។ លើសពីនោះ ខុន តែងតែឆៀងយកផ្លែឈើផ្ញើឲ្យ សាយ រាល់ពេលដែលគាត់មកដឹកដីនៅបរិវេណមន្ទីរនេះ។ សាយ រំឭកថា «គាត់ទុកផ្លែឈើនឹងអ្នកយាមតាមទម្លាប់នៅពេលគាត់មកដឹកដីនៅក្បែរនោះម្តងៗ។ រយៈពេល៤-៥ថ្ងៃ គាត់បើកឡានដឹកដីឆ្លងកាត់ទីនោះមានផ្លែឈើផ្ញើតាមអ្នកយាម ដូចជាផ្លែមៀននិងផ្លែសៃដា។ ពូខន ប្រាប់អ្នកយាមថា ពេលវ៉ា

*ឃើញខ្ញុំមកថ្ងៃបន្តិច វាមកហើយ វាដឹងថាខ្ញុំយករបស់មកផ្ញើ ។*

នៅឆ្នាំ១៩៧៩ ពេលកងទ័ពវៀតណាមផ្តួលរំលំរបបនេះ ស្ថានភាពច្របូកច្របល់បានកើតមានឡើងដោយការផ្ទោងផ្តក់ដាក់គ្នារវាងកងទ័ពវៀតណាមនិងកងទ័ពខ្មែរក្រហម ។ ប្រធានមន្ទីរគុកជ្រៃអូរញ្ញោបាត់បង់ភាពម្ចាស់ការរត់ប្រាសអាយុរកកន្លែងសុវត្ថិភាព ចំណែកអ្នកទោសនាំគ្នាសម្រុកចេញដើម្បីរត់គេចពីគ្រាប់ផ្លោងនេះ ។ ដោយភ័យខ្លាចគ្រាប់ សាយ មិនហ៊ានត្រឡប់ទៅរកសាច់ញាតិបងប្អូនវិញទេ ហើយចេះតែបន្តរត់ទៅមុខតាមគណៈកងដោយគ្មានគោលដៅច្បាស់លាស់រហូតធ្លាក់មកនៅពេជ្រនិល ។ នៅទីនោះ សាយ បានជួបស្ត្រីមេម៉ាយម្នាក់ឈ្មោះ អេត គុល ។ គុល បានហៅ សាយ ឲ្យរួមដំណើរជាមួយគាត់ត្រឡប់មកស្រុកកំណើតនៅឯខេត្តកំពង់ស្ពឺ ។ ដោយមិនដឹងថា ខ្លួនត្រូវធ្វើដំណើរទៅទិសណាទៀត ណាមួយមិនស្គាល់ស្រុកកំណើតច្បាស់លាស់ និងដោយយល់ពីការលំបាកនេះ គុល បានយក សាយ ធ្វើជាកូនចិញ្ចឹមរបស់ខ្លួននិងចិញ្ចឹមរហូតដល់ពេញរូបរាងនិងបានផ្សំផ្គុំឲ្យមានគ្រួសារ ។

អេត គុល ឋិតនៅក្នុងវ័យ៦០ឆ្នាំថ្វាយក្នុងសម្លៀកបំពាក់ជាស្ត្រីខ្មែរជនបទបានមានប្រសាសន៍មួយៗថាៈ ពេលគាត់រត់ដល់ភ្នំពេជ្រនិល គាត់បានជួប សាយ នៅទីនោះ ។ ក៏ប៉ុន្តែមិនឃើញនរណាយកចិត្តទុកដាក់ចំពោះ សាយ ទេ ម្នាក់ៗរត់ប្រាសអាយុរៀងៗខ្លួន ។ ដោយក្តីអាណិតអាសូរ គុល ក៏បានយក សាយ មកចិញ្ចឹម និងគ្រាន់បានគ្នាលេងជាមួយកូនរបស់គាត់ ។ គុល រំឭកថា *«កូនខ្ញុំមួយនិងវាហ្នឹងរត់ឆ្លងកាត់ព្រៃមកស្រុកកំណើត ។ វាដេកកើយភ្លៅម្ខាង កូនខ្ញុំដេកកើយភ្លៅម្ខាងទៀត»* ។ មកដល់ស្រុកកំណើត គុល បាននាំ សាយ និងកូនរបស់គាត់ទៅរស់នៅក្នុងខ្ទមជាមួយបងជីដូនមួយដែលនៅក្នុងភូមិជាមួយគ្នា ។ នៅក្នុងអំឡុងពេលនោះ គុល តែងជួយស៊ើបសួររកសាច់ញាតិរបស់ សាយ ដើម្បីឲ្យ សាយ បានជួបជុំបងប្អូនវិញ ។ គុល បន្តថា *«ខ្ញុំជូនទៅរកម្តងព្រោះថា គេបាត់កូននៅស្វាយរលំ ខ្ញុំខំទៅទីនោះគេថាមិនមែនកូនខ្ញុំទេកូនខ្ញុំមិនមែនអ៊ីចឹងទេ»* ហើយគាត់ក៏បាននាំ សាយ ត្រឡប់មកផ្ទះវិញរង់ចាំក្រែងមានដំណឹងពីប្រភពផ្សេងទៀត ។

ក្រោយឆ្នាំ១៩៩៣ បន្ទាប់ព្រឹត្តិការណ៍បោះឆ្នោតតាមបែបលទ្ធិប្រជាធិបតេយ្យដែលរៀបចំឡើងដោយអង្គការសហប្រជាជាតិដើម្បីជ្រើសរើសរដ្ឋាភិបាលថ្មីមួយនិងដើម្បីរៀបចំស្រុកទេសឲ្យមានសុខសន្តិភាពឡើងវិញ សាយ បានសម្រេចចិត្តសុំម្តាយចិញ្ចឹមទៅរកសាច់ញាតិខាងម្តាយនៅខេត្តកំពង់ចាមតាមការចងចាំដោយស្រពេចស្រពិល ។ គុល បានធ្វើដំណើរជាមួយ សាយ ទៅដល់ខេត្តកំពង់ចាមដើម្បីតាមសាកសួររកឪពុកឈ្មោះ ប្រាក់ ។ សាយ ចាំបានថា ឪពុករបស់គាត់ឈ្មោះ ប្រាក់ និងម្តាយ ឈ្មោះ សាង ប៉ុណ្ណោះ ជាហេតុធ្វើឲ្យគាត់មានការលំបាកក្នុងការស្វែងរក ។ នៅខេត្តកំពង់ចាម សាយ បានស៊ើបរកឃើញគ្រួសារមួយដែលមានឈ្មោះ ប្រាក់ ដែរ ប៉ុន្តែឈ្មោះ សេង ប្រាក់ ទៅវិញ ។ អ្នកទាំងពីរចំណាយពេលអស់ជាច្រើនថ្ងៃស្នាក់នៅខេត្តកំពង់ចាមដើម្បីស៊ើបសួររកឈ្មោះនេះបន្តទៀត ។ នៅទីបំផុតអ្នកទាំងពីរទទួលបានដំណឹងមិនច្បាស់លាស់ថា ប្រាក់ ដែលខ្លួនកំពុងស្វែងរកនោះកំពុងរស់នៅស្រុកក្រូចឆ្មារឯណោះ ។ ដោយសារខ្វះខាតសោហ៊ុយធ្វើដំណើរអ្នកទាំងពីរក៏វិលត្រឡប់មកផ្ទះវិញ ។

នៅក្នុងឆ្នាំ២០០៣ សាយ បន្តស្វែងរកអ្នកទាំងពីរទៀតដោយប្រកាសសួររកតាមវិទ្យុសំបុកឃ្មុំនិងតាមទូរទស្សន៍ប៉ុស្តិ៍លេខ៣ ប៉ុន្តែនៅតែមិនបានទទួលដំណឹងអ្វីទាំងអស់ ធ្វើឲ្យ សាយ ចាប់ផ្តើមគិតថា បើអ្នកទាំងពីរនៅរស់ច្បាស់ជាតាមរកគាត់វិញមិនខាន ។ ស្រាប់តែថ្មីៗនេះតាមរយៈពូម្នាក់ធ្វើការនៅមហាវិទ្យា-ល័យជាតិគ្រងគ្រងនិងដែលតែងតែតាមដានអានទស្សនាវដ្តី «ស្វែងរកការពិត» បានពើបប្រទះដំណឹងនេះ ។ បុរសម្នាក់នេះបានដឹងច្បាស់អំពីប្រវត្តិរបស់ សាយ ពីព្រោះថា គុល ជាជនួងរបស់គាត់ ។ បុរសម្នាក់នោះគាត់បានព្យាយាមទំនាក់ទំនងមក សេក សារ៉ុន ជាម្ចាស់អត្ថបទមួយដែលចុះផ្សាយនៅលើទំព័រទស្សនាវដ្តីលេខ៨៧ ខែមីនា ឆ្នាំ២០០៧ ដើម្បីផ្តល់ដំណឹងអំពីកុមារីម្នាក់ សេក សុធី (សាយជាឈ្មោះហៅក្រៅ) ដែលបានបែកគ្នានៅក្នុងឆ្នាំ១៩៧៩ក្នុងខណៈពេលរត់ចេញពីមន្ទីរសន្តិសុខជ្រៃអូរញ្ញោ ។

វត្តមានបងប្រុសជីដូនមួយបានធ្វើឲ្យ សាយ រំភើបចិត្តឥតឧបមា និងធ្វើឲ្យគាត់នឹកឃើញដល់សកម្មភាពដែលគាត់រត់ចេញពីមន្ទីរសន្តិសុខជ្រៃអូរញ្ញោ ។ នៅពេលនោះ សាយ បានរត់ទៅតាមពីក្រោយបងប្រុសដើម្បីសុំបងប្រុសទៅជាមួយ ប៉ុន្តែបងប្រុស

*របស់គាត់មិនអនុញ្ញាត ព្រោះគាត់ត្រូវចូលបម្រើកងទ័ពទៀត ។ "ខ្ញុំសុំគាត់ទៅជាមួយ គាត់មិនឲ្យទៅ គាត់ប្រាប់ថា ខ្លាចគេឲ្យគាត់ធ្វើទាហាន ដូច្នេះខ្ញុំក៏ចេះតែរត់ទៅទិសខាងលិចតាមគេឯង ហើយក៏បានជួបម្តាយចិញ្ចឹមដែលបានហៅឲ្យទៅនៅជាមួយគាត់" ។*

## ជួបសាច់ញាតិខាងឪពុក

*សាយ សប្បាយរីករាយយ៉ាងខ្លាំងព្រោះពេលទៅដល់ស្រុកកំណើតបងប្អូនអ៊ីមាមីងខាងឪពុក និងបងជីដូនមួយជាច្រើនឈរចាំទទួលស្វាគមន៍ ។ គ្មានអ្វីសប្បាយជាងការជួបជុំគ្រួសារនោះទេ សាយ រំពុកដោយទឹកមុខញញឹមថា "បងប្អូនស្រីៗរបស់ខ្ញុំស្រែកថា "ហ្នឹងហើយវា" គាត់ចំណាំភ្នែកខ្ញុំ ។ ចំណែកអ៊ីខ្ញុំប្រាប់ថាចំណាំ កំភួនជើងខ្ញុំ គាត់ថាកំភួនជើងខ្ញុំដូចម៉ែខ្ញុំ គាត់ចេះតែលបគន់មើលខ្ញុំ ។ ទោះបីជាយ៉ាងណាក៏ដោយ សាយ ហាក់ដូចជាប្រែទឹកមុខបន្តិចហើយនិយាយទាំងអួលដើមកថា ការជួបជុំនេះអាចធ្វើឲ្យត្រេកអរតែមួយរយៈពេលខ្លីប៉ុណ្ណោះ ប៉ុន្តែអារម្មណ៍ទាំងនោះមិនអាចស្មើនឹងអារម្មណ៍ដូចបានជួបឪពុកម្តាយឡើយ ។ "បានជួបបងប្អូនអាចធ្វើឲ្យសប្បាយតែមួយរយៈពេលខ្លីប៉ុណ្ណោះ ។ បើសិនជាបានជួបម៉ែឪ ហ្នឹងរឹតតែសប្បាយ" ។ នៅទីបំផុតក្តីសង្ឃឹមទាំងប៉ុន្មានដែល សាយ រង់ចាំអស់រយៈពេលជាច្រើនឆ្នាំ ទទួលបានត្រឹមតែឃើញរូបថតម្តាយមួយសន្លឹកនិងប្អូនប្រុសពៅក្នុងសម្លៀកបំពាក់ជាអ្នកទោសប៉ុណ្ណោះ ។ សាយ រំពុកថា ម្តាយគាត់មានចរិតម៉ឹងម៉ាត់មិនសូវចេះនិយាយច្រើនទេ ប៉ុន្តែបើឪពុករបស់គាត់លេងសើចខ្លះ ហើយគាត់កម្រវាយកូនណាស់ ។ ឪពុកគាត់ច្រើនស្លៀកសម្លៀកបំពាក់ទាហានពណ៌ស្លឹកឈើពាក់ស្បែកជើងកង់ឡាន ចេញទៅធ្វើការបាត់ៗ ថ្ងៃបាក់សៀលឬប្រហែលមួយសប្តាហ៍ទើបត្រឡប់មកផ្ទះម្តង ។ អ្នកធ្លាប់រស់នៅជាមួយឪពុករបស់គាត់ក៏និយាយដែរថា ឪពុករបស់គាត់ធ្វើទ័ពតាំងពីក្មេង ។*

*សាយ សម្លឹងមើលរូបថតម្តាយបន្តិចហើយនិយាយថា ពេលគាត់ទទួលបានរូបថតនិងដំណឹងនៃការស្លាប់របស់អ្នកទាំងពីរ គាត់បានចូលបច្ច័យ ធ្វើបុណ្យឡើងសាលានៅវត្តមួយនៅក្នុងភូមិ ដើម្បីឧទ្ទិសកុសលផលបុណ្យទៅឲ្យឪពុកម្តាយនិងប្អូនៗគាត់ ។ នៅពេលឆាប់ៗខាងមុខនេះ ក្រោយពេលដូវច្រូតកាត់រួចរាល់ សាយ មានគម្រោងទៅស្រុកកំណើតខាងម្តាយម្តងទៀត ដើម្បីស្រាវជ្រាវរកសាច់ញាតិខាងម្តាយ នៅរស់ប៉ុន្មាននាក់តាមប្រវត្តិរូបរបស់ម្តាយគាត់ដែលមានតម្កល់ទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ។ សាយ សង្ឃឹមថា មីងរបស់គាត់ ដែលនៅមន្ទីរពេទ្យសំរ៉ោងជាមួយគ្នាអាចនឹងនៅរស់ព្រោះពេលបែកនោះមីងរបស់គាត់នៅក្មេងនៅឡើយ ។*

*សាយ ហាក់ដូចជាមានការរសាយចិត្តក្នុងការដាក់ពាក្យប្តឹងទៅតុលាការក្នុងនាមជាកូនជនរងគ្រោះ ។ គោលបំណងរបស់ សាយ គឺចង់ឃើញការកាត់ទោសនេះនិងចង់ចូលរួមធ្វើជាសាក្សីក្នុងថ្ងៃបើកសវនាការ ប៉ុន្តែគាត់ព្រួយបារម្ភថា គាត់មិនចេះនិយាយឲ្យបានក្បោះក្បាយ ពីព្រោះគាត់មិនបានរៀនសូត្រជ្រៅជ្រះ ។*

**លី សុផល**

# ដំណឹងស្វែងរកបងប្រុស

*នាងខ្ញុំឈ្មោះ ប៊ុន ឡាម៉ៃ សព្វថ្ងៃរស់នៅទីក្រុងហុងកុង សូមស្វែងរកបងប្រុសឈ្មោះ ប៊ុន ឡាទោត ដែលបានបែកគ្នានៅចុងឆ្នាំ១៩៧៥ កាលពីអាយុ១៦ឆ្នាំ ក្នុងភូមិដងអៀន ស្រុកអារញ្ញ យាផាថេត ខេត្តសាកែវ ប្រទេសថៃ ក្បែរព្រំប្រទល់ប្រទេសខ្មែរនៃខេត្តបន្ទាយមានជ័យ ។ ឪពុកឈ្មោះ ប៊ុនឡា ប៊ុតស៊ី (នៅរស់) និងម្តាយឈ្មោះ ប៊ុន ឡាគឿ (នៅរស់) ។ ខ្ញុំបាទមានបងប្អូនបួននាក់ បងទី១) ប៊ុន ឡាទោត (បាត់ខ្លួន), បងទី២) ប៊ុន ឡាអាត (នៅរស់), បងទី៣) ប៊ុន ឡាលេត (នៅរស់) និងបងទី៤) ប៊ុន ឡាឡៃ (នៅរស់) ។*


ប៊ុន ឡាទោត

*ប្រសិនបើបងប្អូនណាស្គាល់ឈ្មោះ ប៊ុន ឡាទោត នេះ សូមទំនាក់ទំនងមកទូរស័ព្ទលេខ ០១២ ១៨៣៧ ៣៥៨ ដែលមានអសយដ្ឋានផ្ទះលេខ៣៩AEo ផ្លូវលេខ២៨២ សង្កាត់វាលវង់ ខណ្ឌ៧មករា ក្រុងភ្នំពេញ ។ យើងខ្ញុំនឹងមានជូនដាសគុណ ។*

# គុកខ្មែរក្រហម

## ខេត្តកំពង់ចាម

### ស្រុកបាធាយ

#### ១) មន្ទីរសន្តិសុខបាធាយ

មន្ទីរសន្តិសុខបាធាយគឺជាវត្តបាធាយ ស្ថិតនៅក្នុងភូមិបាធាយ ឃុំបាធាយ ស្រុកបាធាយ ខេត្តកំពង់ចាម ។ មន្ទីរសន្តិសុខនេះបង្កើតឡើងក្រោយខែមេសា ឆ្នាំ១៩៧៥សម្រាប់អ្នកទោសធ្ងន់និងអ្នកទោសស្រាល ។ អ្នកទោសធ្ងន់ជាប្រភេទអ្នកទោសដែលជាប់និន្នាការពីសង្គមចាស់ ដូចជាទាហាន ប៉ូលិស និងមន្ត្រីរដ្ឋការផ្សេងៗ ។ អ្នកទាំងនេះជាប់ខ្នោះជើងនៅមួយកន្លែង ត្រៀមខ្លួនចាំតែសន្តិសុខនាំទៅសួរចម្លើយប៉ុណ្ណោះ ចំណែកអ្នកទោសស្រាលត្រូវកងសន្តិសុខបញ្ជាឲ្យជីករណ្តៅសម្រាប់កប់សាកសពតាំងពីព្រលឹមរហូតដល់ព្រលប់ ។

រហូតមកដល់ចុងឆ្នាំ១៩៧៦ ខ្មែរក្រហមបានសម្លាប់អ្នកទោសធ្ងន់អស់ជាច្រើននាក់បន្ទាប់ពីសួរចម្លើយរួច ។ ការសម្លាប់បានប្រព្រឹត្តទៅជារៀងរាល់ថ្ងៃ ។ ទីតាំងសម្លាប់ស្ថិតនៅខាងមុខរបងវត្តបាធាយតែម្តង ។

ចាប់ពីឆ្នាំ១៩៧៧រហូតដល់ចុងឆ្នាំ១៩៧៨ អ្នកទោសធ្ងន់ទាំងអស់ត្រូវបានសម្លាប់ចោល ដើម្បីយកកន្លែងដាក់អ្នកទោសស្រាលដែលបញ្ជូនមកពីភូមិ ឃុំ និងសហករណ៍ផ្សេងៗក្នុងស្រុក ។ ឆាយ ឡឹង ជាអតីតអ្នកទោសនៅមន្ទីរសន្តិសុខវត្តបាធាយបានប្រាប់ថាគាត់ត្រូវចោទប្រកាន់ថាបានសម្លាប់គោរបស់អង្គការ ។ កាលពីឆ្នាំ១៩៧៨ អ្នកទោសត្រូវខ្មែរក្រហមដឹកពីភូមិភាគបូព៌ាមកកាន់មន្ទីរសន្តិសុខស្រុកបាធាយ ។ ក្រោយមកអ្នកទោសទាំងនេះត្រូវបានសម្លាប់ចោលទាំងអស់ ។ គឺបានឲ្យដឹងថា ក្រុមគាត់បានទទួលបញ្ជាពីកងសន្តិសុខឲ្យជីករណ្តៅទំហំទទឹង២ម៉ែត្រនិងបណ្តោយ៣ម៉ែត្រចំនួនពី៤០០ទៅ៥០០រណ្តៅសម្រាប់កប់សាកសពអ្នកទោសដែលដឹកមកពីភូមិភាគបូព៌ា ។ ឡឹង បានឃើញហេតុការណ៍សម្លាប់នេះ ព្រមទាំងបានលួចអានបញ្ជីសម្លាប់របស់កងសន្តិសុខ ដែលទុកចោលទៀតផង ។ ឡឹង និយាយថា «អ្នកទោសភូមិភាគបូព៌ាចំនួន ៦.០០០នាក់ត្រូវបានសម្លាប់រួចជាស្រេច» ។ ឃឹម ជាប្រធានមន្ទីរសន្តិសុខ និង លឹម ជាអនុប្រធាន ។ សព្វថ្ងៃ លឹម មានប្រពន្ធរស់នៅភូមិតាំងថ្មើង ឃុំមេព្រីង ស្រុកបាធាយ ។ ចំណែក ឃឹម បានបាត់ខ្លួនជាមួយនឹងកងសន្តិសុខឯទៀត ។

#### ២) មន្ទីរសន្តិសុខវត្តប្រើសមាស

មន្ទីរសន្តិសុខវត្តប្រើសមាសមានទីតាំងនៅក្នុងបរិវេណ



មន្ទីរសន្តិសុខវត្តប្រើសមាស

វត្តប្រើសមាស ស្ថិតនៅក្នុងភូមិថ្កូវ ឃុំត្រប់ ស្រុកបាធាយ ខេត្តកំពង់ចាម និងបង្កើតនៅឆ្នាំ១៩៧៦ ។ កុដិធំមួយចំកណ្តាលបរិវេណវត្តត្រូវខ្មែរក្រហមប្រើប្រាស់ធ្វើជាកន្លែងឃុំឃាំងអ្នកទោសធ្ងន់ និងកន្លែងសួរចម្លើយ ។ ចំណែកអ្នកទោសស្រាលឃុំឃាំងនៅតាមកុដិតូចៗ និងកន្លែងដទៃទៀតក្នុងទីធ្លាវត្ត ។

ញ៉ិប ញៀប បាននិយាយពីហេតុការណ៍ ដំបូងដែលនាំឲ្យខ្មែរក្រហមយកវត្តប្រើសមាសធ្វើជាមន្ទីរសន្តិសុខថា កាលពីឆ្នាំ ១៩៧៥ ខ្មែរក្រហមបានចាប់ផ្សឹកព្រះសង្ឃដែលគង់នៅក្នុងវត្ត រួចបញ្ជូនទៅរស់នៅតាមសហករណ៍នានាក្នុងឃុំត្រប់ជាមួយឧបាសក-ឧបាសិកា ។ នៅដើមឆ្នាំ១៩៧៦ វត្តនេះបានក្លាយជាកន្លែងឃុំឃាំងអ្នកទោសដែលមាន នី និង ឡឿន ជាប្រធានគ្រប់គ្រងមន្ទីរសន្តិសុខវត្តប្រើសមាសនេះ ។ មាច ថាញ់ មេឃុំត្រប់បាននិយាយថា ឧបករណ៍សម្រាប់ធ្វើទារុណកម្មមានដំបងនិងកាំបិត ។ នៅបរិវេណជុំវិញវត្តប្រើសមាសដូចជា ចម្ការគាតាំងជាដើម បរិវេណខាងក្រៅនិងខាងក្នុងវត្តប្រើសមាសគឺជាកន្លែងសម្លាប់អ្នកទោស ។

នៅក្រោយថ្ងៃជ័យជម្នះឆ្នាំ១៩៧៩ មន្ទីរសន្តិសុខវត្តប្រើសមាសត្រូវរដ្ឋអំណាចថ្មីរំលាយចោល ។ អ្នកទោសមួយចំនួនបានរួចខ្លួនពីសេចក្តីស្លាប់ ។ កម្មាភិបាលខ្មែរក្រហមខ្លះត្រូវបានសម្លាប់និងខ្លះទៀតរត់គេចខ្លួនទៅកាន់តំបន់ឆ្ងាយៗ ។ ស្នាមឈាមប្រឡាក់និងឧបករណ៍ធ្វើទារុណកម្មដែលនៅរាយប៉ាយពេញកុដិត្រូវបានប្រជាជនបោសសម្អាតនិងរៀបចំជួសជុលឡើងវិញទាំងស្រុង ។

## ស្រុកចម្ការលើ

### ១) មន្ទីរសន្តិសុខមិត្តសៅ

មន្ទីរសន្តិសុខមិត្តសៅជាមន្ទីរអប់រំកែប្រែដែលអង្គការបដិវត្តន៍បង្កើតឡើងនៅភូមិពព្រេង ឃុំស្ពឺ ស្រុកចម្ការលើ ខេត្តកំពង់ចាមនៅក្នុងឆ្នាំ១៩៧៣ ។ អ្នកមានទ្រព្យសម្បត្តិបន្តួរនិងអ្នកមានមួយចំនួនតូចដែលត្រូវខ្មែរក្រហមហៅមកធ្វើការអប់រំកែប្រែនៅក្នុងមន្ទីរនេះ ។ ចំពោះអ្នកដែលកែប្រែមិនបានត្រូវសម្លាប់ចោល ។ ការបង្ក្រាបបែបនេះបានធ្វើឲ្យប្រជាជនភាគច្រើនបាក់ស្បាត ។

ចាប់តាំងពីថ្ងៃជ័យជម្នះ ១៧ មេសា ១៩៧៥ ក្រុមគ្រួសារភាគច្រើនត្រូវបានបំបែកនិងសម្លាប់ចោលដោយសារតែរឹងទទឹងនឹងអង្គការ ។ មន្ទីរអប់រំកែប្រែមិត្តសៅ ត្រូវប្តូរមកជាមន្ទីរសន្តិសុខប្រចាំស្រុកចម្ការលើពេញលក្ខណៈ ដោយមានសមមិត្ត សៅ ជាអ្នកគ្រប់គ្រង ។ អ្នកទោសដែលជាប់នៅទីនោះជាប្រជាជនជម្លៀសមកពីទីក្រុងភ្នំពេញនិងប្រជាជនមូលដ្ឋានដែលអង្គការអប់រំមិនបាន ។ ប្រជាជនជម្លៀសគ្មានសិទ្ធិធ្វើអ្វីទាំងអស់ក្រៅតែពីឆ្លើយនឹងសំណួរដែលសួរដោយកម្មាភិបាលខ្មែរក្រហមប៉ុណ្ណោះ ហើយត្រូវបាននាំយកទៅសម្លាប់ចោលជាបន្តបន្ទាប់ ។ ចំណែកអ្នកទោសថ្មីៗត្រូវបានបញ្ជូនមកឃុំឃាំងរាល់ថ្ងៃ ។ ក្នុងអំឡុងឆ្នាំ១៩៧៦ អ្នកទោសដែលកងសន្តិសុខបញ្ជូនមកកាន់មន្ទីរនេះ សុទ្ធតែជាអ្នកដែលធ្លាប់ពាក់ព័ន្ធនឹងរដ្ឋការមុន (របប លន់ នល់ និង សីហនុ) ដូចជាគ្រូបង្រៀន មន្ត្រីរដ្ឋការ នាយទុនធំៗ ប៉ូលិស តម្រួត យោធានិងគិញសម្ងាត់ជាដើម ។ អ្នកទោសមួយចំនួនធំត្រូវបាននាំយកទៅសម្លាប់នៅទីតាំងត្រពាំងគុកសំនិងត្រពាំងខ្នា ។ ប៊ី ណាក់ មេភូមិពព្រេង ឃុំស្ពឺបាននិយាយថា នៅចុងឆ្នាំ១៩៧៦ អ្នកទោសដែលចាប់ខ្លួនតាំងពីឆ្នាំ១៩៧៥ ត្រូវបានសម្លាប់ទាំងអស់ ។ ចាប់តាំងពីពេលនោះមក មន្ទីរសន្តិសុខមិត្តសៅគ្រប់គ្រងតែប្រជាជនមូលដ្ឋាននិងកម្មាភិបាលខ្មែរក្រហមដូចគ្នា ។ ចាប់ពីឆ្នាំ១៩៧៧ ខ្មែរក្រហមបានស្រាវជ្រាវរកក្រុមគ្រួសារអ្នកជាប់និន្នាការពីសង្គមមុនដែលខ្លួនបានចាប់កាលពីឆ្នាំ១៩៧៥-៧៦ ហើយដែលត្រូវសម្លាប់រួចហើយ និងប្រជាជនមួយចំនួនទៀតដែលខ្មែរក្រហមចោទប្រកាន់ពីបទខុសសីលធម៌ លួចនេះលួចនោះរបស់សហករណ៍ និងកម្មាភិបាលខ្មែរក្រហមភាគច្រើនដែលអនុវត្តខុសពីគោលការណ៍របស់អង្គការមកដាក់ឃុំឃាំងនៅក្នុងមន្ទីរសន្តិសុខមិត្តសៅថែមទៀត ។ អ្នកទោសទាំងនេះថ្វីដ្បិតតែមានទោសកំហុសស្រាល ប៉ុន្តែការធ្វើទារុណកម្មនិងសួរចម្លើយគឺមិនខុសពីអ្នកទោសកម្រិតធ្ងន់ឡើយ ។ បន្ទាប់ពីការធ្វើទារុណកម្មអ្នកទោសទាំងអស់ត្រូវបានបញ្ជូនយកទៅសម្លាប់ចោលនៅចុងឆ្នាំ១៩៧៨ ។

មន្ទីរសន្តិសុខមិត្តសៅបានរលត់រលាយនៅដើមឆ្នាំ១៩៧៩ បន្ទាប់ពីប្រទេសជាតិត្រូវបានរំដោះទាំងស្រុង ។ អ្នកទោសខ្លះបានរួចខ្លួនពីការកាប់សម្លាប់នេះ ហើយបានវិលមករស់នៅជាមួយក្រុមគ្រួសារវិញ ។ បច្ចុប្បន្ននេះ អតីតមន្ទីរសន្តិសុខមិត្តសៅ ជាដីភូមិ

ចាស់មួយដែលគ្មានមនុស្សរស់នៅ ប៉ុន្តែជាទីសំចតរបស់ក្មេងៗឃ្វាលគោប៉ុណ្ណោះ ។

## ២) មន្ទីរសន្តិសុខចម្ការតាប៉ុម

ចម្ការតាប៉ុមជាចម្ការមួយមានទំហំធំស្ថិតនៅក្នុងឃុំចម្ការអណ្តូង ស្រុកចម្ការលើ ។ តាប៉ុម ជាម្ចាស់ចម្ការនេះតាំងពីសម័យសង្គមរាស្ត្រនិយមមកម្ល៉េះ ហើយក៏ជាអ្នកមានទ្រព្យសម្បត្តិជាងគេម្នាក់នៅក្នុងឃុំចម្ការអណ្តូងដែរ ។ ប៉ុន្តែនៅសម័យខ្មែរក្រហមចម្ការតាប៉ុមត្រូវបានអង្គការដកហូតមកធ្វើជាទីតាំងសម្លាប់មនុស្សនិងមន្ទីរសន្តិសុខប្រចាំឃុំចម្ការអណ្តូងវិញ ។ ចម្ការតាប៉ុមមានឈ្មោះហៅផ្សេងពីរទៀតគឺចម្ការស្វាយ និងចម្ការអណ្តូង ។ ទីតាំងនេះមានចម្ងាយប្រហែលពាគីឡូម៉ែត្រពីសាលាស្រុកចម្ការលើប៉ែកខាងជើង ។

មន្ទីរសន្តិសុខនៅចម្ការតាប៉ុម គ្រាន់តែជាកន្លែងឃុំឃាំងមនុស្សបណ្តោះអាសន្នប៉ុណ្ណោះមុននឹងយកទៅសម្លាប់ ។ អ្នកទោសច្រើនណាស់ដែលត្រូវខ្មែរក្រហមដឹកទាំងរថយន្តៗមកដាក់នៅមន្ទីរសន្តិសុខបណ្តោះអាសន្ននេះ ។ អភិបាលស្រុកចម្ការលើបានប្រាប់ឲ្យដឹងថា ពួកខ្មែរក្រហមបានប្រមូលជនរងគ្រោះពីតំបន់៤១ដែលស្ថិតនៅប៉ែកខាងកើតទន្លេមេគង្គដូចជាស្រុកក្រូចឆ្មារ ស្រុកត្បូងឃ្មុំ ស្រុកមេមត់ ស្រុកតំបែរ ស្រុកពញាក្រែក និងខ្លះទៀតពីស្រុកកងមាស ព្រៃឈរ ជើងព្រៃ និងស្រុកបាធាយមកដាក់នៅទីនេះទាំងអស់ ។ ខួត ផន ប៉ាន់ប្រមាណថា ជនរងគ្រោះមានរាប់ម៉ឺននាក់ដែលខ្មែរក្រហមដឹកមកប្រមូលផ្តុំនៅទីនេះ ។ ការឃុំឃាំងអ្នកទោសគឺពុំមានដាក់ខ្នោះ ឬចងដៃជើងអ្វីទេ ប៉ុន្តែឲ្យស្នាក់នៅក្រោមដើមឈើធំៗក្នុងបរិវេណសម្លាប់របស់ចម្ការតាប៉ុមតែម្តង ព្រោះគ្មានរោងសម្រាប់ដាក់អ្នកទោស ។ អ្នកទោសដែលដឹកមកពីតំបន់៤១ភាគច្រើនជាប្រជាជនជម្លៀសពីទីក្រុងភ្នំពេញ ដែលអង្គការចម្រាញ់យកតាមសហករណ៍នានាទូទាំងស្រុកមន្ត្រីជាន់ខ្ពស់នៃរបបសាធារណរដ្ឋខ្មែរ និងមនុស្សដែលខ្មែរក្រហមចាត់ទុកជានាយទុន ។ ក្រៅពីនេះអ្នកទោសខ្លះទៀតត្រូវកងសន្តិសុខដឹកមកពីឃុំនានាក្នុងស្រុកចម្ការលើ ។ ការឃុំឃាំង និងសម្លាប់បានប្រព្រឹត្តទៅចាប់តាំងពីឆ្នាំ១៩៧៥ ហើយបន្តរហូតមកដល់ចុងឆ្នាំ១៩៧៨ ។

នៅក្រោយឆ្នាំ១៩៧៩ ចម្ការតាប៉ុមជាដីដាំដំណាំមួយដែលមានដីជាតិជាងដីឯទៀត ។ ប្រជាកសិករក្នុងឃុំចម្ការអណ្តូងបាននាំគ្នាដាំដំណាំផ្សេងៗដូចជាល្ង សណ្តែក ។ល ។

## ៣) មន្ទីរសន្តិសុខចម្ការស្វាយចន្ទី

ចម្ការស្វាយចន្ទី ស្ថិតនៅក្នុងភូមិវាលរីលិច ឃុំស្វាយទាប ស្រុកចម្ការលើ ខេត្តកំពង់ចាម និងមានចម្ងាយប្រហែល២០០ម៉ែត្រខាងលិចសាលារៀនស្វាយទាប ។ របងព័ទ្ធជុំវិញចម្ការសុទ្ធតែព្រៃឫស្សីយ៉ាងក្រាស់ពិបាកនឹងចូលដល់ ។ ក្រោយថ្ងៃរំដោះទី៧ ខែមករា ឆ្នាំ១៩៧៩ ចម្ការនេះមានម្ចាស់គ្រប់គ្រងបីនាក់គឺ តាឆេង, តាចេង និងតាឃិន ។ ម្ចាស់ចម្ការទាំងបីបានដាំដំណាំផ្សេងៗពីគ្នាដូចជា ល្ង ស្វាយចន្ទី ស្វាយថ្លៃ មាក់ប្រេង និងល្ហុង ។

ប្រជាជនគ្រប់គ្នាដែលរស់នៅក្នុងស្រុកចម្ការលើ ហើយដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមសុទ្ធតែដឹងឮថាចម្ការស្វាយចន្ទីជាមន្ទីរសន្តិសុខដែលមានឃុំឃាំងមនុស្សយ៉ាងច្រើននិងជាកន្លែងសម្លាប់មនុស្សច្រើនជាងគេនៅស្រុកចម្ការលើចាប់តាំងពីពាក់កណ្តាលឆ្នាំ១៩៧៨ដល់ថ្ងៃរំដោះ ។ គីង យ៉ាត អាយុ៥១ឆ្នាំជាប្រធានឃុំស្វាយទាបបានអះអាងថា ចម្ការស្វាយចន្ទីជាមន្ទីរសន្តិសុខប្រចាំឃុំស្វាយទាបតាំងពីឆ្នាំ១៩៧៥ និងជាកន្លែងសម្លាប់មនុស្សចាប់ពីពាក់កណ្តាលឆ្នាំ១៩៧៨រហូតដល់ជិតបែកឆ្នាំ១៩៧៩ ។ អ្នកទោសភាគច្រើនបំផុតត្រូវបាននាំយកទៅសម្លាប់នៅក្នុងចម្ការកៅស៊ូចម្ការអណ្តូង ហើយមួយចំនួនទៀតត្រូវសម្លាប់នៅនឹងទីតាំងចម្ការស្វាយចន្ទីតែម្តង ។ អ្នកទោសមានលាយចម្រុះគ្នាទាំងជនជាតិវៀតណាម ចិន ចាម និងខ្មែរ ។ ប្រសិនបើជនជាតិខ្មែរយកគ្រួសារជាវៀតណាម ក៏ត្រូវចាប់ខ្លួនមកកាន់មន្ទីរសន្តិសុខដែរ ។ លី ឃិន បច្ចុប្បន្នរស់នៅភូមិវាលរីលិច ឃុំស្វាយទាប ស្រុកចម្ការលើបានបន្ថែមថា អ្នកទោសមានអ្នកជាប់និន្នាការនយោបាយតាំងពីជំនាន់សីហនុ-លន់នល់ អ្នកខ្ជិលច្រអូសមិនមកធ្វើការ អ្នកខុសសីលធម៌ផ្សេងៗនិងអ្នកដែលលួចនេះលួចនោះក្នុងសហករណ៍ ។

ចាប់ពីពាក់កណ្តាលឆ្នាំ១៩៧៨ មន្ទីរសន្តិសុខប្រចាំឃុំស្វាយទាបត្រូវបានរំលាយចោល បន្ទាប់ពីខ្មែរក្រហមយកធ្វើជាទីតាំងសម្លាប់មនុស្សដ៏ល្បីល្បាញនៅស្រុកចម្ការលើ ។ អ្នកទោសដែលនៅសេសសល់ក្នុងមន្ទីរសន្តិសុខចម្ការស្វាយចន្ទីទាំងប៉ុន្មានត្រូវបានសម្លាប់ទាំងអស់ដើម្បីរៀបចំឲ្យទៅជាកន្លែងសម្លាប់មនុស្សតាមផែនការបន្ទាន់របស់ថ្នាក់លើ ។ គីង យ៉ាត បាននិយាយថា

ខ្មែរក្រហមបានកោះហៅប្រជាជនទាំងអស់ដែលត្រូវសម្លាប់ដោយគិតទាំងប្រជាជនថ្មី(១៧មេសា) និង ប្រជាជនចាស់ផងឲ្យមកប្រជុំ ដោយប្រាប់ថាប្រជុំ ត្រៀមផ្លាស់ប្តូរទីលំនៅពីភូមិមួយទៅភូមិមួយទៀត ។ កិច្ចប្រជុំបានធ្វើឡើងនៅវេលាម៉ោង៤ទៀបភ្លឺត្រង់កន្លែងមួយជិតមន្ទីរសន្តិសុខចម្ការស្វាយចន្ទី ។ ប្រជាជនដែលត្រូវចូលរួមប្រជុំមិនអនុញ្ញាតឲ្យយកអីវ៉ាន់តាមខ្លួនច្រើនឡើយ ។ ក្រោយពីប្រជុំចប់និងក្រោយពីហៅឈ្មោះឲ្យឡើងជិះរទេះគោ ប្រជាជនទាំងនោះត្រូវបានដឹកយកទៅសម្លាប់ចោលនៅចម្ការស្វាយចន្ទី ។ ឡុង សុខខៃ សព្វថ្ងៃរស់នៅភូមិវាលរីកើត ឃុំស្វាយទាបបានប្រាប់ថាប្រធានកងរបស់គាត់បានកោះហៅឲ្យទៅចូលរួមប្រជុំដែរ ប៉ុន្តែថ្ងៃនេះគាត់រវល់ទៅដឹកខសមកឲ្យសហករណ៍ ទើបគាត់បានរួចខ្លួនពីការសម្លាប់ ។ ព្រឹត្តិការណ៍នេះបានកើតមានប្រហែលជានៅខែកក្កដា ឬខែសីហាឆ្នាំ១៩៧៨គឺបន្ទាប់ពីការរំលាយមន្ទីរសន្តិសុខភ្នាម១ ។

សុខខៃ រំឭកថា ខ្មែរក្រហមបានចាត់ឲ្យគាត់មកយាមនៅជ្រុងប៉ែកខាងជើងក្បែររបងព្រៃឫស្សីមន្ទីរសន្តិសុខដើម្បីយាមអ្នកទោសដែលទទួលបញ្ជាឲ្យជីករណ្តៅទាំងយប់លួចរត់ចេញ ។ សុខខៃ ឮសូរសំឡេងកាប់ដីពេញមួយយប់ ហើយអ្នកកាប់ដីគឺប្រជាជនដែលជាប់និន្នាការនយោបាយពីសង្គមចាស់និងជនជាតិយួន ។ ក្រោយពីកាប់រណ្តៅរួច អ្នកទាំងនោះត្រូវខ្មែរក្រហមសម្លាប់ទម្លាក់ចូលក្នុងរណ្តៅដែលអ្នកទោសបានជីក ហើយរណ្តៅខ្លះទុកសម្រាប់ដាក់សាកសពជនរងគ្រោះដទៃទៀតដែលត្រូវសម្លាប់នៅពេលក្រោយទៀត ។ រយៈពេលជិតកន្លះឆ្នាំមានជនរងគ្រោះប្រហែល៧.០០០នាក់ត្រូវបានសម្លាប់ ។ ការសម្លាប់ត្រូវបានធ្វើឡើងជាបីដំណាក់កាលគឺ÷

- **ដំណាក់កាលទី១:** សម្លាប់ជនជាតិយួន(អ្នកជាប់ខ្សែវៀតណាម) ព្រោះខ្មែរក្រហមគិតថាជាការសងសឹកមួយចំពោះការវាយបករបស់វៀតណាមមកលើខ្មែរក្រហមនៅដើមឆ្នាំ១៩៧៨ ។
- **ដំណាក់កាលទី២:** សម្លាប់ប្រជាជនពិសេសបុរសដែលមានមាឌធំៗមាំមួន ដោយបញ្ឆោតថា ឲ្យមកជួយរៀបចំធ្វើផ្ទះ ។ បន្ទាប់មកក៏យកទាំងគ្រួសារមកសម្លាប់តាមក្រោយ ។
- **ដំណាក់កាលទី៣:** សម្លាប់រួមប្រជាជនគ្រប់ភូមិដែលមានចំនួន១៣ភូមិចំណុះឲ្យឃុំស្វាយទាប ។

ឈុន ឡា ជាសាក្សីតែម្នាក់គត់ដែលបានឃើញហេតុការណ៍នេះនៅពេលគាត់ដឹកអ្នកទោសចូលទៅកាន់កន្លែងសម្លាប់នៅចម្ការស្វាយចន្ទី ។ ឈុន ឡា បរិយាយថា មេខ្មែរក្រហមពីរនាក់ដែលក្នុងនោះមានម្នាក់ឈ្មោះ សួន បញ្ជាឲ្យកងឈ្លបចូលទៅចងមនុស្សនៅលើរទេះទាំងប៉ុន្មានយកទៅសម្លាប់ចោលដោយឲ្យលុតជង្គង់ក្បែរមាត់រណ្តៅ ហើយកងឈ្លបទាំងនោះប្រើដំបងនិងពូថៅវាយទៅលើជនរងគ្រោះទម្លាក់ក្នុងរណ្តៅតែម្តង ។ ដោយសារតែគាត់ឃើញហេតុការណ៍នេះ ទើបប៉ុន្មានថ្ងៃក្រោយប្រធានឃុំស្វាយទាបនិងជាប្រធានចាត់ចែងផ្ទាល់នៅទីតាំងសម្លាប់ស្វាយចន្ទីឈ្មោះ យ៉ុន ហៅគាត់ឲ្យមកប្រជុំនៅម៉ោង៦ល្ងាច ដើម្បីបំផុសកម្លាំងឲ្យចូលរួមកម្ទេចខ្មាំងជួយគាំទ្របក្សនិងប្រកាន់ជំហរម៉ឺងមាត់ជួយលាក់ការណ៍ខ្ពស់ឲ្យបក្ស ។

ការសម្លាប់មនុស្សនៅចម្ការស្វាយចន្ទីបានបញ្ចប់នៅមុនថ្ងៃរំដោះ ៧ មករា ១៩៧៩ ព្រោះមានការហាមឃាត់ពីគណៈភូមិភាគឈ្មោះ កែ ពក ។ យ៉ុន ដែលជាប្រធានចាត់ចែងក្នុងការសម្លាប់មនុស្សនៅទីនោះ ត្រូវបានសម្លាប់តាមបញ្ជាផ្ទាល់របស់ កែ ពក ។ ឈុន ឡា បានឲ្យដឹងថា កែ ពក ប្រហែលជាបានទទួលបញ្ជាតាមលិខិតដែលចេញដោយគណៈ៨៧០ថា ត្រូវបញ្ឈប់ការសម្លាប់មនុស្សនៅក្នុងរយៈពេលប៉ុន្មានខែចុងឆ្នាំ១៩៧៨នេះ ។ ឈុន ឡា បន្តថា ឈ្មោះរបស់គាត់ត្រូវសន្តិសុខកត់ត្រាចូលទៅក្នុងបញ្ជីសម្លាប់ជាមួយមនុស្សប្រមាណ២០នាក់ផ្សេងទៀត ប៉ុន្តែគាត់និងអ្នកឯទៀតបែរជារួចពីការសម្លាប់ ហើយទទួលភារៈជាអ្នកដើរមើលការខុសត្រូវរោងចក្រនិងស្ពានទំនប់ទឹក ។

ក្នុងចំណោមប្រជាជន១៣ភូមិគឺនៅសល់ប្រជាជនភូមិព្រៃព្រាលមួយប៉ុណ្ណោះដែលមិនទាន់បានសម្លាប់ ព្រោះសារាចររបស់គណៈ៨៧០ បានចេញទប់ស្កាត់ការសម្លាប់នេះទាន់ពេលវេលា ។

## ៤) មន្ទីរសន្តិសុខចម្ការកៅស៊ូគីឡូលេខ២

មន្ទីរសន្តិសុខចម្ការកៅស៊ូគីឡូលេខ២ ស្ថិតនៅក្នុងភូមិលេខ២ ឃុំចម្ការអណ្តូង ស្រុកចម្ការលើ ខេត្តកំពង់ចាម ។ ខ្មែរក្រហមសាងសង់ឡើងដើម្បីឃុំឃាំងអ្នកទោសជាប្រជាជនមូលដ្ឋានដែលលួចទ្រព្យសម្បត្តិសមូហភាព ខ្ជិលធ្វើការ កម្មករចម្ការកៅស៊ូ

យុទ្ធជន និងអ្នកមានជាប់ពាក់ព័ន្ធនឹងនិន្នាការនយោបាយពីសង្គមចាស់ ។ មន្ទីរសន្តិសុខនេះជារបស់ឃុំចម្ការអណ្ដូង ។ អ្នកទោសទាំងអស់ត្រូវកងសន្តិសុខបញ្ជាឲ្យធ្វើពលកម្មធ្ងន់ៗ ហើយរបបអាហារត្រូវបានកំណត់តាមកម្លាំងពលកម្មដែលបានបំពេញការងារ ។ ផែង ពល បច្ចុប្បន្នរស់នៅភូមិលេខ១ ឃុំចម្ការអណ្ដូង ស្រុកចម្ការលើ ជាអ្នកធ្លាប់ជាប់គុកនៅមន្ទីរសន្តិសុខនេះ ។ ពល ពោលថា លំបាកខ្លាំងណាស់ ហើយអ្នកទោសភាគតិចបំផុតដែលអាចទ្រាំទ្រនឹងពលកម្មធ្ងន់ៗបាន ។ អ្នកទោសដែលពុំសូវប្រឹងប្រែងធ្វើការងារត្រូវកងសន្តិសុខនាំយកទៅសម្លាប់ចោលនៅប៉ែកខាងក្រោយមន្ទីរសន្តិសុខ ។ ការសម្លាប់មនុស្សបានប្រព្រឹត្តទៅជារៀងរាល់ថ្ងៃតាំងពីមន្ទីរនេះកកើតដំបូងនៅឆ្នាំ១៩៧៦ ។ ផែង ពល ដឹងថា មានការសម្លាប់មនុស្សយ៉ាងច្រើននៅចម្ការកៅស៊ូគីឡូលេខ២នេះ ប៉ុន្តែគាត់មិនដឹងពីចំនួនពិតប្រាកដឡើយ ។ ប្រធានឃុំចម្ការអណ្ដូង ឈ្មោះ ម៉ែន មួង បានបន្ថែមថា គាត់សង្កេតឃើញមានរណ្ដៅចំនួនពី៣០ទៅ៤០នៅជុំវិញបរិវេណមន្ទីរសន្តិសុខ ព្រោះមានស្លាកស្នាមជីកគាស់រកមាសនិងវត្ថុមានតម្លៃផ្សេងទៀតកាលពីអំឡុងឆ្នាំ១៩៨០ ដែលធ្វើឲ្យឆ្អឹងនិងលលាដ៍ក្បាលនៅរាយពាសពេញចម្ការកៅស៊ូ ។ មួង បានដឹងថា សាត ជាប្រធានសន្តិសុខចុងក្រោយបង្អស់នៅចម្ការកៅស៊ូគីឡូ២និងជាមនុស្សរបស់ភូមិភាគនិរតី ។ ផែន ពល បន្ថែម ថា សាត ជាអ្នកបញ្ជាផ្ទាល់ក្នុងការសម្លាប់អ្នកទោសដែលមានចំនួនប្រមាណពី៣០០ទៅ៤០០នាក់ ។ ម៉ែន មួង អះអាងថា «មានគ្រួសារមួយនោះ (ភ្លេចឈ្មោះ) ត្រូវខ្មែរក្រហមនាំយកទៅសម្លាប់ទាំងគ្រួសារដោយសារ មានបងប្អូនធ្វើជាទាហានលន់នល់» ។ ផែន ពល និយាយទាំងហួសចិត្តថា នៅចុងឆ្នាំ១៩៧៨ សារាចរមួយរបស់គណៈ៨៧០ ប្រកាសជាចំហឲ្យផ្អាក«ការសម្លាប់មនុស្ស»សិន ។ សារាចរនេះបានចេញយឺតពេលបន្តិចព្រោះកងសន្តិសុខបានសម្លាប់មនុស្សអស់ជាង៣០០នាក់រួចទៅហើយនៅមន្ទីរឃុំឃាំងចម្ការកៅស៊ូគីឡូលេខ២ ។ ពល បានអានសារាចរនេះហើយដឹងច្បាស់ថា ពិតជាមានមតិណែនាំលែងឲ្យមានការសម្លាប់មនុស្សតទៅទៀតមែន ។ ពល សង្កត់ធ្ងន់ថា នៅខាងលើសារាចរនេះមានដាក់ថា «គណៈ៨៧០» ។ បន្ទាប់ពីទទួលបានសារាចរនេះមន្ទីរសន្តិសុខចម្ការកៅស៊ូគីឡូលេខ២លែងមានសមកម្មភាពសម្លាប់ ។ ផែន ពល និងអ្នកឯទៀតបានវិលត្រឡប់ទៅស្រុកកំណើតរៀងៗខ្លួនវិញ ។

សព្វថ្ងៃនេះអតីតមន្ទីរសន្តិសុខចម្ការកៅស៊ូគីឡូលេខ២បានក្លាយទៅជាការិយាល័យរបស់កងជីវពលការពារចម្ការកៅស៊ូចម្ការអណ្ដូង ។ ចំណែកកន្លែងកប់សាកសពដែលមានចម្ងាយប្រហែល១៥០ម៉ែត្រពីមន្ទីរសន្តិសុខបានក្លាយទៅជាដីវាលរាបស្មើមួយសម្រាប់បណ្ដុះកូនកៅស៊ូ ។

## ស្រុកជើងព្រៃ

### មន្ទីរសន្តិសុខឡធ្យូង

មន្ទីរសន្តិសុខឡធ្យូងស្ថិតនៅភូមិរវាងឃុំខ្នុរដំបង ស្រុកជើងព្រៃ ខេត្តកំពង់ចាម ។ មន្ទីរនេះសាងសង់ឡើងនៅឆ្នាំ១៩៧៤ ធ្វើពីឈើប្រក់ស្លឹកត្នោត និងហ៊ុមព័ទ្ធជុំវិញ ដោយរបងឫស្សីខ្ពស់ៗ សម្រាប់ឃុំឃាំងអ្នកទោសដែលខ្មែរក្រហមចាប់មកពីកន្លែងផ្សេង និងអ្នកដែលជាប់និន្នាការពីសង្គមចាស់ ។

ចេក ឈួន ជាជាងឈើនៅក្នុងរបបខ្មែរក្រហមបាននិយាយថា គាត់លបមើលទៅក្នុងមន្ទីរឃុំឃាំងតាមប្រឡោះរបងឃើញអ្នកទោសអង្គុយពីរជួរទល់មុខគ្នាគឺបុរសមួយជួរនិងស្ត្រីមួយជួរ ។ នៅចុងជើងអ្នកទោសទាំងពីរជួរ កងសន្តិសុខបានសឹករនុកដែកខ្ទាស់ចាក់សោនៅខាងចុងយ៉ាងរឹងមាំ ។ នៅខាងត្បូងមន្ទីរឃុំឃាំងប្រហែល៥០០ម៉ែត្រ មានទីតាំងកប់សាកសពពីរកន្លែងដែលសរុបទៅមានប្រហែលជាង៤០០រណ្ដៅ ។

## ស្រុកដំបែ

### មន្ទីរសន្តិសុខខ្នុរចាស់

មន្ទីរសន្តិសុខតំបន់២១ខ្នុរចាស់ស្ថិតនៅក្នុងភូមិខ្នុរ ឃុំនាងទើត ស្រុកដំបែ ។ ខ្នុរចាស់មានទីតាំងធំទូលាយមួយមានទំហំប្រហែល១៥០ម៉ែត្របួនជ្រុង ។ នៅក្នុងឆ្នាំ១៩៧៦ ទីតាំងនេះបានក្លាយជាមន្ទីរសន្តិសុខប្រចាំតំបន់២១ ។ ខ្មែរក្រហមបានសង់រោងធំៗចំនួនប្រាំ រោងខ្លះប្រក់ស្បូវ រោងខ្លះប្រក់ក្បឿង និងបាំងជញ្ជាំងឈើ ។ នៅជុំវិញបរិវេណនេះជាដីព្រៃ ស្ថិតនៅឆ្ងាយពីភូមិអ្នកស្រុក ។ ប៉ុន្តែបច្ចុប្បន្ន ខ្នុរចាស់ត្រូវប្រជាជនកាប់ឆ្ការរានយកដីដាំដំណាំនិងធ្វើជាដីកម្មសិទ្ធិ ។ លើសពីនេះទៅទៀត ផ្លូវដែលទើបនឹងស្ថាបនាមានសភាពហាក់ដូចជាខណ្ឌចែកទីតាំងនេះជាពីរផ្នែក ។

រោងទាំងប្រាំនៅក្នុងមន្ទីរសន្តិសុខនោះ ត្រូវអ្នកស្រុករុះរើគ្មានសល់ ។

យីវ អ៊ូច មានប្រសាសន៍ថា គាត់តែងតែក្រឡេកមើលទិដ្ឋភាពទីតាំងសម្លាប់ និងមន្ទីរសន្តិសុខខ្នុរចាស់នេះជានិច្ច ព្រោះវាមានចម្ងាយតែប្រមាណ៤០០ម៉ែត្រប៉ុណ្ណោះពីផ្ទះរបស់គាត់ ។ កូនគាត់ម្នាក់ឈ្មោះ សេង សែត ត្រូវខ្មែរក្រហមសម្លាប់នៅឆ្នាំ១៩៧៧ ក្នុងភូមិគោកស្រុក ឃុំចុងដាច ស្រុកដំបែ ។ សេង សាត ជាអតីតយុទ្ធជនកងពិសេសរបស់ខ្មែរក្រហមបាននិយាយថា មន្ទីរសន្តិសុខខ្នុរចាស់ជាមន្ទីរសន្តិសុខប្រចាំតំបន់២១ ។ អ្នកទោសភាគច្រើនត្រូវបានសម្លាប់ដាក់ក្នុងរណ្តៅខាងក្រោយមន្ទីរសន្តិសុខនេះ ។ ខ្មែរក្រហមបានចងមុខអ្នកទោស រួចចាប់បោះដាក់ទៅលើរថយន្តធំៗដែលចតចាំជាស្រេចដើម្បីដឹកចេញទៅកាន់មន្ទីរសន្តិសុខខ្នុរចាស់ ។ ចំណែកអ្នកទោសជាអតីតកម្មាភិបាលធំៗរបស់កងទ័ពខ្មែរក្រហម (ចាប់ពីប្រធានក្រុមឡើងទៅ) និងប្រជាជនដែលមានជាប់ខ្សែខាងរបបលន់នល់ ក៏ត្រូវឃុំឃាំងនៅមន្ទីរសន្តិសុខខ្នុរចាស់នេះដែរ ដោយសាររឿងរ៉ាវខុសសីលធម៌ និងអនុវត្តខុសពីមាគ៌ាបក្ស ។

នៅឆ្នាំ១៩៧៦ ស៊ឹម វុន ប្រធានវរសេនាធំការពារព្រំដែន នៅភូមិត្រមូង(ឃុំត្រមូង) ខេត្តកំពង់ចាម ត្រូវខ្មែរក្រហមចាប់យកមកឃុំឃាំងនៅក្នុងមន្ទីរសន្តិសុខនេះ ហើយបង្ខំឲ្យទៅធ្វើស្រែ និងរំលំដើមឈើនៅកន្លែងឆ្ងាយៗពីមន្ទីរសន្តិសុខ ។ នៅឆ្នាំ១៩៧៧ វុន ត្រូវបានដោះលែងមកវិញ ។ ចំណែកអ្នកទោសផ្សេងទៀតមិនមានសំណាងដូចគាត់ឡើយ ។

យន់ សុភី ជាប្រធានមន្ទីរសន្តិសុខតំបន់២១នៅខ្នុរចាស់ និង ឡៃ ឡេត ជាអនុប្រធាន ។ អ្នកទាំងពីរត្រូវបានសម្លាប់នៅដើមឆ្នាំ១៩៧៩ ។

## ស្រុកកំពង់សៀម

### មន្ទីរសន្តិសុខវត្តភ្នំប្រុស

វត្តភ្នំប្រុសជាវត្តល្អប្រណីតមួយសាងសង់ឡើងនៅលើកំពូលកូនភ្នំមួយដាច់ស្រឡះពីភូមិប្រជាជន ។ យើងអាចមើលឃើញវត្តយ៉ាងច្បាស់ពីផ្លូវជាតិលេខ៧ ហើយនៅជិតនោះមានវត្តមួយទៀតស្ថិតនៅលើកំពូលភ្នំដូចគ្នាគឺវត្តភ្នំស្រី ។ វត្តភ្នំប្រុសត្រូវខ្មែរក្រហមយកធ្វើជាមន្ទីរឃុំឃាំងអ្នកទោស ហើយនៅខាងជើងចន្លោះវត្តទាំងពីរមានរណ្តៅសាកសពធំៗចំនួន៤៧រណ្តៅនិងរណ្តៅតូចៗជាច្រើនទៀត ។ មន្ទីរសន្តិសុខនៅលើវត្តភ្នំប្រុសមានអ្នកទោសចំនួនប្រមាណ១០.០០០នាក់ដែលក្រោយមកត្រូវខ្មែរក្រហមសម្លាប់ចោលទាំងអស់ ។ ការសម្លាប់និងធ្វើទារុណកម្មអ្នកទោសបានកើតឡើងព្រមគ្នា ។ សាក្សីម្នាក់ (មិនស្គាល់ឈ្មោះ) បានចង្អុលបង្ហាញដើមឈើមួយដើមនៅជិតរណ្តៅសាកសពដែលខ្មែរក្រហមប្រើសម្រាប់សម្លាប់កូនក្មេងម្នាក់ដោយចាប់ជើងបោកផ្ទប់ ។ ក្រោយថ្ងៃរំដោះគាត់បានឃើញខួរឈាមនិងសក់នៅជាប់សំបកដើមឈើនៅឡើយ ។

វង់ សុផានី បានរាយការណ៍ថា កាលពីជំនាន់ខ្មែរក្រហមគ្រួសាររបស់គាត់ធ្លាប់ជាប់ឃុំឃាំងនៅក្នុងគុកភ្នំប្រុសនិងទទួលរងការធ្វើទណ្ឌកម្មយ៉ាងខ្លាំង ។ ម្តាយរបស់គាត់ត្រូវកម្មាភិបាលពេទ្យខ្មែរក្រហមចាក់ថ្នាំសម្លាប់នៅពេលដែលគាត់សម្រាកក្នុងមន្ទីរពេទ្យនោះដែរ ។ មន្ទីរពេទ្យដែល សុផានី សម្រាក គឺស្ថិតនៅក្នុងបរិវេណមន្ទីរសន្តិសុខវត្តភ្នំប្រុសតែម្តង ។ ដោយឃើញសភាពការណ៍បែបនេះ សុផានី បានលួចរត់ចេញពីមន្ទីរពេទ្យនៅពេលយប់ជាមួយប្អូនប្រុសពៅរបស់គាត់ ។ សុផានី និងប្អូនប្រុសបានត្រូវកងសន្តិសុខខ្មែរក្រហមម្នាក់ដេញតាមចាប់ ប៉ុន្តែ សុផានី ត្រូវបានប្រធានជនពិការខ្មែរក្រហមម្នាក់ជួយសង្គ្រោះឲ្យរួចខ្លួនពីគ្រោះថ្នាក់ ។ រយៈពេល៣ថ្ងៃក្រោយមក សុផានី បានភៀសខ្លួនទៅរស់នៅជនបទដោយជិះរថយន្តដឹកទំនិញមួយគ្រឿងដែលមានសមមិត្ត អង់ គឹមអេង ជាអ្នកបើកបរ ហើយបច្ចុប្បន្នគឺជាប្តីរបស់គាត់ ។ សុផានី និយាយទាំងខ្សឹកខ្សួលថា ប្អូនប្រុសម្នាក់ បងស្រី២នាក់និងឪពុកម្តាយរបស់គាត់ត្រូវពួកខ្មែរក្រហមសម្លាប់ទាំងអស់ ។

នៅក្រោយថ្ងៃរំដោះឆ្នាំ១៩៧៩ រណ្តៅសាកសពភាគច្រើនត្រូវបានគាស់បំផ្លាញ ហើយឆ្អឹងសាកសពស្ថិតនៅលើដីរាយប៉ាយពេញទីនោះ ។ ឆ្អឹងសាកសពមួយចំនួនត្រូវបានប្រមូលតម្កល់ទុកក្នុងអគារចាស់មួយខ្នងដែលពីមុនជាផ្ទះបាយរបស់ព្រះសង្ឃនិងដូនជីសំណាក់ធម៌ ប៉ុន្តែក្រោយមកអដ្ឋិធាតុទាំងនេះត្រូវបានដឹកជញ្ជូនយកទៅតម្កល់ទុកនៅវត្តនគរវិញ ។ ***(នៅមានត)***

**ផេង ពង្សរ៉ាស៊ី**




# ព្រះពុទ្ធសាសនាក្រោមរបបប៉ុលពត

## អៀន ហ៉ែរីស

*ឯកសារស៊េរីលេខ១៣ ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា*

*ស្នាដៃនិពន្ធថ្មីដោយលោក អៀន ហ៉ែរីស សាស្ត្រាចារ្យផ្នែកព្រះពុទ្ធសាសនានៅសាកលវិទ្យាល័យ ខុមប្រៀ ចក្រភពអង់គ្លេស ស្រាវជ្រាវពីវាសនារបស់ព្រះពុទ្ធសាសនានៅមុនអំឡុងនិងក្រោយរបបកម្ពុជាប្រជាធិបតេយ្យ ។ ព្រំ ដល្លា បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាជាជំនួយការក្នុងគម្រោងស្រាវជ្រាវនេះ ។*

*បណ្ឌិត អៀន ហ៉ែរីស ចាប់ផ្តើមធ្វើការសិក្សាដោយពិនិត្យទៅលើព្រះពុទ្ធសាសនានៅក្នុងរបបសម្តេច សីហនុ និងរបបលន់នល់ បន្ទាប់មកលោកដឹកបុសគល់ទៅរកដើមកំណើតនិងទំនាក់ទំនងរបស់កុម្មុយនីស្តជាមួយព្រះពុទ្ធសាសនាក្នុងប្រទេសកម្ពុជា ។ បន្ទាប់មកលោកសិក្សាអំពីព្រះពុទ្ធសាសនានៅភាគខាងដើមនៃរបបនេះ ដូចជាការជម្លៀសព្រះសង្ឃ ការភៀសខ្លួនចេញទៅបរទេស ការសម្រាត ស្បង់ជីពរ ការរៀបការ ដោយបង្ខំ ការចូលបម្រើការងារកងទ័ព និងការធ្វើគតព្រះសង្ឃ ។*

*ការប្រណិប័តន៍ព្រះពុទ្ធសាសនានៅក្នុងរបបខ្មែរក្រហមក៏ត្រូវបានស្រាវជ្រាវ រួមមានទាំងពិធីសាសនា វាសនារបស់វត្តអារាម រូបគំនូរ និងគម្ពីរសាសនាជាដើម ។ បណ្ឌិត ហ៉ែរីស បានពិនិត្យពិច័យ ថ្លឹងថ្លែង ការអះអាងពីការស្លាប់របស់ព្រះសង្ឃនិងវត្តអារាមដែលត្រូវបានបំផ្លាញនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យទៅនឹងការរកឃើញរបស់គាត់ពីបទសម្ភាសន៍ដ៏ច្រើនរួមទាំងឯកសារស្រាវជ្រាវផ្សេងៗ ។ បណ្ឌិត ហ៉ែរីស បានសន្និដ្ឋានថានៅរបបកម្ពុជាប្រជាធិបតេយ្យគ្មានគោលនយោបាយណាមួយក្នុងការលុបបំបាត់ព្រះសង្ឃជាទូទៅទេ ។*

*អៀន ហ៉ែរីស ជាសាស្ត្រាចារ្យសិក្សាផ្នែកព្រះពុទ្ធសាសនា នៅសាកលវិទ្យាល័យខុមប្រៀចក្រភព អង់គ្លេស និង ទុង លីន កុកយូអិន ជាសាស្ត្រាចារ្យព្រះពុទ្ធសាសនានិងផ្នែកសង្គម បច្ចុប្បន្នបម្រើការនៅសាកលវិទ្យាល័យអង់គ្លេសកូឡុមបៀ វ៉ាន់គូវ័រ ប្រទេសកាណាដា ។ លោក អៀន ហ៉ែរីស ជាសហស្ថាបនិកនៃសមាគមសិក្សាព្រះពុទ្ធសាសនានៃចក្រភពអង់គ្លេស (UKABS) និងជាអ្នកនិពន្ធនៃស្នាដៃជាច្រើនស្តីពីសីលធម៌និងនយោបាយរបស់ព្រះពុទ្ធសាសនា ដោយធ្លាប់មានស្នាដៃក្នុងសៀវភៅមុនរបស់លោកគឺព្រះពុទ្ធសាសនាកម្ពុជាប្រវត្តិសាស្ត្រនិងការប្រតិបត្តិ(២០០៥) ។ សព្វថ្ងៃ លោកកំពុងអង្កេតអំពីទំនាក់ទំនងរវាងព្រះពុទ្ធសាសនានិងនយោបាយសម័យមុនប៉ុលពតនៅប្រទេសកម្ពុជា ។*

*សូមអញ្ជើញជាវសៀវភៅ «ព្រះពុទ្ធសាសនាក្រោមរបបប៉ុលពត» នៅការិយាល័យព័ត៌មានសាធារណៈរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ឬនៅម៉ូញ៉ូវមិនប៊ុក ចាប់ពីខែមករានេះ ឬទាក់ទងមជ្ឈមណ្ឌលតាមរយៈសារអេឡិចត្រូនិច dccam@online.com.kh ឬទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ មួយក្បាលតម្លៃ១៥ដុល្លារអាមេរិក ។*

*យើងខ្ញុំសូមថ្លែងអំណរគុណដល់ភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិស៊ុយអែត (Sida) ដែលបានជួយឧបត្ថម្ភក្នុងការបោះពុម្ពផ្សាយនេះ និង USAID និង Sida ចំពោះការគាំទ្រដ៏សំខាន់ដល់មជ្ឈមណ្ឌលឯកសារកម្ពុជា ។*

# ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)

## ជំពូកទី១០

## ទំនាក់ទំនងការបរទេស

កម្ពុជាប្រជាធិបតេយ្យបានធ្វើទំនាក់ទំនងការទូតជាមួយប្រទេសចិន កូរ៉េខាងជើង វៀតណាម ឡាវ គុយបា រូម៉ានី យូហ្គោស្លាវី អាល់បានី និងអេហ្ស៊ីប ។ ប្រទេសទាំងអស់នេះមានស្ថានទូតក្នុងទីក្រុងភ្នំពេញ ។ ក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ ឯកអគ្គរដ្ឋទូតទាំងអស់លើកលែងតែឯកអគ្គរដ្ឋទូតចិនត្រូវបានបង្ខាំងឲ្យនៅតែក្នុងស្ថានទូតរៀងៗខ្លួន ។

កម្ពុជាប្រជាធិបតេយ្យបានបើកស្ថានទូតរបស់ខ្លួននៅប្រទេសចិន កូរ៉េខាងជើង វៀតណាម (រហូតដល់ខែធ្នូឆ្នាំ ១៩៧៧) និងឡាវ ។ ក្នុងចំណោមប្រទេសទាំងនេះ ទំនាក់ទំនងជាមួយចិននិងកូរ៉េខាងជើងមានលក្ខណៈល្អប្រសើរ ហើយទំនាក់ទំនងជាមួយឡាវមានលក្ខណៈល្អបង្គួរ ។ ប៉ុន្តែទំនាក់ទំនងជាមួយវៀតណាមកាន់តែមានលក្ខណៈអាក្រក់ទៅៗ ដោយសារតែការប៉ះទង្គិចគ្នានៅតាមបណ្តោយព្រំដែននិងការខ្វែងគំនិតគ្នាខាងមនោគមវិជ្ជា ។ មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាភាគច្រើនជាអ្នកប្រឆាំងនឹងវៀតណាម ហើយមេដឹកនាំណាដែលធ្លាប់រស់នៅ ឬធ្លាប់មានទំនាក់ទំនងជាមួយវៀតណាមនឹងត្រូវធ្វើវិសុទ្ធកម្ម (លើកលែងតែ សុន សេន និង អៀង សារី) ។ អ្នកទាំងអស់នេះត្រូវបានចោទប្រកាន់ថាជាមនុស្ស "ក្បាលយួន ខ្លួនខ្មែរ" ។ ប្រទេសទាំងពីរក៏មានការខ្វែងគំនិតគ្នាផងដែរទៅលើបញ្ហាថាតើអ្នកណាជាអ្នកកាន់កាប់កោះប្រេងកាតនៅក្នុងដែនសមុទ្រខ្មែរ ។

បក្សកុម្មុយនីស្តកម្ពុជាមានបំណងចង់ដណ្តើមយកកម្ពុជាក្រោមពីវៀតណាមមកវិញ ។ បក្សក៏មិនពេញចិត្តចំពោះគំនិត



មេដឹកនាំកម្ពុជាប្រជាធិបតេយ្យនិងគណៈប្រតិភូបរទេស



មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមនិងគណៈប្រតិភូបរទេស

របស់វៀតណាមដែលចង់បង្កើតសហព័ន្ធឥណ្ឌូចិនដែរ ។

ការប៉ះទង្គិចគ្នារវាងកម្ពុជាប្រជាធិបតេយ្យ និងវៀតណាម បានចាប់ផ្តើមឡើងនៅចុងឆ្នាំ១៩៧៥ ។ បន្ទាប់ពីនោះ ការប្រយុទ្ធគ្នាដ៏ខ្លាំងក្លាបានផ្ទុះឡើងនៅកោះត្រល់ (ហ្វូកុកជាភាសាវៀតណាម) ។ នៅពាក់កណ្តាលឆ្នាំ១៩៧៦ កម្ពុជាប្រជាធិបតេយ្យបានបង្កើនទំនាក់ទំនងកាន់តែជិតស្និទ្ធជាមួយប្រទេសចិនហើយជម្លោះរវាងកម្ពុជាប្រជាធិបតេយ្យនិងវៀតណាមបានក្លាយទៅជាផ្នែកមួយនៃជម្លោះរវាងចិននិងសូវៀតដែលនៅពេលនោះរដ្ឋាភិបាលក្រុងមូស្គូគាំទ្រវៀតណាម ហើយរដ្ឋាភិបាលក្រុងប៉េកាំងគាំទ្រកម្ពុជាប្រជាធិបតេយ្យ ។ នៅចុងឆ្នាំ១៩៧៦ កម្ពុជាប្រជាធិបតេយ្យទទួលបានជំនួយយោធាយ៉ាងច្រើនសន្ធឹកសន្ធាប់ពីចិន ។ ក្នុងឆ្នាំ១៩៧៧ កងទ័ពកម្ពុជាប្រជាធិបតេយ្យបានបើកការវាយប្រហារទៅលើភូមិមួយចំនួនរបស់វៀតណាមដែលស្ថិតនៅតាមបណ្តោយព្រំដែនជាមួយកម្ពុជានិងបានសម្លាប់ប្រជាជនស្លូតត្រង់រាប់រយនាក់ ។ ទំនាក់ទំនងការទូតរវាងប្រទេសទាំងពីរត្រូវបានកាត់ផ្តាច់ទាំងស្រុងនៅខែធ្នូ ឆ្នាំ១៩៧៧ ។

ក្នុងឆ្នាំ១៩៧៨ កម្ពុជាប្រជាធិបតេយ្យបានខិតខំពង្រីកទំនាក់ទំនងការទូតរបស់ខ្លួន ហើយពាណិជ្ជកម្មក្រៅប្រទេសនៅពេលនោះបានឈានដល់កម្រិតកំពូល ។ ប្រទេសដែលធ្លាប់ធ្វើទំនាក់ទំនងពាណិជ្ជកម្មជាមួយកម្ពុជាប្រជាធិបតេយ្យមានប្រទេសចិន កូរ៉េខាងជើង ថៃ ជប៉ុន ហុងកុង ម៉ាដា ហ្គាស្កា បង់ក្លាដែស និងសិង្ហបុរី ។ ទំនិញនាំចេញសំខាន់ៗរបស់កម្ពុជាប្រជាធិបតេយ្យរួមមាន ស្រូវ ជ័រកៅស៊ូ ឈើ និងសរីរាង្គសត្វដ៏កម្រ (ស្បែក, ភ្លុក, ស្នូក) ។ ចំណែកទំនិញនាំចូលវិញ រួមមានគ្រឿងសព្វាវុធ រថក្រោះ កាំភ្លើងធំ ម៉ាស៊ីនសម្រាប់ធ្វើស្រែចម្ការ ផលិតផលគីមី និងក្រណាត់ ។

ទំនិញនាំចេញភាគច្រើនរបស់កម្ពុជាប្រជាធិបតេយ្យមានចំនួនតិចតួចណាស់ បើប្រៀបធៀបទៅនឹងការនាំចេញនៅមុនឆ្នាំ១៩៧០ ហើយត្រូវបាននាំយកទៅប្រទេសចិនដែលជាប្រទេសតែមួយគត់មានឥទ្ធិពលមកលើកម្ពុជាប្រជាធិបតេយ្យ ។ ពីឆ្នាំ១៩៧៧ដល់ចុងឆ្នាំ១៩៧៨ ចិនបានផ្តល់ឲ្យកម្ពុជាប្រជាធិបតេយ្យនូវរថក្រោះរាប់រយគ្រឿង រថយន្ត អាវុធធុនធ្ងន់ គ្រាប់ផ្លោងនិងគ្រាប់កាំភ្លើងរាប់ពាន់តោន និងយន្តហោះប្រតិកម្មចំនួនប្រាំមួយគ្រឿង ។ រដ្ឋាភិបាលចិនក៏បានផ្តល់ឲ្យនូវការជួសជុលផ្លូវរថភ្លើងមួយខ្សែភ្ជាប់ពីក្រុងភ្នំពេញទៅក្រុងកំពង់សោមនិងព្រលានយន្តហោះថ្មីមួយទៀតនៅខេត្តកំពង់ឆ្នាំង ។ ក្រៅពីទំនាក់ទំនងពាណិជ្ជកម្ម ជំនួយយោធា និងជំនួយហិរញ្ញវត្ថុ ចិនបានបញ្ជូនអ្នកជំនាញការរាប់ពាន់នាក់ឲ្យមកធ្វើជាអ្នកបច្ចេកទេសនិងជាទីប្រឹក្សារបស់កម្ពុជាប្រជាធិបតេយ្យ ។ អ្នកជំនាញការទាំងនេះបានជួយបង្ហាត់បង្រៀនក្បួនយោធា បច្ចេកទេសពេទ្យ និងបច្ចេកទេសក្នុងរោងចក្រដល់កម្មាភិបាលខ្មែរក្រហម ។ កម្ពុជាប្រជាធិបតេយ្យបានស្នើឲ្យចិនបញ្ជូនទ័ពមកជួយច្បាំងជាមួយវៀតណាម ប៉ុន្តែចិនបានបដិសេធ ហើយស្នើឲ្យមានបទឈប់បាញ់គ្នានិងធ្វើការចរចា ។ កម្ពុជាប្រជាធិបតេយ្យបានទាត់ចោលសំណើនេះ ។

## ជំពូកទី១១

## ការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ

### ១) មូលហេតុបីយ៉ាងនៃការដួលរលំរបស់កម្ពុជាប្រជាធិបតេយ្យ

*សភាពទុក្ខទ្រោមរបស់ប្រជាជន ៖* ផែនការបួនឆ្នាំរបស់កម្ពុជាប្រជាធិបតេយ្យបញ្ជាក់ថា កម្ពុជានឹងផលិតស្រូវឲ្យបានបីតោនក្នុងមួយហិកតារៀងរាល់ឆ្នាំ ។ តួលេខនេះមានចំនួនច្រើនលើសទិន្នផលមុនសម័យបដិវត្តន៍ ។ នៅពេលទិន្នផលស្រូវមិនបានគ្រប់ផែនការកំណត់កម្មាភិបាលនៅទូទាំងប្រទេសបានធ្វើរបាយការណ៍ក្លែងក្លាយ ។ បន្ទាប់មកកម្មាភិបាលទាំងនេះនឹងបញ្ជូនស្រូវយ៉ាងច្រើនទៅតាមចំនួនផែនការកំណត់ដោយទុកឲ្យប្រជាជនទទួលរង

ការអត់ឃ្លាន ។

ដោយសារតែប្រតិបត្តិការទូទាំងប្រទេសជាការសម្ងាត់នោះ ធ្វើឲ្យផែនការក្នុងការប្រមូលទិន្នផលស្រូវឲ្យបានបីតោនក្នុងមួយហិកតាមិនអាចអនុវត្តបាន ។ តំបន់ទាំងអស់ទូទាំងប្រទេសមិនត្រូវបានអនុញ្ញាតឲ្យចែករំលែកព័ត៌មានគ្នាទៅវិញទៅមកឬត្រួតពិនិត្យមើលថាតើមានបញ្ហាអ្វីខ្លះកំពុងកើតមានឡើងទេ ។ មជ្ឈិមបក្សកម្រចុះមកមើលស្ថានភាពរស់នៅរបស់ប្រជាជនឬរៀបចំផែនការឲ្យកម្មាភិបាលថ្នាក់ក្រោមរបស់ខ្លួនអនុវត្តណាស់ ។ មេដឹកនាំថ្នាក់លើហាក់ដូចជាជឿទាំងស្រុងនូវអ្វីដែលថ្នាក់ក្រោមបានរាយការណ៍ ចំណែកថ្នាក់ក្រោមមិនហ៊ានរាយការណ៍ព័ត៌មានមិនល្អណាមួយទៅថ្នាក់លើឡើយ ។ មន្ត្រីជាន់ខ្ពស់បក្សកុម្មុយនីស្តកម្ពុជាជឿជាក់ថា បក្សមិនដែលប្រព្រឹត្តកំហុសនិងមិនដែលសម្រេចចិត្តខុសទាល់តែសោះ ។ រាល់បញ្ហាដែលកើតមានឡើងត្រូវបានមេដឹកនាំទាំងនោះចោទប្រកាន់ថាជាកំហុសរបស់ជនបរទេសឬជនក្បត់ ។ ដោយសារតែលក្ខខណ្ឌរស់នៅកាន់តែមានសភាពយ៉ាប់យ៉ឺនទៅៗ ប្រជាជនរាប់សែននាក់បានស្លាប់ជាបន្តបន្ទាប់ដោយការធ្វើការហួសកម្លាំងនិងគ្មានអាហារបរិភោគគ្រប់គ្រាន់ ។

វិសុទ្ធកម្ម ៖ នៅពាក់កណ្តាលឆ្នាំ១៩៧៦ សមាជិកសំខាន់ៗជាច្រើនរូបរបស់បក្សកុម្មុយនីស្តកម្ពុជាត្រូវបានធ្វើវិសុទ្ធកម្ម ។ ចាប់ពីពេលនោះមក ប៉ុល ពត និងសហការីជឿថា ការបះបោរប្រឆាំងនឹងថ្នាក់ដឹកនាំបក្សកាន់តែកើតមានច្រើនឡើងៗ ។ ថ្នាក់ដឹកនាំទាំងនេះជឿថា សត្រូវរបស់ខ្លួនមាននៅគ្រប់ទីកន្លែង ។ គណៈភូមិភាគ គណៈតំបន់ និងមេបញ្ជាការកងទ័ព ជាច្រើនរូបត្រូវបានចាប់ខ្លួននិងសម្លាប់ចោល ។ សភាពការណ៍កាន់តែមានសភាពធ្ងន់ធ្ងរទៅៗក្នុងឆ្នាំ១៩៧៧ នៅពេលដែល ប៉ុល ពត បញ្ជាឲ្យធ្វើការសម្លាប់កម្មាភិបាលភូមិភាគបូព៌ានិងធ្វើវិសុទ្ធកម្មទៅលើប្រជាជនដែលរស់នៅក្នុងភូមិភាគនេះស្ទើរគ្មានសល់ ។ នៅពេលវៀតណាមវាយចូលភូមិភាគនេះនៅចុងឆ្នាំ១៩៧៧ ប្រជាជនដែលសេសសល់



កងចល័តកុមារ

ត្រូវបានចោទថាបានចូលដៃជាមួយវៀតណាម ហើយត្រូវបានមជ្ឈិមបក្សចាត់ទុកថាជាមនុស្ស“*ក្បាលយួន ខ្លួនខ្មែរ*” ។ ហេតុដូច្នេះហើយមជ្ឈិមបក្សបានបញ្ជូនកងទ័ពជាច្រើនមកវាយប្រហារភូមិភាគបូព៌ា ដែលបានសម្លាប់ប្រជាជនរាប់ម៉ឺននាក់ ។ ប្រជាជនរាប់ពាន់នាក់បានរត់ភៀសខ្លួនទៅវៀតណាម ដែលនៅទីនោះរដ្ឋាភិបាលវៀតណាមបានជួយបង្កើតកងកម្លាំងយោធាមួយ ។

*ការប៉ះទង្គិចជាមួយវៀតណាម* ៖ នេះគឺជាមូលហេតុធំបំផុតនៃការដួលរលំរបស់កម្ពុជាប្រជាធិបតេយ្យ ។ នៅឆ្នាំ១៩៧៥ កម្ពុជាប្រជាធិបតេយ្យចាប់ផ្តើមបង្កបញ្ហានៅតាមព្រំដែនបណ្តើរៗជាមួយវៀតណាម ។ ការប្រយុទ្ធគ្នាដ៏ខ្លាំងក្លាបានផ្ទុះឡើងនៅពាក់កណ្តាលឆ្នាំ១៩៧៧ គឺនៅពេលដែលខ្មែរក្រហមបានបាញ់ផ្លោងទៅលើទីរួមខេត្តចូវដុក ស្រុកហាទៀង និងខេត្តមួយចំនួនទៀតរបស់វៀតណាមដែលបណ្តាលឲ្យគ្រោះថ្នាក់ដល់ប្រជាជនស៊ីវិល និងកងទ័ពវៀតណាមជាច្រើននាក់ដែលមិនបានត្រៀមខ្លួនជាមុន ។ ប្រជាជនវៀតណាមរាប់ពាន់នាក់បានរត់ចូលទៅក្នុងផ្ទៃប្រទេស ។ ក្នុងអំឡុងពេលតែពីរ-បីថ្ងៃនៃការវាយប្រហារប្រជាជនស៊ីវិលវៀតណាមប្រហែលមួយពាន់នាក់បានរងរបួសនិងស្លាប់ ។

នៅខែធ្នូ ឆ្នាំ១៩៧៧ វៀតណាមបានប្រើយន្តហោះនិងកាំភ្លើងធំបើកការវាយប្រហារទ្រង់ទ្រាយធំមួយមកលើកម្ពុជាប្រជាធិបតេយ្យ ដោយដណ្តើមកាន់កាប់បានតំបន់ចំពុះសេកក្នុងខេត្តស្វាយរៀង ។ កងទ័ពវៀតណាមបានវាយសម្រុកចូលជាងម្ភៃគីឡូម៉ែត្រមកក្នុងទឹកដីកម្ពុជាប្រជាធិបតេយ្យ ហើយកាន់កាប់បានទីរួមខេត្តស្វាយរៀង ។ ឆ្លើយតបទៅវិញកម្ពុជាប្រជាធិបតេយ្យបានកាត់ផ្តាច់ចំណងការទូតជាមួយប្រទេសវៀតណាម ហើយបានបញ្ជាឲ្យអ្នកការទូតវៀតណាមទាំងអស់នៅទីក្រុងភ្នំពេញចាកចេញពីប្រទេសកម្ពុជា ។ ខ្មែរក្រហមយល់ព្រមធ្វើការចរចាលុះត្រាណាតែកងទ័ពវៀតណាមទាំងអស់ដកចេញពីទឹកដីកម្ពុជាប្រជាធិបតេយ្យជាមុនសិន ។ មួយរយៈកាលក្រោយមកទៀត



កងកុមារ

វៀតណាមបានដកទ័ពចេញពីប្រទេសកម្ពុជាដោយកៀរអ្នកទោស និងប្រជាជនស៊ីវិលរាប់ពាន់នាក់យកទៅជាមួយផង ។ គ្មានការចរចាណាមួយត្រូវបានធ្វើឡើងទេ ។

វៀតណាមបានចោទខ្មែរក្រហមថា បានធ្វើការវាយប្រហារទៅលើខេត្តទាំងប្រាំបីរបស់ខ្លួនដែលស្ថិតនៅតាមបណ្តោយព្រំដែនជាប់កម្ពុជា ។ វៀតណាមបានជំរុញឲ្យមានការបង្កើតកម្លាំងបដិបក្ខមួយដើម្បីធ្វើការបះបោរប្រឆាំងនឹងខ្មែរក្រហម ។ វៀតណាមក៏បានចាប់ផ្តើមហ្វឹកហ្វឺនជនកម្ពុជាដែលរស់នៅក្នុងប្រទេសវៀតណាមឲ្យចូលរួមក្នុងប្រតិបត្តិការយោធា និងបង្កើតកម្លាំងស្នូលសម្រាប់របបថ្មីមួយ ។ ប្រទេសទាំងពីរបានប្រយុទ្ធគ្នាពេញមួយរយៈកាលនៃឆ្នាំ១៩៧៨ ។

នៅថ្ងៃទី៣ ខែមេសា ឆ្នាំ១៩៧៨ វិទ្យុក្រុងហាណូយដែលផ្សាយជាភាសាខ្មែរបានអំពាវនាវឲ្យប្រជាជនកម្ពុជាទាំងអស់ក្រោកឈរឡើងប្រឆាំងនឹងរបបកម្ពុជាប្រជាធិបតេយ្យ ។ វៀតណាមបានជ្រើសរើសប្រជាជនខ្មែរមួយចំនួនដែលបានភៀសខ្លួនទៅវៀតណាមឲ្យចូលបម្រើក្នុងជួរកងទ័ពដឹកនាំដោយវៀតណាម ។ ភាគច្រើននៃជនជាតិខ្មែរទាំងនេះគឺជាកម្មាភិបាល កងទ័ព និងប្រជាជនមកពីភូមិភាគបូព៌ា ។ មកត្រឹមពេលនេះមួយផ្នែកនៃភូមិភាគបូព៌ាស្ថិតនៅក្រោមការគ្រប់គ្រងរបស់វៀតណាម ហើយមួយផ្នែកទៀតស្ថិតនៅក្រោមការគ្រប់គ្រងរបស់កងកម្លាំងបះបោរដែលប្រឆាំងនឹងខ្មែរក្រហម ។

នៅថ្ងៃទី៣ ខែធ្នូ ឆ្នាំ១៩៧៨ វិទ្យុក្រុងហាណូយបានផ្សព្វផ្សាយពីការបង្កើតឡើងនូវរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ។ រណសិរ្សនេះដឹកនាំដោយសមមិត្ត ហេង សំរិន ដែលបានភៀសខ្លួនទៅវៀតណាមនៅចុងឆ្នាំ១៩៧៨ ។

មេបញ្ជាការកងទ័ពវៀតណាម វ៉ាន់ ទៀនយុង បានដឹកនាំធ្វើការវាយប្រហារយ៉ាងខ្លាំងក្លាមកលើកម្ពុជាប្រជាធិបតេយ្យនៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៧៨ ។ ទ័ពរបស់ វ៉ាន់ ទៀនយុង បានវាយកាន់កាប់ខេត្តក្រចេះ ក្នុងរយៈពេលប្រាំថ្ងៃ និងខេត្តកំពង់ចាមក្នុងរយៈពេលមួយសប្តាហ៍ ។ បន្ទាប់មកនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ កងទ័ពវៀតណាមនិងកងទ័ពរបស់រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាវាយដណ្តើមបានរដ្ឋធានីភ្នំពេញ និងស្ទើរតែផ្ទៃប្រទេសទាំងមូលក្នុងពេលបន្តបន្ទាប់មកទៀត ។ កងទ័ពទាំងពីរបានរៀបចំមហាសន្និបាតមួយដើម្បីបង្កើតក្រុមប្រឹក្សាប្រជាជនបដិវត្តន៍កម្ពុជាឲ្យធ្វើជារដ្ឋាភិបាលបណ្តោះអាសន្នក្រោមការដឹកនាំរបស់សមមិត្ត ហេង សំរិន ។

## ២) កម្ពុជាប្រជាធិបតេយ្យក្រោយឆ្នាំ១៩៧៩

ដើមឆ្នាំ១៩៧៩ វៀតណាមបានជួយរៀបចំបង្កើតរបបថ្មីមួយនៅទីក្រុងភ្នំពេញដែលមានឈ្មោះថា "សាធារណរដ្ឋប្រជាមានិតកម្ពុជា" ។ របបនេះគ្រប់គ្រងប្រទេសកម្ពុជារហូតដល់វៀតណាមដកទ័ពចេញមួយទសវត្សរ៍ក្រោយមកទៀតគឺនៅឆ្នាំ១៩៩០ ។ មេដឹកនាំនិងកងទ័ពរបស់កម្ពុជាប្រជាធិបតេយ្យបានរត់ភៀសខ្លួនពីទីក្រុងភ្នំពេញទៅភាគពាយ័ព្យប្រទេស ដោយថ្មើរជើង រថយន្តនិងរទេះភ្លើង ។ ខ្មែរក្រហមបានកៀរប្រជាជនរាប់ម៉ឺននាក់ដោយបង្ខំឲ្យទៅជាមួយខ្លួន ។ ក្នុងអំឡុងពេលនៃការជម្លៀសជាលើកទីពីរនេះ ប្រជាជនជាច្រើនបានស្លាប់ដោយសារអត់អាហារ ជំងឺនិងរបួស ។

ប្រជាជនជាច្រើនបានស្វះស្វែងរកផ្លូវត្រឡប់មកភូមិកំណើតរបស់ខ្លួនវិញ ។ សម្តេចព្រះនរោត្តម សីហនុ និងព្រះញាតិវង្សានុវង្សត្រូវបានជម្លៀសតាមយន្តហោះទៅប្រទេសចិន ។

ខ្មែរក្រហមបានរៀបចំអង្គការចាត់តាំងរបស់ខ្លួនឡើងវិញនៅតាមបណ្តោយព្រំដែនថៃ ដោយមានជំនួយយោធាពីបរទេសរួមមានមកពីប្រទេសចិននិងប្រទេសថៃ ។ រហូតដល់ឆ្នាំ១៩៩០ មហាសន្និបាតអង្គការសហប្រជាជាតិបានអនុញ្ញាតឲ្យតំណាងរបស់កម្ពុជាប្រជាធិបតេយ្យបន្តកាន់កាប់អាសនៈរបស់កម្ពុជានៅអង្គការសហប្រជាជាតិ បើទោះបីជាមានការជំទាស់ពីសាធារណរដ្ឋប្រជាមានិតកម្ពុជានិងសម្ព័ន្ធមិត្តសង្គមនិយមរបស់ខ្លួនមួយចំនួនក៏ដោយ ។

ឆ្នាំ១៩៧៩ ខ្មែរក្រហមបានប្រកាសពីការបង្កើត "រណសិរ្សមហាសាមគ្គីជាតិ ស្នេហាជាតិ និងប្រជាធិបតេយ្យ" ប៉ុន្តែមិនបានទទួលការគាំទ្រពីប្រជាជនឡើយ ។ នៅពេលជាមួយគ្នានោះដែរ ចលនាតស៊ូមិនមែនកុម្មុយនីស្តដំបូងមួយ "រណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ" ត្រូវបានបង្កើតឡើងដឹកនាំដោយសម្តេច សឺន សាន ដែលជាអតីតនាយករដ្ឋមន្ត្រីក្នុងសម័យសង្គមរាស្ត្រនិយម (១៩៥៥-១៩៧០) ។

ក្រុមអ្នកតស៊ូរាជានិយមមួយដែលមានឈ្មោះថា រណសិរ្សរួបរួមជាតិដើម្បីកម្ពុជាមួយឯករាជ្យ អព្យាក្រឹត សន្តិ និងសហប្រតិបត្តិ ហៅកាត់ថា "ហ៊្វុនស៊ីនប៉ិច" ក៏ត្រូវបានបង្កើតដែរ ក្នុងពេលបន្តបន្ទាប់គ្នានោះ ក្រោមព្រះរាជកិច្ចដឹកនាំរបស់សម្តេចព្រះនរោត្តម សីហនុ។ នៅឆ្នាំ១៩៨២ ក្រុមរាជានិយមហ៊្វុនស៊ីនប៉ិច ក្រុមរណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ និងក្រុមខ្មែរក្រហម បានរួបរួមគ្នាបង្កើតរដ្ឋាភិបាលចម្រុះត្រីភាគីដែលមានសម្តេចព្រះនរោត្តម សីហនុ ជាប្រធាន ខៀវ សំផន ជាអនុប្រធាន និងសម្តេច សឺន សាន ជានាយករដ្ឋមន្ត្រី។ គោលបំណងរួមរបស់រដ្ឋាភិបាលនេះគឺដើម្បីប្រមូលកម្លាំងធ្វើការតស៊ូរំដោះប្រទេសកម្ពុជាពីការជ្រៀតជ្រែករបស់វៀតណាម ។ រដ្ឋាភិបាលចម្រុះត្រីភាគីដែលមានក្រុមខ្មែរក្រហមជាក្រុមធំជាងគេនោះបានកាន់កាប់អាសនៈរបស់កម្ពុជានៅអង្គការសហប្រជាជាតិ ។

បន្ទាប់ពីការចរចាអស់រយៈពេលជាច្រើនឆ្នាំ ភាគីជម្លោះកម្ពុជាទាំងអស់បានយល់ព្រមចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាពនៅទីក្រុងប៉ារីសនៅថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ ហើយយល់ព្រមឲ្យមានការរៀបចំការបោះឆ្នោតជាតិមួយក្រោមការត្រួតពិនិត្យរបស់អាជ្ញាធរបណ្តោះអាសន្នអង្គការសហប្រជាជាតិនៅកម្ពុជា ហៅកាត់ថា "អ៊ុនតាក់" ។ ក្រុមខ្មែរក្រហមបានធ្វើពហិការមិនចូលរួមការបោះឆ្នោតជាតិដែលរៀបចំឡើងដោយអ៊ុនតាក់ ហើយបដិសេធមិនព្រមរំសាយកងទ័ពរបស់ខ្លួនឡើយ ។ ក្រោយការបោះឆ្នោតជាសកលឆ្នាំ១៩៩៣ កងទ័ពខ្មែរក្រហមបានបន្តប្រយុទ្ធប្រឆាំងនឹងកងកម្លាំងរបស់រាជរដ្ឋាភិបាលកម្ពុជាដែលដឹកនាំដោយព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ ជានាយករដ្ឋមន្ត្រីទីមួយ និងសម្តេច ហ៊ុន សែន ជានាយករដ្ឋមន្ត្រីទីពីរ អស់ជាច្រើនឆ្នាំបន្តទៀត ។

នៅខែសីហា ឆ្នាំ១៩៩៦ អៀង សារី បានចុះចូលជាមួយរាជរដ្ឋាភិបាលកម្ពុជា ដោយនាំទាំងកងទ័ពមួយចំនួនមកជាមួយ


ការវិលត្រឡប់របស់អ្នកដែលនៅរស់រានមានជីវិតបន្ទាប់ពីការដួលរលំរបស់ខ្មែរក្រហមនៅខែមករា ឆ្នាំ១៩៧៩

ផង ។ មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមមួយចំនួនទៀតដូចជា កែ ពក នួន ជា និង ខៀវ សំផន បានចុះចូលជាមួយរាជរដ្ឋាភិបាលកម្ពុជាក្នុងឆ្នាំ១៩៩៨ ។ បន្ទាប់ពី ប៉ុល ពត ទទួលមរណភាព នៅឆ្នាំ ១៩៩៨ តាម៉ុក ជាមេខ្មែរក្រហមតែម្នាក់គត់ដែលបដិសេធមិនព្រមចុះចូលជាមួយរាជរដ្ឋាភិបាលកម្ពុជា ហើយត្រូវបានចាប់ខ្លួននៅខែមីនា ឆ្នាំ១៩៩៩ ។ ត្រឹមដំណាក់កាលនេះ មេដឹកនាំខ្មែរក្រហមដែលនៅរស់ទាំងអស់បានសារភាពចុះចាញ់ឬត្រូវបានចាប់ខ្លួន ហើយចលនាខ្មែរក្រហមទាំងមូលបានដួលរលំជាស្ថាពរ ។ ប្រជាពលរដ្ឋខ្មែរដែលរស់នៅតាមតំបន់ត្រួតត្រារបស់ខ្មែរក្រហមទាំងអស់បានធ្វើមាតុភូមិនិវត្តន៍ និងរួបរួមជាមួយរាជរដ្ឋាភិបាលកម្ពុជាវិញ ។

## សេចក្ដីបញ្ចប់

ឧក្រិដ្ឋកម្មក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យគឺជាសោកនាដកម្មរបស់មនុស្សជាតិដ៏អាក្រក់បំផុតមួយក្នុងចំណោមសោកនាដកម្មទាំងឡាយនាសតវត្សរ៍ទី២០ ។ របបនេះបានសម្លាប់ជីវិតមនុស្សអស់ប្រមាណពីរលាននាក់ហើយ បន្សល់ទុកនូវស្ត្រីមេម៉ាយនិងកុមារកំព្រារាប់រយរាប់ពាន់នាក់ ។ ប្រជាជនខ្មែររាប់សែននាក់បានរត់ចេញពីប្រទេស ហើយបានក្លាយជាជនភៀសខ្លួន ។ គ្រាប់មីនរាប់លានគ្រាប់ត្រូវបានបង្កប់ដោយកងទ័ពខ្មែរក្រហមនិងកងកម្លាំងរបស់រដ្ឋាភិបាលដែលបានបណ្ដាលឲ្យប្រជាជនរាប់ពាន់នាក់ស្លាប់និងពិការ ចាប់តាំងពីទសវត្សរ៍ឆ្នាំ១៩៨០រហូតមក ។ ប្រជាពលរដ្ឋខ្មែរជាច្រើនមានបញ្ហាជំងឺផ្លូវចិត្ត ដោយសារតែការបាត់បង់សមាជិកគ្រួសារ ដែលធ្វើឲ្យប៉ះទង្គិចដល់ផ្លូវចិត្តយ៉ាងខ្លាំង ។ កត្តាទាំងអស់នេះហើយជាមូលហេតុចម្បងមួយដែលនាំឲ្យមានភាពក្រីក្រក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ន ។

មេដឹកនាំខ្មែរក្រហមទាំងអស់មានគំនិតជ្រុលនិយមហួសហេតុដែលខ្លួនទទួលយកពីមនោគមវិជ្ជាកុម្មុយនីស្តរបស់ចិន អតីតសហភាពសូវៀត និងវៀតណាម ។ មេដឹកនាំទាំងនេះបានបង្កើតឡើងនូវគោលនយោបាយជាច្រើនដែលប្រមាថជីវិតមនុស្ស និងបានធ្វើទុកបុកម្នេញនិងសម្លាប់រង្គាលប្រជាជនយ៉ាងច្រើនសន្ធឹកសន្ធាប់ ។ មេដឹកនាំខ្មែរក្រហមទាំងនេះយល់ឃើញថា បដិវត្តន៍របស់ខ្លួនគឺជាផ្លូវតែមួយគត់ដែលអាចនាំកម្ពុជាទៅកាន់ឯករាជ្យភាពនិងសមភាពសង្គម ។ មេដឹកនាំខ្មែរក្រហមទាំងនេះបានអះអាងថាបដិវត្តន៍របស់ខ្លួនមិនបានយកគំរូតាមមនោគមវិជ្ជាខាងក្រៅណាមួយទេ ទោះបីជាខ្លួនពិតជាបានចម្លងតាមមនោគមវិជ្ជារបស់អតីតសហភាពសូវៀតនិងចិន ដូចជាសមូហភាវូបនីយកម្ម ការជម្លៀសប្រជាជនចេញពីទីក្រុងនិងទីប្រជុំជន ផែនការបួនឆ្នាំនិងបដិវត្តន៍មហាលោតផ្លោះមហាអស្ចារ្យក៏ដោយ ។

ខ្មែរក្រហមមិនឲ្យតម្លៃទៅលើការសិក្សានៅតាមសាលាទេ ។ មានតែមេដឹកនាំខ្មែរក្រហមមួយចំនួនតូចប៉ុណ្ណោះដែលមានកម្រិតវប្បធម៌ខ្ពស់ ហើយក្រៅពីនេះសុទ្ធតែជាមនុស្សដែលគ្មានបទពិសោធន៍ក្នុងការដឹកនាំរដ្ឋ ។ កម្មាភិបាលថ្នាក់ក្រោមភាគច្រើនជាមនុស្សមិនចេះអក្សរ ឬចេះអាននិងសរសេរបន្តិចបន្តួច ។ ទោះជាមានឧបសគ្គយ៉ាងនេះក្តី ក៏ខ្មែរក្រហមតែងតែមានមហិច្ឆតាចង់សម្រេចកិច្ចការធំក្នុងរយៈពេលដ៏ខ្លីដោយមិនបានពិចារណាអំពីធនធានដែលមាន ឬលទ្ធផលដែលចេញមកពីគោលនយោបាយទាំងនេះឡើយ ។ ក្នុងន័យនេះ ខ្មែរក្រហមបានប្រែក្លាយប្រទេសទាំងមូលទៅជាវាលស្រែ ហើយប្រែក្លាយប្រជាជនទាំងអស់ឲ្យទៅជាកសិករនិងជាអ្នកទោសរបស់អង្គការ ។

សិទ្ធិនិងតម្រូវការជាមូលដ្ឋានរបស់ប្រជាជនមិនត្រូវបានយកចិត្តទុកដាក់ ។ ទ្រព្យសម្បត្តិឯកជនត្រូវបានរឹបអូស ។ សាសនាក្រដាសប្រាក់ និងប្រពៃណីទំនៀមទម្លាប់បានក្លាយទៅជារបស់ឥតប្រយោជន៍ ។ ទំនាក់ទំនងជាមួយអន្តរជាតិស្ទើរតែត្រូវបានកាត់ផ្ដាច់ទាំងស្រុង ។ របបនេះមិនអនុញ្ញាតឲ្យមានការរិះគន់ចំពោះថ្នាក់ដឹកនាំ ឬគោលនយោបាយរបស់ជាតិ សូម្បីតែបន្តិចបន្តួចក៏ដោយ ។ ខ្មែរក្រហមបានចាត់ទុកអ្នកចេះដឹង អ្នករដ្ឋការរបស់របបចាស់និងអ្នកដែលប្រឆាំងនឹងនយោបាយរបស់ខ្លួនថាជាសត្រូវរបស់រដ្ឋឬជាជនក្បត់បដិវត្តន៍ដែលត្រូវតែកម្ទេចចោល ។ មិនមានការលើកលែងទោស ហើយក៏មិនមានការផ្សះផ្សាជាតិដែរនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ខ្មែរក្រហមបានប្រែក្លាយប្រទេសឲ្យទៅជាជំរំឃុំឃាំងដ៏ធំមួយដែលក្រោយមកបានក្លាយទៅផ្នូររបស់ប្រជាជនខ្មែរជិតពីរលាននាក់ដែលរួមបញ្ចូលទាំងកម្មាភិបាលនិងថ្នាក់ដឹកនាំជាន់ខ្ពស់របស់ខ្លួនមួយចំនួនផង ។ **ឌី ខាំបូលី**

# ធម្មយាត្រាដើម្បីយុត្តិធម៌និងសន្តិភាព

## "ធម្មយាត្រាដើម្បីការផ្សះផ្សាជាតិនិងសន្តិភាព" "អង្គជំនុំជម្រះវិសាមញ្ញជាឱ្យសរំខាប់ការចងពៀរ"

នៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០៧ មជ្ឈមណ្ឌលឯកសារកម្ពុជាបានរៀបចំក្បួនដង្ហែ «ធម្មយាត្រាដើម្បីយុត្តិធម៌ និងសន្តិភាព» មួយដែលមានការចូលរួមពីព្រះសង្ឃ ដូនជី-តាជី ប្រជាជនខ្មែរអ៊ីស្លាម និងសិស្សានុសិស្សប្រមាណជា៦០០នាក់ ដោយចេញដំណើរពីបរិវេណវត្តភ្នំតាមរថយន្តក្រុងឆ្ពោះទៅកាន់ដងនង្គ័លដែលមានទីតាំងនៅក្បែរអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ រួចបន្តដំណើរដោយថ្មើរជើងប្រមាណជា៧គីឡូម៉ែត្រដើម្បីទៅដល់អគារអង្គជំនុំជម្រះវិសាមញ្ញ ។ នេះជាលើកទី១ហើយចាប់តាំងពីអង្គជំនុំជម្រះវិសាមញ្ញចាប់ផ្តើមការងាររបស់ខ្លួន ។ គោលបំណងនៃការធ្វើធម្មយាត្រានេះគឺដើម្បីឲ្យតុលាការដំណើរការកាត់ក្តីឲ្យបានកាន់តែឆាប់ប្រកបដោយយុត្តិធម៌និងសន្តិភាពចំពោះបណ្តាមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងដើម្បីឲ្យជនរងគ្រោះស្វែងរកនូវសេចក្តីសុខនិងការផ្សះផ្សារួមគ្នា ។

យើងសង្កេតឃើញថា ក្បួនធម្មាយាត្រាបានបោះជំហានជាមួយនឹងទឹកមុខស្រស់ស្រាយ ទោះបីជាក្រោមអាកាសធាតុក្តៅនិងធ្វើដំណើរវែងឆ្ងាយបន្តិចក៏ពិតមែន ក៏ប៉ុន្តែអ្នកចូលរួមទាំងអស់សប្បាយរីករាយនឹងការធ្វើដំណើរនេះ ដោយគាត់យល់ថាវត្តមានរបស់គាត់នៅពេលនេះគឺជាជំហានដ៏សំខាន់ក្នុងការគាំទ្រតុលាការដើម្បីឲ្យមន្ត្រីតុលាការដំណើរការរបស់ខ្លួនបានឆាប់រហ័ស ពីព្រោះអាយុកាលរបស់មេដឹកនាំទាំងនោះកាន់តែមានវ័យចំណាស់ណាស់ទៅហើយ ។ អ្នកចូលរួមមួយចំនួនបានបង្ហាញពីអារម្មណ៍ផ្សេងៗទៅតាមការយល់ឃើញរបស់ខ្លួនចំពោះធម្មយាត្រានេះ ។ ព្រះតេជគុណវត្តធេវ៉ាហៅវត្តថាន់បានមានសង្ឃដីកាថា កាលដែលព្រះអង្គចូលរួមគឺដោយសារថា «ទី១) ដូនជី ព្រះសង្ឃធ្លាប់ទទួលរងនូវការលំបាករងកម្មនូវអំពើប្រល័យពូជសាសន៍ប៉ុលពត ដូច្នេះព្រះសង្ឃត្រូវតែចូលរួមចំណែកក្នុងសកម្មភាពដើរធម្មយាត្រានេះ ទី២) ធ្វើយ៉ាងណាកុំឲ្យរងនូវគុណវិបត្តិដូចអតីតកាលទៀត» ។

តំណាងដូនជីម្នាក់របស់សមាគមដូនជីនិងឧបាសិកាកម្ពុជរដ្ឋបានសម្តែងថា ធម្មយាត្រាប្រារព្ធឡើងដើម្បីសុំឲ្យមានការផ្សះផ្សាជាតិតាមផ្លូវធម៌ ដែលតាមរយៈនេះទាមទារឲ្យជនរងគ្រោះមានការអត់ធ្មត់ ចេះខន្តីសាមគ្គីគ្នា អហិង្សា គោរពសិទ្ធិគ្នាទៅវិញទៅមកជាពិសេសចេះការអភ័យទោសរាល់ទង្វើដែលខុសឆ្គងខ្លះដែលគួរអនុគ្រោះបាន ។ ចិត្តមេត្តាករុណានិងការអភ័យអាចនាំឲ្យអ្នកដទៃមានសេចក្តីសុខនិងខ្លួនយើងក៏មានសេចក្តីសុខដែរ ដែលទាំងអស់នេះហើយជាលទ្ធផលនៃការផ្សះផ្សាជាតិ ។ លោកយាយម្នាក់ទៀតបានមានប្រសាសន៍





ថាគាត់សប្បាយចិត្តដែលបានចូលរួមដើម្បីទាមទាររកយុត្តិធម៌ជូនអ្នកដែលបានស្លាប់ទៅនោះនិងស្វែងរកការពិតរបស់ខ្មែរក្រហមតើវាពិតយ៉ាងណាឲ្យឃើញនឹងភ្នែក ។ *«អ្នកផ្សេងក៏គេសប្បាយចិត្តដូច្នេះដែរ ព្រោះសុទ្ធតែចង់ដឹងការពិតទាំងអស់គ្នា»* ។ សារី ហៀត អាយុ៦០ឆ្នាំ ជាជនជាតិខ្មែរអ៊ិស្លាម មកពីឃុំជ្រោយមេត្រី ខេត្តកណ្តាល បានប្រាប់ពីគោលបំណងរបស់គាត់ថា គាត់មកនេះគឺចង់មកឃើញមេខ្មែរក្រហមដែលបានសម្លាប់មនុស្ស ។ ទោះបីជាមានការហត់នឿយបន្តិចក៏ដោយ ក៏គាត់តស៊ូដើរឲ្យទាល់តែដល់ដែរ ។ សារីហៀត ក៏ជាជនរងគ្រោះម្នាក់ដែលបានទទួលរងនូវការធ្វើទុក្ខបុកម្នេញពីសំណាក់ខ្មែរក្រហមទាំងការងារ ការហូបចុក និងការប្រណិប័តន៍សាសនាជាដើម ។ សារីហៀត សប្បាយចិត្តដែលបានមកចូលរួមក្នុងដំណើរធម្មយាត្រានេះ *«ពីដំនាន់ប៉ុលពតគេមិនឲ្យកាន់សាសនាទេ ។ ក្តៅក៏ទ្រាំដែរ ចិត្តចង់ហើយ ។ ក្តៅលើកមុនបានក្តៅខ្លាំង»* ។

ណារី អាយុ១៩ឆ្នាំ ជានិស្សិតមហាវិទ្យាល័យន័រតុនបានសម្រេចចិត្តចូលរួមដំណើរធម្មយាត្រនេះ ដោយសារនាងចង់ដឹងនិងចង់សុំការចែករំលែកបទពិសោធន៍ដូនជី-តាជីនិងអ្នកដទៃទៀតដែលធ្លាប់បានឆ្លងកាត់របបនេះ ពីព្រោះថាបងប្រុសរបស់នាងបានស្លាប់និងឪពុកម្តាយរបស់នាងទទួលទុក្ខទោសច្រើននៅក្នុងរបបនោះដែរ ។ ណារី ធ្លាប់បានស្តាប់រឿងរ៉ាវទាំងនេះពីគ្រូរបស់នាងហើយនាងស្ទើរតែមិនជឿថារបបនេះសាហាវបែបនេះសោះហើយពិបាកនឹងជឿទៀតផង ។ ណារី ជឿជាក់ថា ធម្មយាត្រានេះជាចំណែកមួយរបស់តុលាការក្នុងការនាំមកនូវភាពយុត្តិធម៌និងការផ្សះផ្សាជូនជនរងគ្រោះ ពីព្រោះថាអ្នកភូមិរបស់នាងកំពុងតាមដានអំពីព្រឹត្តិការណ៍ទាំងអស់នេះតាមវិទ្យុនិងទូរទស្សន៍ ហើយគាត់រីករាយនឹងចូលរួមដំណើរការនេះ ។ ចំណែកយុវសិស្សម្នាក់មកពីវិទ្យាល័យអន្តស្ទួលបានសម្តែងពីឆន្ទៈថា *«ខ្ញុំហត់ខ្លះ សប្បាយចិត្តខ្លះ ព្រោះយើងបានចូលរួមធម្មយាត្រាមួយដើម្បីឲ្យប្រជាពលរដ្ឋដឹងថាសូម្បីតែព្រះសង្ឃ ដូនជីតាជី អ្នកកាន់ព្រះពុទ្ធសាសានាទាំងអស់ក៏ជួយគាំទ្រការកាត់ទោសខ្មែរក្រហមដើម្បីរកសន្តិភាពនិងការផ្សះផ្សាដែរដើម្បីកុំឲ្យមានទំនាស់តទៅទៀត»* ។

ក្រោពីបម្រើឲ្យបំណងយុត្តិធម៌និងសន្តិភាព ធម្មយាត្រានេះជាដំណើរការមួយដែលធ្វើគាត់នឹកឃើញថា ដល់ថ្ងៃដែលប្រជាជនកម្ពុជាត្រូវបានបង្ខំឲ្យចាកចេញពីទីក្រុងភ្នំពេញឆ្ពោះទៅកាន់ទីជនបទក្រោមកម្តៅថ្ងៃក្តៅហែងក្នុងខែចែត្រ ដែលជាដំណើរឆ្ពោះទៅរកសេចក្តីស្លាប់ ។ ដូនជីម្នាក់បានមានប្រសាសន៍ថា *«យាយនឹកឃើញដល់ពេលជម្លៀសព្រោះថាការទៅរកសេចក្តីស្លាប់ តែធម្មយាត្រានេះយាយសប្បាយចិត្តដូចថាដើម្បីឲ្យអ្នករងគ្រោះបានសុខក្នុងអាណាចក្រនិងពុទ្ធចក្រ»* ។

ក្បួនដង្ហែនេះបានបញ្ចប់នៅវេលាម៉ោង១១ថ្ងៃ បន្ទាប់ពីបានស្តាប់ការបកស្រាយចម្ងល់និងសំណួរមួយចំនួនរបស់លោករាជ សម្បត្តិ អ្នកនាំពាក្យសាលាក្តីខ្មែរក្រហម ។ អ្នកចូលរួមទាំងអស់បានត្រឡប់ទៅកាន់លំនៅដ្ឋានរៀងៗខ្លួនដោយពាំនាំនូវក្តីសង្ឃឹមថាការផ្សះផ្សានិងសន្តិភាពនឹងបានដល់ជនរងគ្រោះនិងប្រជាជាតិទាំងមូលដើម្បីកុំឲ្យកើតមានការចងគំនុំគ្នាតទៅទៀត ។ **លី សុផល**

# ធម្មយាត្រាដើម្បីយុត្តិធម៌ និង ស








# ន្តិភាពថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០៧










# ត្រៀមខ្លួនស្វែងរកយុត្តិធម៌

«ត្រៀមខ្លួនស្វែងរកយុត្តិធម៌» គឺជាចំណងជើងខ្សែភាពយន្តឯកសារខ្លាតខ្លីរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាដែលផលិតនៅឆ្នាំ២០០៧ ។ នេះគឺជាសមិទ្ធិផលទី៣របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ ខ្សែភាពយន្តទី១មានចំណងជើងថា «វាលស្រែខ្មែរក្រហម» គឺជាប្រវត្តិរឿងរ៉ាវរបស់ស្ត្រីម្នាក់ដែលត្រូវកងទ័ពខ្មែរក្រហមចាប់រំលោភ ខ្លឹមសារនៃរឿងនេះបានបង្ហាញពីការតស៊ូរស់រានមានជីវិតរបស់ស្ត្រីកម្ពុជាពីរបបខ្មែរក្រហម ។ ខ្សែភាពយន្តទី២ មានចំណងជើងថា «នៅកៀនជញ្ជាំងមន្ទីរស-២១ៈ ប្រវត្តិរឿងរ៉ាវពីគុកទួលស្លែង» ដែលបានបង្ហាញពីជនរងគ្រោះ២នាក់ និងឆ្មាំគុកម្នាក់រំឭកឡើងវិញអំពីរឿងរ៉ាវកាលពីអតីតកាលនិងបទពិសោធន៍រស់នៅក្នុងគុកទួលស្លែង ជាពិសេសការតស៊ូរស់រានមានជីវិតពីគុកដ៏សាហាវឃោរឃៅនេះ ។



សៅ ឡូន

«ត្រៀមខ្លួនស្វែងរកយុត្តិធម៌» គឺជាខ្សែភាពយន្តដែលផលិតឡើងពីដំណើរទស្សនកិច្ចរបស់ប្រជាជនដែលរៀបចំឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ។ តាមរយៈដំណើរទស្សនកិច្ចនេះ មជ្ឈមណ្ឌលឯកសារកម្ពុជាបានអញ្ជើញប្រជាជនដែលមកពីតាមបណ្តាខេត្ត-ក្រុងទូទាំងប្រទេស ដែលមានដូចជា សិស្ស និស្សិត ជនជាតិខ្មែរ-អ៊ីស្លាម ដូនជី មេឃុំ និងប្រជាជនដែលរស់នៅតាមតំបន់ក្រីក្រដាច់ស្រយាលឲ្យមកចូលរួមនៅក្នុងដំណើរការស្វែងរកយុត្តិធម៌ ។ ដំណើរទស្សនកិច្ចនេះបាននាំប្រជាជនទៅទស្សនាសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង វាលពិឃាតជើងឯកនិងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ប្រជាជនមានឱកាសបានឃើញនូវទីតាំងប្រវត្តិសាស្ត្រសំខាន់ៗរបស់ខ្មែរក្រហមនិងបានចូលរួមស្តាប់ការបកស្រាយពន្យល់យ៉ាងក្បោះក្បាយពីសំណាក់អ្នករៀបរៀងច្បាប់និងមន្ត្រីអង្គជំនុំជម្រះវិសាមញ្ញ ។ ប្រជាជនក៏មានឱកាសសួរនូវសំណួរ និងចូលរួមបញ្ចេញមតិយោបល់របស់ខ្លួនដោយសេរីដែលពាក់ព័ន្ធទៅនឹងការកាត់ទោសមេដឹកនាំខ្មែរក្រហម ។

សៅ ឡូន ជាអ្នកចូលរួមដំណើរទស្សនកិច្ចមកពីខេត្តតាកែវ មានការរំភើបនៅពេលដែលបានឃើញរូបថតជាច្រើននៅទួលស្លែង ។ ឡូន បានបញ្ជាក់ថា៖ «ខ្ញុំមិនដែលបានចូលមកទីនេះទេ ។ អ៊ីចឹងបានខ្ញុំឃើញ ខ្ញុំស្រក់ទឹកភ្នែក ។ ទាំងបងប្អូនយើងនិងបងប្អូនគេរងគ្រោះដូចតែគ្នា ។ បងប្អូនខ្ញុំស្លាប់អស់៦-៧នាក់ហើយរួមទាំងឪពុកខ្ញុំម្នាក់ទៀតគឺត្រូវខ្មែរក្រហមយកទៅសម្លាប់» ។

អ៊ែល ជាជនជាតិខ្មែរ-អ៊ីស្លាមមកពីក្រុងព្រះសីហនុ បានត្អូញត្អែរថា គាត់ធ្លាប់ទៅមើលគុកទួលស្លែងម្តងកាលពីឆ្នាំ១៩៨៣ ។ កាលណោះគុកទួលស្លែងមិនទាន់បានលាងសម្អាតឲ្យបានស្អាតបាតនៅឡើយទេ ។ ប៉ុន្តែពេលនេះ គាត់បានមកចូលរួមក្នុងដំណើរទស្សនកិច្ចបានឃើញគុកនេះម្តងទៀត ហើយមានលក្ខណៈខុសប្លែកកាលពីលើកមុន ដោយរៀបចំបានស្អាត ។ គាត់មានកំហឹងឈឺចាប់ចំពោះទង្វើរបស់ខ្មែរក្រហម ។ ចំណែក ម៉ៅ ប៊ុនណា ជាសិស្សមកពីវិទ្យាល័យអង្គស្នួល បាននិយាយថា ពីមុនខ្លួនមិនដែលបានមកគុកទួលស្លែងទេ ។ ទើបតែមជ្ឈមណ្ឌលឯកសារកម្ពុជាផ្តល់ឱកាសឲ្យចូលរួមនៅក្នុងដំណើរទស្សនកិច្ច ទើបខ្លួនមានឱកាសបានមកឃើញនូវទីតាំងប្រវត្តិសាស្ត្រសំខាន់ៗរបស់ខ្មែរ



អ៊ែល

ក្រហម ។ គាត់មានអារម្មណ៍រំភើបនិងរន្ធត់នៅពេលឃើញអំពើឃោរឃៅរបស់ខ្មែរក្រហម ។ សួន ឧត្តម ក៏ជានិស្សិតម្នាក់ដែលចូលរួមក្នុងដំណើរទស្សនកិច្ចនេះដែរ ។ ឧត្តម បញ្ជាក់ថាពីមុនធ្លាប់តែឮឪពុកម្តាយបងប្អូននិយាយប្រាប់ពីរឿងរ៉ាវនៅក្នុងរបបខ្មែរក្រហម ។ ខ្លួនបានឃើញជាក់ស្តែងនៅគុកទួលស្លែងក៏ដូចជាបឹងជើងឯកគឺឃើញមាននូវភស្តុតាងជាច្រើនដែលបញ្ជាក់ថា ពិតជាមានអំពើប្រល័យពូជសាសន៍កើតឡើងមែន ។

ខ្សែភាពយន្តនេះផ្តល់សារសំខាន់ចំពោះជនរងគ្រោះនៃអំពើប្រល័យពូជសាសន៍ ពីព្រោះគាត់មិនត្រឹមតែមានតួនាទីសំខាន់ក្នុងការផ្តល់ភស្តុតាងនិងជាកសិណសាក្សីនៅក្នុងតុលាការប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាអ្នកផ្តល់នូវការអប់រំដល់ក្មេងជំនាន់ក្រោយដែលជាអ្នកចូលរួមស្ថាបនា និងដឹកនាំកម្ពុជាទៅថ្ងៃអនាគតទៀតផង ។ ជាងនេះទៅទៀតបានផ្តល់ឱកាសឲ្យប្រជាជនបានស្គាល់ទីកន្លែងប្រវត្តិសាស្ត្រសំខាន់ៗ និងធ្វើឲ្យគាត់គិតថាខ្លួនគាត់ផ្ទាល់ក៏ជាមនុស្សសំខាន់ម្នាក់ ហើយដែលប្រទេសជាតិត្រូវការគាត់ក្នុងការស្វែងរកយុត្តិធម៌ដែរ ។ តាមរយៈការទស្សនាទីតាំងសំខាន់ៗរបស់ខ្មែរក្រហម ប្រជាជនមួយចំនួនបានរកឃើញនូវរូបថតមិត្តភក្តិនិងសាច់ញាតិរបស់ខ្លួនដែលបានបាត់ខ្លួននិងខ្លះទៀតស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។ តាមរយៈការរកឃើញរូបថតនេះបានធ្វើឲ្យគាត់ធូរស្រាលមួយកម្រិតបន្ទាប់ពីការទន្ទឹងរង់ចាំអស់រយៈពេលជាច្រើនឆ្នាំ និងជាចម្លើយមួយចំពោះការរង់ចាំរបស់គាត់ ។ ហ៊ាង វីន និង ហឿង ហឿន បានរកឃើញរូបថតប្អូនប្រុសរបស់គាត់នៅពេលដែលគាត់ធ្វើទស្សនកិច្ចនៅសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង ។ អ្នកទាំងពីរស្គាល់រូបថតច្បាស់ដោយសម្គាល់ទៅលើសក់និងបបូរមាត់ ។ ក្រោយពីបានឃើញរូបថតនេះអ្នកទាំងពីរគិតថាប្អូនប្រុសរបស់គាត់លំបាកវេទនានៅក្នុងគុកទួលស្លែងនេះ ។ មុនពេលមកដល់ទួលស្លែង ទាំងពីរនាក់ភ័យដងអរដងស្មានថាប្អូនប្រុសរស់នៅប្រទេសក្រៅ ។ គាត់មានការសោកស្តាយចំពោះការស្លាប់របស់ប្អូនប្រុសគាត់ ។ ចុងបញ្ចប់គាត់បានឃើញត្រឹមតែរូបថត ។ គឹម ភ៊ាត ក្នុងវ័យ៧៩ឆ្នាំ និងជាអ្នកដែលបានឆ្លងកាត់ដោយផ្ទាល់នៅក្នុងរបបខ្មែរក្រហមបានរៀបរាប់ទាំងឈឺចាប់ថា នៅពេលដែលគាត់ឃើញគុកទួលស្លែងនិងវាលពិឃាតបឹងជើងឯក គាត់មានអារម្មណ៍ថា រឿងរ៉ាវទាំងនេះហាក់បីដូចជាទើបតែកើតឡើងថ្មីៗនៅឡើយ ។

ត្រៀមខ្លួនស្វែងរកយុត្តិធម៌ មិនត្រឹមតែឆ្លុះបញ្ចាំងពីតួនាទីរបស់អ្នកនៅរស់ពីរបបខ្មែរក្រហមប៉ុណ្ណោះទេ គឺថែមទាំងបានលើកកម្ពស់ទំនាក់ទំនងនិងការយល់ដឹងផ្ទាល់របស់ប្រជាជនចំពោះតុលាការកម្ពុជា និងថែមទាំងបំផុសឲ្យតុលាការរឹតតែយកចិត្តទុកដាក់ក្នុងការស្វែងរកយុត្តិធម៌តាមរយៈការចូលរួមនិងការជឿទុកចិត្តដ៏សម្បើមរបស់ប្រជាជនផង ។

ស៊ុម សុយ មានការពេញចិត្តយ៉ាងខ្លាំងចំពោះតុលាការខ្មែរក្រហម ។ គាត់យល់ថា តុលាការអាចធ្វើឲ្យប្រជាពលរដ្ឋអស់ចិត្តព្រោះតែកំហឹងឈឺចាប់អស់រយៈពេលជាយូរមកហើយ ។

**ប៊ាង ពីច័ន**

# ដំណឹងស្វែងរកឪពុក

ខ្ញុំបាទឈ្មោះ ខូវ ថាបូរិន និងបងប្រុស ខូវ ថាបូរៈ ហៅ ដក់ ម្តាយឈ្មោះ ប៉ែន ភាន់ (បានទទួលដំណឹងថាស្លាប់នៅក្នុងរបបប៉ុលពត) សូមប្រកាសស្វែងរកឪពុកឈ្មោះ ម៉ុង ខុន (បច្ចុប្បន្នអាយុប្រហែល៦៨ឆ្នាំ) អតីតទាហានស័ក្តិបួនកន្លះនៅក្នុងរបបសាធារណរដ្ឋខ្មែរ ។ យើងខ្ញុំទាំងពីរបានបែកពីគាត់តាំងពីឆ្នាំ១៩៧៥ ដែលពេលនោះសភាពការណ៍ច្របូកច្របល់ គាត់ក៏បញ្ជូនយើងខ្ញុំទាំងពីរទៅរស់នៅជាមួយជីដូននៅឯភូមិអន្លង់វិល ឃុំអន្លង់វិល ស្រុកសង្កែ ខេត្តបាត់ដំបង ហើយគាត់ត្រឡប់ធ្វើការនៅភ្នំពេញ ហើយក៏បាត់ដំណឹងរហូត ។ ថ្មីៗខ្ញុំបាទបានជួបស្ត្រីម្នាក់ដែលលេងស្រុកកំណើតបានប្រាប់ថាឈ្មោះនេះប្រហែលជាអាចនៅរស់ក្នុងប្រទេសបារាំង ។ គាត់សន្យាថានឹងពឹងមិត្តភក្តិរបស់គាត់ដែលរស់នៅទីនោះជួយរកឈ្មោះនេះ ប៉ុន្តែត្រូវរង់ចាំពេលគាត់ត្រឡប់ទៅប្រទេសបារាំងវិញបន្ទាប់ពីការបោះឆ្នោត ។

ដូចបានរៀបរាប់ខាងលើនេះ ប្រសិនបើបងប្អូនញាតិមិត្តណាបានស្គាល់ឬដឹងរស់នៅកន្លែងណា សូមមេត្តាផ្តល់ដំណឹងតាមអាសយដ្ឋានផ្ទះលេខ១១២ ផ្លូវ២២ សង្កាត់ផ្សារដេប៉ូ៣ ខណ្ឌទួលគោក ក្រុងភ្នំពេញ យើងខ្ញុំទាំងពីរនឹងមានជូនជាសគុណ ។ សូមអរគុណ ។

# តម្លៃនៃការនិយាយពីជម្លោះអតីតកាល

**(តចប់)**

## ការបរិយាយរឿង អត្តសញ្ញាណនិងការតម្រង់ទិស

ឥទ្ធិពលនៃនិមិត្តរូបប្រវត្តិសាស្ត្រ ទេវកថា និងបែបផែននៃការបរិយាយរឿងរ៉ាវប្រវត្តិសាស្ត្រដើម្បីតម្រង់ទិសនិងជំរុញសកម្មភាពសង្គម ត្រូវបានចងក្រងជាឯកសារបានយ៉ាងត្រឹមត្រូវ ។ ជនល្មោភសង្គ្រាមនិងបណ្ដាញភេរវករបានដឹងច្បាស់អំពីសក្ដានុពលភាពនៃការនិយាយរឿងប្រវត្តិសាស្ត្រ ។ ដូច្នេះហើយសំណួរគឺថាប្រវត្តិសាស្ត្រមានសក្ដានុពលប្រកបដោយន័យស្ថាបនាស្រដៀងគ្នានេះដែរឬទេ? អ្នកប្រាប់រឿងរ៉ាវនៅស្ថាប័ន ស៊ីតេសិន អាគីវេត ជឿជាក់យ៉ាងមុតមាំទៅលើរឿងនេះថាវាមានឥទ្ធិពលស្មើគ្នា ។ ម៉ាក ខុងហ្គោ បានដឹងរឿងនេះ មុនពេលគាត់ត្រូវបានដោះលែងពីគុកនៅលើកោះរូបិន ។

ដើម្បីឆ្លើយទៅនឹងសំណួរអំពីថាតើដំណើរការនេះកើតឡើងយ៉ាងដូម្ដេច ថាតើដំណើរការប្រកបដោយការស្ថាបនានេះកើតឡើងនៅពេលដែលអតីតកាលត្រូវបានផ្សារភ្ជាប់ជាមួយបច្ចុប្បន្នកាល និងរបៀបដែលដំណើរការនេះអាចបង្កើតនូវតួនាទីតម្រង់ទិសសម្រាប់ជម្រើសសកម្មភាពនាពេលអនាគត ទាំងអស់នេះគឺជាចំណុចសំខាន់សម្រាប់ធ្វើការស្រាវជ្រាវ ។ ប្រសិនបើយើងអាចសិក្សាបន្ថែមទៀតអំពីទំនាក់ទំនងនេះ វានឹងអាចបង្ហាញពីសក្ដានុពលសម្រាប់អ្នកបេះដឹង អ្នកកសាងសន្តិភាព អ្នកសម្របសម្រួល និងអ្នកផ្សេងទៀតដើម្បីលើកកម្ពស់ឥរិយាបថនិងការយល់ដឹងអំពីតថភាពនៃសង្គមនិងវប្បធម៌ ។

ខ្ញុំជឿថានេះគឺជាកិច្ចការមួយដែលត្រូវបានដោះស្រាយតាមរយៈការស្រាវជ្រាវដ៏ត្រឹមត្រូវ ។ តាមគំនិតរបស់ខ្ញុំ កិច្ចការជាទ្រឹស្ដីដែលនិយាយអំពីទំនាក់ទំនងពេលបច្ចុប្បន្ននេះស្ថិតនៅត្រង់ការរៀបរាប់ប្រកបដោយន័យស្ថាបនាចំពោះសង្គមឆ្ពោះទៅរកភាពពិតមួយ ។ ខ្ញុំនឹងចង្អុលបង្ហាញដោយសង្ខេបនូវធាតុសំខាន់មួយចំនួននៃចក្ខុវិស័យឆ្ពោះទៅរកការយល់ឃើញអំពីរបៀបថាតើការបង្ហាញនិងការនិយាយរឿងរ៉ាវបែបប្រវត្តិសាស្ត្រអាចបម្រើឲ្យគោលបំណងដ៏សំខាន់មួយដូចនៅស្ថាប័ន ស៊ីតេសិន អាគីវេត នៅក្នុងប្រទេសន័រវេសដែរ ហើយកិច្ចខិតខំប្រឹងប្រែងក្នុងការនិយាយរឿងរ៉ាវដែលមាននៅក្នុងប្រទេសកម្ពុជាដែលផ្សារភ្ជាប់អតីតកាល បច្ចុប្បន្នកាល និងអនាគតកាល ។ ខ្ញុំនឹងផ្ដោតជាពិសេសលើការចូលរួមចំណែកដែលបានធ្វើឡើងដោយលោក ជីជិន ដែលគូសបញ្ជាក់ពីតួនាទីនៃការនិយាយរឿងរ៉ាវប្រកបដោយន័យការស្ថាបនាចំពោះតថភាពសង្គម ។

នៅក្នុងសៀវភៅរបស់ ជីជិន ដែលមានចំណងជើងថាៈ តថភាពនិងទំនាក់ទំនង បានអះអាងថាអ្វីៗទាំងអស់ដែលមានអត្ថន័យគឺកើតចេញមកពីការទំនាក់ទំនង ។ ជីជិន និងអ្នកកត់ត្រារឿងរ៉ាវសង្គមបានរួមចំណែកដ៏សំខាន់ចំពោះការយល់ឃើញអំពីរបៀបនៃរឿងរ៉ាវដែលអ្នកចូលរួមជួបប្រទះនៅក្នុងអំឡុងពេលធ្វើ


ធម្មយាត្រាដើម្បីយុត្តិធម៌និងសន្តិភាព
ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៧

ទស្សនកិច្ច ។ ទាំងអស់នេះអាចបង្កើតជាមូលដ្ឋានគ្រឹះសម្រាប់សកម្មភាពជាជម្រើសនៅពេលអនាគតដែលស្របជាមួយនឹងគោលដៅនៃដំណើរទស្សនកិច្ច ។ ចំណុចចាប់ផ្តើមដើម្បីយល់បាននូវរឿងនេះ គឺសិក្សាអំពីការបរិយាយរឿង ។

ជីជិន បានសរសេរថា «សព្វថ្ងៃនេះ ការសិក្សាអំពីនិទានកថាកើតមាននៅគ្រប់សង្គមមនុស្សនិងវិទ្យាសាស្ត្រសង្គម ។ រីឯបញ្ហាដែលបានលើកឡើងតាមរយៈការវិភាគទៅលើទស្សនៈប្រវត្តិ-សាស្ត្ររបស់យើងរួមជាមួយនឹងមនសិការប្រវត្តិសាស្ត្ររបស់បុគ្គលម្នាក់ៗគឺមានភាពស៊ីជម្រៅ ។ លើសពីនេះទៅទៀត ឥឡូវនេះវាមានការតម្រង់ទិសដាច់ដោយឡែកនិងការបញ្ចូលគ្នាបានល្អទៅលើនិទានកថា ភាពប្រាកដនិយម បាតុភូតនិយម ចិត្តសាស្ត្រ ការយល់ដឹងដោយខ្លួនឯង ការបង្ក្រងអត្ថបទ ភាពឥតលម្អៀងនិងវោហារស័ព្ទគឺស្ថិតក្នុងចំណោមការតម្រង់ទិសទាំងនោះ ។ បញ្ហានីមួយៗលេចឡើងនូវទំនាក់ទំនងខុសៗគ្នាចំពោះការស្វែងយល់អំពីប្រវត្តិ-សាស្ត្រ អំពីអត្តសញ្ញាណនិងមនសិកាប្រវត្តិសាស្ត្រនៅក្នុងសង្គមបច្ចុប្បន្ន» ។

ជីជិន អះអាងទៀតថា និទានកថាគឺជាទម្រង់នៃសកម្មភាពសង្គម ។ និទានកថាធ្វើឲ្យយើងមើលឃើញនូវបាតុភូតសង្គមនិងបង្កើតនូវការរំពឹងទុកចំពោះបាតុភូតនៅថ្ងៃមុខ ។ យើងប្រើប្រាស់រឿងរ៉ាវទាំងឡាយដើម្បីឲ្យដឹងពីអត្តសញ្ញាណខ្លួនយើងនិងស្គាល់ពីទំនាក់ទំនងខ្លួនយើង ហើយស្គាល់អំពីទំនាក់ទំនងជាមួយអ្នកដទៃ ។ តាមវិធីជាច្រើនយើងអាចផ្តល់អត្ថន័យចំពោះការរស់នៅរបស់យើងនិងទំនាក់ទំនងសង្គមតាមរបៀបផ្សេងៗដោយបង្កើតរឿងរ៉ាវចេញពីបទពិសោធន៍និងរឿងរ៉ាវទាំងឡាយដែលយើងបានជួបប្រទះ ។ នៅក្នុងន័យនេះ ទោះ



ក្នុងវិធីមួយឬវិធីផ្សេងទៀតក៏ដោយ ក៏ការយល់ឃើញទាំងអស់ត្រូវតែមានទំនាក់ទំនងនឹងរឿងរ៉ាវជាច្រើន ឬក៏មានទំនាក់ទំនងនឹងការកើតឡើងនៃភាសាវិទ្យាដើម្បីឲ្យមានន័យគ្រប់គ្រាន់ ។

ជីជិន បានផ្តោតទៅលើអ្នកនិពន្ធជាច្រើនរូបដូចជា លោក *MacIntyre* លោក *Mink* និងលោក *Sarbin* នៅពេលនោះគាត់បាននិយាយថា ការយល់ឃើញនៃសកម្មភាពមនុស្សមិនអាចពឹងផ្អែកលើអ្វីផ្សេងក្រៅពីមូលដ្ឋានគ្រឹះនៃការនិយាយរឿងនោះទេ ។ ដើម្បីឲ្យយល់បាននូវសកម្មភាពមួយគឺត្រូវដាក់បញ្ចូលទៅក្នុងខ្នាតពេលវេលាគឺមានអតីតកាល បច្ចុប្បន្នកាលនិង អនាគតកាល ។ នេះហាក់បីដូចជាលទ្ធភាពពីធម្មជាតិមួយចំពោះមនសិការរបស់មនុស្ស ។ នៅពេលយើងព្យាយាមយល់អំពីបញ្ហាទាំងឡាយដែលយើងជួបប្រទះនៅក្នុងជីវិតគឺយើងត្រូវទុកបញ្ហាទាំងនោះទៅជាបែបបទនិទានកថា ។ យើងបង្កើតរឿងមួយដែលព្រឹត្តការណ៍ខុសៗគ្នានៅក្នុងជីវិតរបស់យើងមានជាប់ទាក់ទងជាប្រព័ន្ធនៅក្នុងផ្ទៃរឿងហើយក៏អាចឲ្យយើងយល់បានថាជាផ្នែកមួយនៃដំណើរការឬហេតុការណ៍ ។ យើងបង្កើតអត្ថន័យតាមរយៈការបង្កើតនូវនិទានកថាជាច្រើន ។ អ្នកនិពន្ធដទៃទៀតដូចជាលោក *de Waele &* លោក *Harre,* លោក *Kohli,* និងលោក *Cohler* ក៏បានសរសេរអំពីរឿងនេះដែរ ។

ដើម្បីយល់បានអំពីតួនាទីនៃការនិយាយរឿងរ៉ាវប្រកបដោយន័យស្ថាបនាចំពោះតថភាពសង្គមគឺជាផ្នែកមួយសំខាន់ក្នុងការពន្យល់ថាតើការនិយាយរឿងរ៉ាវផ្សារភ្ជាប់ទៅអតីតកាលបច្ចុប្បន្នកាលនិងអនាគតកាល អាចបម្រើនូវតួនាទីជម្រើសសកម្ម-ភាពអនាគត ដើម្បីតម្រង់ទិសសម្រាប់បុគ្គលដែលចូលរួមនៅក្នុងដំណើរទស្សនកិច្ចនេះ ។ បញ្ហានេះមានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធទៅនឹងគំនិតស្តីអំពីមនសិការប្រវត្តិសាស្ត្រ ។ លោក *Joern Ruesen* សរសេរថា «មនសិការប្រវត្តិសាស្ត្រគឺវាបានរំកិលពីបច្ចុប្បន្នកាលទៅរកអតីតកាល រួចត្រឡប់មកបច្ចុប្បន្នកាលវិញដោយពាំនាំមកនូវបទពិសោធន៍ដើម្បីបង្ហាញពីអនាគត ដែលជាចំណុចចាប់ផ្តើមនៃសកម្មភាពដែលយើងអាចមើលឃើញ ។ ទន្ទឹមនេះដែរមនសិការប្រវត្តិសាស្ត្រអាចលាតសន្ធឹងចេញពីអតីតកាលទៅអនាគត ប្រសិនបើនរណាម្នាក់ចាប់អារម្មណ៍ថាអតីតកាល គឺជា

ចំណុចចេញដំណើរដែលលាតសន្ធឹងពីបច្ចុប្បន្នឆ្ពោះទៅអនាគត ។ ក្នុងករណីទាំងពីរនេះមនសិការប្រវត្តិសាស្ត្រគឺធ្វើឲ្យយើងដឹងនូវបទពិសោធន៍មួយនៃភាពខុសគ្នារវាងអតីតកាលនិងបច្ចុប្បន្នកាល ប៉ុន្តែទន្ទឹមគ្នានេះវាក៏ផ្ជិតការបែងចែកនេះដោយភ្ជាប់មួយទៅមួយទៀត ។ ពាក្យបច្ចេទេសសម្រាប់រចនាសម្ព័ន្ធនេះគឺការបរិយាយរឿង ។

## មនសិការ និង អត្តសញ្ញាណប្រវត្តិសាស្ត្រ

របៀបដែលយើងអធិប្បាយពីអតីតកាលវាជះឥទ្ធិពលដល់ការយល់ដឹងរបស់យើងនាពេលបច្ចុប្បន្ន និងបញ្ហាជាច្រើនដែលយើងកំពុងប្រឈមមុខក្នុងជីវិតប្រចាំថ្ងៃ ។ នេះជាកត្តាដ៏សំខាន់ក្នុងពិចារណានៅពេលយើងកំពុងនិយាយអំពីតម្លៃនៃគោលដៅសមស្របក្នុងការបរិយាយរឿងក្នុងពេលដំណើរទស្សនកិច្ចដូចដំណើរទស្សកិច្ចនៅស្ថាប័ន «ស៊ីតេសិនអាគីវេត» នៅក្នុងប្រទេសន័រវេស និងនៅក្នុងដំណើរទស្សនកិច្ចរបស់គម្រោងឯកសាររស់នៅក្នុងប្រទេសកម្ពុជា ។

មនុស្សម្នាក់ៗដែលចូលរួមនៅក្នុងដំណើរទស្សនកិច្ចនេះបាននាំនាំមកនូវការចែករំលែករឿងរ៉ាវដ៏ស្មុគស្មាញរបស់ខ្លួននិងរឿងរ៉ាវជាច្រើនទៀត ។ ខ្ញុំនឹងអះអាងថា នៅពេលយើងជជែកអំពីមនសិការប្រវត្តិសាស្ត្រយើងត្រូវតែភ្ជាប់រឿងនេះទៅនឹងទស្សនៈអត្តសញ្ញាណ ។ ប្រហែលជាតួនាទីចម្បងក្នុងមនសិការប្រវត្តិសាស្ត្រគឺត្រូវបង្កើតនិងការថែរក្សាអត្តសញ្ញាណ ។

នៅពេលដែលបុគ្គលម្នាក់ចូលរួមដំណើរទស្សនកិច្ចដែលផ្សារភ្ជាប់រឿងរ៉ាវអតីតកាលទៅនឹងជីវិតផ្ទាល់ខ្លួនរបស់បុគ្គល ហើយដើម្បីឲ្យការយល់ដឹងរបស់បុគ្គលអំពីរបៀបដែលខ្លួនទទួលឥទ្ធិពលពីអតីតកាល និងអំពីថាតើអនាគតរបស់បុគ្គលនឹងពឹងផ្អែកទៅលើទំនាក់ទំនងនេះដោយរបៀបណា ទាំងនេះគឺមានទំនាក់ទំនងច្រើនទៅនឹងការស្វែងយល់អំពីអត្តសញ្ញាណ ។ និទានកថានិងអត្តសញ្ញាណគឺមានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធ ។ ជីជិន សរសេរថា និទានកថា មិនត្រឹមតែដើរតួនាទីសំខាន់នៅក្នុងតថភាពដែលមានរចនាសម្ព័ន្ធនិងទំនាក់ទំនងប៉ុណ្ណោះទេ ប៉ុន្តែវាក៏ដើរតួនាទីសំខាន់ក្នុងកម្រិតមួយគឺគោលគំនិតរបស់បុគ្គលនិងគំនិតបុគ្គលម្នាក់ៗត្រូវបានផ្តល់តាមរយៈសកម្មភាពនៃការរៀបរាប់» ។

វីតហ្កែនស្ទែន ម្តងនោះបាននិយាយថា «ដែនកំណត់ប្រពៃណីនៃការរៀបរាប់នាំឲ្យមានការកំណត់អត្តសញ្ញាណរបស់យើង» ។ ការបង្កើតនិទានកថាជាច្រើនបានផ្តល់នូវអត្ថន័យនិងទិសដៅឲ្យជីវិតរបស់យើងអាចត្រូវបានលើកយកសិក្សាជាផ្នែកសំខាន់មួយនៃអត្តសញ្ញាណរបស់បុគ្គល ។ អត្តសញ្ញាណរបស់


ធម្មយាត្រាដើម្បីយុត្តិធម៌និងសន្តិភាព
ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០៧

យើងគឺជាលទ្ធផលនៃរឿងរ៉ាវជីវិត ដែលបទពិសោធន៍ គំនិត អត្ថន័យ និងអាកប្បកិរិយា ត្រូវបានផ្តល់តម្លៃថាជាផ្នែកមួយនៃការបរិយាយរឿង ។ ការបង្កើតនិទានកថាមួយអាចមានសារៈសំខាន់យ៉ាងខ្លាំងនៅពេលមានការផ្តល់ឲ្យនូវទម្រង់បែបបទអត្ថន័យ និងទិសដៅឲ្យជីវិត ។ ក្នុងន័យនេះ ការចងក្រងនិទានកថា ការបង្កើតថែរក្សា ការរារាំង ឬផ្លាស់ប្តូរប្រពៃណីដ៏មានតម្លៃ ហើយយើងផ្លាស់ប្តូរ ការសម្រប ការរារាំង ការបង្កើតនិងប្រកួតប្រជែងនិទានកថា ដែលយើងប្រើប្រាស់ដើម្បីធ្វើឲ្យជីវិតរបស់យើងមានន័យដែលមានទំនាក់ទំនងទៅនឹងការនិយាយរឿងរ៉ាវតិចឬច្រើន ហើយរឿងរ៉ាវនោះយើងកំពុងជួបប្រទះនៅក្នុងដំណើរជីវិតរបស់យើង ។ ចំណុចនេះគឺជាការរួមចំណែកដ៏សំខាន់ចំពោះការយល់ដឹងអំពីរបៀបដែលរឿងរ៉ាវអតីតកាលអាចបម្រើតួនាទីតម្រង់ទិសសម្រាប់សកម្មភាពសង្គម ។

ចូអែន រូសិន រៀបរាប់អំពីរបៀបនៃវិវឌ្ឍន៍មនសិការប្រវត្តិសាស្ត្រឆ្ពោះទៅរកសមត្ថភាពនៃការបរិយាយរឿងដ៏ច្បាស់លាស់ ។ សមត្ថភាពនៃការបរិយាយរឿងគឺ និយាយអំពីលទ្ធភាពបង្កើតទំនាក់ទំនងរវាងអតីតកាលនិងបច្ចុប្បន្នកាលនៅក្នុងរបៀបមួយដែលអតីតកាលមានតួនាទីតម្រង់ទិស ជាអ្នកនាំផ្លូវ ឬជាសំអាងសម្រាប់បុគ្គលដោះស្រាយបញ្ហាជីវិតផ្ទាល់ខ្លួន ។ រូសិន បានជជែកពីរបៀបដែលសមត្ថភាពនេះអាចសម្រេចបានជោគជ័យតាមរយៈការប្រឈមមុខឬការឆ្លងកាត់រឿងរ៉ាវអតីតកាល ហើយតាមរយៈដំណើរការនៃការឆ្លុះបញ្ចាំងប្រវត្តិសាស្ត្រនិងអត្តសញ្ញាណបុគ្គលមានទស្សនវិស័យមួយដែលនាំឲ្យជីវិតក្លាយជាផ្នែកមួយនៃប្រវត្តិសាស្ត្រឬក៏ជាផ្នែកមួយនៃការបរិយាយរឿងអំពីអតីតកាលមួយដែលជះឥទ្ធិពលមកលើជីវិតបច្ចុប្បន្ននិងអនាគតរបស់បុគ្គល ។ នៅក្នុងន័យនេះ អតីតកាលអាចបម្រើជាជម្រើសសកម្មភាពនាពេលអនាគត ។

តាមទស្សនៈជាច្រើននេះគឺជាដំណើរការត្រូវបានរំពឹងថានឹងកើតឡើងនៅដំណើរទស្សនកិច្ចនៅស្ថាប័ន ស៊ីតេសិន អាគីវេត ក្នុងប្រទេសន័រវេសនិងនៅក្នុងដំណើរទស្សនកិច្ចនៅក្នុងគម្រោងឯកសាររស់នៅក្នុងប្រទេសកម្ពុជា ។ គោលដៅជាច្រើននៃការប្រាប់រឿងរ៉ាវគឺមានភាពខុសគ្នា ចំណែកកាលៈទេសៈប្រវត្តិសាស្ត្រនិងវប្បធម៌ក៏មានការខុសគ្នាដែរ ។

អ្វីដែលអ្នកទាំងនោះមានដូចគ្នាគឺរបៀបដែលអតីតកាលមានទំនាក់ទំនងជាមួយបច្ចុប្បន្ននិងអនាគតដែលជាផ្នែកមួយនៃការបរិយាយរឿង ហើយថាវាជាដំណាក់កាលនិងការនិទានរឿងបែបនេះគឺ ដើម្បីបម្រើឲ្យវត្ថុបំណងមួយជាក់លាក់ ។

នៅក្នុងប្រទេសន័រវេសនៅឯស្ថាប័ន ស៊ីតេសិន អាគីវេត វត្ថុបំណងជាក់លាក់នៃការបរិយាយរឿងអាចធ្វើឲ្យលេចចេញនូវអាកប្បកិរិយា និងការយល់ដឹងដែលនឹងធ្វើឲ្យសិស្សសាលាចេះអំពីរបៀបដែលសិស្សទទួលខុសត្រូវចំពោះការទ្រទ្រង់សេរីភាពដែលមនុស្សត្រូវបានទទួលទារុណកម្មនៅ អាគីវេត និងរបៀបសេរីភាពក្នុងការបញ្ចេញមតិតាមបែបលទ្ធិប្រជាធិបតេយ្យដែលតំណាងឲ្យការទទួលខុសត្រូវនៅពេលធ្វើសកម្មភាព ។ គោលបំណងផ្សេងមួយទៀតគឺអាចលើកកម្ពស់ការយល់ដឹងអំពីថាតើយន្តការសង្គមពន្យល់ពីរបៀបដែលមនុស្សម្នាក់អាចធ្វើទារុណកម្មលើមនុស្សម្នាក់ផ្សេងទៀតដោយរបៀបណា ។ យន្តការនេះអាចត្រូវបានគេស្គាល់នៅក្នុងទម្រង់ផ្សេងទៀតនៅក្នុងជីវិតប្រចាំថ្ងៃរបស់សិស្សសាលាក្នុងការបង្កើតអំពើហិង្សានៅក្នុងក្រុមឬជាតិសាសន៍និយម ។

នៅក្នុងប្រទេសកម្ពុជា វត្ថុបំណងនៃការបរិយាយរឿងគឺមានភាពខុសគ្នា ។ វត្ថុបំណងនេះអាចទាក់ទងនឹងការធានានូវមូលដ្ឋានគ្រឹះក្នុងការកសាងមូលដ្ឋានរួមគ្នាសម្រាប់បង្កើតនូវវប្បធម៌សន្តិភាពនិងប្រជាធិបតេយ្យយូរអង្វែងមួយ ដើម្បីលើកម្ពស់ការជាសះស្បើយខាងសង្គមនិងការផ្សះផ្សាជាមួយអំពើឃោរឃៅពីអតីតកាលឬដើម្បីឲ្យមនុស្សបានចូលរួមយល់ដឹងអំពីជម្លោះនាពេលបច្ចុប្បន្នដែលអាចភ្ជាប់ទៅនឹងអតីតកាលដ៏ឃោរឃៅ ហើយនិងអំពីរបៀបដែលត្រូវដោះស្រាយជាមួយអតីតកាលនិងការរៀនសូត្រនូវកំហុសពីអតីតកាលដែលអាចទប់ស្កាត់កុំឲ្យកើតឡើងនូវជម្លោះម្តងទៀត ។

ប្រហែលរយៈពេល២០ឆ្នាំទៅមុខទៀតវត្ថុបំណងនៃការបរិយាយរឿងអំពីជម្លោះអតីតកាលនៅក្នុងប្រទេសកម្ពុជានឹងមានដូចគ្នានៅក្នុងគោលបំណងនៅឯស្ថាប័ន ស៊ីតេសិន អាគីវេត សព្វថ្ងៃនេះដែរ ។ **ឌីធីល ក្រូជីម**

# នៅចំពោះមុខអង្គបុរេជំនុំជម្រះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
# លេខ ០០២,១៩-០៩-២០០៦ ការិយាល័យ ហ្គេកអ៊ាវ (ហៅ ឌុច)

## តាមរយៈសេចក្តីអញ្ជើញរបស់ប្រធានអង្គបុរេជំនុំជម្រះឱ្យធ្វើសារណាជាលាយលក្ខណ៍អក្សរ អនុលោមតាមវិធាន៣៣នៃវិធានផ្ទៃក្នុងសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## សារណារបស់សាស្ត្រាចារ្យ ដេវីដ សេហ្វ័រ អ្នកជំនាញច្បាប់អន្តរជាតិ ក្នុងនាមជាអ្នកផ្តល់សារណាគាំទ្រសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត

### អ្នកផ្តល់សារណា

អនុលោមទៅតាមសេចក្តីជូនដំណឹងកាលពីថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០០៧ អ្នកផ្តល់សារណា ដេវីដ សេហ្វ័រ បានសរសេរសារណានេះដាក់ជូនអង្គបុរេជំនុំជម្រះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីជម្រាបជូនអង្គបុរេជំនុំជម្រះនូវចំណុចសំខាន់ៗមួយចំនួនដែលត្រូវបានមើលរំលង ឬដែលបានលើកឡើងនៅក្នុងសារណាបណ្តឹងឧទ្ធរណ៍ចំពោះដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៧ (សារណាបណ្តឹងឧទ្ធរណ៍របស់មេធាវីចុងចោទ) ដែលត្រូវបានដាក់ជូនអង្គបុរេជំនុំជម្រះកាលពីថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០០៧ ទាក់ទងនឹងបុគ្គល កាំង ហ្គេកអ៊ាវ ហៅ ឌុច) និងដែលបានលើកឡើងនៅក្នុងដីកាឃុំខ្លួនបណ្តោះអាសន្នដែលចុះហត្ថលេខាដោយសហចៅក្រមស៊ើបអង្កេតកាលពីថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ២០០៧ ។

លោក ដេវីដ សេហ្វ័រ ជាសាស្ត្រាចារ្យច្បាប់ដែលទទួលបានគោរមងារ Mayer Brown/Robert A. Helman និងជានាយកមជ្ឈមណ្ឌលសិទ្ធិមនុស្សអន្តរជាតិនៅមហាវិទ្យាល័យច្បាប់នៃសាកលវិទ្យាល័យន័រវេស្ទឺននៅទីក្រុងឈីកាហ្គោ រដ្ឋអ៊ីលីន័រ សហរដ្ឋអាមេរិក ។ លោកសាស្ត្រាចារ្យបង្រៀនមុខវិជ្ជាច្បាប់ព្រហ្មទណ្ឌអន្តរជាតិនិងច្បាប់សិទ្ធិមនុស្សអន្តរជាតិ ។ ព័ត៌មានបន្ថែមអំពីលោកសាស្ត្រាចារ្យអាចរកមើលបាននៅលើគេហទំព័រដូចនេះ www.law.northwestern.edu/faculty/profiles/David Scheffer ។


ឌុច ថតដោយ ហេង ស៊ីនិត

លោកសាស្ត្រាចារ្យ ដេវីដ សេហ្វ័រ គឺជាអតីតឯកអគ្គរដ្ឋទូត

គោចរនៃសហរដ្ឋអាមេរិកទទួលបន្ទុកលើបញ្ហាឧក្រិដ្ឋកម្មសង្គ្រាម (ឆ្នាំ១៩៩៧-២០០១) និងមានការទទួលខុសត្រូវយ៉ាងសំខាន់នៅក្នុងរដ្ឋាភិបាលសហរដ្ឋអាមេរិកទាក់ទងនឹងការស៊ើបអង្កេតនិងជំនុំជម្រះឧក្រិដ្ឋកម្មឃោរឃៅ (ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម) នៅជុំវិញពិភពលោក ។ ក្នុងនាមជាអ្នកតំណាងឲ្យរដ្ឋាភិបាលសហរដ្ឋអាមេរិក លោកសាស្ត្រាចារ្យបានធ្វើការចរចាលើច្បាប់ និងសម្របសម្រួលនូវការគាំទ្រសម្រាប់បង្កើតសាលាក្តីព្រហ្មទណ្ឌអន្តរជាតិនិងសាលាក្តីព្រហ្មទណ្ឌចម្រុះដែលមានដែនយុត្តាធិការលើបទឧក្រិដ្ឋកម្មធ្ងន់ធ្ងរ ហើយលោកសាស្ត្រាចារ្យក៏ជាអ្នកដឹកនាំគណៈប្រតិភូសហរដ្ឋអាមេរិកនៅក្នុងការចរចាក្នុងក្របខ័ណ្ឌសហប្រជាជាតិក្នុងការបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិដែរ ។ លោកសាស្ត្រាចារ្យ ដេវីដ សេហ្វ័រ បានចូលរួមយ៉ាងសកម្មនៅក្នុងការចរចាលើច្បាប់បង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ (ច្បាប់បង្កើតអង្គជំនុំជម្រះវិសាមញ្ញ) និងការពិភាក្សាទាក់ទងនឹងកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ (កិច្ចព្រមព្រៀងអង្គការសហប្រជាជាតិនិងកម្ពុជា) ។ លោកសាស្ត្រាចារ្យជាអ្នកគ្រប់គ្រងលើគេហទំព័រឯករាជ្យមួយដែលបង្កើតឡើងសម្រាប់កិច្ចការឃ្លាំមើលអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (www.cambodiatribunal.org) ជាសមាជិកអចិន្ត្រៃយ៍នៃគណៈមេធាវីនៅរដ្ឋញូវយ៉កនិងវ៉ាស៊ីនតោនឌីស៊ី ព្រមទាំងជាសមាជិកអចិន្ត្រៃយ៍របស់ American Society of International Law ។

## សេចក្តីសង្ខេបនៃអំណះអំណាង

១) សារណាបណ្តឹងឧទ្ធរណ៍របស់មេធាវីចុងចោទ ខកខានមិនបានទទួលស្គាល់នូវឯករាជ្យភាពរបស់អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងប្រព័ន្ធតុលាការកម្ពុជា ។ ក្នុងនាមជាតុលាការដោយឡែកដែលមានឯករាជ្យភាព មានការចូលរួមពីសំណាក់អន្តរជាតិនិងដែលមិនទាន់មានរូបរាងនៅឡើយក្នុងអំឡុងពេលដែល ឌុច ត្រូវបានឃុំឃាំងដោយតុលាការយោធា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គឺមិនទទួលខុសត្រូវចំពោះការឃុំឃាំងខ្លួន ឌុច ដោយតុលាការយោធាឡើយ ហើយអង្គជំនុំជម្រះវិសាមញ្ញនេះក៏មិនទទួលខុសត្រូវចំពោះទង្វើរបស់តុលាការយោធាដែលបានប្រើប្រាស់ច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញដែរ ។ នៅក្រោមអំណាចច្បាប់គ្រប់គ្រងដំណើរការរបស់ខ្លួន អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការនេះពុំមានដែនយុត្តាធិការសម្រេចលើភាពស្របច្បាប់ ចំពោះដីកាឃុំឃាំងខ្លួនដែលចេញដោយចៅក្រមស៊ើបអង្កេតក្នុងតុលាការយោធាឡើយ ។

២) ឌុចបានដឹងអំពីបទចោទប្រកាន់មកលើខ្លួន នៅពេលឌុចត្រូវឃុំឃាំងដោយតុលាការយោធា ដូច្នេះស្ថានភាពពិតប្រាកដរបស់ ឌុច គឺខុសគ្នាទៅនឹងឧទាហរណ៍ដែលបានលើកឡើងនៅក្នុងសារណាបណ្តឹងឧទ្ធរណ៍របស់មេធាវីចុងចោទដែលបានសរសេរថានៅមុនពេលត្រូវឃុំខ្លួនដោយអង្គជំនុំជម្រះវិសាមញ្ញ ចុងចោទមិនបានដឹងអំពីបទចោទប្រកាន់កាលពីពេលត្រូវឃុំខ្លួនដោយតុលាការយោធា ។

៣) ឌុច បានរស់នៅលាក់មុខចាប់ពីឆ្នាំ១៩៧៩ រហូតដល់ឆ្នាំ១៩៩៩ នៅពេលដែលគាត់ត្រូវបានឃុំខ្លួនដោយអាជ្ញាធរកម្ពុជា ។ ភ័ស្តុតាងដែលប្រហែលជាអាចបញ្ជាក់ថានៅអំឡុងពេលរស់នៅដោយលាក់មុខ ឌុច មិនបានបង្កជាការគំរាមកំហែងដល់សុវត្ថិភាពសាធារណៈ គឺមិនទាក់ទងអ្វីទៅនឹងស្ថានភាពបច្ចុប្បន្ននេះទេ ។ បច្ចុប្បន្ននេះ អត្តសញ្ញាណនិងទីកន្លែងរបស់ ឌុច ត្រូវបានគេស្គាល់ជាសាធារណៈ ។ សុវត្ថិភាពផ្ទាល់ខ្លួនរបស់ ឌុច អាចមានបញ្ហាប្រសិនបើឌុចត្រូវបានដោះលែងឲ្យនៅក្រៅឃុំ ហើយឱកាសដើម្បីរត់គេចទៅលាក់ខ្លួនម្តងទៀត (ប្រហែលជាអាចមានជំនួយពីខាងក្រៅ) នឹងអាចមានច្រើន ប្រសិនបើដាក់ ឌុច ឲ្យនៅក្រោមការឃុំខ្លួនក្នុងផ្ទះ ។ សារណាបណ្តឹងឧទ្ធរណ៍របស់មេធាវីចុងចោទមិនបានផ្តល់អ្វីក្រៅតែអំពីការបញ្ចេញយោបល់សុទិដ្ឋិនិយមផ្ទាល់ខ្លួនជាលក្ខណៈមិនបានគិតគូរវែងឆ្ងាយដល់ជោគវាសនារបស់ ឌុច ក្នុងករណីដែលឌុចត្រូវបានដោះលែងឲ្យនៅក្រៅឃុំ ហើយសារណាបណ្តឹងឧទ្ធរណ៍របស់មេធាវីចុងចោទនេះក៏បានបញ្ជាក់មិនត្រឹមត្រូវអំពីអ្នកដែលមានបន្ទុកបង្ហាញភ័ស្តុតាងក្នុងការកំណត់ថាតើ ឌុច

ត្រូវឃុំខ្លួនដដែល ឬត្រូវដោះលែងឲ្យនៅក្រៅឃុំនោះ ។

**អំណះអំណាង**

**I. អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាអាចមិនសម្រេចអំពីភាពស្របច្បាប់នៃការឃុំខ្លួនកាលពីមុនរបស់ ឌុច ដោយសារតែអង្គជំនុំជម្រះវិសាមញ្ញមិនទទួលខុសត្រូវចំពោះការឃុំឃាំងខ្លួននោះ ហើយអង្គជំនុំជម្រះវិសាមញ្ញនេះក៏មិនមានយុត្តាធិការលើតុលាការយោធានៅទីក្រុងភ្នំពេញឡើយ ។**

**ក) ចរិតឯករាជ្យរបស់អង្គជំនុំជម្រះវិសាមញ្ញបានហាមឃាត់អង្គជំនុំជម្រះនេះមិនឲ្យសម្រេចលើភាពស្របច្បាប់នៃដីកាឃុំខ្លួនរបស់តុលាការយោធា ។**

បើទោះបីជាអង្គជំនុំជម្រះវិសាមញ្ញមានដំណើរការនៅក្នុងក្របខ័ណ្ឌនៃច្បាប់កម្ពុជា និងច្បាប់អន្តរជាតិក៏ដោយ អង្គជំនុំជម្រះវិសាមញ្ញនេះមានភាពឯករាជ្យពេញលេញពីផ្នែកផ្សេងៗទៀតនៃប្រព័ន្ធយុត្តិធម៌កម្ពុជា ។ រចនាសម្ព័ន្ធរបស់អង្គជំនុំជម្រះវិសាមញ្ញគឺខុសគ្នាយ៉ាងខ្លាំងពីរចនាសម្ព័ន្ធរបស់តុលាការកម្ពុជាផ្សេងៗទៀត ។ វិធានផ្ទៃក្នុងដែលគ្រប់គ្រងដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញគឺមានលក្ខណៈពិសេស ។ ជាងនេះទៅទៀត អង្គជំនុំជម្រះនៃតុលាការកំពូលរបស់អង្គជំនុំជម្រះវិសាមញ្ញមិនមានសិទ្ធិប្តឹងសាទុក្ខទៅកាន់តុលាការកម្ពុជាផ្សេងទៀតទេ ។ ដោយយោងទៅលើភាពឯករាជ្យនិងអំណាចដ៏តូចចង្អៀតរបស់ខ្លួន អង្គជំនុំជម្រះវិសាមញ្ញអាចមិនសម្រេចទៅលើភាពស្របច្បាប់នៃការឃុំឃាំងខ្លួនកាលពីមុនរបស់ ឌុច ទេ ។

នៅក្នុងអំឡុងពេលនៃការចរចាអស់រយៈពេលជាច្រើនឆ្នាំ រហូតនាំទៅដល់ការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងនាមជាតុលាការត្រឹមត្រូវស្របច្បាប់ដែលមានលក្ខណៈពិសេស («វិសាមញ្ញ») និងឯករាជ្យនៅក្នុងប្រព័ន្ធច្បាប់កម្ពុជាពុំដែលមានការគិតថា អង្គជំនុំជម្រះវិសាមញ្ញនឹងមានអំណាចវិនិច្ឆ័យទៅលើសាលក្រមរបស់តុលាការស៊ីវិល ឬតុលាការយោធារបស់កម្ពុជាទេ ។ ដូចដែលបានចែងនៅក្នុងច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញ និងកិច្ចព្រមព្រៀងអង្គការសហប្រជាជាតិនិងកម្ពុជាអំពីចឹង អង្គជំនុំជម្រះវិសាមញ្ញត្រូវបានបង្កើតឡើងធ្វើយ៉ាងណាឲ្យដាច់ដោយឡែកពីតុលាការកម្ពុជាដែលមានស្រាប់ និងវិនិច្ឆ័យសេចក្តីលើជនចុងចោទមួយក្រុមដែលត្រូវបានឲ្យនិយមន័យយ៉ាងតឹងតែងពីបទឧក្រិដ្ឋកម្មមួយចំនួនដែលប្រព្រឹត្តនៅក្នុងរយៈពេលមួយជាក់លាក់ ។ ពុំមានបញ្ញត្តិណាមួយដែលមានចែងយ៉ាងច្បាស់លាស់ ឬដោយប្រយោលនៅក្នុងច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញ នៅក្នុងកិច្ចព្រមព្រៀងរបស់អង្គការសហប្រជាជាតិ និងកម្ពុជា ឬនៅក្នុងវិធានផ្ទៃក្នុង («ឧបករណ៍ច្បាប់គ្រប់គ្រង ដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញ») ដែលបានផ្តល់អំណាចឲ្យអង្គជំនុំជម្រះវិសាមញ្ញអាចប្រើប្រាស់យុត្តាធិការរបស់ខ្លួនលើតុលាការកម្ពុជាផ្សេងទៀត ឬអាចពិនិត្យមើលឡើងវិញ ឬវិនិច្ឆ័យសេចក្តីលើសាលក្រមរបស់តុលាការកម្ពុជាផ្សេងៗទៀតឡើយ ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ និងចៅក្រមអន្តរជាតិពុំមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការវិនិច្ឆ័យសេចក្តីលើសាលក្រមដែលចេញដោយតុលាការកម្ពុជាក្នុងស្រុកដែលស្ថិតនៅក្រោមក្របខ័ណ្ឌច្បាប់កម្ពុជាទាំងស្រុងទេ ។ តាមការពិតមិនមាននីតិវិធីណាមួយចែងនៅក្នុងដែនអំណាចច្បាប់ដែលគ្រប់គ្រងដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញអនុញ្ញាតឲ្យចាប់ផ្តើមការស៊ើបអង្កេត ឬជំនុំជម្រះនៅក្នុងតុលាការកម្ពុជាក្នុងស្រុក និងសម្រេចចុងក្រោយបន្ទាប់នៅក្នុងអង្គជំនុំជម្រះវិសាមញ្ញនោះទេ ។ មិនមានទំនាក់ទំនងនីតិវិធីណាមួយរវាងតុលាការក្នុងប្រទេសកម្ពុជា និងអង្គជំនុំជម្រះវិសាមញ្ញដើម្បីធ្វើការពិនិត្យឡើងវិញលើសាលក្រមរបស់តុលាការក្នុងប្រទេសកម្ពុជាឡើយ ។ ដូច្នេះអង្គជំនុំជម្រះវិសាមញ្ញមិនមានយុត្តាធិការលើតុលាការក្នុងប្រទេសកម្ពុជាផ្សេងទៀតនិងលើសំណុំរឿងរបស់ឌុចនៅក្នុងតុលាការក្នុងស្រុកនោះឡើយ ។

**ខ) អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាពុំទទួលខុសត្រូវចំពោះការឃុំខ្លួនឌុច ។**

ប្រសិនបើអង្គជំនុំជម្រះវិសាមញ្ញត្រូវទទួលខុសត្រូវចំពោះការឃុំខ្លួនពីមុនរបស់ឌុច វាប្រហែលជារឿងសមរម្យក្នុងការស្នើសុំឲ្យអង្គជំនុំជម្រះវិសាមញ្ញនេះពិចារណាអំពីការឃុំខ្លួននោះដោយបញ្ជាឲ្យបន្តឃុំខ្លួនបណ្តោះអាសន្ន ។ ប៉ុន្តែបើទោះបីជាមានសារណាបណ្តឹងឧទ្ធរណ៍របស់មេធាវីចុងចោទក៏ដោយ ក៏អង្គជំនុំជម្រះវិសាមញ្ញមិនទទួលខុសត្រូវចំពោះការឃុំឃាំងឌុចដោយតុលាការយោធាឡើយ ។ សារណាបណ្តឹងឧទ្ធរណ៍របស់មេធាវីចុងចោទបាន

លើកឡើងថា «ចាប់ពីខែកុម្ភៈ ឆ្នាំ២០០២មក ការចោទប្រកាន់និងដីកាសម្រេចឃុំខ្លួន និងបន្តឃុំខ្លួនលោក កាំង ហ្កេកអ៊ាវ បានធ្វើឡើងដោយផ្អែកទៅលើច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០១...» ។ វាហាក់បីដូចជាថា បទចោទប្រកាន់ថ្មីៗទៅលើ ឌុច កាលពីខែកុម្ភៈ ឆ្នាំ២០០៥ ក៏ត្រូវបានធ្វើឡើងដោយផ្អែកទៅលើច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញដែរ ។ បើយោងទៅតាមសារណាបណ្តឹងឧទ្ធរណ៍របស់មេធាវីចុងចោទ មានន័យថាចំណាត់ការផ្សេងៗនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ គឺមាន «ទំនាក់ទំនងយ៉ាងជិតស្និទ្ធ»នឹងការឃុំខ្លួន ឌុច ដោយតុលាការយោធា ។

ការណ៍ដែលតុលាការយោធាបានប្រើប្រាស់ច្បាប់មួយដែលមិនទាន់ចូលជាធរមាននៅឡើយ និងសម្រាប់ប្រើប្រាស់ក្នុងតុលាការមួយដែលមិនទាន់ទាំងមានរូបរាងផងនោះ (ពោលគឺអង្គជំនុំជម្រះវិសាមញ្ញ) ដើម្បីធ្វើការចោទប្រកាន់មកលើ ឌុច គឺពិតជាសុំឲ្យមានការពន្យល់មួយ ក៏ប៉ុន្តែការពន្យល់នេះគឺមិនមែនសុំឲ្យផ្តល់នូវមូលដ្ឋានណាមួយទាក់ទងនឹងការពិនិត្យឡើងវិញរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានោះទេ ។ ច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមិនអាចយកមកប្រើប្រាស់ទាក់ទងនឹងការស៊ើបអង្កេតមុខសញ្ញាណាមួយនៅមុនថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០៧ បានឡើយ (នៅពេលដែលអង្គជំនុំជម្រះវិសាមញ្ញចាប់ផ្តើមដំណើរការទន្ទឹមនឹងការអនុម័តវិធានផ្ទៃក្នុង) ហើយការចោទប្រកាន់ទាំងឡាយនៅក្រោមយុត្តាធិការរបស់ច្បាប់នេះត្រូវតែធ្វើឡើងដោយសហព្រះរាជអាជ្ញារបស់អង្គជំនុំជម្រះវិសាមញ្ញនិងត្រូវមានការយល់ព្រមដោយសហចៅក្រមស៊ើបអង្កេតរបស់អង្គជំនុំជម្រះវិសាមញ្ញទៀតផង ។ ទាំងសហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេតមិនទាន់ត្រូវបានតែងតាំងនៅឡើយទេនៅក្នុងឆ្នាំ២០០២ឬ២០០៥ ។ តែការប្រើប្រាស់ច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញដោយតុលាការយោធាតែមួយមុខគឺមិនគ្រប់គ្រាន់ទេក្នុងការភ្ជាប់ការឃុំឃាំងខ្លួន ឌុច ដោយតុលាការយោធាទៅនឹងដំណើរការជំនុំជម្រះពេលបច្ចុប្បន្នរបស់អង្គជំនុំជម្រះវិសាមញ្ញ ។

អង្គជំនុំជម្រះវិសាមញ្ញមិនទទួលខុសត្រូវចំពោះកិច្ចការរបស់តុលាការយោធាទេ ព្រោះខ្លួនមិនមានយុត្តាធិការលើតុលាការយោធាមួយនេះ ហើយជាពិសេសអង្គជំនុំជម្រះវិសាមញ្ញមិនទាន់ទាំងមានរូបរាងផងនៅពេលតុលាការយោធាអនុវត្តកិច្ចការទាំងនោះ (ក្នុងឆ្នាំ២០០២ និង២០០៥) ។ នៅក្នុងឧទាហរណ៍ទាំងអស់ដែលបានលើកឡើងនៅក្នុងសារណាបណ្តឹងឧទ្ធរណ៍របស់មេធាវីចុងចោទ តុលាការដែលវិនិច្ឆ័យលើសំណុំរឿងទាំងនោះមិនត្រឹមតែមិនទាន់មានរូបរាងនៅក្នុងអំឡុងពេលឃុំខ្លួនដែលមានបញ្ហាប៉ុណ្ណោះទេ ថែមទាំងសុទ្ធតែមានយុត្តាធិការចម្បង និង/ឬ ដូចគ្នាទៅលើតុលាការទាំងនោះ ឬមន្ត្រីដែលទទួលខុសត្រូវចំពោះការឃុំឃាំងខ្លួនទៀតផង ។ ផ្ទុយទៅវិញអង្គជំនុំជម្រះវិសាមញ្ញមិនមានយុត្តាធិការលើតុលាការយោធា ហើយមិនទាន់ទាំងមានរូបរាងនៅឡើយទេ ក្នុងមួយរយៈពេលទាំងស្រុងដែលឌុចស្វែងរកដំណោះស្រាយនេះ ។ ដូច្នេះអង្គជំនុំជម្រះវិសាមញ្ញមិនអាចពិនិត្យឡើងវិញលើរឿងដ៏ចម្រូងចម្រាស់ដែលកើតចេញពីការអនុវត្ត ច្បាប់របស់តុលាការយោធាបានទេ ហើយចំណុចនេះគួរតែយកទៅដោះស្រាយនៅចំពោះតុលាការយោធាទើបត្រឹមត្រូវជាង ។

បើទោះបីជាតុលាការយោធាបានប្រើប្រាស់ច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញដើម្បីធ្វើការចោទប្រកាន់ប្រឆាំងនឹង ឌុច ដែលការចោទប្រកាន់នោះបានផ្តល់នូវមូលដ្ឋានសម្រាប់ការឃុំឃាំងពីមុនមកក៏ដោយ អង្គជំនុំជម្រះវិសាមញ្ញមិនទទួលខុសត្រូវចំពោះសកម្មភាពនេះទេ ។ ដូចដែលបានរៀបរាប់ខាងលើ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាស្ថិតនៅដាច់ដោយឡែកពីតុលាការយោធា និងពីប្រព័ន្ធយុត្តិធម៌នៅកម្ពុជាផ្សេងៗទៀត ហើយអង្គជំនុំជម្រះវិសាមញ្ញមិនទាន់ទាំងមានរូបរាងផងទេ នៅពេលដែលមានការចោទប្រកាន់ទាំងនោះ កុំថាឡើយដល់ទៅរៀបចំ ឬអនុញ្ញាតឲ្យមានការចោទប្រកាន់ទាំងនោះ ។ ដូចដែលបានលើកឡើងនៅក្នុងសារណាបណ្តឹងឧទ្ធរណ៍របស់មេធាវីចុងចោទអ៊ីចឹង ប្រវត្តិឃុំខ្លួនកាលពីមុនរបស់ឌុច ដោយសារដីកាតុលាការយោធា អាចជាកត្តាខ្លះសម្រាប់ឲ្យអង្គជំនុំជម្រះវិសាមញ្ញយកមកពិចារណានៅចុងបញ្ចប់នៃការវិនិច្ឆ័យសេចក្តី ។ នៅក្នុងករណីដែល ឌុច ត្រូវដោះលែង ឌុចអាចទទួលបានសំណងជំងឺចិត្ត ។ ក្នុងករណីដែល ឌុច ត្រូវរកឃើញថាមានកំហុស ទោសដែល

ឌុច ទទួលអាចត្រូវកាត់បន្ថយដើម្បីកាត់សងចំពោះរយៈពេលដែល ឌុច បានចំណាយនៅក្នុងមន្ទីរឃុំឃាំងកាលពីមុន ។ ក៏ប៉ុន្តែការមានដំណោះស្រាយបែបនោះនៅក្រោយដំណាក់កាលនៃការជំនុំជម្រះមិនបានផ្តល់ឲ្យឌុចនៅក្នុងដំណាក់កាលមុនជំនុំជម្រះនូវការដោះលែងមិនសមស្រប ការដោះលែងដោយបង់ប្រាក់ធានា ឬការឃុំឃាំងនៅក្នុងផ្ទះនោះទេ ។

**II. ឌុចបានដឹងពីបទចោទប្រកាន់នៅពេលដែលត្រូវឃុំឃាំងដោយតុលាការយោធា ។**

សារណាបណ្តឹងឧទ្ធរណ៍របស់មេធាវីចុងចោទបានលើកឡើងថាពេញមួយរយៈពេលនៃការឃុំខ្លួន ឌុច ដោយតុលាការយោធា ចាប់ពីថ្ងៃទីមួយនៃការឃុំខ្លួននៅថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៩ រហូតដល់មានដីកាចោទប្រកាន់ចុងក្រោយចេញកាលពីថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០៥ និងដូច្នេះ រហូតដល់ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៧ នៅពេលដែល ឌុច ត្រូវចោទប្រកាន់ និងត្រូវផ្ទេរមកកាន់អង្គជំនុំជម្រះវិសាមញ្ញ ឌុច ត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មនៅក្រោមច្បាប់កម្ពុជា ។ ច្បាប់កម្ពុជាហាក់ដូចជាតម្រូវថា ឌុច ត្រូវតែទទួលបាននូវការជូនដំណឹងគ្រប់បទចោទប្រកាន់ទាំងអស់មកលើខ្លួននៅពេលដែលតុលាការយោធាធ្វើការចោទប្រកាន់ ។ ពុំមានភស្តុតាងណាមួយបង្ហាញនៅក្នុងសារណាបណ្តឹងឧទ្ធរណ៍របស់មេធាវីចុងចោទដែលបញ្ជាក់ថា ឌុច មិនបានទទួលនូវការជូនដំណឹងអំពីបទចោទប្រកាន់ ឬប្រហែលជានៅថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៩, ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០២ និងថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០៥ នៅពេលដែលបទចោទប្រកាន់ទាំងបីត្រូវបានចោទប្រកាន់ដោយតុលាការយោធា ។

ការណ៍ដែលឌុចដឹងរហូតមកអំពីបទចោទប្រកាន់មកលើខ្លួនដោយតុលាការយោធាពេញមួយរយៈពេលនៃការឃុំខ្លួននៅឯតុលាការយោធានោះ បានធ្វើឲ្យស្ថានភាពរបស់ឌុចខុសពីឧទាហរណ៍សំខាន់ដែលលើកឡើងនៅក្នុងសារណាបណ្តឹងឧទ្ធរណ៍របស់មេធាវីចុងចោទ ។ មេធាវីចុងចោទបានដកស្រង់ពីសាលក្រមបារ៉ាយ៉ាហ្គីហ្សារបស់អង្គជំនុំជម្រះឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉ាន់ដា និងការឃុំខ្លួនបណ្តោះអាសន្នដែលកើតចេញពីសំណុំរឿងនូវ«ការសម្រេចដែលចៀសមិនរួច ...ថាសិទ្ធិរបស់ចុងចោទក្នុងការទទួលបានការជូនដំណឹងភ្លាមៗចំពោះបទចោទប្រកាន់ត្រូវបានរំលោភបំពាន» ។ អង្គជំនុំជម្រះឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉ាន់ដាបានសម្រេចថា «ការពិតនោះគឺថា ចុងចោទបានចំណាយពេលយ៉ាងយូរនៅក្នុងការឃុំខ្លួនបណ្តោះអាសន្នដោយមិនបានដឹងអំពីបទចោទប្រកាន់ជាទូទៅមកលើខ្លួន» ។ ស្ថានភាពបែបនេះគឺមិនបានកើតឡើង និងកើតឡើងចំពោះករណី ឌុច ឡើយ ។ ដូចជាទំនងថា ឌុច បានដឹងពីបទចោទប្រកាន់ដោយតុលាការយោធាតាំងពីថ្ងៃទីមួយដែលត្រូវឃុំខ្លួននៅក្នុងឆ្នាំ១៩៩៩ ហើយ ឌុច ក៏បានដឹងពីបទចោទប្រកាន់ដោយអង្គជំនុំជម្រះវិសាមញ្ញ តាំងពីថ្ងៃទីមួយនៃការឃុំខ្លួនបណ្តោះអាសន្នដោយអង្គជំនុំជម្រះវិសាមញ្ញដែរ ។ ឌុច មានពេលវេលាគ្រប់គ្រាន់ដើម្បីជំទាស់ទៅនឹងបទចោទប្រកាន់មកលើខ្លួនដោយតុលាការយោធាចាប់តាំងពីថ្ងៃទីមួយនៃការឃុំខ្លួននៅក្នុងឆ្នាំ១៩៩៩ ។ តាមវិធានផ្ទៃក្នុង ឌុចមានឱកាសគ្រប់គ្រាន់ដើម្បីជំទាស់ទៅនឹងបទចោទប្រកាន់ដោយអង្គជំនុំជម្រះវិសាមញ្ញដែលឥឡូវនេះកំពុងតែធ្វើការស៊ើបអង្កេតដោយសហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញ ។ នៅក្នុងករណីនេះមិនមានចន្លោះប្រហោងដែលថាឌុចមិនបានដឹងអំពីបទចោទប្រកាន់ ដូចដែលមានកើតឡើងនៅក្នុងសំណុំរឿងបារ៉ាយ៉ាហ្គីហ្សារបស់អង្គជំនុំជម្រះឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉ាន់ដាឡើយ ។

**III. ការរស់នៅមុនពេលឃុំខ្លួនរបស់ ឌុច នៅក្នុងប្រទេសកម្ពុជាគឺខុសគ្នាស្រឡះទៅនឹងស្ថានភាពថ្មី ប្រសិនបើត្រូវដោះលែងឲ្យនៅក្រៅឃុំមុនពេលចេញដីកាដំណោះស្រាយ ដូច្នេះហើយការព្រួយបារម្ភរបស់ចៅក្រមស៊ើបអង្កេតគឺត្រឹមត្រូវ ហើយការឃុំខ្លួនបណ្តោះអាសន្នគួរតែត្រូវរក្សាទុកដដែល ។**

**ក) ការពណ៌នាធ្វើឲ្យគេយល់ខុសរបស់មេធាវីចុងចោទអំពីទីកន្លែង និងអាកប្បកិរិយាពីឆ្នាំ១៩៧៩ដល់ឆ្នាំ១៩៩៩បានធ្វើឲ្យពិបាកយល់អំពីការណ៍ដែលថា ឌុច បំពេញបានយ៉ាងហោចណាស់លក្ខខណ្ឌបីនៅក្នុងវិធាន ៦៣(៣) នៃវិធានផ្ទៃក្នុងសម្រាប់ការឃុំខ្លួនបណ្តោះអាសន្ន ។**

សារណាបណ្តឹងឧទ្ធរណ៍របស់មេធាវីចុងចោទមានបំណងចង់បង្ហាញថា ឌុចពុំបំពេញតាមលក្ខខណ្ឌចែងនៅក្នុងវិធានផ្ទៃក្នុង

សម្រាប់ការឃុំខ្លួនបណ្តោះអាសន្នទេ ។ សារណាបណ្តឹងឧទ្ធរណ៍របស់
មេធាវីចុងចោទមានការខុះចន្លោះច្រើនក្នុងការធ្វើការពណ៌នា
រយៈពេល២៨ឆ្នាំមុន ។ សារណានោះបានលើកឡើងថា «លោក
កាំង ហ្គេកអ៊ាវ មានសេរីភាពតាំងពីឆ្នាំ១៩៧៩រហូតដល់ឆ្នាំ១៩៩៩
ដែលនៅពេលនោះគាត់ពុំដែលបានបង្កអ្វីឲ្យប៉ះពាល់ដល់សុវត្ថិភាព
សាធារណៈឡើយ ។ នេះជាចំណុចតែមួយគត់នៅក្នុងសំណុំរឿង
ដែលផ្តល់ជាគំនិតអំពីប្រតិកម្មរបស់សាធារណជន ក្នុងករណីមាន
ការដោះលែងលោក កាំង ហ្គេកអ៊ាវ» ។ ស្ថានភាពរបស់ឌុចនៅក្នុង
សង្គមកម្ពុជាមុនពេលឃុំខ្លួននៅក្នុងឆ្នាំ១៩៩៩ និងសព្វថ្ងៃនេះ
(និងជាពិសេស ប្រសិនបើ ឌុច ត្រូវបានដោះលែងមុនពេលចេញ
ដីកាដំណោះស្រាយ) គឺខុសគ្នាដូចយប់និងថ្ងៃ ។ ឌុច ប្រហែលជា
មិនបង្កជាការគំរាមកំហែងដល់សណ្តាប់ធ្នាប់សាធារណៈនៅមុន
ពេលមានការចាប់ខ្លួននៅឆ្នាំ១៩៩៩ ។ ឌុច រស់នៅដោយលាក់មុខ
ប្រើឈ្មោះថ្មី និងមានបំណងដកខ្លួនចេញពីសង្គម ។ តាមរយៈអ្វី
ដែលយើងដឹងពីប្រភពព័ត៌មានសាធារណៈ ឌុចចង់រស់នៅដោយ
លាក់មុខលាក់ឈ្មោះ ឈប់បន្តប្រព្រឹត្តអំពើឃោរឃៅ ដែលគាត់
ត្រូវបានចោទប្រកាន់នៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញប្រព្រឹត្ត
ទង្វើដែលទាក់ទងជាមួយរបបប៉ុលពតទៀត ។ នៅក្នុងស្ថានភាព
បែបនោះ ឌុច មានមូលហេតុគ្រប់គ្រាន់ក្នុងការធ្វើខ្លួនមិនឲ្យបង្កជា
ការគំរាមកំហែងដល់សុវត្ថិភាពសាធារណៈ ហើយមូលហេតុចម្បង
បំផុតគឺដើម្បីថែរក្សាសុវត្ថិភាពផ្ទាល់ខ្លួននៅក្នុងរយៈពេលនៃការ
លាក់ខ្លួននោះ ។

ក៏ប៉ុន្តែ ឥឡូវនេះ ឌុចបានក្លាយជាមនុស្សដែលគេស្គាល់ជា
សាធារណៈម្តងទៀត ដូចកាលពីពេលនៅក្រោមរបបខ្មែរក្រហម
ដែរ ។ ប្រសិនបើ ឌុច ត្រូវបានដោះលែងឲ្យនៅក្រៅឃុំរង់ចាំការ
ជំនុំជម្រះក្តី អត្តសញ្ញាណ និងទីកន្លែងរស់នៅរបស់ឌុចនឹងត្រូវបាន
គេដឹងជាសាធារណៈ ។ មិនមាននរណាម្នាក់រួមទាំងមេធាវី ឌុច ផង
ដែរអាចបង្ហាញថា ឌុចអាចមានសុវត្ថិភាពនៅកន្លែងផ្សេងពីមន្ទីរ
ឃុំឃាំងខ្លួនបច្ចុប្បន្ន ហើយការបង្ហាញនេះមិនមានអ្វីលើសពីការ
ដែលអង្គបុរេជំនុំជម្រះអាចបង្ហាញថា ឌុច អាចប្រថុយប្រថាន
ចំពោះសុវត្ថិភាពផ្ទាល់ខ្លួននោះទេ ។ មានមនុស្សរាប់សែននាក់
ដែលជាសមាជិកគ្រួសាររបស់ជនរងគ្រោះរាប់ម៉ឺននាក់ដែលបាត់
បង់ជីវិតនៅក្នុងគុកទួលស្លែងដែលធ្វើដំណើរនៅតាមដងវិថីសព្វថ្ងៃ
និងធ្វើស្រែចម្ការនៅក្នុងប្រទេសកម្ពុជាបច្ចុប្បន្ន ។ មេធាវីចុងចោទ
មិនអាចធានាចំពោះមុខអង្គបុរេជំនុំជម្រះថា សមាជិកគ្រួសារទាំង
នេះមិនបង្កជាការគំរាមកំហែងដល់សុវត្ថិភាពរបស់ ឌុច ប្រសិនបើ
ឌុច ត្រូវបានដោះលែងឲ្យនៅក្រៅឃុំ មុនពេលមានការចេញដីកា
ដំណោះស្រាយ ។ ដូចជាទំនងដែលថា សមាជិកគ្រួសារជនរង
គ្រោះទាំងនោះនឹងជាការគំរាមកំហែងខ្លាំងក្លាដល់សុវត្ថិភាព
របស់ឌុច ។

ការស្លាប់ដ៏គួរឲ្យសង្ស័យរបស់ប៉ុល ពត កាលពីខែមេសា
ឆ្នាំ១៩៩៨ ទន្ទឹមនឹងពេលដែលហៀបតែនឹងចាប់ខ្លួនគាត់នៅតាម
ព្រំដែនកម្ពុជា-ថៃ គឺជាឧទាហរណ៍អំពីការគំរាមកំហែងដល់
សុវត្ថិភាពរបស់ ឌុច នៅពេលនេះ ។ នៅពេលនោះខ្ញុំជាឯកអគ្គរដ្ឋទូត
សហរដ្ឋអាមេរិកទទួលបន្ទុកបញ្ហាឧក្រិដ្ឋកម្មសង្គ្រាម ហើយខ្ញុំបាន
ចូលរួមយ៉ាងសកម្មនៅក្នុងកិច្ចព្យាយាមទៅកាន់ទីតាំងប៉ុលពតដើម្បី
ចាប់ខ្លួនគាត់ ។ នៅសល់តែប៉ុន្មានម៉ោងទៀតប៉ុណ្ណោះ កងសន្តិសុខ
នឹងទៅដល់ទីកន្លែងលាក់ខ្លួនរបស់ប៉ុលពតទៅហើយ ស្រាប់តែប្រព័ន្ធ
ផ្សព្វផ្សាយព័ត៌មានបានបង្ហើបព័ត៌មានអំពីការហៀបនឹងចាប់ខ្លួនរបស់
ប៉ុល ពត ។ នៅយប់នោះ ប៉ុល ពត បានស្លាប់យ៉ាងអាថ៌កំបាំង ។
ការស្លាប់នេះបានពន្យារពេលទទួលខុសត្រូវចំពោះអំពើឃោរឃៅ
ដោយខ្មែរក្រហមអស់រយៈពេលជាច្រើនឆ្នាំ ។ មិនគួរមើលស្រាល
ចំពោះគ្រោះថ្នាក់សម្រាប់បុគ្គលសំខាន់ដែលត្រូវចោទប្រកាន់ពីបទ
ឧក្រិដ្ឋកម្មធ្ងន់ធ្ងរឡើយ ដោយសារតែពួកគេមិនអាចការពារខ្លួនពី
សត្រូវរាប់មិនអស់ដែលមានហេតុផលផ្សេងៗគ្នា រួមទាំងការ
សងសឹក និងការការពារខ្លួន ។ ប៉ុល ពត ខ្លួនឯងនៅពេលនោះស្ថិត
នៅក្រោមការឃុំឃាំងខ្លួននៅក្នុងផ្ទះដោយខ្មែរក្រហម ក្រោយមក
គាត់បានស្លាប់យ៉ាងទាន់ហន់ ហើយសម្រាប់អ្នកដែលព្យាយាម
គេចវេះពីយុត្តិធម៌ការស្លាប់គឺជាវិធីមួយយ៉ាងងាយៗក្នុងការគេច
វេះពីយុត្តិធម៌បែបនេះ ។

មេធាវីចុងចោទមិនអាចបង្ហាញថា ឥឡូវនេះឌុចនឹងមិនឆក់
ឱកាសគេចខ្លួនទៅរស់នៅលាក់មុខពីអាជ្ញាធរនៅពេលដែលលក្ខខណ្ឌ
អត្តសញ្ញាណ និងលក្ខខណ្ឌផ្លូវច្បាប់របស់គាត់ត្រូវបានគេដឹងជា
ទូទៅនៅក្នុងប្រទេសកម្ពុជា ហើយការណ៍នេះគឺវាផ្ទុយទៅនឹង

ស្ថានភាពរស់នៅរបស់គាត់កាលពីមុនពេលចាប់ខ្លួននៅក្នុងឆ្នាំ ១៩៩៩ ។ ស្ថានភាពរបស់គាត់បានផ្លាស់ប្តូរយ៉ាងខ្លាំង ។ ដូចដែលសារណាបណ្តឹងឧទ្ធរណ៍របស់មេធាវីចុងចោទបានលើកឡើងការធ្វើអំណះអំណាងថា តិចឬច្រើន ជីវិតរស់នៅលាក់មុខយ៉ាងស្ងៀមស្ងាត់អស់រយៈពេលជាច្រើនឆ្នាំកាលពីអតីតកាលអាចយកមកប្រើប្រាស់ម្តងទៀតដើម្បីធានាសុវត្ថិភាព និងធានាការវិលត្រឡប់មកបង្ហាញខ្លួនវិញ នៅពេលសវនាការក្នុងករណីដែលត្រូវតុលាការកោះហៅ បានធ្វើឲ្យការស្រមើស្រមៃនេះចាកឆ្ងាយពីតថភាពជាក់ស្តែង ។ បទដ្ឋានឈានមុខគេចែងនៅក្នុងអនុសញ្ញាសិទ្ធិមនុស្សសំខាន់ពីរ (មួយក្នុងចំណោមនេះគឺអនុសញ្ញាស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយដែលរដ្ឋាភិបាលកម្ពុជាជាសមាជិកដែរនោះ) តម្រូវឲ្យមានការធានាត្រឡប់មកបង្ហាញខ្លួនវិញនៅពេលជំនុំជម្រះ នៅមុនពេលមានសេចក្តីសម្រេចឆន្ទាគតិទាក់ទងទៅនឹងការដោះលែងឲ្យនៅក្រៅឃុំបណ្តោះអាសន្នត្រូវសម្រេចឡើងដោយចៅក្រម ។

ការពណ៌នាមិនគ្រប់ជ្រុងជ្រោយ នៅក្នុងសារណាបណ្តឹងឧទ្ធរណ៍របស់មេធាវីចុងចោទអំពីទីកន្លែងនិងសកម្មភាពកាលនៅក្នុងរយៈពេល២៨ឆ្នាំរបស់ ឌុច បានធ្វើឲ្យមានការពិបាកយល់អំពីលក្ខណៈនៃភាពប្រថុយប្រថានចំពោះសណ្តាប់ធ្នាប់សាធារណៈដូចគ្នានឹងការធ្វើឲ្យមានការពិបាកយល់អំពីចរិតនៃភាពប្រថុយប្រថានចំពោះសុវត្ថិភាពផ្ទាល់ខ្លួននិងការរត់គេចខ្លួនរបស់ឌុចដែរ ។ នៅក្នុងរយៈពេលជាច្រើនឆ្នាំ នៅពេលដែល ឌុច មានសេរីភាពប្រទេសកម្ពុជាស្ថិតនៅក្នុងស្ថានភាពសង្គ្រាមស៊ីវិលនៅឡើយ ហើយបរិយាកាសនៅពេលនោះគឺមិនមានសុវត្ថិភាពទេ ។ ការមានសេរីភាពរបស់មនុស្សសំខាន់ៗរបស់ខ្មែរក្រហមដូចជា ឌុច (មិនគិតដល់តួនាទីផ្ទាល់ខ្លួនរបស់ឌុចនៅក្នុងរយៈពេលនោះ) អាចបណ្តាលឲ្យអស្ថិរភាពនិងជម្លោះប្រដាប់អាវុធកាន់តែមានសភាពខ្លាំងជាងមុន ។ ជាងនេះទៅទៀត ដុយនឹងការរស់នៅដោយលាក់មុខចាប់ពីឆ្នាំ១៩៧៩ រហូតដល់ឆ្នាំ១៩៩៩ សព្វថ្ងៃនេះឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ទៅលើឌុចត្រូវបានផ្សព្វផ្សាយជាសាធារណៈ ហើយសាធារណជនបានដឹងយ៉ាងច្បាស់លាស់អំពីការឃុំឃាំងខ្លួន ឌុចនៅឯអង្គជំនុំជម្រះវិសាមញ្ញ ។ ដូចជាទំនងណាស់ថាការដោះលែងឌុចអាចបង្កជាការខឹងសម្បានៅក្នុងចំណោមប្រជាជនកម្ពុជាដូចដែលបានលើកឡើងដោយសហចៅក្រមស៊ើបអង្កេត ។

នៅក្នុងករណីដែលអង្គបុរេជំនុំជម្រះទទួលយកនូវអំណះអំណាងដែលថា ការដោះលែងឌុចនឹងមិនបង្កជាការគំរាមកំហែងអ្វីដល់សណ្តាប់ធ្នាប់សាធារណៈ ការយល់ឃើញបែបនេះគឺមិនត្រូវមិនគិតដល់ការពិចារណារបស់អង្គបុរេជំនុំជម្រះអំពីលក្ខខណ្ឌផ្សេងទៀតនៃវិធាន ៦៣(៣)(៣) នៃវិធានផ្ទៃក្នុង (ពោលគឺដើម្បី «ធានាវត្តមានជនជាប់ចោទនៅក្នុងដំណើរការនីតិវិធី») និងវិធាន ៦៣(៣)(៤) (ពោលគឺដើម្បី«ការពារសន្តិសុខឲ្យជនជាប់ចោទ») ដែលទាំងអស់នេះ ដូចដែលបានរៀបខាងលើ គឺជាការព្រួយបារម្ភខ្លាំង បើយើងពិនិត្យមើលអំពីកាលៈទេសៈកម្ពុជាសព្វថ្ងៃនេះ ។ ការរកឃើញដោយអង្គបុរេជំនុំជម្រះថាមានលក្ខខណ្ឌមួយឬលក្ខខណ្ឌទាំងពីរដែលបានលើកឡើងខាងលើគឺគ្រប់គ្រាន់សម្រាប់ការឃុំឃាំងខ្លួនបណ្តោះអាសន្នរបស់ ឌុច ។

**ខ) សេចក្តីសម្រេចរបស់ចៅក្រមស៊ើបអង្កេតទាក់ទងនឹងការឃុំខ្លួន ឌុច សមនឹងទទួលយកបាននូវការគោរព ហើយសេចក្តីសម្រេចនេះសមស្របតាមវិធានផ្ទៃក្នុងច្បាប់បរទេស (សហរដ្ឋអាមេរិក) និងច្បាប់អន្តរជាតិ ។**

សំខាន់បំផុត សារណាបណ្តឹងឧទ្ធរណ៍របស់មេធាវីចុងចោទគឺមិនត្រឹមត្រូវទេនៅពេលដែលការបង្ខំឲ្យសហចៅក្រមស៊ើបអង្កេតបង្ហាញថា «ពិតជាមានការគំរាមកំហែងចំពោះសន្តិសុខរបស់លោក កាំង ហ្កេកអ៊ាវ» ឬបង្ហាញថា ឌុចអាចរត់គេចខ្លួន ។ នៅពេលដែលតុលាការប្រឈមមុខនឹងការធ្វើសេចក្តីសម្រេចចិត្តបែបនេះ ទាក់ទងនឹងលទ្ធភាពកើតឡើងនូវព្រឹត្តិការណ៍ដែលជាប់ពាក់ព័ន្ធនឹងជនសង្ស័យមួយដែលស្នើសុំដោះលែងឲ្យនៅក្រៅឃុំបណ្តោះអាសន្នមុនមានសវនាការ ការគោរពយ៉ាងម៉ឺងម៉ាត់ត្រូវបានផ្តល់ជូនចៅក្រមនិងសេចក្តីសម្រេចរបស់ចៅក្រមទាក់ទងនឹងអ្វីដែលនឹងអាចកើតមានឡើងនាពេលខាងមុខ ។ នេះគឺជាសេចក្តីសម្រេចរួមគ្នារបស់សហចៅក្រមស៊ើបអង្កេតដែលពិបាកនឹងធ្វើឡើងខ្លាំងណាស់ ។

អង្គបុរេជំនុំជម្រះអាចរកមើលពីបទពិសោធន៍របស់តុលាការនៅក្នុងសហរដ្ឋអាមេរិកជុំវិញបញ្ហាឃុំខ្លួនបណ្តោះអាសន្នរបស់

ជនសង្ស័យដូចជា ឌុច និងអ្នកដែលត្រូវចោទប្រកាន់ពីបទល្មើសតូចតាចជាងនេះ ។ នៅក្នុងសហរដ្ឋអាមេរិក ច្បាប់កំណែទម្រង់ចំពោះការដាក់ប្រាក់ធានា (ច្បាប់ដាក់ប្រាក់ធានា ឬ **Bail Act**) មានចែងអំពីបន្ទុកបង្ហាញភ័ស្តុតាងទាក់ទងនឹងការឃុំខ្លួនបណ្តោះអាសន្ន ។ ច្បាប់ដាក់ប្រាក់ធានានេះគាំទ្រឲ្យមានការដាក់ប្រាក់ធានាលើកលែងតែ (១) ករណីដែលចៅក្រមមិនច្បាស់ថា ជនសង្ស័យនឹងបង្ហាញខ្លួនសម្រាប់ពេលជំនុំជម្រះ និង/ឬ (២) «ឧក្រិដ្ឋកម្មធ្ងន់ធ្ងរបំផុត» (មានការបញ្ជាក់បន្ថែមត្រង់ចំណុចនេះ) ។ «ឧក្រិដ្ឋកម្មធ្ងន់ធ្ងរ» ទាំងនេះរួមមានឧក្រិដ្ឋកម្មហិង្សាដែលអតិបរមានៃទោសយ៉ាងហោចណាស់ជាប់ឃុំឃាំងរយៈពេល១០ឆ្នាំ និងបទល្មើសដែលអតិបរមានៃទោសគឺឃុំឃាំងអស់មួយជីវិត ឬប្រហារជីវិត ។

ឧក្រិដ្ឋកម្មធ្ងន់ធ្ងរនេះវាជំរុញឲ្យមានការសន្មតថា «មិនមានលក្ខខណ្ឌមួយ ឬច្រើនដែលនឹងអាចធានាបានយ៉ាងសមហេតុសមផលនូវវត្តមានចុងចោទនៅពេលជំនុំជម្រះ ឬសុវត្ថិភាពរបស់សហគមន៍» ។ នៅពេលដែលការសន្មតបែបនេះត្រូវបានធ្វើឡើង ហើយជនជាប់ចោទមានភារៈក្នុងបន្ទុកត្រឹមកម្រិតណាមួយក្នុងការបង្ហាញភ័ស្តុតាងថា ខ្លួននឹងមិនរត់គេចខ្លួនទេ ។

បន្ទាប់ពីជនជាប់ចោទបង្ហាញភ័ស្តុតាង បន្ទុកនេះបានធ្លាក់ទៅលើរដ្ឋាភិបាលម្តង (ពោលគឺព្រះរាជអាជ្ញា) ក្នុងការបង្ហាញភ័ស្តុតាងដែលមានទម្ងន់ធ្ងន់យ៉ាងខ្លាំងក្លាថាចុងចោទអាចរត់គេចខ្លួនបាន ។ នៅក្នុងការសម្រេចចិត្តចុងក្រោយនេះ តុលាការត្រូវតែថ្លឹងថ្លែងភ័ស្តុតាងរបស់ជនសង្ស័យដែលបញ្ជាក់ថាខ្លួនមិនរត់គេចទៅនឹងៈ (១) លក្ខណៈ និងស្ថានភាពនៃការបទចោទប្រកាន់ (២) ទម្ងន់នៃភ័ស្តុតាងដាក់បន្ទុកលើជនសង្ស័យ (៣) ប្រវត្តិនិងអត្តចរិតរបស់ជនសង្ស័យ និង(៤) លក្ខណៈនិងស្ថានភាពគ្រោះថ្នាក់ចំពោះជនណាម្នាក់ឬសហគមន៍ ក្នុងករណីដែលជនសង្ស័យត្រូវបានដោះលែងឲ្យនៅក្រៅឃុំ ។ នៅពេលសម្រេចអំពីលទ្ធភាពនៃការរត់គេចខ្លួនតុលាការបានពិចារណាដល់រយៈពេលនៃទោសជាប់ឃុំឃាំងប្រសិនបើរកឃើញថាមានកំហុសនិងលទ្ធភាពរកធនធានហិរញ្ញវត្ថុ ។

នៅក្នុងសំណុំរឿងម៉ឺស៊ីឌែស (**Mercedes**) តុលាការឧទ្ធរណ៍បានច្រានចោលការដោះលែងដោយសាលាដំបូងចំពោះចុងចោទបីនាក់ពីបទប្លន់ប្រដាប់អាវុធ ។ នៅក្នុងការវិភាគរបស់តុលាការចុងចោទទីមួយខកខានមិនបានបង្ហាញភ័ស្តុតាងដើម្បីជម្រះការសន្មតដែលថា ចុងចោទអាចរត់គេចខ្លួន ដូច្នេះចុងចោទម្នាក់នេះអាចរត់គេចខ្លួន ។ ចុងចោទទីពីរបានព្យាយាមជម្រះការសង្ស័យនេះ ដោយបានបង្ហាញភ័ស្តុតាង ដូចជាគាត់មានសញ្ជាតិអាមេរិកមិនធ្លាប់មានប្រវត្តិប្រព្រឹត្តបទល្មើសមានទំនាក់ទំនងជិតស្និទ្ធជាមួយអ្នកធានា និងគាត់ខ្វះខាតធនធានហិរញ្ញវត្ថុ ។ ក៏ប៉ុន្តែរដ្ឋាភិបាលបានគាំទ្រការរកឃើញរបស់ខ្លួនដោយសង្កត់ធ្ងន់ពីចរិតហិង្សានៃបទល្មើសដែលបានចោទប្រកាន់ និងប្រវត្តិប្រព្រឹត្តអំពើហិង្សាក្នុងគ្រួសាររបស់ជនចុងចោទនេះ ។ ការអះអាងរបស់ចុងចោទទីបីថាខ្លួនមិនធ្លាប់មានប្រវត្តិប្រព្រឹត្តបទល្មើស ក៏ត្រូវបានបដិសេធដោយរដ្ឋាភិបាលដែរដែលរកឃើញថា ជននោះគ្មានការងារធ្វើជននោះមិនមែនជាពលរដ្ឋអាមេរិក និងមានប្រាក់ធានាតិចតួច ។

ដូចតុលាការនៅក្នុងសំណុំរឿងម៉ឺស៊ីឌែសដែរ តុលាការនៅក្នុងសំណុំរឿងសហរដ្ឋអាមេរិកនិងអាបាដ សុខចិត្តបដិសេធភ័ស្តុតាងយ៉ាងរឹងមាំដែលបញ្ជាក់ថា ចុងចោទនឹងមិនរត់គេចខ្លួនដោយសារតែតុលាការយល់ថា បទឧក្រិដ្ឋដែលបានចោទប្រកាន់នោះគឺមានលក្ខណៈធ្ងន់ធ្ងរគ្រប់គ្រាន់ ។ នៅក្នុងសំណុំរឿង អាបាដ ជនជាតិហ្វីលីពីនម្នាក់ត្រូវបានចោទប្រកាន់ពីបទរួមភេទជាមួយក្មេងមិនទាន់គ្រប់អាយុ ។ ចុងចោទបានជំទាស់ទៅនឹងការសន្មតដោយច្បាប់នោះដោយបានផ្តល់ភ័ស្តុតាងថា គ្រួសាររបស់គាត់នឹងធ្វើភាគីតតិយជនឃ្លាំមើលគាត់ លិខិតធានាថា គាត់នឹងមិនរត់គេចខ្លួននិងប្រាក់ធានាចំនួន៦៥.០០០ដុល្លារដែលជាតម្លៃផ្ទះរបស់ក្រុមគ្រួសារគាត់ ។ ប៉ុន្តែតុលាការយល់ឃើញថា ការធានាទាំងនេះមិនមានតម្លៃស្មើនឹងភាពគ្មានសញ្ជាតិអាមេរិករបស់គាត់ ភ័ស្តុតាងយ៉ាងរឹងមាំបញ្ជាក់ពីទោសកំហុសគាត់ និងភាពធ្ងន់ធ្ងរនៃទោសរបស់គាត់ (ជាប់ពន្ធនាគាររយៈពេល៣០ឆ្នាំ) ។

នៅក្រោមប្រព័ន្ធច្បាប់សហរដ្ឋអាមេរិក ភាពធ្ងន់ធ្ងរនៃបទចោទប្រកាន់មកលើ ឌុច គឺច្បាស់ណាស់ នឹងទាញការសន្មតថា ឌុច អាចរត់គេចខ្លួន ។ ឌុច អាចព្យាយាមជំទាស់នឹងការសន្មតនេះតាមរយៈការពន្យល់មិនគ្រប់គ្រាន់ដូចដែលបានធ្វើរួចហើយនៅក្នុងសារណាបណ្តឹងឧទ្ធរណ៍របស់មេធាវីចុងចោទ ក៏ប៉ុន្តែនៅទីបំផុតចរិតធ្ងន់ធ្ងរនៃបទចោទប្រកាន់មកលើឌុចនេះគឺជាសញ្ញាណយ៉ាងរឹងមាំ

បញ្ជាក់ថា ឌុចអាចរត់គេចខ្លួន ។ ជាងនេះទៅទៀតភ័ស្តុតាងដ៏រឹងមាំទាំងឡាយនៅក្នុងដៃរបស់សហចៅក្រមស៊ើបអង្កេតបញ្ជាក់ពីការទទួលខុសត្រូវរបស់ ឌុច គឺកាន់តែផ្តល់ទម្ងន់ទៅលើការឃុំខ្លួន ឌុចបន្ថែមទៀត ។ លទ្ធភាពរកធនធានហិរញ្ញវត្ថុអាចពីសំណាក់សាច់ញាតិនិងអតីតកម្មាភិបាលខ្មែរក្រហមជាមួយនឹងមធ្យោបាយជួយឲ្យឌុចរត់គេចខ្លួនក៏នឹងរារាំងមិនឲ្យមានការដោះលែង ឌុច ផងដែរ ។

ជាងនេះទៅទៀត នៅក្រោមប្រព័ន្ធអាមេរិក ប្រសិនបើជនសង្ស័យមិនអាចជម្រះការសង្ស័យ ដូចដែលបានរៀបរាប់ខាងលើទេ ជនសង្ស័យមិនអាចស្នើសុំរបៀបឃុំខ្លួនដែលស្រាលជាងធម្មតានោះបានទេ ។ ជាធម្មតា សូម្បីតែតុលាការសហរដ្ឋអាមេរិកមិនអាចធានាថា ជនសង្ស័យនឹងបង្ហាញខ្លួននៅពេលជំនុំជម្រះក៏ដោយ តុលាការ«ត្រូវចេញដីកាដោះលែងជនសង្ស័យឲ្យនៅក្រៅឃុំជាបណ្តោះអាសន្ន...ដោយដាក់ឲ្យនៅក្រោមលក្ខខណ្ឌស្រាលបំផុត ឬលក្ខខណ្ឌច្រើនដែល...នឹងអាចធានាយ៉ាងសមហេតុសមផលថាជនសង្ស័យនឹងបង្ហាញខ្លួនដូចដែលតម្រូវ[ដោយតុលាការ]» ។ លក្ខខណ្ឌដែលលើកឡើងនេះរួមមាន ការដាក់ឲ្យនៅក្រោមការមើលខុសត្រូវរបស់តតិយជនរក្សាមុខរបរការងារឲ្យនៅដដែល គោរពការដាក់កំហិតក្នុងការធ្វើទំនាក់ទំនងផ្សេងៗដាក់ឲ្យនៅជាប់ឃុំក្នុងផ្ទះ ទិញប័ណ្ណប្រាក់រដ្ឋាភិបាលនិងបំពេញ «លក្ខខណ្ឌផ្សេងទៀតដែលចាំបាច់ដើម្បីធានាឲ្យមានវត្តមានរបស់ជនសង្ស័យនៅក្នុងតុលាការ» ។ នៅក្នុងសហរដ្ឋអាមេរិក រដ្ឋាភិបាលមានបន្ទុកបង្ហាញពីអវត្តមាននៃលក្ខខណ្ឌបែបនោះតាមរយៈភ័ស្តុតាងដែលមានទម្ងន់នៅក្នុងសំណុំរឿង ។

ឌុចបានស្នើសុំឲ្យអនុវត្តរបៀបឃុំខ្លួនដែលស្រាលជាងធម្មតានៅក្នុងការធានាវត្តមានរបស់ខ្លួននៅពេលជំនុំជម្រះ ប៉ុន្តែប្រសិនបើ ឌុច ស្នើសុំបែបនេះនៅក្នុងតុលាការសហរដ្ឋអាមេរិកវិញ ឌុចនឹងឃើញថា របៀបឃុំខ្លួនដែលស្រាលជាងធម្មតានេះមិនយកមកអនុវត្តចំពោះបទឧក្រិដ្ឋកម្មធ្ងន់ធ្ងរដែលធ្វើឲ្យមានការសន្មតថា គាត់នឹងរត់គេចខ្លួននោះទេ ។ ដូចៗគ្នា តុលាការមិនសុខចិត្តអនុវត្តវិធានការ«ស្រាលបំផុត»នេះចំពោះជនសង្ស័យនៃឧក្រិដ្ឋកម្មធ្ងន់ធ្ងរទេ ។ តុលាការព្រហ្មទណ្ឌអន្តរជាតិបានទទួលស្គាល់គោលការណ៍នេះនៅក្នុងមាត្រា៥៩(៤)នៃលក្ខន្តិកៈក្រុងរ៉ូម ដែលតម្រូវថា នៅពេលធ្វើការសម្រេចលើករណីដោះលែងឲ្យនៅក្រៅឃុំបណ្តោះអាសន្ន «អាជ្ញាធរដែលមានសមត្ថកិច្ចនៅក្នុងនៅរដ្ឋដែលឃុំខ្លួនជនសង្ស័យត្រូវគិតគូរដល់ស្ថានភាពធ្ងន់ធ្ងរនៃបទចោទប្រកាន់ដើម្បីសម្រេចថា តើមានស្ថានភាពបន្ទាន់ ឬពិសេសណាមួយដែលតម្រូវឲ្យដោះលែងជាបណ្តោះអាសន្នដែរឬអត់ និងថាតើមានការធានាចាំបាច់ផ្សេងៗដែលបង្ហាញថា រដ្ឋដែលឃុំខ្លួនជនសង្ស័យអាចបំពេញកាតព្វកិច្ចប្រគល់ជននោះមកឲ្យតុលាការដែរឬអត់» ។ បទដ្ឋានដូចគ្នានេះនឹងត្រូវយកមកអនុវត្តនៅពេលជនសង្ស័យស្ថិតក្រោមការឃុំឃាំងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ។ នៅក្រោមប្រព័ន្ធច្បាប់អាមេរិក បទឧក្រិដ្ឋដែលចោទប្រកាន់មកលើឌុចគឺនៅក្នុងប្រភេទបទឧក្រិដ្ឋ ១៨ *U.S.CA. §3182(f)* ហើយប្រភេទបទឧក្រិដ្ឋនេះគឺតម្រូវឲ្យមានការសន្មតថា ជនជាប់ចោទប្រាកដជានឹងរត់គេចខ្លួន ។ បើពិនិត្យមើលអំពីការសន្មតនេះ ឌុចមិនអាចស្នើសុំឲ្យអនុវត្តរបៀបឃុំខ្លួនដែលមានលក្ខណៈបន្ធូរបន្ថយទេ ។ ជាងនេះទៅទៀតភាពធ្ងន់ធ្ងរនៃបទចោទប្រកាន់មកលើឌុចគឺតម្រូវមិនឲ្យមានការអនុវត្តរបៀបឃុំខ្លួនដែលមានលក្ខណៈបន្ធូរបន្ថយទេ ។

ដោយសារតែច្បាប់ដាក់ប្រាក់ធានារបស់អាមេរិកនិងវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញមានរចនាសម្ព័ន្ធស្រដៀងគ្នា អង្គបុរេជំនុំជម្រះគួរតែគិតគូរដល់មធ្យោបាយដូចគ្នា[ទៅនឹងតុលាការអាមេរិក] នៅក្នុងការសម្រេចអំពីការឃុំខ្លួនរបស់ឌុច ។ វិធានផ្ទៃក្នុងអនុញ្ញាតឲ្យមានការឃុំខ្លួនបណ្តោះអាសន្ននៅពេលដែលមានហេតុផលគ្រប់គ្រាន់ក្នុងការជឿជាក់ថា ជនជាប់ចោទប្រហែលជាបានប្រព្រឹត្តបទល្មើសមែន និងជាងនេះទៅទៀតជាវិធានការចាំបាច់ដើម្បីៈ (១)ការពារកុំឲ្យជនជាប់ចោទប្រើប្រាស់ការគៀបសង្កត់ទៅលើសាក្សី (២)ថែរក្សាភ័ស្តុតាងឬការពារការបំផ្លាញភ័ស្តុតាង (៣)ធានាវត្តមានរបស់ជនជាប់ចោទនៅពេលជំនុំជម្រះ (៤)ការពារសុវត្ថិភាពរបស់ជនជាប់ចោទឬ(៥)ថែរក្សាសណ្តាប់ធ្នាប់សាធារណៈ ។ ស្រដៀងគ្នាដែរ ច្បាប់ដាក់ប្រាក់ធានាតម្រូវឲ្យឃុំខ្លួនជនជាប់ចោទនៅក្នុងករណីៈ (១)ភាពប្រថុយប្រថានខ្ពស់ដែលថាជនជាប់ចោទនឹងគេចខ្លួន (២)ភាពប្រថុយប្រថានខ្ពស់ដែលថាជនជាប់ចោទនឹងរារាំងដល់ដំណើរការយុត្តិធម៌ ឬគំរាមកំហែង បង្ករបួសស្នាម ឬបំភិតបំភ័យសាក្សី ឬគណៈវិនិច្ឆ័យ ។

ក៏ប៉ុន្តែច្បាប់ដាក់ប្រាក់ធានាមានភាពធូរលុងក្នុងការដោះលែងជនជាប់ចោទឲ្យនៅក្រៅឃុំជាងវិធានផ្ទៃក្នុង ។ ភាពខុសគ្នាដោយអន្លើនេះគឺមានសារសំខាន់ណាស់ ប្រសិនបើពិនិត្យមើលអំពីតួនាទីខុសគ្នារវាងតុលាការទាំងពីរនេះ ។ ច្បាប់ដាក់ប្រាក់ធានានេះអនុវត្តនៅក្នុងសហរដ្ឋអាមេរិកចំពោះឧក្រិដ្ឋជនដ៏ច្រើនលើសលប់ដែលប្រព្រឹត្តបទឧក្រិដ្ឋធម្មតា ឬបទឧក្រិដ្ឋធ្ងន់ធ្ងរ ហេតុដូច្នេះច្បាប់នេះមានភាពទន់ភ្លន់ជាង ។ ច្បាប់ដាក់ប្រាក់ធានាត្រូវបានគាក់តែងឡើងដើម្បីផ្តល់សេរីភាពក្នុងការបង់ប្រាក់ធានាខ្លួនឲ្យទៅជនជាប់ចោទជាទូទៅតែម្តង លុះត្រាណាតែតុលាការសម្រេចអនុវត្តខុសពីនេះដោយពិចារណាអំពីលក្ខខណ្ឌផ្សេងៗ ។ មានតែបទឧក្រិដ្ឋកម្មធ្ងន់ធ្ងរមួយចំនួនតូចប៉ុណ្ណោះដែលមិនអនុញ្ញាតឲ្យបង់ប្រាក់ធានានៅក្រៅឃុំ ។

ផ្ទុយទៅវិញ យុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញគឺជំនុំជម្រះតែជនដែលមួយចំនួនតូចដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មឃោរឃៅ ហើយតុលាការសហរដ្ឋអាមេរិកកម្រនឹងអនុញ្ញាតឲ្យដាក់ប្រាក់ធានានៅក្រៅឃុំណាស់ចំពោះឧក្រិដ្ឋកម្មឃោរឃៅប្រភេទនេះ ។ តាមរយៈវិធានផ្ទៃក្នុងការដោះលែងឲ្យនៅក្រៅឃុំគឺជា និងគួរតែជាឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះទាំងស្រុង ដោយសារតែវាជាការគំរាមកំហែងចំពោះសណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពរបស់ជនជាប់ចោទខ្លួនឯងនេះ មិនទាំងនិយាយដល់ការប្រថុយប្រថានចំពោះការគេចខ្លួនរបស់ជនជាប់ចោទពីបទឧក្រិដ្ឋធ្ងន់ធ្ងរបែបនេះផង ។ សហចៅក្រមស៊ើបអង្កេតចាំបាច់គ្រាន់តែ «គិតថាការឃុំខ្លួនបណ្តោះអាសន្នជាវិធានការចាំបាច់» ដើម្បីបំពេញតាមលក្ខខណ្ឌរបស់អង្គជំនុំជម្រះប៉ុណ្ណោះ ។ នៅចុងបញ្ចប់ ខុសប្លែកពីច្បាប់ដាក់ប្រាក់ធានា វិធានផ្ទៃក្នុងមិនបានចែងអំពីគោលការណ៍សម្រាប់ការឃុំខ្លួនដែលមានលក្ខណៈបន្ធូរបន្ថយដូចជាឃុំខ្លួនក្នុងផ្ទះ ឬក៏ប្រើប្រាស់ឧបករណ៍អេឡិកត្រូនិកតាមដាននោះទេ ។ ការមិនចែងបែបនេះគឺត្រឹមត្រូវណាស់ បើពិនិត្យមើលអំពីការរត់គេចខ្លួន និងការព្រួយបារម្ភចំពោះសុវត្ថិភាពជនជាប់ចោទពេលនៅក្រៅអង្គជំនុំជម្រះវិសាមញ្ញ ។

ដូច្នេះ មានការគាំទ្រយ៉ាងច្រើននៅក្នុងច្បាប់បរទេស (សហរដ្ឋអាមេរិក) និងច្បាប់អន្តរជាតិ ក៏ដូចជាវិធានផ្ទៃក្នុងសម្រាប់ការយល់ឃើញថាសហចៅក្រមស៊ើបអង្កេតគឺត្រឹមត្រូវក្នុងការសន្និដ្ឋានថា «អង្គហេតុដែលត្រូវដាក់បន្ទុកចំពោះជនជាប់ចោទមានលក្ខណៈធ្ងន់ធ្ងរ សូម្បីតែបទឧក្រិដ្ឋដែលបានកើតឡើង៣០ឆ្នាំមកហើយក៏នៅតែបង្កជាបញ្ហាធ្ងន់ធ្ងរដល់សណ្តាប់ធ្នាប់សាធារណៈ ហេតុដូច្នេះមិនមែនជាការហួសហេតុពេកទេក្នុងការអះអាងថា នៅក្នុងបរិបទដ៏ប្រថុយប្រថាននៃសង្គមកម្ពុជាបច្ចុប្បន្ន ការដោះលែងជនជាប់ចោទនេះឲ្យនៅក្រៅឃុំអាចនឹងបង្កឲ្យមានការមិនពេញចិត្តជាទូទៅដែលអាចបង្កជាអំពើហិង្សា ឬអាចប៉ះពាល់ដល់សន្តិសុខផ្ទាល់ខ្លួនរបស់ជនជាប់ចោទ ។ ក្រៅពីនេះទោសឧក្រិដ្ឋអស់មួយជីវិតដែល ឌុច ត្រូវប្រឈមមុខនាំឲ្យមានការបារម្ភថា ជនជាប់ចោទនឹងរត់គេចខ្លួន» ។ អង្គបុរេជំនុំជម្រះគួរតែគាំទ្រការសន្និដ្ឋានដោយសហចៅក្រមស៊ើបអង្កេតនេះនិងចេញដីកាឃុំខ្លួន ឌុច រហូតដល់សហចៅក្រមស៊ើបអង្កេតចេញដីកាដំណោះស្រាយ ។

## សេចក្តីសន្និដ្ឋាន

ឯករាជ្យភាពរបស់អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងប្រព័ន្ធច្បាប់កម្ពុជាគឺមានភាពចាំបាច់ណាស់ ដោយសារតែគោលបំណងតែមួយនិងមានកំណត់ចរិតអន្តរជាតិរបស់អង្គជំនុំជម្រះវិសាមញ្ញនិងរចនាសម្ព័ន្ធ ធម្មនុញ្ញពិសេសរបស់អង្គជំនុំជម្រះនេះ ។ ឌុច បានស្វែងរកដំណោះស្រាយបានតែអ្វីដែលមានចែងនៅក្នុងអំណាចធម្មនុញ្ញរបស់អង្គជំនុំជម្រះវិសាមញ្ញប៉ុណ្ណោះ ដែលក្នុងនេះរួមមានអំណាចរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងការផ្តល់សំណងជំងឺចិត្តនៅក្នុងករណីដែលមិនមានដីកាបញ្ជូនរឿងឲ្យជំនុំជម្រះឬជនជាប់ចោទ ត្រូវសម្រេចឲ្យរួចខ្លួនពីបទចោទប្រកាន់ ឬអំណាចរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងការកាត់បន្ថយទោសក្នុងករណីដែលជនជាប់ចោទត្រូវសម្រេចឲ្យជាប់ទោស ។ កត្តាដែលអង្គជំនុំជម្រះវិសាមញ្ញត្រូវតែពិចារណានៅពេលសម្រេចអំពីការឃុំខ្លួនបណ្តោះអាសន្នត្រូវឆ្លុះបញ្ចាំងអំពីបទពិសោធន៍របស់ច្បាប់បរទេសនិងច្បាប់អន្តរជាតិ ហើយនៅក្នុងករណីរបស់ឌុច កត្តាទាំងនោះតម្រូវឲ្យមានការឃុំខ្លួនជាបន្តតាមវិធានផ្ទៃក្នុងរហូតដល់ពេលដែលសហចៅក្រមស៊ើបអង្កេតចេញដីកាដំណោះស្រាយអំពី ឌុច នេះ ។

**ដេវីដ សេហ្វ័រ**

# ការិយាល័យរដ្ឋបាលរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានឹងទទួលបានផលប្រយោជន៍ ប្រសិនបើមានការរៀបចំខ្លួនឱ្យមានលក្ខណៈដូចគ្នាច្រើននៅនឹង "ការិយាល័យក្រឡាបញ្ជី"

រឿងរ៉ាវដ៏ច្រើនដែលចុះក្នុងសារព័ត៌មានថ្មីៗកន្លងទៅនេះ បានធ្វើឲ្យមានការកើនឡើងនូវកង្វល់ជាសាធារណៈក្នុងចំណោមមន្ត្រីនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានិងអ្នកសង្កេតការណ៍ពីខាងក្រៅទៅលើការរៀបចំរបស់ការិយាល័យរដ្ឋបាលរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាក្នុងការដោះស្រាយកិច្ចការតុលាការដែលចេះតែកើនឡើងកាន់តែច្រើន ។ កាលពីខែមិថុនាកន្លងទៅមានការចេញរបាយការណ៍ពីររិះគន់ចំពោះការចាត់ចែងការងាររបស់អង្គជំនុំជម្រះវិសាមញ្ញដោយអ្នកជំនាញអន្តរជាតិពីរក្រុមខុសគ្នា ។ ក្រុមមួយដែលមានសមាសភាពអ្នកជំនាញឯករាជ្យពីររូប ដែលមានជំនាញខាងកិច្ចការរដ្ឋបាលបានបំពេញទស្សនកិច្ចនៅអង្គជំនុំជម្រះវិសាមញ្ញនៅចុងខែខសភា ដើម្បីវាយតម្លៃលើការរៀបចំរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងការចាត់ចែងកិច្ចការតុលាការរបស់ខ្លួន ។ របាយការណ៍វាយតម្លៃរបស់ក្រុមនេះស្ថិតនៅជាកិច្ចការសម្ងាត់នៅឡើយ លើកលែងតែសេចក្តីសង្ខេបខ្លីៗនៃការជូនយោបល់តែប៉ុណ្ណោះដែលត្រូវបានទម្លាយឲ្យដឹង ។ ទោះបីជាយ៉ាងនេះក៏ដោយ សេចក្តីសង្ខេបរួមគ្នាជាមួយរឿងរ៉ាវចុះផ្សាយតាមបណ្តាញសារព័ត៌មានដែលក្រុមនេះបានរកឃើញបញ្ជាក់ឲ្យឃើញថា ជំនាញការទាំងពីររូបជឿជាក់យ៉ាងមុតមាំថាមាន «ការខ្វះចន្លោះ» ច្រើននៅក្នុងការដឹកនាំផ្នែករដ្ឋបាល និងរចនាសម្ព័ន្ធក្នុងការធ្វើរបាយការណ៍របស់អង្គជំនុំជម្រះវិសាមញ្ញ ។

នៅឯអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដំណើរការផ្នែករដ្ឋបាលទូទៅគឺជាការទទួលខុសត្រូវរបស់ការិយាល័យរដ្ឋបាល ។ ជាការបន្ថែមលើកិច្ចការជ្រើសរើសនិងគ្រប់គ្រងបុគ្គលិករបស់អង្គជំនុំជម្រះវិសាមញ្ញ ការិយាល័យរដ្ឋបាលជួយជ្រោមជ្រែងដល់ការិយាល័យច្បាប់ផ្សេងៗទៀតរបស់អង្គជំនុំជម្រះវិសាមញ្ញតាមរយៈការធ្វើជាបណ្តាញផ្លូវការសម្រាប់ទំនាក់ទំនងខាងក្នុងនិងខាងក្រៅរបស់អង្គជំនុំជម្រះវិសាមញ្ញ ថែរក្សាប្រព័ន្ធទិន្នន័យដែលរួមមានឯកសារទាក់ទងនឹងរឿងក្តីទាំងអស់ ថែរក្សានិងទុកដាក់ភ័ស្តុតាងឲ្យបានគង់វង្ស ធានាសុវត្ថិភាពផ្នែកសន្តិសុខ ត្រួតពិនិត្យលក្ខខណ្ឌឃុំខ្លួន ហ៊ីកហ៊ីន បុគ្គលិករបស់អង្គជំនុំជម្រះវិសាមញ្ញ ព្រមទាំងផ្តល់ជូននូវតម្រូវការទាំងផ្នែកសម្ភារៈ និងកិច្ចការរដ្ឋបាល (ដែលរួមមានសម្ភារៈការិយាល័យ សម្ភារៈប្រើប្រាស់ ការចាត់ចែងសម្ភារៈ និងអគារធ្វើការ បច្ចេកវិទ្យា ព័ត៌មាន និងការដឹកជញ្ជូនជាដើម) ។

## ការរៀបចំចាត់ចែងកិច្ចការរដ្ឋបាលពេលបច្ចុប្បន្ន

ការិយាល័យរដ្ឋបាលដឹកនាំដោយប្រធានខ្មែរមួយរូបនិងអនុប្រធានបរទេសមួយរូប ។ ប្រធានខ្មែរនៃការិយាល័យរដ្ឋបាលគឺទទួលខុសត្រូវលើ«ភារកិច្ចគ្រប់គ្រងទូទៅ» លើកលែងតែ «កិច្ចការណាដែលពាក់ព័ន្ធនឹងបទដ្ឋាននិងនីតិវិធីអង្គការសហប្រជាជាតិ» តែប៉ុណ្ណោះ ។ ភារកិច្ចទទួលខុសត្រូវរបស់ប្រធានការិយាល័យរដ្ឋបាលរួមមានជ្រើសរើសបុគ្គលិកខ្មែរនិងស្នើសុំការតែងតាំងពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា ។ អនុប្រធានបរទេសមានភារកិច្ចទទួលខុសត្រូវលើកិច្ចការរដ្ឋបាលនៃគ្រប់ការិយាល័យបរទេសរបស់អង្គជំនុំជម្រះវិសាមញ្ញដោយរួមបញ្ចូលទាំងការជ្រើសរើសនិងគ្រប់គ្រងបុគ្គលិកបរទេសផង ។ ក្នុងការបំពេញភារកិច្ចទាំងនេះ ប្រធាននិងអនុប្រធានរដ្ឋបាលតម្រូវឲ្យមាន «ការសហការគ្នាដើម្បីធានាឲ្យបាននូវដំណើរការ និងការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព និងទទួលបានផលល្អ» ។

បើទោះបីជាការដឹកនាំរបស់ការិយាល័យរដ្ឋបាលត្រូវបានគិតថាមានទំនាក់ទំនងការងារសមស្រប និងរីកចម្រើនក៏ដោយ សិទ្ធិអំណាចដែលបែកដាច់ពីគ្នារវាងការិយាល័យរបស់ខ្មែរនិងបរទេសទាក់ទិននឹងថវិកា ការជ្រើសរើស និងការធ្វើរបាយការណ៍របស់បុគ្គលិកទំនងនឹងធ្វើឲ្យខូចដល់កិច្ចខិតខំប្រឹងប្រែងក្នុងការ

ឆ្លើយតបទៅនឹងកិច្ចការលំបាកៗនៃការដំណើរការរបស់តុលាការថ្មីដែលមានលក្ខណៈស្មុគស្មាញនេះ ។ ដោយយោងទៅតាមរឿងរ៉ាវថ្មីៗ ក្រុមវាយតម្លៃបានកំណត់ថាការបែងចែកការគ្រប់គ្រង «ផ្តល់នូវឧបសគ្គជារឿយៗ មានការច្របូកច្របល់ជាញឹកញាប់ព្រមទាំងធ្វើឲ្យស្រាកស្រាន្តដល់ការខិតខំប្រឹងប្រែងរបស់បុគ្គលិកទាំងសងខាងនៅក្នុងដំណើរការនេះ» ។ ក្រៅពីនេះ នៅមានកង្វល់ផ្សេងៗទៀតដូចជា សមត្ថភាពសម្រាប់ការការពារសាក្សីនៅក្រោមអំណាចរបស់ការិយាល័យរដ្ឋបាល ការគ្រប់គ្រងឯកសារ ការគាំពារជនរងគ្រោះ ការគ្រប់គ្រងមន្ទីរឃុំឃាំងបណ្តោះអាសន្ន ។ បន្ថែមពីលើនេះទៀត បន្ទប់សវនាការនៅមិនទាន់រៀបចំឲ្យរួចរាល់នៅឡើយ ឧបករណ៍សំឡេង និងសោតទស្សន៍មិនទាន់បានដំឡើងឲ្យបានស្រួលបួលនៅឡើយទេ ហើយនិងសេវាកម្មបកប្រែក៏ពុំមានលក្ខណៈសម្បត្តិគ្រប់គ្រាន់និងគួរឲ្យបារម្ភខ្លាំង ។

## ការគ្រប់គ្រងរដ្ឋបាលជាជម្រើសថ្មី

ស្ទើរតែនៅគ្រប់តុលាការដែលមានយុត្តាធិការចម្រុះជាតិនិងអន្តរជាតិបែបនេះ (ដែលឲ្យឈ្មោះថា តុលាការ «កូនកាត់») ក៏ដូចជាតុលាការអន្តរជាតិដទៃទៀតដែរ ការិយាល័យក្រឡាបញ្ជីមានការទទួលខុសត្រូវសម្រាប់មុខងាររដ្ឋបាល ។ ការិយាល័យក្រឡាបញ្ជីដែលត្រូវបានរៀបចំជាពីរផ្នែកបញ្ជាក់ឲ្យឃើញច្បាស់ថាការិយាល័យរដ្ឋបាលអាចនឹងរៀបចំដំណើរការទៅបានប្រសើរជាង និងប្រកបដោយប្រសិទ្ធភាពជាងនេះ ។

## ការដឹកនាំដែលមានលក្ខណៈរួបរួមនិងទទួលខុសត្រូវច្បាស់លាស់

ទិដ្ឋភាពដែលមានបែងចែកយ៉ាងច្បាស់លាស់រវាងការិយាល័យក្រឡាបញ្ជីនិងការិយាល័យរដ្ឋបាលគឺនៅត្រង់ចំណុចដែលថាការដឹកនាំនិងជារឿយៗរចនាសម្ព័ន្ធរបាយការណ៍របស់ការិយាល័យក្រឡាបញ្ជីស្ថិតនៅរួមគ្នាក្រោមការគ្រប់គ្រងរបស់មន្ត្រីតុលាការតែម្នាក់ ។ ឧទាហរណ៍ លក្ខន្តិកៈក្រុងរ៉ូមចែងថា «ការិយាល័យក្រឡាបញ្ជីត្រូវដឹកនាំដោយក្រឡាបញ្ជីដែលជាមន្ត្រីរដ្ឋបាលគោលរបស់តុលាការ» ។ ការដឹកនាំរួមមិនត្រឹមតែជាគន្លឹះសំខាន់ប៉ុណ្ណោះទេ ថែមទាំងជាធាតុផ្សំដ៏មានប្រយោជន៍សម្រាប់ការិយាល័យរដ្ឋបាលដឹកនាំការងារបានល្អទៀតផង ។ ផ្ទុយទៅវិញ កង្វះចន្លោះអំពីសិទ្ធិអំណាចច្បាស់លាស់ឈានដល់ការគ្មាននរណាម្នាក់ធ្វើជាម្ចាស់លើកិច្ចការដ៏សំខាន់ជាច្រើន ។

ឧទាហរណ៍ សម្រាប់រយៈពេលបីឆ្នាំដំបូងនៃប្រតិបត្តិការរបស់តុលាការពិសេសសម្រាប់ឧក្រិដ្ឋកម្មធ្ងន់ធ្ងរនៅទីម័រខាងកើតដែលជាតុលាការកូនកាត់មានភាពស្រដៀងគ្នាច្រើននឹងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាគឺគ្មានអំណាចរដ្ឋបាលកណ្តាលមួយក្នុងការធ្វើការសម្រេច និងទទួលខុសត្រូវលើសេចក្តីសម្រេចអំពីការគ្រប់គ្រងចម្បងឡើយ ។ អ្នកអង្កេតការណ៍ជំនាញបានកត់សម្គាល់ឃើញភាពខ្វះចន្លោះរបស់តុលាការនេះទាក់ទិននឹងបញ្ហាគ្រប់គ្រងនេះតែម្តង ។ ដោយផ្នែកមុខងារគ្រប់គ្រងនិងដឹកនាំកិច្ចការរដ្ឋបាលមានការបែងចែកគ្នារវាងបេសកកម្មរបស់អង្គការសហប្រជាជាតិ និងអាជ្ញាធរកម្ពុជា ដោយភាគីទាំងពីរពឹងផ្អែកលើយុត្តាធិការផ្សេងទៀតនៅពេលដែលមានបញ្ហាណាមួយកើតឡើង ។ ភាពលំបាកខ្លាំងទាំងនេះកើតមានឡើងមួយផ្នែក បន្ទាប់ពីមានការបង្កើតឲ្យមានតួនាទីរបស់អ្នកសម្របសម្រួលកិច្ចការច្បាប់ និងមានបុគ្គលិកដែលបម្រើការងារដោយមន្ត្រីមានលក្ខណៈសម្បត្តិល្អ ។ តាមរយៈសម្តីរបស់មន្ត្រីនោះ ការបែងចែកអំណាចបានបង្កើតឲ្យមានបរិយាកាសមួយដែលធ្វើឲ្យ «ខ្សែសង្វាក់បញ្ជាពុំមានលក្ខណៈច្បាស់លាស់ ព្រំដែនទទួលខុសត្រូវមិនច្បាស់លាស់ជារឿយៗ ហើយភារកិច្ចក្នុងការធ្វើឲ្យមាននិរន្តរភាពនិងការគាំទ្រដល់ដំណើរការមិនបានកំណត់ច្បាស់លាស់» ។

ដូចដែលក្រុមវាយតម្លៃបានធ្វើការកត់សម្គាល់ភាពទន់ខ្សោយស្រដៀងគ្នារបស់ការិយាល័យរដ្ឋបាលកើតមកពីរចនាសម្ព័ន្ធនិងការដឹកនាំដែលញែកចេញដាច់ពីគ្នារបស់អង្គជំនុំជម្រះវិសាមញ្ញបង្កើតឲ្យមានការច្របូកច្របល់តួនាទីនិងការទទួលខុសត្រូវរវាងមន្ត្រីកំពូលទាំងពីរនាក់ ។ ជាផលវិបាកគឺថា គ្មានមន្ត្រីនៃការិយាល័យរដ្ឋបាលណាម្នាក់មានអាណត្តិពេញលេញក្នុងការចាត់វិធានការដែលសមស្របចំពោះប្រតិបត្តិការមុនៗអង្គជំនុំជម្រះវិសាមញ្ញ ក៏ដូចជាពុំមាននរណាម្នាក់ត្រូវបានដាក់ឲ្យទទួលខុសត្រូវចំពោះការដែលមិនបានបំពេញការងារឲ្យបានល្អរបស់ខ្លួនដែរ ។

## ការសម្របសម្រួលនិងការគ្រប់គ្រងផ្នែកតុលាការ

ភាពខុសគ្នាសំខាន់ទី២រវាងការិយាល័យរដ្ឋបាលនិង

ការិយាល័យក្រឡាបញ្ជីស្ថិតនៅត្រង់ថា ការិយាល័យក្រឡាបញ្ជីធ្វើការងារដោយសម្របសម្រួលគ្នាយ៉ាងជិតស្និទ្ធ ហើយនៅក្រោមសិទ្ធិអំណាចរបស់មន្ត្រីច្បាប់ជាន់ខ្ពស់របស់តុលាការ ដែលជាទូទៅត្រូវបានហៅថា ប្រធានតុលាការ ។ សិទ្ធិអំណាចគ្រប់គ្រងរបស់ប្រធានតុលាការអាចដាក់ឲ្យប្រធានការិយាល័យក្រឡាបញ្ជីទទួលខុសត្រូវផ្ទាល់ ចំពោះអង្គភាពតុលាការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, និងធានាឲ្យប្រាកដថា កង្វល់ផ្សេងៗទាក់ទិននឹងច្បាប់ត្រូវបានទទួលដឹងព្និងត្រូវបានដោះស្រាយ ។ លើសពីនេះទៅទៀត ដោយសារតែប្រធានការិយាល័យក្រឡាបញ្ជីបំពេញភារកិច្ចក្នុងនាមប្រធានតុលការ ប្រធានក្រឡាបញ្ជីនោះមានអាណត្តិធំធេងក្នុងការធ្វើនិងអនុវត្តសេចក្តីសម្រេចចិត្តដែលចាំបាច់ក្នុងការធានាឲ្យប្រតិបត្តិការរបស់តុលាការទាំងមូលមានប្រសិទ្ធភាព ។

ចំណែកអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាវិញ ទាំងកិច្ចព្រមព្រៀងដែលចែងពីក្របខ័ណ្ឌ សហប្រតិបត្តិការរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាំងច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាពុំបានបង្កើតឲ្យមានការិយាល័យតែមួយរបស់ប្រធានតុលាការឡើយ ។ ផ្ទុយទៅវិញបែរជាបង្កើតឲ្យមានប្រធានខ្មែរសម្រាប់អង្គជំនុំជម្រះនីមួយៗដូចជា អង្គបុរេជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូលទៅវិញ ហើយគ្មានប្រធានអង្គជំនុំជម្រះណាម្នាក់ទទួលខុសត្រូវក្នុងការគ្រប់គ្រងលើការិយាល័យរដ្ឋបាលឡើយ ។ វិធានផ្ទៃក្នុងបានដោះស្រាយបញ្ហានេះមួយផ្នែកខ្លះដោយបង្កើតឡើងនូវ «គណៈកម្មាធិការរដ្ឋបាលតុលាការ» ដែលមានសមាសភាពចៅក្រមជាតិ៣រូប និងចៅក្រមអន្តរជាតិ២រូប និងមានប្រធាន និងអនុប្រធានការិយាល័យរដ្ឋបាលចូលរួមត្រឹមឋានៈ «ពិគ្រោះយោបល់» តែប៉ុណ្ណោះ ។ គណៈកម្មាធិការនេះត្រូវបានផ្តល់សិទ្ធិក្នុងការ «ផ្តល់ប្រឹក្សា និងណែនាំដល់ការិយាល័យរដ្ឋបាលអំពីសកម្មភាពទាំងឡាយដែលពាក់ព័ន្ធទៅនឹងការគាំទ្រផ្នែករដ្ឋបាល និងតុលាការដល់ការិយាល័យសហព្រះរាជអាជ្ញា ការិយាល័យសហចៅក្រមស៊ើបអង្កេត និងអង្គជំនុំជម្រះដោយរួមទាំងការរៀបចំ និងការអនុវត្តថវិកា» ទៀតផង ។

ក៏ប៉ុន្តែ សិទ្ធិអំណាចរបស់គណៈកម្មាធិការរដ្ឋបាលតុលាការក្នុងការ «ផ្តល់ប្រឹក្សា និងណែនាំ» ពុំត្រូវបានផ្តល់អំណាចឲ្យក្នុងការដាក់ឲ្យការិយាល័យរដ្ឋបាលទទួលខុសត្រូវចំពោះមុខអង្គភាពតុលាការ [អង្គភាពតុលាការអាចហៅម្យ៉ាងទៀតថា អង្គជំនុំជម្រះ] ឡើយ ហើយគណៈកម្មាធិការនេះក៏មិនអាចធានាបាននូវការសហការគ្នាជាទៀតទាត់ដែរ ។ ជាវិបាក អំណាចរបស់គណៈកម្មាធិការនេះមិនរឹងមាំគ្រប់គ្រាន់ក្នុងការដោះស្រាយបញ្ហាគ្រប់គ្រងនាពេលបច្ចុប្បន្ននៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានទេ ។ គួរតែធ្វើការកត់សម្គាល់ឲ្យច្បាស់ថា តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីមានគណៈកម្មាធិការគ្រប់គ្រងដែលជួយសម្របសម្រួលការងារជាមួយការិយាល័យក្រឡាបញ្ជី ក៏ប៉ុន្តែប្រធានតុលាការនៅតែមានអំណាច «គ្រប់គ្រង» ជាក់ច្បាស់លើសកម្មភាពរបស់ការិយាល័យក្រឡាបញ្ជីដដែល ។

## ការជូនយោបល់ឲ្យមានប្រធានក្រឡាបញ្ជីនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ការិយាល័យរដ្ឋបាលនឹងទទួលបានប្រយោជន៍ច្រើនជាពុំខានក្នុងការមានខ្សែសង្វាក់បញ្ជាដែលមានលក្ខណៈកំណត់ច្បាស់លាស់ជាងនេះ ។ តាមទ្រឹស្តី កិច្ចការនេះអាចអនុវត្តបានសម្រេចដោយគ្រាន់តែធ្វើការកំណត់ដោយប្រុងប្រយ័ត្ននូវការទទួលខុសត្រូវចំពោះការដឹកនាំនៅក្នុងគ្រប់ផ្នែក ។ ក្រុមវាយតម្លៃរបស់អង្គការសហប្រជាជាតិបានជូនយោបល់នេះដោយសង្កត់ធ្ងន់ទៅលើភាពចាំបាច់ក្នុងការ «បញ្ជាក់ឲ្យបានច្បាស់លាស់នូវការទទួលខុសត្រូវរបស់ប្រធាននិងអនុប្រធានការិយាល័យរដ្ឋបាលក្នុងការធានាឲ្យមានការសម្រេចចិត្តប្រកបដោយប្រសិទ្ធភាព តាមរយៈការព្រមព្រៀង ចែករំលែកការទទួលខុសត្រូវសម្រាប់ផ្នែកសំខាន់មួយចំនួនទៅវិញទៅមក ហើយថាបុគ្គលិកដែលធ្វើការនៅក្នុងផ្នែកទាំងនោះត្រូវរាយការណ៍ផ្ទាល់ជូនទៅប្រធាន ឬអនុប្រធានដែលទទួលខុសត្រូវលើផ្នែកនោះតែម្តង» ។

ក៏ប៉ុន្តែ បើទោះបីជាតួនាទីរបស់ប្រធាន និងអនុប្រធានត្រូវបានកំណត់ច្បាស់លាស់ក៏ដោយ ការបែងចែកដាច់ពីគ្នាលើសិទ្ធិអំណាចប្រចាំថ្ងៃរវាងភាគីជាតិនិងអន្តរជាតិអាចនៅតែជាការរាំងស្ទះដល់លទ្ធភាពរបស់ការិយាល័យរដ្ឋបាលក្នុងការធ្វើការ

សម្រេចចិត្តដដែល ។ សម្រាប់ហេតុផលនេះ យើងគួរតែត្រូវបង្កើតតំណែងប្រធានក្រឡាបញ្ជីថ្មីមួយទៀតដែលមានអំណាចគ្រប់គ្រងជាពិសេសលើកិច្ចការទាំងមូលរបស់ការិយាល័យរដ្ឋបាល ហើយត្រូវបម្រើការងារដោយអ្នកដែលមានបទពិសោធន៍នៅក្នុងកិច្ចការរដ្ឋបាលតុលាការទៀតផង ។ ទាំងនេះនៅមិនទាន់និយាយដល់ការអនុវត្ត ការជូនយោបល់របស់ក្រុមវាយតម្លៃផ្សេងទៀតផងទេ នោះគឺការប្រុងប្រយ័ត្ន ... 

ទន្ទឹមគ្នានេះដែរ បទពិសោធន៍របស់តុលាការដែលមានលក្ខណៈជាអន្តរជាតិលើកឡើងថា ការិយាល័យរដ្ឋបាលនឹងអាចធ្វើការឲ្យមានប្រសិទ្ធភាពជាងនេះ ប្រសិនបើការដឹកនាំក្នុងការិយាល័យនេះត្រូវបានផ្តល់ឲ្យមានអាណត្តិនិងការទទួលខុសត្រូវក្នុងការធ្វើសេចក្តីសម្រេចស្ថិតនៅក្រោមអំណាចតុលាការ ។ ដូច្នេះក្រុមវាយតម្លៃបានជូនយោបល់ថា ចៅក្រមកណ្តាល[សម្រាប់ធ្វើទំនាក់ទំនង] ឬចៅក្រមនៅហ្នឹងកន្លែងត្រូវមានអំណាចក្នុងការផ្តល់ឲ្យការិយាល័យរដ្ឋបាលនូវ «សេចក្តីសម្រេចនិងការណែនាំផ្សេងៗទាក់ទិននឹងកិច្ចការរដ្ឋបាលតុលាការមួយចំនួន» ។ អាស្រ័យដោយមានលក្ខណៈសំខាន់ក្នុងការបញ្ចូលទាំងទស្សនៈយល់ឃើញរបស់ភាគីអន្តរជាតិនិងភាគីកម្ពុជាមានការជូនយោបល់ថា ការទទួលខុសត្រូវបែបនេះគួរត្រូវផ្តល់ជូនទៅប្រធានតុលាការដែលមានសមាសភាពចៅក្រមអន្តរជាតិ១រូប និងចៅក្រមកម្ពុជា១រូប ។ សហប្រធានតុលាការដែលមានអំណាចគ្រប់គ្រងលើកិច្ចការរដ្ឋបាលរួមតែមួយអាចជួយដោះស្រាយរាល់កង្វល់ផ្សេងៗអំពីការរក្សាតុល្យភាពពេលបច្ចុប្បន្នទាក់ទិននឹងការធ្វើសេចក្តីសម្រេចចិត្តជាតិនិងអន្តរជាតិនៅក្នុងការិយាល័យរដ្ឋបាលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ **វ៉អែន ហេនដែល**

# សាលាក្តីខ្មែរក្រហមមានសារសំខាន់ចំពោះសហគមន៍អន្តរជាតិ

បន្ទាប់ពីមួយទសវត្សរ៍នៃកិច្ចចរចាដ៏រំដើបរំជួលដែលជាញឹកញាប់ទទួលបរាជ័យ ប៉ុន្តែវាមានសារសំខាន់សម្រាប់ការចងចាំដែលជំរុញឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបច្ចុប្បន្ន ។ មេធាវីនិងចៅក្រមកំពុងតែស្វែងរកយុត្តិធម៌ជូនប្រជាជនកម្ពុជាប្រមាណ ១,៧លាននាក់ ដែលបានស្លាប់ក្នុងរបបខ្មែរក្រហមដែលគ្រប់គ្រងអំណាចពីខែមេសា ឆ្នាំ១៩៧៥ រហូតដល់ខែមករា ឆ្នាំ១៩៧៩ ។ ៣០ឆ្នាំមកហើយ តាំងពីវាលពិឃាតក្នុងប្រទេសកម្ពុជាដែលបង្កើតឡើងដោយរបបប៉ុលពតបណ្តាលឲ្យមនុស្សជាច្រើនស្លាប់បាត់បង់ជីវិតនិងប្រើប្រាស់ប្រជាជនខ្មែររាប់លាននាក់ទៀតប្រៀបដូចជាទាសករ ។ ហេតុអ្វីបានជាសហគមន៍អន្តរជាតិគួរតែយកចិត្តទុកដាក់ចំពោះអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានេះ ជាពិសេសពេលវេលាបានកន្លងហួសអស់ជាច្រើនឆ្នាំហើយមានតែមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមមួយចំនួនតូចប៉ុណ្ណោះដែលនៅរស់រានមានជីវិត និងក្នុងពេលមួយដែលប្រទេសកម្ពុជាស្ថិតក្នុងសន្តិភាពបែបនេះ? ហេតុអ្វីបានជាសហគមន៍អន្តរជាតិចំណាយលើតុលាការកូនកាត់ដែលប្រកបដោយការប្រថុយប្រថាននិងលទ្ធផលមិនច្បាស់លាស់បែបនេះ? ចម្លើយគឺស្ថិតនៅលើការខិតខំប្រឹងប្រែងឥតឈប់ឈរដើម្បីបំបាត់ចោលនូវនិទ្ទណ្ឌភាពឧក្រិដ្ឋកម្មដ៏ឃោរឃៅ (អំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម) ដើម្បីឲ្យយើងដឹងពីអតីតកាល បច្ចុប្បន្នកាល ហើយនឹងមិនមានប៉ះពាល់ដល់អនាគតកាល ។

មិត្តរួមការងាររបស់ខ្ញុំនៅភ្នំពេញ លោក ឆាំង យុ ជានាយកមជ្ឈមណ្ឌលឯកសារកម្ពុជាបានសរសេរអត្ថបទអមជាមួយគ្នាដែលពន្យល់អំពីសារសំខាន់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាចំពោះប្រជាជនកម្ពុជា ។ នៅក្នុងអត្ថបទនេះខ្ញុំអធិប្បាយដោយសង្ខេបពីហេតុផលដែលអង្គជំនុំជម្រះវិសាមញ្ញគួរតែមានសារសំខាន់ចំពោះសហគមន៍អន្តរជាតិ ។ ដោយមានឧបសគ្គរបស់តុលាការផ្សេងទៀតនៅក្នុងឧក្រិដ្ឋកម្មដ៏ឃោរឃៅក្នុងពិភពលោករួមទាំងសាលាក្តីឧក្រិដ្ឋកម្មសង្គ្រាមជាច្រើនផ្សេងទៀតទាមទារឲ្យមានការឧបត្ថម្ភខាងថវិកានិងនយោបាយពីជាតិផ្សេងៗ ។ តើសហគមន៍

អន្តរជាតិអាចពេញចិត្តនិងបន្តជំនួយរបស់ខ្លួនដល់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែរឬទេ? ខ្ញុំនឹងផ្តល់ចម្លើយខ្លះទៅនឹងសំណួរនេះ ៖

នៅអំឡុងពេលកិច្ចចរចាដែលចាប់ផ្តើមតាំងពីឆ្នាំ១៩៩៧ ខ្ញុំតែងតែប្រឈមមុខនឹងទស្សនៈអវិជ្ជមានថា ការស្វែងរកយុត្តិធម៌ចំពោះឧក្រិដ្ឋកម្មឃោរឃៅនៅក្នុងរបបប៉ុលពតគឺជាការព្យាយាមមួយទាំងអស់សង្ឃឹម ខ្ញុំរំឭកដល់មនុស្សដែលមើលឃើញតែរឿងអវិជ្ជមាន (មានមនុស្សបែបនេះច្រើនណាស់) ថា យើងមានការទទួលខុសត្រូវខ្ពស់ចំពោះមនុស្សដែលបានស្លាប់នៅក្នុងប្រទេសកម្ពុជាដោយនាំយកជនដៃដល់ជាន់ខ្ពស់ទៅកាត់ទោស ។ ខ្ញុំមិនអាចមានសតិសម្បជញ្ញៈចរចានឹងការបង្កើតសាលាក្តីសម្រាប់ជម្លោះនៅបាល់កង់នៅដើមទសវត្សរ៍ឆ្នាំ១៩៩០ អំពើប្រល័យពូជសាសន៍នៅរ៉្វាន់ដាឆ្នាំ១៩៩៤ អំពីអំណាចឃោរឃៅនៅចុងទសវត្សរ៍ឆ្នាំ១៩៩០ ឬក៏តុលាការឧក្រិដ្ឋកម្មអន្តរជាតិជាអចិន្ត្រៃយ៍ដោយមិនអើពើនឹងអ្វីដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជាកាលពីចុងទសវត្សរ៍ឆ្នាំ១៩៧០ទេ ។ សហគមន៍អន្តរជាតិគួរតែកុំបោះបង់ចោលឧបសគ្គខាងប្រព័ន្ធតុលាការដែលកំពុងកើតចេញពីការរំលោភបំពានយ៉ាងធ្ងន់ធ្ងរមកលើប្រជាជនខ្មែរ នៅខណៈពេលដែលពិភពលោកមិនបានយកចិត្តទុកដាក់បន្ទាប់ពីសោកនាដកម្មសង្គ្រាមនៅវៀតណាម ។ ដោយឡែកសម្រាប់ជនជាតិអាមេរិកការទម្លាក់គ្រាប់បែកដោយសម្ងាត់មកលើកម្ពុជានៅអំឡុងពេលកាន់អំណាចរបស់លោកប្រធានាធិបតី និចសុន ធ្វើឲ្យប្រទេសនោះគ្មានស្ថិរភាព ធ្វើឲ្យខ្មែរក្រហមបានកំពុងតែបង្កើនអំណាច រឿងនេះធ្វើឲ្យយើងគ្មានជម្រើសសីលធម៌ ប៉ុន្តែយើងធ្វើការប្រឹងប្រែងគ្រប់បែបយ៉ាងដើម្បីសម្រេចបាននូវវិធានការដាក់ឲ្យមានការទទួលខុសត្រូវចំពោះការសម្លាប់រង្គាលដែលបានកើតមាន ។ ប្រសិនបើសារដែលគ្មានប្រយោជន៍ បន្ទាប់ពីសង្គ្រាមលោកលើកទីពីរ «មិនកើតឡើងម្តងទៀត» នោះមេរៀនសំខាន់សម្រាប់ប្រជាជនខ្មែរដែលអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាសម្តែងចំពោះប្រជាជនកម្ពុជានោះគឺ «មិនអាចបំភ្លេចបាន» ។ ប្រហែលជាគោលបំណងសំខាន់ជាងគេរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាចេញពីទស្សនៈអន្តរជាតិនោះគឺចង្អុលបង្ហាញ និងជំរុញឲ្យអង្គជំនុំជម្រះបន្តដើរតួនាទីស្របទៅនឹងច្បាប់ដែលធ្វើរួចនេះដើម្បីធានាថានិទ្ទណ្ឌភាពនឹងមិនមានចំពោះមេដឹកនាំខ្មែរក្រហមឬអ្នកដែលត្រូវទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដ៏ឃោរឃៅនៅក្នុងរបបប៉ុលពតនោះទេ ។ ការពិតមួយដែលផ្តល់សញ្ញាណដ៏មានប្រសិទ្ធភាពទៅកាន់ទូទាំងពិភពលោកដែលសហគមន៍អន្តរជាតិយកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះការទទួលខុសត្រូវនៃឧក្រិដ្ឋកម្មដ៏សាហាវដែលយុត្តិធម៌នៅតែមានរហូត ។ ប្រសិនបើអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមានការកាត់ក្តីដ៏យុត្តិធម៌ស្របតាមដំណើរការច្បាប់ត្រឹមត្រូវរបស់បទដ្ឋានអន្តរជាតិ នោះការកាត់ទោសដោយមានសុភនិច្ឆ័យទៅលើភាពគ្មានទោសឬក៏មានទោសនឹងលេចឡើងជាសញ្ញានៃក្តីសង្ឃឹមសម្រាប់ជនរងគ្រោះទាំងអស់នៃអំពើបំពានទៅលើមនុស្សជាតិ ។ គេនឹងយល់ថា ប្រសិនបើយុត្តិធម៌អាចកាត់សេចក្តីបាននៅក្នុងប្រទេសកម្ពុជានៅរយៈពេលពាទសវត្សរ៍បន្ទាប់ពីវិនាសកម្មនោះ ប្រជាជនកម្ពុជានឹងមានសង្ឃឹមថា ខ្លួនក៏អាចបង្កើតឬស្វែងរកតុលាការដែលផ្តល់យុត្តិធម៌ពិតដល់ខ្លួនមិនខាន ។ ប្រសិនបើការកាត់ទោសមិនដំណើរការក្នុងពេលភ្លាមៗ ក្រោយមកក៏នឹងមានការដាក់ទោសដែរ ។

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គឺជាតុលាការដែលមានភាពប៉ិនប្រសប់តែមួយគត់ដែលសហគមន៍អន្តរជាតិនឹងផ្តោតទៅលើ ថាតើតុលាការនេះសម្រេចបានតាមគោលការណ៍និងសុចរិតភាពឬគ្រាន់តែធ្វើតាមឥទ្ធិពលនិងការរៀបចំខាងនយោបាយ ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមិនមែនជាតុលាការឧក្រិដ្ឋកម្មអន្តរជាតិ ប៉ុន្តែជាតុលាការពិសេសក្នុងស្រុករបស់កម្ពុជាដែលមានការសហការពីអង្គការសហប្រជាជាតិគោរពតាមសន្ធិសញ្ញាដែលយកច្បាប់អន្តរជាតិ និងដំណើរការច្បាប់ត្រឹមត្រូវរបស់បទដ្ឋានអន្តរជាតិ តុលាការពិសេសនៅសេរ៉ាឡេអូនដែលបង្កើតឡើងដោយសន្ធិសញ្ញារវាងរដ្ឋាភិបាលរបស់សេរ៉ាឡេអូននិងអង្គការសហប្រជាជាតិ គឺជាតុលាការឧក្រិដ្ឋកម្មអន្តរជាតិ រីឯអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវបានគាត់តែងខុសប្លែកពីគ្នាគឺជាតុលាការជាតិមួយមាន «ភាពវិសាមញ្ញ» មានលក្ខណៈជាអន្តរជាតិ ។ អ្នកសង្កេតការណ៍អន្តរជាតិជាច្រើននឹងមើលព្រមទាំងសង្កេតអំពីដំណើរនៃកិច្ចការងារស៊ើបអង្កេតរាល់

ថ្ងៃរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ការកាត់ទោសការពិភាក្សាច្បាប់ និងការដាក់ទោសដោយមិនគ្រប់ដណ្តប់ដោយបញ្ហានយោបាយដែលមានក្នុងសង្គមកម្ពុជា ។ វាគ្មានការសង្ស័យថាអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាគឺជាការធ្វើពិសោធន៍ ប៉ុន្តែជាជម្រើសមួយដែលពុំអាចមានជម្រើសផ្សេងពីនេះក្នុងការផ្លាស់ប្តូរបន្ទាប់ពីកិច្ចចរចាអស់រយៈពេលជាច្រើនឆ្នាំ ។ ប្រសិនបើអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាអាចសម្រេចបាននូវយុត្តិធម៌ដែលគួរឲ្យជឿទុកចិត្តបានក្នុងតុលាការកម្ពុជានោះវានឹងបង្ហាញថា យុត្តិធម៌អន្តរជាតិ អាចសាយភាយនៅក្នុងចំណោមតុលាការជាតិនិងអន្តរជាតិ ជាមួយនឹងការទុកចិត្តខ្លាំងដែលយើងគួរតែអាចធ្វើការស្រមើស្រមៃឃើញតាំងពីទសវត្សរ៍មុន ។

ជាទីបញ្ចប់ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាគឺជាការសាកល្បងដ៏សំខាន់មួយរបស់អង្គការសហប្រជាជាតិដែលជាដៃគូយ៉ាងជិតស្និទ្ធជាមួយរាជរដ្ឋាភិបាលកម្ពុជាក្នុងការគ្រប់គ្រងបុគ្គលិក ថវិកា និងការគ្រប់គ្រងអង្គជំនុំជម្រះ ។ សហគមន៍អន្តរជាតិមិនចង់បានអ្វីទាំងអស់ពីរាជរដ្ឋាភិបាលកម្ពុជា ក្រៅពីចង់ឲ្យអង្គជំនុំជម្រះវិសាញ្ញក្នុងតុលាការកម្ពុជា និងធ្វើតាមបទដ្ឋានខ្ពស់ដែលតម្រូវដោយមន្ត្រីនិយម ។ តើអង្គការសហប្រជាជាតិរក្សាទំនាក់ទំនងដ៏ល្អជាមួយកម្ពុជាដោយរបៀបណាដែលក្នុងទំនាក់ទំនងនេះត្រូវការភាពអត់ធ្មត់ សេចក្តីព្យាយាម ទំនាក់ទំនងការទូតនិងការការពារនីតិរដ្ឋ ទំនាក់ទំនងនេះនឹងនិយាយច្រើនអំពីអង្គការអន្តរជាតិ ព្រមទាំងសមត្ថភាពដើម្បីគ្រប់គ្រងយន្តការប្លែក តែសំខាន់របស់យុត្តិធម៌នៅក្នុងស្រុកនិងអន្តរជាតិ ។ គេហទំព័រនៃអ្នកឃ្លាំមើលតុលាការកម្ពុជា (www.cambodiatribunal.org) ក៏ជាសកម្មភាពផ្សេងមួយរបស់អន្តរជាតិតែមួយ ។ គេហទំព័រនេះនឹងចាក់ផ្សាយអំពីដំណើរការកាត់ទោសនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងសម្ភាសពីប្រតិកម្មរបស់ប្រជាជាតិខ្មែរចំពោះសាលាក្តី ។ ដោយនាំយកការកាត់ទោសផ្តល់ជូនប្រជាជនបរទេសនិងជំរុញប្រជាជនកម្ពុជាឲ្យចេះប្រើអ៊ីនធឺណែតកំពុងតែកើនឡើង ។ អ្នកឃ្លាំមើលតុលាការកម្ពុជាមានបំណងដើម្បីបញ្ចប់នូវនិទ្ទណ្ឌភាពតាមរយៈការអប់រំនិងការយល់ដឹងពីអំពើដ៏ឃោរឃៅដែលកើតឡើងពីអតីតកាល ។ គោលបំណងនេះដំណើរការទៅបាន លុះត្រាតែមនុស្សជំនាន់ក្រោយទូទាំងពិភពលោកមិនបំភ្លេចអំពីអ្វីដែលបានកើតឡើងនៅកម្ពុជា ។ **ដេវីត សេហ្វ័រ**



ទិដ្ឋភាពក្នុងអគារសវនាការ

# ការកែប្រែរចនាសម្ព័ន្ធតុលាការក្នុងកាត់ៈ
# កំណែទម្រង់គតិយុត្តិផ្នែកព្រហ្មទណ្ឌជាតិ និងការផ្តល់អំណាចក្នុងតំបន់

***(តពីលេខមុន)***

*ដូចគ្នាទៅនឹងចៅក្រមទាំងនោះដែរ បុគ្គលិកដែលនៅសល់ទាំងប៉ុន្មានសុទ្ធសឹងតែមានសមត្ថភាព ។ ជាពិសេសអយ្យការអាចបង្កើតជាយុទ្ធសាស្ត្របានយ៉ាងច្បាស់លាស់និងមានលំដាប់លំដោយត្រឹមត្រូវ ។ នៅពេលនោះ សាលាក្តីពិសេសអន្តរជាតិ ។ សាលាក្តីព្រហ្មទណ្ឌអន្តរជាតិពិសេសបានសម្រេចធ្វើការកាត់ទោស សាដាម ហ៊ូសេន និងអតីតមេដឹកនាំរបប* Ba'ath *ផ្សេងទៀតតាមលំដាប់សំណុំរឿងដោយផ្តោតទៅលើហេតុការណ៍ជាក់លាក់មួយៗ ជាជាងធ្វើការកាត់ទោសរួមគ្នាធំមួយដូចក្នុងករណី មីឡូសីវិក ដែលបានធ្វើឡើងនៅឯសាលាក្តីព្រហ្មទណ្ឌអន្តរជាតិនៃប្រទេសយូហ្គោស្លាវី ។ ដោយការសម្រេចចាប់ផ្តើមដោះស្រាយករណីតូចៗនិងករណីសាមញ្ញ អយ្យការនឹងអាចផ្តោតបានយ៉ាងទូលំទូលាយទៅលើការជំទាស់ផ្នែកច្បាប់ចំពោះដំណើរការប្តឹងរបស់ចុងចោទដែលនេះអាចបង្ការមិនឲ្យចុងចោទប្តឹងតបតមកវិញចំពោះបញ្ហាដ៏ស្មុគស្មាញទាំងនេះ ដោយសារតែការសម្រេចជាចុងក្រោយរបស់តុលាការ ។ តាមការប៉ាន់ប្រមាណឃើញថា មានចំនួនប្រហែលដប់ពីរករណី សម្រាប់ការនាំខ្លួនសាដាម ទៅកាត់ទោសជាមួយនឹងមេដឹកនាំកំពូល* Ba'athists *មួយក្រុមតូចផ្សេងទៀតបាន ដែលក្នុងនោះមានករណី* al-Dujail *ដែលមាន* Shi'a *ចំនួន១៤៣នាក់ទទួលរងគ្រោះអំពើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងដែលត្រូវបានសម្លាប់នៅក្នុងឆ្នាំ១៩៨២ ដោយការប្រើឧស្ម័នពុលសម្លាប់ជនជាតិឃឺតក្នុងទីក្រុង* Halabja *នាឆ្នាំ១៩៨៨ យុទ្ធនាការប្រឆាំងនឹងពួកឃឺតក្នុងរវាងខែកុម្ភៈ និងខែកញ្ញា ឆ្នាំ១៩៨៨ ការវាយប្រហារលើជនជាតិភាគតិចក្នុងគៀរគុក ការសម្លាប់រង្គាលលើពួកមូស្លីមស៊ីអាយ ក្រោយពីបដិវត្តន៍ឆ្នាំ១៩៩១ ការឈ្លានពានប្រទេសគុយវ៉ែតក្នុងឆ្នាំ១៩៩០ សង្គ្រាមអ៊ីរ៉ង់-អ៊ីរ៉ាក់ឆ្នាំ១៩៨០-៨៨ ការវាយប្រហារជាយថាក្រមទៅលើ* Marsh Arabs *ការសម្លាប់និងការបណ្តេញចេញពួក* U'Faili Kurds *ព្រមទាំងការរំលាយក្រុមសាសនានិងគណបក្សនយោបាយផង ។*

*តាំងពីពេលចាប់ផ្តើម សាលាក្តីត្រូវដោះស្រាយបញ្ហាលំបាកដ៏គួរឲ្យបារម្ភច្រើន ។ ជាក់ស្តែង តុលាការបានពើបប្រទះនឹងបញ្ហាខាងផ្នែកភាសា ដែលបញ្ហានេះមួយផ្នែកកើតឡើងដោយសារកង្វះអ្នកចេះនិយាយភាសាអារ៉ាប់នៅក្នុងការិយាល័យភ្ជាប់ទំនាក់ទំនងឧក្រិដ្ឋកម្មទៅនឹងរបបដែលបានអនុវត្តនិងកំពុងអនុវត្តប្រតិបត្តិការជាច្រើនសម្រាប់សាលាក្តីពិសេសអន្តរជាតិ ។ លើសពីនេះទៅទៀត សាលាក្តីពិសេសអន្តរជាតិបានពើបប្រទះនឹងទំនាស់ទាក់ទិនទៅនឹងការបញ្ចូលប្រព័ន្ធប្រតិបក្សបែបអាមេរិកជាមួយនឹងប្រព័ន្ធស៊ីបស្លូររបស់អ៊ីរ៉ាក់ ព្រមទាំងត្រូវដោះស្រាយបញ្ហាជ្រៀតជ្រែកនិងនយោបាយកម្មជ្រុលរបស់អាមេរិកផង ។ កង្វល់មួយចំនួនទៀតគឺ បុគ្គលិកដែលមិនបានទទួលបណ្តុះបណ្តាលជាពិសេសចៅក្រមដែលមានប្រវត្តិជាមន្ត្រីតុលាការតូចតាចធ្វើឲ្យអ្នកទាំងនោះមិនបានត្រៀមខ្លួនជាមុនដើម្បីដោះស្រាយជាមួយសវនាការដែលមានទ្រង់ទ្រាយធំ ។ ទោះបីជាបញ្ហាដែលបានរៀបរាប់ខាងលើសំខាន់យ៉ាងណាក៏ដោយ ក៏ឧបសគ្គដ៏ចម្បងៗដែលបានបង្អាក់ដំណើរដ៏រលូនរបស់សាលាក្តីពិសេសអន្តរជាតិបានស្តែងឡើងយ៉ាងច្បាស់ថា ជាបញ្ហាធម្មនុញ្ញភាព ការជ្រៀតជ្រែកខាងនយោបាយនិងវិបត្តិសន្តិសុខ ។*

*ធម្មនុញ្ញភាពរបស់សាលាក្តីពិសេសអន្តរជាតិ នៅតែពុំមានភាពច្បាស់លាស់ក្នុងរយៈពេលមួយដោយសារមានការផ្លាស់ប្តូរផ្នែកនយោបាយទ្រង់ទ្រាយធំក្នុងប្រទេសអ៊ីរ៉ាក់ ដែលទាំងនេះនាំឲ្យកើតមានសំណួរថា តើអនាគតរដ្ឋាភិបាលអ៊ីរ៉ាក់នឹងសម្រេចដោះស្រាយយ៉ាងណាចំពោះសាលាក្តីពិសេសអន្តរជាតិព្រមទាំងថាតើអ្នកទាំងនេះត្រូវប្រឈមមុខខ្លាំងយ៉ាងណាដើម្បីដោះស្រាយបញ្ហាដែលអាមេរិកកាន់កាប់ដំណើរការកាត់ក្តីនានា ។ បញ្ហានៃការរំលោភបំពានទៅលើច្បាប់ការងារអន្តរជាតិរបស់អាមេរិកនិង*

សារជាតិនៃបញ្ហាជាទូទៅរបស់ TAL ធ្វើឲ្យមានឡើងនូវសំណួរជាច្រើនអំពីភាពស្របច្បាប់របស់តុលាការក្នុងពេលខ្លះ ។ អ្នកជំនាញជាច្រើននាក់បានធ្វើការជជែកវែកញែកថា សាលាក្តីអ៊ីរ៉ាក់អាចចាត់ទុកថាជាស្ថាប័នមិនស្របច្បាប់មួយពីព្រោះ ១) ទាក់ទិនទៅនឹងការរំលោភបំពានច្បាប់អន្តរជាតិ ការលុកលុយរបស់អាមេរិក-អង់គ្លេសមកក្នុងប្រទេសអ៊ីរ៉ាក់ គឺជាការកាន់កាប់មួយមិនស្របច្បាប់ ដោយផ្អែកទៅលើការប្រើប្រាស់កម្លាំងខុសច្បាប់ប្រឆាំងនឹងបូរណភាពដែនដីនិងឯករាជ្យភាពផ្នែកនយោបាយរបស់ប្រទេសមានអធិបតេយ្យភាព និង ២) មានការប្រើប្រាស់កម្លាំងជាបន្តបន្ទាប់ប្រឆាំងនឹងប្រជាជនអ៊ីរ៉ាក់ និងមានការកាន់កាប់ផ្នែកធំៗនៃប្រទេសអ៊ីរ៉ាក់ ។ យោបល់ទាំងនេះគឺផ្អែកលើអនុសញ្ញាទីក្រុងហ្សឺណែវលើកទីបួនដែលចែងថា អំណាចកាន់កាប់អាចនឹងមិនអាចរំលាយចោលស្ថាប័នតុលាការរបស់ប្រទេសមួយហើយបង្កើតស្ថាប័នតុលាការផ្ទាល់ខ្លួនឡើយ លើកលែងតែក្នុងស្ថានភាពមួយចាំបាច់ ។ ដូច្នេះ តាមការបកស្រាយយ៉ាងខ្លីមួយនូវខ្លឹមសារអនុសញ្ញាទីក្រុងហ្សឺណែវអាចបង្ហាញថា សាលាក្តីពិសេសអន្តរជាតិអ៊ីរ៉ាក់ ជាស្ថាប័នតុលាការមួយមិនស្របច្បាប់យោងទៅតាមតួនាទីរបស់តុលាការនេះ ដូចជាការបង្កើតឲ្យមានអំណាចកាន់កាប់មួយ ដោយពុំមានហេតុផលផ្នែកយោធាឬភាពបន្ទាន់ខាងមនុស្សធម៌ ។

ការកែប្រែដែលធ្វើឡើងចំពោះសាលាក្តីពិសេសអន្តរជាតិនិងការផ្លាស់ប្តូរទម្រង់របស់តុលាការនេះឲ្យទៅជាសាលាក្តីព្រហ្មទណ្ឌពិសេសអាចត្រូវចាត់ទុកថាបានដោះស្រាយនូវបញ្ហាភាពស្របច្បាប់មួយចំនួន ។ ការសម្រេចចិត្តឲ្យមានរដ្ឋាភិបាលបោះឆ្នោតនិងរដ្ឋាភិបាលមិនបោះឆ្នោតរបស់អ៊ីរ៉ាក់ក្នុងចំណុចខ្លះអាចកែតម្រូវបញ្ហានានាដែលមានប្រភពមកពីការបង្កើតដំបូងនូវកម្លាំងកាន់កាប់របស់អាមេរិក ។ ការកែប្រែសំខាន់ៗរួមមានការអនុញ្ញាតជាមុនរបស់ក្រុមប្រឹក្សាភិបាលរបស់ប្រទេសអ៊ីរ៉ាក់ ទោះបីជាពុំមានការបោះឆ្នោតជ្រើសរើសក៏ដោយ ហើយកាន់តែច្បាស់លាស់ទៅទៀតនោះគឺការប្រកាសរបស់ក្រុមប្រឹក្សាភិបាលរបស់ប្រទេសអ៊ីរ៉ាក់ នូវច្បាប់របស់សាលាក្តីពិសេសរបស់អ៊ីរ៉ាក់នាថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០០៣ ។ ការអភិវឌ្ឍច្បាប់ជាគន្លឹះមួយទៀតគឺមាត្រា៤៨នៃច្បាប់រដ្ឋបាលសម្រាប់ប្រទេសអ៊ីរ៉ាក់ក្នុងអំឡុងពេលអន្តរកាល (រដ្ឋធម្មនុញ្ញបណ្តោះអាសន្នរបស់ប្រទេសអ៊ីរ៉ាក់) ដែលសង្កត់បន្ថែមលើច្បាប់ឆ្នាំ២០០៣ ថាជាការកំណត់ជាពិសេសនូវនីតិវិធីនិងយុត្តាធិការរបស់សាលាក្តីពិសេសអន្តរជាតិ ។ នាថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៥ រដ្ឋសភាជាតិ អន្តរកាលបានចេញច្បាប់ដែលពិនិត្យរួចរាល់មួយសម្រាប់សាលាក្តីពិសេសអន្តរជាតិ ដែលច្បាប់នេះបានលុបចោលទាំងស្រុងនូវច្បាប់ឆ្នាំ២០០៣ ដោយបង្ហាញថាសាលាក្តីពិសេសអន្តរជាតិ គឺជាឆន្ទៈរបស់រដ្ឋាភិបាលជ្រើសតាំងដោយការបោះឆ្នោតរបស់អ៊ីរ៉ាក់និងជាការផ្តល់ភាពស្របច្បាប់ដល់ស្ថាប័ននេះ ។ តាមរយៈការបោះឆ្នោតប្តូរឈ្មោះតុលាការ និងប្តូរការអនុវត្តមួយចំនួនដើម្បីឲ្យកាន់តែមានភាពស្របគ្នាទៅនឹងប្រព័ន្ធតុលាការផ្សេងទៀតរបស់ប្រទេស សភាជាតិរបស់អ៊ីរ៉ាក់បានធ្វើឲ្យទស្សនៈដែលថាតុលាការនេះមិនមានភាពស្របច្បាប់បង្កើតឲ្យមានអំណាចកាន់កាប់មួយដោយរំលោភបំពានទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ។

ទោះបីជាភាពស្របច្បាប់មួយចំនួនធំរបស់តុលាការត្រូវបានដោះស្រាយមួយផ្នែកដោយរដ្ឋាភិបាលអ៊ីរ៉ាក់ដូចដែលបានពិពណ៌នាខាងលើក៏ដោយ ហើយទោះបីជាយុទ្ធសាស្ត្រនៃដំណើរការក្តីមើលទៅឃើញថា មានលក្ខណៈត្រឹមត្រូវជាច្រើនចំណុចក៏ដោយ ក៏តុលាការអ៊ីរ៉ាក់ខ្លួនឯង បានបង្ហាញឲ្យឃើញថាខ្លួនងាយនឹងទទួលរងគ្រោះពីអំពើហិង្សា ការគំរាមកំហែង និងការជ្រៀតជ្រែកពីសំណាក់ក្រុមអ្នកទទួលផលប្រយោជន៍ផ្នែកនយោបាយដែលមានឥទ្ធិពលនានា ។

ការជ្រៀតជ្រែកផ្នែកនយោបាយនៅតែជាបញ្ហាចំពោះមុខដ៏ចម្បងមួយសម្រាប់តុលាការ ។ ឥទ្ធិពលដែលចេះតែបន្តទៅមុខ និងជាក់ស្តែង អំណាចលើសលប់របស់បុគ្គលិកអាមេរិកតាមរយៈការិយាល័យភ្ជាប់ទំនាក់ទំនងខុក្រិដ្ឋកម្មទៅនឹងរបបដែលការិយាល័យនេះមាន *Greg Kehoe* ជាប្រធាន បានបង្កើតឲ្យមានមន្ទិលមិនល្អមួយចំនួនទាក់ទិនទៅនឹងការជ្រៀតជ្រែករបស់សហរដ្ឋអាមេរិកដើម្បីបុព្វហេតុនយោបាយនៅក្នុងការកាត់ក្តីទាំងនេះ ។

ជំហានដំបូងៗរបស់តុលាការ បានស្តែងឲ្យឃើញច្បាប់របស់សហរដ្ឋអាមេរិក ឧទាហរណ៍ដូចជានៅក្នុងករណីចេញដីកាចាប់ខ្លួន

សាដាម ហ៊ូសេន ដែលការគ្រោងទុកនាថ្ងៃទី០១ ខែកក្កដា ២០០៤។ ទោះបីជាចៅក្រមអ៊ីរ៉ាក់ ចៅក្រមស៊ើបអង្កេត និងរដ្ឋអាជ្ញានៃសាលាក្តីពិសេសអន្តរជាតិបានកាន់កាប់លើដំណើរការក្តីតាមលំដាប់លំដោយនៃដំណើរនេះក៏ដោយ ក៏ឥទ្ធិពលរបស់អាមេរិកនៅតែលេចឡើងជារូបរាងយ៉ាងច្បាស់តាមរយៈតួនាទីជួយជ្រោមជ្រែងរបស់ការិយាល័យ Regime Crimes Liaison Office (RCLO) ដែលបានប្រើប្រាស់ឥទ្ធិពលដ៏ច្រើនសន្ធាប់សន្ធាប់ជាងក្រុមជំនួយបច្ចេកទេសធម្មតាព្រមទាំង(បាន) ចូលរួមយ៉ាងសកម្មស្ទើរតែក្នុងគ្រប់កិច្ចការទាំងអស់របស់សាលាក្តីនេះ ដែលក្នុងនោះចាប់ផ្តើមពីការប្រមូលភស្តុតាងរហូតដល់ការកសាងហេដ្ឋារចនាសម្ព័ន្ធ។

ដូចគ្នានេះដែរ រូបភាពនៃការជ្រៀតជ្រែករបស់រដ្ឋាភិបាលអ៊ីរ៉ាក់ចូលទៅក្នុងឯករាជ្យភាពរបស់ចៅក្រមអាចគំរាមកំហែងដល់តម្លាភាពនៃដំណើរការក្តី ហើយអាចឃើញថា ជាការរំលោភបំពានលើឯករាជ្យភាពរបស់តុលាការផងដែរ។ ជាពិសេសការរិះគន់ជាសាធារណៈដោយមន្ត្រីជាន់ខ្ពស់របស់រដ្ឋាភិបាលអ៊ីរ៉ាក់និងការទាមទាររបស់សមាជិកសភាគណបក្សកាន់អំណាចឲ្យមានការបណ្តេញចៅក្រមអធិបតី Rizgar Amin ចេញពីមុខតំណែងដែលជាហេតុនាំឲ្យចៅក្រម Amin លាលែងចេញពីតំណែង។ បញ្ហាជាបន្ទាប់មកទៀតដែលកើតឡើងចំពោះអ្នកជំនួសតំណែងរបស់ចៅក្រម Amin គឺចៅក្រម Saeed al-Hammashi ដែលបង្កឡើងដោយគណៈកម្មការ De-Ba'athification របស់អ៊ីរ៉ាក់ បានធ្វើឲ្យសណ្ឋានរបស់តុលាការប្រែប្រួលទៅតាមការជ្រៀតជ្រែកផ្នែកនយោបាយ។ សភាពទាំងនេះអាចមើលឃើញជាពិសេសតាមរយៈសំណើសុំរបស់គណៈកម្មការ De-Ba'athification នាខែកក្កដា ឆ្នាំ២០០៥ ឲ្យបណ្តេញចៅក្រមជាងម្ភៃរូបនិងបុគ្គលិកផ្សេងទៀតរបស់តុលាការចេញពីតំណែងដោយលើកយកអតីតសមាជិកភាពរបស់គណៈបក្ស Ba'ath មកធ្វើជាប្រធានបទចោទប្រកាន់។ ការបណ្តេញចេញនេះត្រូវបានរារាំងដោយកិច្ចអន្តរាគមន៍របស់ប្រធានាធិបតី អ៊ីរ៉ាក់ ហ្សាឡាល តាឡា តាឡាបានី និងនាយករដ្ឋមន្ត្រីអ៊ីរ៉ាក់ អ៊ីប្រាហ៊ីម អាល់ហ្សាហ្វារី តែប៉ុណ្ណោះ។

តុលាការក៏បានទទួលរងនូវការលំបាកផ្នែកសន្តិសុខដែរ ដោយហេតុថាសង្គ្រាមនៅក្នុងប្រទេសអ៊ីរ៉ាក់ ធ្វើឲ្យការស៊ើបអង្កេតនិងការកាត់ក្តីពោរពេញទៅដោយគ្រោះថ្នាក់។ យោងតាមប្រសាសន៍របស់លោក សាលៀម ចាឡាប៊ី អគ្គនាយកទីមួយនៃសាលាក្តីពិសេសអន្តរជាតិបានឲ្យដឹងថា សាលាក្តីបានទទួលរងការលំបាកដោយសារស្ថានភាពអស្ថិរភាពផ្នែកសន្តិសុខជាមូលដ្ឋាននៅក្នុងប្រទេសអ៊ីរ៉ាក់តាំងពីដំបូង។ មានការចាត់វិធានការសន្តិសុខយ៉ាងល្អិតល្អន់ដើម្បីការពារចៅក្រម រដ្ឋអាជ្ញា និងសាក្សី នៅក្នុងការកាត់ក្តី សាដាម ដែលក្នុងនោះមានដូចជាលាក់ឈ្មោះដោយសម្ងាត់ឲ្យបានយូរតាមលទ្ធភាពដែលអាចធ្វើបាន។ បុគ្គលិកនិងចៅក្រមជាច្រើនក្នុងដំណើរការក្តីនេះរស់នៅក្រោមការឃុំខ្លួនយ៉ាងជាក់ស្តែងទុកក្នុងផ្ទះមួយនៅក្នុងតំបន់បៃតងដែលជាកន្លែងតាំងទីបន្ទប់តុលាការ ដែលនេះធ្វើឲ្យមានចំណាប់អារម្មណ៍បន្ថែមទៀតទៅលើការដឹកនាំតុលាការដោយកម្លាំងកាន់កាប់របស់សហរដ្ឋអាមេរិក។ ជាងនេះទៅទៀត បុគ្គលិកនិងមេធាវីការពារក្តីមួយចំនួននៅក្នុងតុលាការអ៊ីរ៉ាក់ត្រូវបានធ្វើឃាត។ បន្ទាប់ពីមានការសម្លាប់មេធាវីការពារក្តី Saadoun al-Janabi nig Adel al-Zubeidi ខាងចុងចោទបានទាមទារពីសាលាក្តីឲ្យមាន «អន្តរាគមន៍ជាអន្តរជាតិដោយផ្ទាល់ដែលមានលក្ខណៈអព្យាក្រឹតនិងអាចធានាបាន» នូវសន្តិសុខ ព្រមទាំងផ្អាកទំនាក់ទំនងជាមួយនឹងតុលាការរហូតសន្តិសុខរបស់អ្នកទាំងនោះត្រូវបានធានា ទោះបីជាខាងចុងចោទបដិសេធទទួលយកការផ្លាស់ប្តូរការកាត់ក្តីទៅកន្លែងផ្សេងឬរស់នៅក្នុងតំបន់បៃតងដែលមានការការពារយ៉ាងតឹងរ៉ឹងក្នុងអំឡុងពេលកាត់ក្តីក៏ដោយ។

នៅទីបញ្ចប់ តុលាការអ៊ីរ៉ាក់ គឺជាការចេញដំណើរដ៏គួរឲ្យចាប់អារម្មណ៍មួយពីគំរូដើមនៃតុលាការកូនកាត់។ ជាតុលាការជាតិអ៊ីរ៉ាក់ដែលនឹងអនុវត្តច្បាប់ក្នុងស្រុកនិងច្បាប់អន្តរជាតិ ក្រោមឥទ្ធិពលដ៏ខ្លាំងក្លារបស់សហរដ្ឋអាមេរិក ប៉ុន្តែស្ទើរតែគ្មានឥទ្ធិពលពីអ្នកចូលរួម ឬស្ថាប័នអន្តរជាតិឡើយ ទាំងអស់គឺស្ថិតនៅក្នុងបរិបទមួយដ៏គ្រោះថ្នាក់និងអស្ថិរភាព។

### ៣) អង្គជំនុំជម្រះក្តីឧក្រិដ្ឋកម្មសង្គ្រាមរបស់តុលាការរដ្ឋនៃប្រទេសប៊ូស្នៀនិងហ៊ឺហ្ស៊ីហ្គោវីណា

ប្រជាជនប្រមាណពី១៥ម៉ឺនទៅ២៥ម៉ឺននាក់បានស្លាប់ក្នុង

ជម្លោះប្រដាប់អាវុធនៅក្នុងប្រទេសប៊ូស្នៀ និងហ៊ឺហ្ស៊ីហ្គោវីណា ក្នុងរវាងឆ្នាំ១៩៩២និង១៩៩៥ ។ សង្គ្រាមក៏មានលក្ខណៈពោរពេញទៅដោយការចាប់រំលោភសេពសន្ថវៈ ការជម្លៀសប្រជាជនជាលក្ខណៈទ្រង់ទ្រាយធំ ដែលក្នុងនោះមានចំនួនប្រមាណមួយលាននាក់បានភៀសខ្លួននិងមួយលាននាក់ទៀតបានជម្លៀសនៅក្នុងប្រទេស ព្រមទាំងមានការកម្ទេចចោលលំនៅដ្ឋានប្រហែលជាសាមសិបប្រាំភាគរយនៃលំនៅដ្ឋានដែលមានមុនសង្គ្រាមដោយរាប់បញ្ចូលទាំងហេដ្ឋារចនាសម្ព័ន្ធសង្គម និងហេដ្ឋារចនាសម្ព័ន្ធបច្ចេកទេសរបស់ប្រទេសប៊ូស្នៀ និងហ៊ឺហ្ស៊ីហ្គោវីណាផង ។ សង្គ្រាមនៅក្នុងប្រទេសប៊ូស្នៀនិងហ៊ឺហ្ស៊ីហ្គោវីណាត្រូវបានបញ្ចប់ ដោយសារមានការចុះហត្ថលេខាលើកិច្ចព្រមព្រៀងក្របខ័ណ្ឌរួមសម្រាប់សន្តិភាពនៅក្នុងប្រទេសប៊ូស្នៀ និងហ៊ឺហ្ស៊ីហ្គោវីណា ។

តុលាការយោធានិងតុលាការការរដ្ឋប្បវេណីក្នុងប្រទេសប្រទេសប៊ូស្នៀនិងហ៊ឺហ្ស៊ីហ្គោវីណា បានកាត់ក្តីឧក្រិដ្ឋកម្មសង្គ្រាមក្នុងពេលនិងក្រោយពេលសង្គ្រាម ប៉ុន្តែត្រូវជួបនឹងឧបសគ្គដោយការបាត់បង់មេធាវីនិងចៅក្រមដែលមានបទពិសោធន៍ការខូចខាតជារូបវ័ន្តនិងការលំបាកក្នុងការបំពេញការងារនៅក្នុងរដ្ឋដែលមានស្ថាប័នពីរប្រើប្រាស់ប្រព័ន្ធច្បាប់ផ្សេងគ្នា គឺកងកម្លាំងនគរបាលនិងក្រសួងយុត្តិធម៌ ។ ការិយាល័យព្រះរាជអាជ្ញានិងតុលាការដែលនៅក្នុងតំបន់ផ្សេងៗក្នុងប្រទេសត្រូវក្រុមជនភាគច្រើនកាន់កាប់ដែលបានធ្វើឲ្យក្រុមជនភាគតិចបាត់បង់ជំនឿជាសាធារណៈទៅលើប្រព័ន្ធតុលាការ ហើយនិងធ្វើឲ្យកាន់តែមានគំនិតបែងចែកបក្សពួក ។

ការបង្កើតឡើងជាផ្លូវការនូវអង្គជំនុំជម្រះក្តីឧក្រិដ្ឋកម្មសង្គ្រាមនៃតុលាការជាតិរបស់ប្រទេសប៊ូស្នៀ និងហ៊ឺហ្ស៊ីហ្គោវីណា នាថ្ងៃទី០៦ ខែមករា ឆ្នាំ២០០៥ នៅក្រុងសារ៉ាយេវ៉ូ បានកំណត់ជាការបង្កើតសាលាក្តីកូនកាត់ចុងក្រោយ និងប្រហែលជាបានរៀបចំល្អបំផុតផងដែរ ក្រោយពីមានការពិភាក្សាអស់រយៈពេលជាច្រើនឆ្នាំមក ។ ទីតាំងរបស់តុលាការដែលនៅក្រុងសារ៉ាយេវ៉ូបានធ្វើឲ្យប្រជាជននៅក្នុងតំបន់អាចមកកាន់អង្គជំនុំជម្រះឧក្រិដ្ឋកម្មសង្គ្រាមនេះ ហើយរចនាសម្ព័ន្ធរបស់តុលាការបានពន្លឿនកម្លាំងច្បាប់អន្តរជាតិ ក្នុងខណៈពេលដែលនៅតែមានការផ្សារភ្ជាប់ជាមួយនឹងច្បាប់ក្នុងស្រុក ដែលនេះបង្ហាញអំពីតម្រូវការក្នុងការថែរក្សាការកាន់កាប់ដំណើរការយុត្តិធម៌ក្នុងស្រុក ។ ច្បាប់ក្នុងស្រុកនិងច្បាប់អន្តរជាតិនឹងដើរតួយ៉ាងសំខាន់នៅក្នុងដំណើរការនេះ ។

អង្គជំនុំជម្រះក្តីឧក្រិដ្ឋកម្មសង្គ្រាមជាស្ថាប័នមួយរបស់ប្រទេសប្រទេសប៊ូស្នៀនិងហ៊ឺហ្ស៊ីហ្គោវីណា ដែលដំណើរការក្រោមច្បាប់របស់ប្រទេសប៊ូស្នៀ និងហ៊ឺហ្ស៊ីហ្គោវីណា ប៉ុន្តែចូលរួមដោយបុគ្គលិកអន្តរជាតិនិងច្បាប់អន្តរជាតិ ។ ជាដំបូងបុគ្គលិកអន្តរជាតិនឹងដើរតួនាទីដ៏សំខាន់ ប៉ុន្តែនឹងត្រូវកាត់បន្ថយអស់ក្នុងរយៈពេលប្រហែលប្រាំឆ្នាំ ។ ទោះបីជានៅក្នុងដំណាក់កាលដំបូង អង្គជំនុំជម្រះក្តីឧក្រិដ្ឋកម្មសង្គ្រាមនឹងមានចៅក្រមអន្តរជាតិពីររូបអង្គុយជាមួយចៅក្រមជាតិមួយរូបនៅក្នុងការជំនុំជម្រះក្តីទាំងអស់ (ការកាត់សេចក្តីនិងឧទ្ធរណ៍) ហើយចៅក្រមអន្តរជាតិនឹងត្រូវអស់តួនាទីបន្ទាប់ពីរយៈពេលប្រាំឆ្នាំក្រោយមកដោយនៅទីបញ្ចប់នៅសល់តែចៅក្រមជាតិមួយប៉ុណ្ណោះ ។ ដូចគ្នានេះដែរ ការិយាល័យព្រះរាជអាជ្ញានឹងចាប់ផ្តើមធ្វើការជាមួយរដ្ឋអាជ្ញាអន្តរជាតិប្រាំពីររូប ប៉ុន្តែនឹងត្រូវជំនួសវិញដោយរដ្ឋអាជ្ញាជាតិនៅពេលក្រោយ ។ ការចុះបញ្ជីក៏នឹងត្រូវប្រែប្រួលពីទម្រង់ជាតុលាការកូនកាត់មកជារចនាសម្ព័ន្ធក្នុងស្រុកសុទ្ធសាធ ។ ក្រោមការដឹកនាំរបស់ប្រធានអន្តរជាតិមួយរូប ផ្នែកគាំទ្រក្រុមអ្នកការពារក្តីព្រហ្មទណ្ឌ ត្រូវបានស្គាល់យ៉ាងទូលំទូលាយតាមរយៈឈ្មោះកាត់ជាភាសាប៊ូស្នៀថា ***OKO (Odsjek Krivicne Odbrane)*** និងតំណាងឲ្យការរីកចម្រើន មួយជំហាននៅក្នុងប្រព័ន្ធមួយដែលពីមុនមកគ្មានការជួយជ្រោមជ្រែងពីក្រុមប្រឹក្សាការពារក្តីឡើយ ។ ដោយមានជំនួយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលអាមេរិក អឺរ៉ុបកណ្តាល និងកិច្ចផ្តួចផ្តើមច្បាប់ ***Eurasian (ABA-CEELI) OKO*** បាន «ខិតខំប្រឹងប្រែងជួយអ្នកដែលមានសមត្ថភាពវិជ្ជាជីវៈច្បាប់ក្នុងស្រុកដើម្បីលើកកម្ពស់ការពារក្តីចុងចោទឲ្យមានប្រសិទ្ធភាពនៅក្នុងដំណើរការក្តីឧក្រិដ្ឋកម្មសង្គ្រាមនៅចំពោះមុខតុលាការ-ឧក្រិដ្ឋកម្មសង្គ្រាម... ។ តាមការប៉ាន់ប្រមាណថា ***OKO*** នឹងបើកវគ្គបណ្តុះបណ្តាលមេធាវីបានប្រហែល៣៥០រូបមកត្រឹមចុងឆ្នាំ២០០៧» ។

ក្នុងតុលាការកូនកាត់ប្រទេសប៊ូស្នៀ បុគ្គលិកអន្តរជាតិអាច

នឹងមានលទ្ធភាពបង្កើនសមត្ថភាពជាតិទាក់ទិនទៅនឹងករណីឧក្រិដ្ឋកម្មសង្គ្រាមដ៏ស្មុគស្មាញ ហើយប្រហែលជាអាចនឹងជួយរៀបចំបុគ្គលិកក្នុងស្រុកផ្សេងទៀតឲ្យមានការចូលរួមកាន់តែល្អ នៅក្នុងកំណែទម្រង់ច្បាប់ថ្មីរបស់ប៊ូស្នៀ និងដែលមានលក្ខណៈកាន់តែប្រទាំងប្រទើស ។ អយ្យការបានរៀបចំវគ្គបណ្តុះបណ្តាលរួចជាស្រេចសម្រាប់បុគ្គលិកស្តីពីច្បាប់មនុស្សអន្តរជាតិ អនុសញ្ញាក្រុងហ្សឺណែវសិទ្ធិមនុស្ស ការស៊ើបអង្កេតឧក្រិដ្ឋកម្មសង្គ្រាម បច្ចេកទេសព័ត៌មានវិទ្យា និងប្រព័ន្ធផ្សព្វផ្សាយ ។

ក្នុងខណៈដែលសាលាក្តីព្រហ្មទណ្ឌអន្តរជាតិយូហ្គោស្លាវីអនុវត្តយុទ្ធសាស្ត្រពេញលេញរបស់ខ្លួននោះ សំណុំរឿងមធ្យមនិងស្រាលត្រូវបញ្ជូនទៅអង្គជំនុំជម្រះក្តីឧក្រិដ្ឋកម្មសង្គ្រាមដែលនឹងអាចបើកសវនាការកាត់ក្តី ប្រហែលជា៨០ឬ១០០ករណី ។ «សាលាក្តីព្រហ្មទណ្ឌអន្តរជាតិយូហ្គោស្លាវីរក្សានូវយុត្តាធិការរបស់ខ្លួនដើម្បីលុបចោលនូវដីកាឲ្យបញ្ជូនមុនមានការផ្តន្ទាទោសឬឲ្យរួចទោសចំពោះចុងចោទ ប្រសិនបើមានបញ្ហាទាក់ទិនទៅនឹងការប្រព្រឹត្តទៅនៃការកាត់សេចក្តីនៅក្នុងប្រទេសប៊ូស្នៀ» ដែលផ្តល់នូវការលើកទឹកចិត្តបន្ថែមដើម្បីឲ្យមានការកាត់ក្តីដោយយុត្តិធម៌ ។ ទោះបីជាចំនួនជាក់លាក់នៃករណីដែលអង្គជំនុំជម្រះថ្មីនេះត្រូវកាត់សេចក្តីពុំទាន់មានការកំណត់ច្បាស់លាស់ក៏ដោយ ក៏ការិយាល័យរដ្ឋអាជ្ញានៃប្រទេសប៊ូស្នៀ និងហ៊ឺហ្សីហ្គោវីណា បានអះអាងថាអង្គជំនុំជម្រះនឹងបើកសវនាការតែចំពោះករណី «ដែលមានផលប៉ះពាល់ធ្ងន់ធ្ងរ» ប៉ុណ្ណោះ ដោយហេតុថាខ្លួន «នឹងគ្មានទាំងធនធាននិងគ្មានពេលវេលាសម្រាប់កាត់ក្តីករណីឧក្រិដ្ឋកម្មសង្គ្រាមទាំងអស់ឡើយ ។» ដូច្នេះ ការងាររបស់តុលាការនឹងត្រូវបញ្ចប់ក្នុងកម្រិតទាបមួយជាមួយនឹងការកាត់ក្តីឧក្រិដ្ឋកម្មសង្គ្រាមនៅចំពោះមុខតុលាការក្នុងស្រុកនិងតុលាការក្នុងតំបន់របស់ប្រទេសប៊ូស្នៀនិងហ៊ឺហ្សីហ្គោវីណា ។ តុលាការមូលដ្ឋានរបស់ស្រុក (Brcko) និងតុលាការស្រុករបស់ *(Republika Srpska)* ដោយហេតុដូច្នេះជោគជ័យដ៏ឧត្តមបំផុតនៃគំនិតផ្តួចផ្តើមយុត្តិធម៌អន្តរកាលនឹងមិនអាស្រ័យលើអង្គជំនុំជម្រះក្តីឧក្រិដ្ឋកម្មសង្គ្រាមប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអាស្រ័យលើតុលាការថ្នាក់ក្រោមក្នុងការទទួលបានថវិកានិងការយកចិត្តទុកដាក់ដែលអ្នកទាំងនេះត្រូវការ ។

ឧបសគ្គចំពោះការប្រព្រឹត្តយ៉ាងមានប្រសិទ្ធភាពនោះរួមមានៈ «ការមិនយកចិត្តទុកដាក់ផ្នែកនយោបាយរបស់អាជ្ញាធរដែលមានលក្ខណៈលម្អៀងឬអាជ្ញាធរដែលគ្មានការសម្រេចចិត្តច្បាស់លាស់ ភាពភ័យខ្លាចរបស់ចៅក្រមនិងព្រះរាជអាជ្ញាចំពោះសន្តិសុខផ្ទាល់ខ្លួន ការលំបាកក្នុងការនាំខ្លួននិងការការពារសន្តិសុខរបស់សាក្សីនិងចុងចោទ ក៏ដូចជាការអនុវត្តការងារ របនាសម្ព័ន្ធ និងនីតិវិធីមិនល្អសម្រាប់កិច្ចប្រតិបត្តិការឆ្លងព្រំដែន» ។ ព្រះរាជអាជ្ញាក៏ត្រូវប្រឈមមុខនឹង «យន្តការការពារសាក្សីមិនពេញលេញ សំណុំរឿងមានចំនួនច្រើន កង្វះខាតធនធានច្បាប់ ការផ្សព្វផ្សាយរបាយការណ៍ច្បាប់និងអត្ថបទច្បាប់មិនបានល្អ កង្វះខាតវគ្គបណ្តុះបណ្តាលស្តីពីច្បាប់មនុស្សជាតិនិងជំនាញចាំបាច់ ដូចជាការពិនិត្យបម្រុះសេចក្តីព្រៀងដីកាចោទប្រកាន់ និងការជ្រើសរើសសាក្សី» ។ អង្គភាពផ្នែកឧក្រិដ្ឋកម្មសង្គ្រាមរបស់ទីភ្នាក់ងារការពារនិងស៊ើបអង្កេតរបស់រដ្ឋប៊ូស្នៀ *(SIPA)* ដែលមានអំណាចធ្វើការស៊ើបអង្កេតក៏ជួបប្រទះបញ្ហាខ្វះបុគ្គលិកនិងត្រូវទទួលបន្ទុកច្រើនលើសលប់ផងដែរ ។

កំណែទម្រង់ផ្នែកច្បាប់ធំៗ នៅក្នុងប្រព័ន្ធយុត្តិធម៌ក្នុងស្រុក ក្រមនីតិវិធីព្រហ្មទណ្ឌថ្មីឆ្នាំ២០០៣ និងការបង្កើតអង្គជំនុំជម្រះក្តីឧក្រិដ្ឋកម្មសង្គ្រាមថ្នាក់រដ្ឋបានបង្កើតនូវភាពមិនប្រាកដក្នុងផ្នែកយុត្តាធិការ និងនីតិវិធី ដែលស្ថាប័នតុលាការត្រូវប្រឈមមុខ ។ ទោះបីជាយ៉ាងណា ការអនុវត្តរួមគ្នានៃកំណែទម្រង់ច្បាប់ដែលមានលក្ខណៈទូលំទូលាយ និងការបង្កើតតុលាការកូនកាត់មួយដែលដើរតួនាទីជាតុលាការគំរូមួយនោះ មិនត្រឹមតែនាំមកនូវបញ្ហាដែលត្រូវដោះស្រាយប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងនាំមកនូវឱកាសល្អៗជាច្រើនទៀតផង ។

លើសពីនេះទៅទៀត ផ្នែកព័ត៌មានសាធារណៈនិងទំនាក់ទំនង *(PIOS)* របស់តុលាការឧក្រិដ្ឋកម្មសង្គ្រាមបានចូលរួមក្នុង «កិច្ចផ្តួចផ្តើមយ៉ាងទូលំទូលាយច្រើនដែលមានសក្តានុពលនិងដែលបានកែលម្អ» ដោយរួមមានទស្សនកិច្ចរបស់ក្រុមជនរងគ្រោះទៅកាន់តុលាការរដ្ឋ កិច្ចផ្តួចផ្តើមស្តីពីការយល់ដឹងអំពីប្រព័ន្ធផ្សព្វផ្សាយនិងការបង្កើតបណ្តាញគាំទ្រតុលាការដែលសម្រួលដល់ការបង្កើតបណ្តាញរបស់អង្គការក្រៅរដ្ឋាភិបាល ដើម្បីផ្សព្វផ្សាយព័ត៌មានអំពីតុលាការឧក្រិដ្ឋកម្មទូទាំងប្រទេសប៊ូស្នៀ ។

*នៅក្នុងខែកញ្ញា ឆ្នាំ២០០៣ គំនិតដែលបង្កើតឲ្យមាន សាលាក្តីថ្នាក់ជាតិរបស់អ៊ីរ៉ាក់ ដែលគាំទ្រពីអន្តរជាតិត្រូវបាន បន្តពិភាក្សាយ៉ាងខ្លាំងក្លាដោយមន្ទីរបញ្ចកោណ ក្រសួងការបរទេស និងក្រសួងយុត្តិធម៌សហរដ្ឋអាមេរិក ក្រោមការជួយសម្របសម្រួល របស់ក្រុមប្រឹក្សាសន្តិសុខជាតិ... ហើយជាចុងក្រោយទទួលបាន ការគាំទ្រពី* GC *និងអាជ្ញាធរបណ្តោះអាសន្នចម្រុះ ។ គំនិតដំបូងផ្តើម នេះបាននាំទៅដល់ការធ្វើសេចក្តីព្រាងលក្ខន្តិកៈសម្រាប់សាលាក្តី ពិសេសរបស់អ៊ីរ៉ាក់ដែលធ្វើឡើងពីខែកញ្ញា រហូតដល់ខែធ្នូ ឆ្នាំ ២០០៣ ។*

*ជាលទ្ធផល លក្ខន្តិកៈសម្រាប់សាលាក្តីពិសេសរបស់អ៊ីរ៉ាក់ នេះអនុញ្ញាតឲ្យមានការចូលរួមពីបេក្ខជនដែលមិនមែនជាជនជាតិ អ៊ីរ៉ាក់ ក្រោមការជ្រើសរើសរបស់អ៊ីរ៉ាក់ ដូច្នេះរដ្ឋាភិបាលក៏អាច តែងតាំងចៅក្រមមិនមែនសញ្ជាតិអ៊ីរ៉ាក់ដែរ ប្រសិនបើការធ្វើ បែបនោះគឺជាការចាំបាច់ ។ ទោះជាយ៉ាងនេះក្តី នៅក្នុងលក្ខន្តិកៈ នេះមិនបានចែងថា ត្រូវរៀបចំរចនាសម្ព័ន្ធសម្រាប់បេក្ខជនមិន មែនជនជាតិអ៊ីរ៉ាក់ ឬក៏ផ្សារភ្ជាប់ទំនាក់ទំនងទាំងនោះទៅនឹងស្ថាប័ន ឬអង្គភាពណាមួយជាតួយ៉ាងដូចជា អង្គការសហប្រជាជាតិ ។ (ឧបមាថា ប្រធានសាលាក្តីអាចស្នើសុំជំនួយពីអង្គការសហប្រជាជាតិ ឬអង្គភាពណាមួយផ្សេងទៀតនៅក្នុងការតែងតាំងជំនាញការ ឬទីប្រឹក្សាអន្តរជាតិមិនមែនសញ្ជាតិអ៊ីរ៉ាក់ យ៉ាងណាមិញការ តែងតាំងនេះ គឺពុំមានរចនាសម្ព័ន្ធជាផ្លូវការ ឬការតម្រូវឲ្យធ្វើ យ៉ាងដូច្នោះឡើយ) ។*

*យោងតាមប្រការ៦ ខ) នៃលក្ខន្តិកៈប្រធានតុលាការ ពិសេសអន្តរជាតិ ត្រូវតែងតាំងអ្នកមិនមានសញ្ជាតិអ៊ីរ៉ាក់ «ដើម្បី ដើរតួនាទីជាទីប្រឹក្សា ឬអ្នកសង្កេតការណ៍នៅក្នុងអង្គជំនុំជម្រះក្តី និងអង្គជំនុំជម្រះឧទ្ធរណ៍» ។ ប្រការ ៧ ធ) និងប្រការ៨ឈ) បានចែងអំពីការតែងតាំងស្រដៀងគ្នានេះដែរ ទាក់ទិនទៅនឹង ចៅក្រមស៊ើបអង្កេតនិងព្រះរាជអាជ្ញា ។ ការណ៍នេះគឺបម្រុងទុក សម្រាប់ការចូលរួមជាអន្តរជាតិ បើទោះជាមានការអនុវត្តទោស ប្រហារជីវិតរបស់សាលាជម្រះក្តីក៏ដោយ ក៏មានប្រទេសដែល មានតុលាការការល្បីល្បាញតិចតួចណាស់ក្រៅពីសហរដ្ឋអាមេរិក អាចនឹងចូលរួម ឬបញ្ជូលបុគ្គលិករបស់ខ្លួនមកចូលរួម ។ ជាក់ស្តែង មកទល់នឹងត្រឹមនេះពាក្យថា «ការចូលរួមជាអន្តរជាតិ» ភាគច្រើន គ្រាន់តែជាពាក្យសម្រាលមួយសម្រាប់ការចូលរួមរបស់សហរដ្ឋ អាមេរិក ជាជាងសំដៅលើអ្វីផ្សេងទៀត ។ រចនាសម្ព័ន្ធរបស់ តុលាការអ៊ីរ៉ាក់បច្ចុប្បន្ន (ដែលបានកែប្រែពីសាលាក្តីពិសេស របស់អ៊ីរ៉ាក់មកជាសាលាក្តីព្រហ្មទណ្ឌកំពូលរបស់អ៊ីរ៉ាក់នៅក្នុង ដំណើរការដែលនឹងរៀបរាប់ខាងក្រោម) គឺដូចគ្នាខ្លាំងទៅនឹង តុលាការក្នុងស្រុក ទោះបីជាតុលាការនោះរក្សាទុកនូវអំណាចក្នុង ការអនុវត្តច្បាប់ជាតិនិងអន្តរជាតិក៏ដោយ ដែលការណ៍ទាំងនេះ បានប្រែក្លាយតុលាការនេះទៅជាតុលាការក្នុងស្រុកដែលមាន លក្ខណៈអន្តរជាតិដែរ ដោយមានការចូលរួមយ៉ាងច្រើនពីសហរដ្ឋ អាមេរិក ។ ទាំងចៅក្រមនិងរដ្ឋអាជ្ញារបស់ប្រទេសអ៊ីរ៉ាក់ត្រូវបាន អះអាងថាមានសមត្ថភាពដោយសារតែមានទេពកោសល្យខាង ច្បាប់ច្រើន ជាពិសេសនៅពេលប្រៀបធៀបទៅនឹងតុលាការ ដែលកើតក្រោយអំពើឃោរឃៅដូចជានៅប្រទេសទីម័រខាងកើត ជាដើម ។*

*យោងតាមអ្នកជំនាញការម្នាក់ក្នុងចំណោមជំនាញការទាំង ប្រាំដែលជ្រើសរើសពីទូទាំងពិភពលោក ដោយការិយាល័យ ទំនាក់ទំនងឧក្រិដ្ឋកម្មទៅនឹងរបបរបស់ក្រសួងយុត្តិធម៌ប្រចាំការ នៅក្នុងទីក្រុងបាដាដដើម្បីជួយបណ្តុះបណ្តាលចៅក្រមសាលាក្តី ពិសេសអន្តរជាតិបានឲ្យដឹងថានៅក្នុងខែមករា ឆ្នាំ២០០៥ មាន សមាជិកគណៈមេធាវីអ៊ីរ៉ាក់ប្រមាណ២ម៉ឺននាក់ ដែលក្នុងនោះ មាន១ម៉ឺននាក់បានរស់នៅក្នុងទីក្រុងបាដាដ ។ ក្នុងចំណោមចៅក្រម ចំនួន៩០០នាក់ មានចៅក្រមប្រហែល១៥០នាក់អត់សមត្ថភាព ពីព្រោះអ្នកទាំងនោះធ្លាប់ជាសកម្មជនរបស់គណបក្សបាអាតដែល ទំនាក់ទំនងទៅនឹងតុលាការសន្តិសុខជាតិរបស់ សាដាម ហ៊ូសេន ។ ដូច្នេះនៅសល់តែចៅក្រមចំនួន៧៥០នាក់ប៉ុណ្ណោះ ដែលមានបទ ពិសោធន៍ដោះស្រាយលើករណីឃាតកម្មមិនទាក់ទងនឹងនយោបាយ ករណីសម្លាប់ ករណីវាយតប់ ករណីចាប់រំលោភសេពសន្ថវៈនិង ករណីទាក់ទងទៅនឹងការកាប្រព្រឹត្តខុសច្បាប់ កិច្ចសន្យា ច្បាប់គ្រួសារ និងបញ្ហាអចលនទ្រព្យ ។*

**(នៅមានត)**

**អេរ៉ែល ហ៊ីហ្គូនេត**

# ការស្លាប់ដោយការអត់អាហារក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

គំនិតយល់ស្របគ្នាមួយហាក់ដូចជាលេចធ្លោឡើងនៅក្នុងការអានរឿងរ៉ាវរបស់អ្នកដែលនៅរស់ពីរបបខ្មែរក្រហម ។ ក្រៅពីនិយាយអំពីការសម្លាប់គេក៏ពិភាក្សាអំពីបញ្ហាកង្វះខាតអាហារដែរ ។ «អាហារគឺជាព្រះរបស់ខ្ញុំ» នេះគឺជាឃ្លាបន្ទរមួយយ៉ាងសាមញ្ញ ។ ជនរងគ្រោះតែងនិយាយអំពីអាហារមួយពេល ៗ ដែលខ្លួនបានហូបធ្វើឲ្យនឹកឃើញដល់ការអត់ឃ្លានដែលខ្លួនបានអត់ទ្រាំកាលពី៣០ឆ្នាំមុន ។ ការនិយាយជាច្រើនដងពីអារម្មណ៍អត់ឃ្លានទាំងនេះនៅជុំវិញការគិតរបស់ប្រជាជនចំពោះរបបខ្មែរក្រហម ។

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានបង្កើតឡើងដើម្បីផ្តល់យុត្តិធម៌ដល់ជនរងគ្រោះនៃរបបខ្មែរក្រហមហើយ តុលាការនេះស្ថិតនៅក្នុងដំណើរការស៊ើបអង្កេតបទឧក្រិដ្ឋដែលថ្នាក់ដឹកនាំបានប្រព្រឹត្តនៅអំឡុងពេលរបបកម្ពុជាប្រជាធិបតេយ្យពី១៩៧៥-១៩៧៩ ។ ដើម្បីធ្វើឲ្យឥទ្ធិពលរបស់តុលាការកាន់តែខ្លាំង វាជាការសំខាន់ណាស់ដែលថាបទឧក្រិដ្ឋសំខាន់ៗ ត្រូវបានកាត់ទោស ។ ព្រះរាជអាជ្ញាអាចនឹងធ្វើការចោទប្រកាន់មេដឹកនាំខ្មែរក្រហមពីបទសម្លាប់និងធ្វើទារុណកម្ម ប៉ុន្តែចុះចំពោះការស្លាប់ដោយសារកង្វះអាហារវិញ?

គ្មានអ្វីគួរឲ្យឆ្ងល់ទេដែលប្រជាជនរាប់រយនាក់បានស្លាប់ដោយការអត់អាហារនៅអំឡុងពេលខ្មែរក្រហមកាន់អំណាច ។ ទោះជាយ៉ាងណាក៏ដោយ ការកាត់ទោសមេដឹកនាំខ្មែរក្រហមសម្រាប់អ្នកស្លាប់ទាំងនោះនឹងត្រូវធ្វើឲ្យអស់ពីលទ្ធភាព ។ ការណ៍នេះមិនមែនគ្រាន់តែជាការចាំបាច់ដើម្បីបង្ហាញថានយោបាយនៃការដឹកនាំរបស់ខ្មែរក្រហមជាមូលហេតុនាំឲ្យខ្វះអាហារប៉ុណ្ណោះទេ ប៉ុន្តែសមាជិកថ្នាក់ដឹកនាំដែលបានរៀបចំនយោបាយបណ្តាល


ប្រជាជនវិលត្រឡប់មកលំនៅដ្ឋានវិញក្នុងឆ្នាំ១៩៧៩

ឲ្យប្រជាជនជួបប្រទះកង្វះខាតអាហារ ឬក៏បានដឹងមុនពីគ្រោះថ្នាក់ដែលថាកង្វះខាតអាហារអាចនឹងកើតមានជាផលវិបាកមួយនៃនយោបាយទាំងនោះ ។ ក្នុងការការពារខ្លួនមេដឹកនាំខ្មែរក្រហមអាចនឹងប្រកែកដោះសាថា ដោយសារតែការគ្រប់គ្រងទន់ខ្សោយនិងទំនាក់ទំនងមិនសូវល្អ ហើយអ្នកទាំងនេះមិនបានដឹងថាកង្វះខាតអាហារបានកើតមាន ឬក៏រំពឹងថាវាអាចនឹងកើតឡើងនោះទេ ។ មេដឹកនាំខ្មែរក្រហមអាចលើកពីមូលហេតុថា ស្ថានភាពទូទាំងប្រទេសគឺខ្លួនមិនបានតាំងចិត្តរៀបចំឡើយ ហើយថារបាយការណ៍អំពីស្ថានភាពអាហារទាំងនោះមានភាពខុសៗគ្នាសូម្បីតែសហករណ៍ដែលនៅជិតខាងគ្នាក៏ដោយ ។ លើសពីនេះទៀតមានឯកសារមួយចំនួនបង្ហាញថា មេដឹកនាំសហករណ៍បានព្យាយាមនិងលាក់បាំងនូវរបបអាហារជាច្រើនពីអ្នកកាន់អំណាចខ្មែរក្រហមថ្នាក់កណ្តាល ។ ទោះបីជាយ៉ាងណាក៏ដោយនយោបាយខ្មែរក្រហមក្នុងការជម្លៀសដោយបង្ខំនិងការនាំអង្ករចេញជាការបញ្ជាក់យ៉ាងជាក់ស្តែងមួយដែលនាំឲ្យកង្វះខាតអាហារ និងជាការបញ្ជាក់ថាថ្នាក់ដឹកនាំច្បាស់ជាបានដឹងថាគ្រោះទុរ្ភិក្សពិតជាបានកើតមានឡើងមែន ។

## ការជម្លៀសដោយបង្ខំ

នយោបាយដ៏ខ្លាំងបំផុតមួយរបស់ខ្មែរក្រហមគឺបង្ខំឲ្យប្រជាជនរស់នៅទីក្រុងផ្លាស់ប្តូរទីលំនៅ ។ ក្រោយពីកាន់កាប់ក្រុងភ្នំពេញនៅឆ្នាំ១៩៧៥ ប្រជាជននៅទីក្រុងនេះប្រមាណ១,៥លាននាក់ត្រូវបានជម្លៀសទៅកាន់ទីជនបទ ។ នៅពេលនោះប្រជាជនទីក្រុងកំពុងតែទទួលបានរួចជាស្រេចពីជំនួយអាហារឧបត្ថម្ភអន្តរជាតិ ។ ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិអាមេរិកដែលបានផ្តល់ជំនួយ៥០.០០០ តោនមុនពេលដែលមានការកាន់កាប់ទីក្រុងភ្នំពេញបានចេញរបាយការណ៍គំរាមកំហែងអំពីស្ថានភាពអាហារនៅក្នុងប្រទេសកម្ពុជា ហើយក្រើនរំឭកថាសកម្មភាពនេះចាំបាច់ត្រូវតែបានធ្វើឡើងដើម្បីចៀសឲ្យផុតពីភាពខ្វះខាត ។

ហេតុផលមួយទៀតនៃការភៀសខ្លួនគឺថាវាជាចេតនាទប់ស្កាត់ពីការអត់អាហារ ។ របាយការណ៍មួយចំនួនបានបង្ហាញថានៅពេលធ្វើការជម្លៀស ឃ្លាំងនៅទីក្រុងភ្នំពេញមានផ្ទុកអាហារសម្រាប់ផ្គត់ផ្គង់បានតែរយៈពេល៨ថ្ងៃប៉ុណ្ណោះ ។ ដូច្នេះអាចមានការជជែកវែកញែកថា តាមរយៈការជម្លៀសប្រជាជនទីក្រុងទៅកាន់ទីជនបទ ខ្មែរក្រហមបានធ្វើឲ្យប្រជាជនចូលកាន់តែកៀកនឹងប្រភពស្រូវ អង្ករ ហើយកាត់បន្ថយបាននូវបញ្ហាចែកចាយស្បៀង ។ ទោះជាយ៉ាងណាក៏ដោយ ព័ត៌មានជាច្រើនស្តីអំពីការជម្លៀសរួមទាំងវិធីឃោរឃៅដែលបានប្រព្រឹត្តគឺមិនមែនជាហេតុផលមនុស្សធម៌ឡើយ ។ ខ្មែរក្រហមមានទស្សនៈថា ទីក្រុងជាជម្រកសម្រាប់ជនដែលប្រឆាំងនឹងបដិវត្តន៍និងធ្វើការជម្លៀសចេញដោយមានការរៀបចំផ្លាស់ប្តូរទីលំនៅរបស់អ្នកទីក្រុងដែលគេយល់ថាជាការគំរាមកំហែងមួយ ។ ឧទាហរណ៍ ចាប លន់ អ្នកជំនួយការរបស់តំបន់៣៧បានបង្ហាញថា ការជម្លៀសប្រជាជនពីទីក្រុងភ្នំពេញគឺជា «គម្រោងការរយៈពេលវែង» និងពាក្យស្លោកថា «ការពារប្រជាជនពីសត្រូវ» ។

អត្ថបទមួយនៅឆ្នាំ១៩៧៥បានចុះផ្សាយការសម្ងាត់ពីការប្រកាសរបស់បក្សកុម្មុយនីស្តកម្ពុជា សៀវភៅទង់បដិវត្តន៍បាននិយាយបន្ថែមពីការសម្រេចនេះសម្រាប់ការជម្លៀសៈ «ប្រសិនបើយើងរក្សាបានភ្នំពេញ វានឹងកាន់តែរឹងប៉ឹង ។ នេះជាការពិតថានៅពេលដែលយើងរស់នៅទីជនបទ យើងរឹងមាំនិងកាន់តែមានឥទ្ធិពលជាងផ្នែកឯកជន ។ ក៏ប៉ុន្តែបើនៅភ្នំពេញ យើងនឹងអាចក្លាយជាអ្នកដែលគេគ្រប់គ្រង ។ ទោះជាយ៉ាងណាយើងមិនទុកឲ្យគេនៅភ្នំពេញទេ» ។ ដូច្នេះ «គហបតីគ្មានកន្លែងដែលត្រូវទៅ ។ អ្នកទាំងនេះក្លាយជាអ្នកគ្រប់គ្រងលើកម្លាំងកសិករធ្វើស្រែចម្ការ ។ អ្នកទាំងនេះត្រូវបានបង្ខំឲ្យធ្វើការងារស្រែចម្ការដោយដៃដូចអ្នកស្រុក ឋានៈរបស់អ្នកទាំងនេះត្រូវដួលរលំ ប៉ុន្តែគំនិតនិងសេចក្តីប្រាថ្នារបស់គេនៅតែមាន ។ ដូច្នេះអ្នកទាំងនេះនៅតែបន្តការតស៊ូប្រឆាំងបដិវត្តន៍ ។ ទោះជាអ្នកទាំងនោះអាចធ្វើសកម្មភាពប្រឆាំងនឹងយើងក៏ដោយ នេះគឺជាស្ថានភាពរួបរួមដែលជំរុញឲ្យយើងសម្រេចបន្តការធ្វើបដិវត្តន៍» ។ សេចក្តីថ្លែងការណ៍នេះមិនត្រឹមតែបញ្ជាក់ថា ហេតុអ្វីបានជាភ្នំពេញត្រូវបានជម្លៀសទេ ប៉ុន្តែថែមទាំងបានបង្ហាញពីកំហឹងដែលមេដឹកនាំខ្មែរក្រហមមានមកលើអ្នកដែលរស់នៅក្នុងទីក្រុងទៀតផង ។ ការណ៍នេះអាចនឹងជួយពន្យល់ថាហេតុអ្វីបានជាមានការជម្លៀសគឺបានធ្វើឡើងបង្កឲ្យមានការស្លាប់មនុស្សយ៉ាងច្រើន ។

មិនយូរប៉ុន្មាន ក្រោយការជម្លៀសប្រជាជនពីទីក្រុងជាលើកដំបូង មេដឹកនាំខ្មែរក្រហមបានបង្កើតនយោបាយមួយគឺនិរទេសអ្នករស់នៅទីក្រុងពីទិសខាងលិចនិងទិសនិរតីឆ្ពោះទៅកាន់ទិសពាយ័ព្យ ។ ប្រជាជនប្រមាណ៨០០.០០០ម៉ឺននាក់ ដែលភាគច្រើនជាអតីតអ្នករស់នៅទីក្រុងភ្នំពេញគឺត្រូវបានផ្លាស់ប្តូរទីតាំងទាំងបង្ខំ ។ ការនិរទេសកើតមានឡើងក្នុងគោលបំណងសំខាន់ពីរ ។ ទីមួយថ្នាក់ដឹកនាំខ្មែរក្រហមចង់បោសសម្អាតនៅទិសនិរតី ចង់ឲ្យកម្លាំងខ្មែរក្រហមគ្រប់គ្រងប្រជាជនទីក្រុងទាំងអស់ដោយបានប្រើពាក្យប្រជាជន «ថ្មី» ដើម្បីបញ្ជាក់ជាសញ្ញាថាជាអ្នកដែលមានសាវតាប្រឆាំងនឹងបដិវត្តន៍ ។ ទិសពាយ័ព្យចង់ឲ្យមានការគ្រប់គ្រងលើរដ្ឋាភិបាលលន់នល់ គឺជាជម្រើសដែលសមហេតុផលដើម្បីបញ្ជូនប្រជាជនថ្មីទៅទីនោះ ពីព្រោះថាសូម្បីតែកសិករធ្វើចម្ការនៅទីនោះក៏មិនអាចជឿជាក់ថាស្មោះត្រង់បដិវត្តន៍ដែរ ។ ដូច្នេះការនិរទេសលើកទីពីរនេះអាចនឹងបោសសម្អាតប្រជាជនថ្មីទាំងអស់នៅភូមិភាគនិរតីនិងចាប់អារម្មណ៍ភាគច្រើនអំពីការមិនចង់ឲ្យរស់នៅតែមួយកន្លែង ។

គោលបំណងទីពីរនៃការនិរទេសសាជាថ្មីអាចជាប់មានទំនាក់ទំនងនឹងការដឹកនាំរបស់ខ្មែរក្រហមក្នុងគោលបំណងបង្កើនផលិតផលស្រូវនៅក្នុងភូមិភាគពាយ័ព្យ ។ ទោះជាយ៉ាងណាក៏ដោយការផ្លាស់ប្តូរទីតាំងស្ទើរតែពីរដងចំពោះប្រជាជនតាមតំបន់ដែលមិនមានធនធានដើម្បីផ្គត់ផ្គង់ប្រជាជនដែលហូរចូលមកច្រើនដូចនេះ ។ ពីដំបូងការនិរទេសម្តងទៀតបានធ្វើឲ្យប្រជាជនស្លាប់ដោយសារការអត់បាយ ។ ឧទាហរណ៍ៈ ប្រជាជនជាច្រើនត្រូវបានសំចតនៅខេត្តពោធិ៍សាត់ ហើយរង់ចាំរថភ្លើងដឹកបន្តទៅកាន់ខេត្តបាត់ដំបង ។ ខណៈនោះប្រជាជនមួយចំនួនមានសំណាងបានឡើងរថភ្លើងភ្លាមៗ ហើយមួយចំនួនទៀតត្រូវរង់ចាំរយៈពេល១ខែឬក៏យូរជាងនេះ ។ ប្រជាជនដែលត្រូវបានទុកឲ្យនៅរង់ចាំគឺត្រូវបានផ្តល់អាហារមិនគ្រប់គ្រាន់ រហូតដល់ភាគច្រើនបានស្លាប់ដោយសារការអត់អាហារ ។

នៅពេលដែលការធ្វើដំណើររបស់អ្នកនិរទេសបានបញ្ចប់ អ្នកទាំងនេះត្រូវបានបញ្ជូនទៅស្ទូងស្រូវនៅក្នុងកសិដ្ឋានសហករណ៍ ។ ថ្វីបើពេលខ្លះប្រជាជនបានទទួលរបបគ្រប់គ្រាន់ ជាពិសេសនៅក្នុងរយៈពេលពីរខែក្រោយពេលការប្រមូលផលក៏ដោយ ប៉ុន្តែភាគច្រើនប្រជាជនទទួលបានតែបបរាវៗប៉ុណ្ណោះ ។ ប្រជាជនជាច្រើនរយនាក់បានស្លាប់ដោយសារការអត់អាហារនិងអាហាររូបបត្ថម្ភមិនគ្រប់គ្រាន់ ទោះការរស់នៅក្នុងសហករណ៍ជាក់ស្តែងទទួលការផ្គត់ផ្គង់បាយមិនគ្រប់គ្រាន់ ។ ឡុក ឡេង ជាអ្នកចម្អិនអាហារនៅក្នុងសហករណ៍ស្បាស្រុកកណ្តៀង ខេត្តពោធិ៍សាត់ បាននិយាយថាប្រធានសហករណ៍បានដាក់កម្រិតចំនួនអង្ករឲ្យប្រជាជនទោះបីជានៅក្នុងឃ្លាំងមានអង្ករពេញក៏ដោយ ។ ប្រធានសហករណ៍បានដាក់បញ្ញាយ៉ាងតឹងរ៉ឹងទៅលើចំនួនអង្ករដែលអនុញ្ញាតឲ្យឡេង យកពីឃ្លាំងសម្រាប់ចម្អិនឲ្យសហករណ៍ ។ ចំនួននេះគឺមានចាប់ពី៣ទៅ១៥កំប៉ុងសម្រាប់ប្រជាជន៦០នាក់ ។ ជាពិសេសប្រជាជនដែលឈឺឆាប់ឃ្លាន (អ្នកទាំងនេះមិនអាចទទួលរបបពេញទេប្រសិនបើជាមិនបានធ្វើការ ។ ទោះជាយ៉ាងណាក៏ដោយប្រជាជនចាស់អ្នកដែលបានរស់នៅតំបន់ក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហមមុនពេលបែកទីក្រុងភ្នំពេញ) ពេលខ្លះបានស្នើសុំនិងទទួលបានរបបអង្ករបន្ថែម ចំណែកប្រជាជនថ្មីកម្រទទួលបានរបបច្រើនជាងរបបប្រចាំថ្ងៃណាស់ ។ លើសពីនេះទៀតការស្វែងរកអាហារដោយគ្មានការអនុញ្ញាតត្រូវបានហាមឃាត់ ។ ប្រសិនបើប្រជាជនត្រូវបានចាប់ដោយការស្វែងរកអារហារលើសពីម្តងអ្នកនោះជាធម្មតានឹងត្រូវបានចាប់ខ្លួននិងពេលខ្លះត្រូវបានប្រហារជីវិតទៀតផង ។

## ការនាំអង្ករចេញ

ហេតុផលមួយដែលប្រជាជនមិនបានហូបអង្ករដែលខ្លួនបានដាំគឺថា អង្ករមួយចំនួនធំត្រូវបានបញ្ជូនទៅកន្លែងឆ្ងាយដើម្បីសម្រេចគោលដៅនៃការនាំចេញរបស់ថ្នាក់ដឹកនាំរបស់ខ្មែរក្រហម ។ ផែនការ៤ឆ្នាំ ដែលគេប៉ាន់ប្រមាណថាជាគម្រោង «មហាលោតផ្លោះ» របស់ប្រទេសពីឆ្នាំ១៩៧៧ដល់១៩៨០ ត្រូវការនាំចេញអង្ករកម្ពុជា២៩ភាគរយ ។ ផែនការនេះបានគ្រោងថាកម្ពុជានឹងនាំចេញអង្ករ ៤០០.០០០តោននៅក្នុងឆ្នាំ១៩៧៧ ហើយនឹងកើនឡើងដល់១.៣លានតោននៅក្នុងឆ្នាំ១៩៨០ ។ ផែនការទាំងនេះគឺជាការកើនឡើងភ្លាមៗនូវអង្ករកម្ពុជា១៥០.០០០តោនត្រូវនាំចេញនៅក្នុងឆ្នាំ១៩៧៦ ។ យោងទៅតាមផែនការនាំអង្ករ

ចេញអាចនឹងបង្កើតបាន១.៤កោដិដុល្លារ (៩០ភាគរយនៃការរំពឹងទុកការធ្វើពាណិជ្ជកម្មជាមួយបរទេស) ។ ដើម្បីសម្រេចតាមទិសដៅនេះ ទិន្នផលស្រូវអាចនឹងកើនឡើងលើសពី១តោនក្នុង១ហិកតាដល់៣តោនក្នុង១ហិកតា (ទិន្នផលស្រូវ៦តោនបានមកពីការដាំដុះនៅលើដីពីរដង) ។

ផែនការ៤ឆ្នាំអំពាវនាវឲ្យភូមិភាគពាយ័ព្យទទួលនាទីចែកផលស្រូវដោយគ្មានសមាមាត្រ ។ តាមរយៈផែនការនៅឆ្នាំ១៩៨០ នៅតំបន់ភាគពាយ័ព្យនឹងទទួលខុសត្រូវក្នុងការនាំអង្ករកម្ពុជាចេញចំនួន៦០ភាគរយ ។ តំបន់ភាគពាយ័ព្យមានគម្រោងបង្កើនទំហំដីដែលប្រមូលផលបានពីរដងចំនួន១៤០.០០០ហិកតា ដោយមិនមានការកាត់បន្ថយទំហំដីដែលប្រមូលផលបានមួយដងផង ។ គ្មានការបកស្រាយណាបង្ហាញថាដីចំនួន១៤០.០០០ហិកតានេះមាននៅកន្លែងណានោះទេ ។ លើសពីនេះទៅទៀតមិនដូចនៅតំបន់ផ្សេងទៀតគ្មានការចាត់តាំងចែកអាហារដល់ប្រជាជនឡើយ ។ តំបន់ភាគពាយ័ព្យត្រូវបានរំពឹងទុកថានឹងផលិតស្រូវបាន១,៦២លានតោន ប៉ុន្តែមិនបានបើកឲ្យតាមរបបកំណត់ ។ ផ្ទុយពីនេះវិញ ៤៧០.០០០តោននៅក្នុងចំណោមស្រូវ១,១៤លានតោនដែលភាគនិរតីផលិតបានត្រូវបានស្តុកទុកសម្រាប់ចិញ្ចឹមប្រជាជន ។ នៅភាគពាយ័ព្យក៏បានដកហូតពន្ធរឹតតែខ្លាំង ។ នៅខណៈពេលនោះផែនការត្រូវការដកហូតផលិតផលស្រូវ២០ភាគរយពីតំបន់ផ្សេងនានា ហើយស្រូវពាក់កណ្ដាលរបស់ភូមិភាគពាយ័ព្យត្រូវទុកសម្រាប់ជា «ជំនូនសម្រាប់រដ្ឋ» ។

ទោះបីជាផែនការ៤ឆ្នាំមិនដែលបានប្រតិបត្តិជាផ្លូវការក៏ដោយថ្នាក់ដឹកនាំរបស់ខ្មែរក្រហមបានដាក់ចំណុចសំខាន់ជាច្រើនទៅលើការនាំអង្ករចេញ ។ អង្ករជាច្រើនដែលបានដាំដុះនៅភាគពាយ័ព្យត្រូវបានបញ្ជូនទៅភ្នំពេញនិងប្រទេសចិន ។ នៅដើមឆ្នាំ១៩៧៦ កប៉ាល់ដឹកអង្ករបានចាកចេញពីកំពង់ផែកំពង់សោមឆ្ពោះទៅប្រទេសចិនស្ទើរតែរាល់ថ្ងៃ ។ ឯកសារមួយបានបង្ហាញថានៅក្នុងឆ្នាំ១៩៧៦ នៅតំបន់ពាយ័ព្យបាននាំចេញអង្ករ ៥០.០០០តោន ក្នុងខណៈដែលប្រទេសបាននាំចេញអង្ករទាំងស្រុងចំនួន១៥០.០០០តោន ។ ក៏មានឯកសារមួយបង្ហាញផងដែរថា ការនាំចេញបានបន្តទោះបីជាស្ថានភាពអាហារកាន់តែអាក្រក់ក៏ដោយ ។ ឯកសារមួយបានផ្ញើជូន ខៀវ សំផន ប្រមុខរដ្ឋនៅរបបកម្ពុជាប្រជាធិបតេយ្យបានបង្ហាញថា ចាប់ពីខែមករា ដល់ខែកញ្ញា ១៩៧៨ កម្ពុជាបាននាំចេញអង្ករ២៩.៧៥៨តោន ដែលមានតម្លៃស្មើនឹង ៥,៩១១,៨៨៣ដុល្លារទៅកាន់ប្រទេសចិន ។ ឯកសារផ្សេងៗទៀតបង្ហាញថា អង្កររាប់តោនត្រូវបាននាំចេញទៅប្រទេសម៉ាដាហ្កាសា យូហ្គោស្លាវី និងហុងកុង ។ លើសពីនេះទៀត ថ្វីបើជីវភាពជាក់ស្តែងនៃស្រូវ «រាប់ពាន់តោន» នៅភ្នំពេញក៏ដោយអង្ករបានដាំនៅភាគពាយ័ព្យត្រូវបានបញ្ជូនទៅកាន់ទីក្រុងដើម្បីផ្គត់ផ្គង់កងទ័ពនិងអ្នកធ្វើការបម្រើបក្ស ។ នារីកម្នាក់បានរាយការណ៍ថា «គ្មានការដឹកជញ្ជូនអង្ករទៅភាគពាយ័ព្យឬទិសខាងជើងទេ» ។

តាមរយៈយុទ្ធសាស្ត្រចែកចាយរបស់របបខ្មែរក្រហមបានបង្កើតជាក្រុមថ្មីផ្សេងៗ ក្រុមនីមួយៗមានឯកសិទ្ធិពិសេស ។ នៅខណៈពេលប្រជាជននៅតាមមូលដ្ឋានតែងតែទទួលបានរបបបន្ថែមឬទទួលបានការអនុញ្ញាតឲ្យមានការដាំបន្លែសម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួន ប្រជាជនថ្មីពិបាកនឹងទទួលបាននូវអត្ថប្រយោជន៍ក្នុងការរក្សាជីវិតណាស់ ។ ក៏ប៉ុន្តែទាហានទទួលបានរបបច្រើនជាងប្រជាជនដែលរស់នៅក្នុងសហករណ៍ ។ ឯកសារកម្ពុជាប្រជាធិបតេយ្យមួយបានបង្ហាញថាចាប់ពីថ្ងៃទី១០ ខែមេសា ដល់ថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៧៧ កងទ័ពទទួលបានអង្ករ០,៧គីឡូក្រាមក្នុងមួយថ្ងៃ បើប្រៀបធៀបនឹងបបររាវដែលអ្នកនៅរស់ជាច្រើនបានរាយការណ៍ ។ ឯកសារផ្សេងទៀតបានបង្ហាញថាកងទ័ពទទួលបានរបប សាច់ អំបិល និងប្រហុក ។ កម្មាភិបាលនៅក្រោមបង្គាប់ទទួលបានរបបបន្ថែម និងអ្នកដឹកនាំជាច្រើនសប្បាយរីករាយនឹងពិធីជប់លៀងផ្សេងៗ ។ ទោះជាយ៉ាងណាការឃោសនាជាច្រើនរបស់ខ្មែរក្រហមពិភាក្សាអំពីទិសដៅនៃការផលិតអង្ករ៣តោនក្នុងមួយហិកតា និងការពន្យល់អំពីបច្ចេកទេសបន្តិចបន្តួចដែលបានផ្តល់ឲ្យជាវិធីដើម្បីសម្រេចតាមផែនការដែលបានធ្វើឡើង ។ ជំនួសឲ្យការបដិវត្តន៍ និងវិធីដែលមិនបានបញ្ជាក់អំពីការរៀបចំដីដាំពីរដងគឺមានន័យថា ក្តីសង្ឃឹមដែលបានកើនឡើងទាំងនេះគឺទទួលបាន ។ ការជឿជាក់ថា នៅក្នុងបដិវត្តន៍អាចជម្នះរាល់ឧបសគ្គដែលធ្វើឲ្យខូចផលិតផល ។ ប្រជាជនដែលបានជ្រើសរើសឲ្យគ្រប់គ្រងគម្រោងកសិកម្មគឺពឹងផ្អែកលើការលះបង់របស់អ្នក

ទាំងនេះចំពោះបដិវត្តន៍ជាជាងមានជំនាញ ។ កសិករដែលមានចំណេះដឹងខាងកសិកម្មដែលបានដាំដុះជាច្រើនឆ្នាំត្រូវបានបណ្តេញដូចជាក្រុមចក្រពត្តិនិយម ។ ជាលទ្ធផលគម្រោងដាំដុះនិងបញ្ចូលទឹកគឺមិនសូវបានផល ។

មិនមែនជាការភ្ញាក់ផ្អើលទេដែលសហករណ៍យល់ឃើញថាវាមិនអាចសម្រេចគោលដៅផលិតផលរបស់ខ្លួន ។ ប៉ុន្តែប្រធានសហករណ៍ដែលមិនអាចធ្វើតាមការរំពឹងទុករបស់ថ្នាក់ដឹកនាំគ្មានជម្រើសឡើយ ។ ប្រជាជនជាច្រើនត្រូវបានបញ្ចុះបញ្ចូលតាមការឃោសនាគណបក្សនិងឲ្យជឿជាក់ថា ការមិនសម្រេចបានតាមទិសដៅរបស់បក្សត្រូវបានចាត់ទុកថាមានភាពមិនស្មោះត្រង់ ។ អ្នកផ្សេងទៀតភ័យខ្លាចពីការមិនអាចសម្រេចបានតាមទិសដៅនេះ ។ ដូច្នេះប្រធានសហករណ៍តែងធ្វើរបាយការណ៍អំពីទិន្នផលល្អប្រសើរទៅថ្នាក់លើជាងការដែលខ្លួនបានសម្រេចជាក់ស្តែង ។ ប្រធានសហករណ៍បានដកពន្ធលើអង្ករដែលខ្លួនមិនបានផលិត ។

**ការបញ្ជាក់ថាមេដឹកនាំខ្មែរក្រហមបានដឹងអំពីកង្វះអាហារ**

ភ័ស្តុតាងមួយចំនួនបញ្ជាក់ថាមេដឹកនាំខ្មែរក្រហមបានដឹងថាប្រជាជនកំពុងខ្វះខាតអាហារ ប៉ុន្តែអ្នកទាំងនោះមិនបានចាត់វិធានការដើម្បីបញ្ឈប់បញ្ហានេះទេ ។ ជាឧទាហរណ៍ថ្នាក់ដឹកនាំទំនងជាដឹងថា ការនិរទេសបានបង្កឲ្យមានមហន្តរាយ ។ ហង្ស ទាវ សមាជិកគណកម្មាធិការបក្សកុម្មុយនីសកម្ពុជាប្រចាំតំបន់ពាយ័ព្យនិយាយថា មូលសម្បត្តិ ជាកងទាហានម្នាក់ទទួលខុសត្រូវការងារនៅភាគពាយ័ព្យបានជំទាស់នឹងការនិរទេសនេះថា «នៅពេលដែលគាត់បានដឹងពីផែនការរបស់ថ្នាក់ដឹកនាំនៅក្នុងឆ្នាំ១៩៧៥ គាត់បានគំរាមអ្នកទាំងនេះថា «កុំដឹកជញ្ជូនអ្នកទាំងនេះមកទីនេះ» «អ្នកទាំងនេះកំពុងតែត្រូវបោះបង់ចោល» ។ លើសពីនេះទៀតមានភ័ស្តុតាងថារបាយការណ៍រៀបរាប់ពីកង្វះខាតអាហារនៅក្នុងភូមិភាគពាយ័ព្យទៅដល់ទីក្រុងភ្នំពេញ ។ នៅពាក់កណ្តាលឆ្នាំ១៩៧៦ ប៉ុល ពត បានបញ្ជូន អៀង ធីរិទ្ធ រដ្ឋមន្ត្រីសង្គមកិច្ចទៅធ្វើការ «ស៊ើបអង្កេតការគ្រប់គ្រងនៅក្នុងផ្នែកសុខភាព តមអាហារ និងផ្ទះរបស់កម្មករ» នៅក្នុងភាគពាយ័ព្យ ។ នាងបានរាយការណ៍ថា ប្រជាជនមិនមាន



ប្រជាជនវិលត្រឡប់មកលំនៅដ្ឋានវិញក្នុងឆ្នាំ១៩៧៩

អាហារហូបគ្រប់គ្រាន់និងបានស្លាប់ដោយសារជំងឺគ្រុនចាញ់និងរាក ។ ទោះជា អៀង ធីរិទ្ធ បានស្តីបន្ទោសឲ្យស្ថានភាពដែលគួរឲ្យខ្លើមបែបនេះទៅលើសត្រូវដែលបានជ្រៀតចូលឋានៈនៅតំបន់ភាគពាយ័ព្យក៏ដោយ ក៏សេចក្តីរាយការណ៍នេះបានសន្មតថាបានទៅដល់ភ្នំពេញដែលបញ្ជាក់ថ្នាក់ដឹកនាំខ្មែរក្រហមបានដឹងថាប្រជាជននៅភាគពាយ័ព្យបានស្លាប់ដោយសារការខ្វះអាហារនៅដើមឆ្នាំ ១៩៧៦ ។

នីក លី ជាប្រធានសហករណ៍នៅឃុំអូរដំបងបានរាយការណ៍ការថាឃើញអ្នកដឹកនាំជាន់ខ្ពស់មកសួរសុខទុក្ខសហករណ៍នៅភាគពាយ័ព្យ ហើយបាននិយាយថាថ្នាក់ដឹកនាំបានបញ្ជូនអ្នកស៊ើបការណ៍ចូលទៅក្នុងសហករណ៍ដើម្បីរាយការណ៍ពីអ្វីដែលកំពុងកើតមានឡើង ។ ទោះជាមានឬមិនមានភ័ស្តុតាងច្បាស់លាស់នៅក្នុងរបាយការណ៍ទាំងនេះ ឬក៏ទោះជាអ្នកទាំងនេះបានទៅជួបថ្នាក់ដឹកនាំនៅភ្នំពេញក៏ដោយ វាមិនអាចថាការធ្វើដំណើរនេះអាចធ្វើឡើងដោយគ្មានការប្រុងប្រយ័ត្នការត្រួតពិនិត្យរបស់ថ្នាក់ដឹកនាំចំពោះការពិតដែលប្រជាជននៅក្នុងសហករណ៍កំពុងតែស្លាប់ដោយការអត់អាហារនោះទេ ។

ការយល់ដឹងពីស្ថានភាពអាក្រក់នៅភាគពាយ័ព្យក៏អាចបង្ហាញពីរបាយការណ៍របស់ការប្រជុំបក្សដែរ ។ នៅដើមឆ្នាំ ១៩៧៧ នៅក្នុងការប្រជុំ «គណៈអចិន្ត្រៃយ៍» ហូ នឹម រដ្ឋមន្ត្រីពត៌មាននិងមេដឹកនាំបដិវត្តន៍បាននិយាយអំពីកង្វះខ្វះអាហារនៅក្នុងភាគពាយ័ព្យ ។ នៅក្នុងការទទួលខុសត្រូវចំពោះកង្វះខ្វះអាហារនៅក្នុងភាគពាយ័ព្យ នឹម បានរាយការណ៍ស្នើសុំថាឲ្យមានការចាយលុយឡើងវិញដើម្បីជាការបង្កើតការលើកទឹកចិត្តក្នុងការបង្កើនផលិតផល ។ រឿងរ៉ាវរបស់ នឹម ត្រូវបានបញ្ជាក់ដោយ លឹម មាន អ្នកដឹកនាំតំបន់របស់បក្សកុម្មុយនីស្តកម្ពុជាដែលបានរត់ទៅប្រទេសថៃនៅឆ្នាំ១៩៧៨ ។ មាន បានរាយការណ៍ថា អ្នកដឹកនាំមួយចំនួនរួមទាំង ហូ នឹម ផង បានស្នើសុំបក្សដើម្បីឲ្យមានការលើកទឹកចិត្តដល់ប្រជាជននិងបញ្ចូលឲ្យមានការចាយលុយឡើងវិញ ។ មានដែលមានឈ្មោះថា រស់ ញឹម អ្នកដឹកនាំនៅតំបន់ភាគពាយ័ព្យរហូតឆ្នាំ១៩៧៧ ជាអ្នកដែលបានធ្វើអន្តាគមន៍ជំនួសឲ្យការខ្វះអាហាររបស់ប្រជាជន ។ ការរាយការណ៍របស់ នឹម បានបន្តរហូតទៅដល់ថ្នាក់ដឹកនាំខ្មែរក្រហមដើម្បីប្រឆាំងនឹងរដ្ឋធម្មនុញ្ញ ហើយទទួលយកជំនួយបរទេសដើម្បីការពារប្រជាជនកម្ពុជាចេញពីការរងទុក្ខ ។ ទោះជាយ៉ាងណាក៏ដោយថ្នាក់ដឹកនាំបានយល់ថាទាំងការបង្កើតឲ្យមានការចាយលុយឡើងវិញ និងជំនួយបរទេសដែលជាការប្រឆាំងនឹងបដិវត្តន៍ ហើយសំណូមពរទាំងនេះត្រូវបានបដិសេធ ។

ទោះបីជាយ៉ាងណាក៏ដោយមានភ័ស្តុតាងថា កង្វះអាហារគឺជាមូលហេតុមួយនៃការយល់ឃើញមនុស្សមួយចំនួនចំពោះថ្នាក់ដឹកនាំខ្មែរក្រហម ។ ការទទួលរបបអាហារមិនគ្រប់គ្រាន់គឺជាការពិបាកនឹងទប់ស្កាត់តាមការប៉ាន់ស្មានរបស់គិលានុបដ្ឋាយិការម្នាក់ដែលធ្វើការនៅក្នុងមន្ទីរពេទ្យកម្ពុជាប្រជាធិបតេយ្យថា ស្ត្រី៩០ ភាគរយអត់មានរដូវ ។ ដូច្នេះផលវិបាកនេះបានធ្វើឲ្យអត្រាកំនើតប្រចាំឆ្នាំមានការថយចុះយ៉ាងខ្លាំង ។ រយៈពេលជិត៤ឆ្នាំនៃរបបខ្មែរក្រហមតាមការប៉ាន់ស្មានថា ស្ថានភាពរស់នៅបានកាត់បន្ថយអត្រាកំណើត៥៧០.០០០ ។ អត្រាស្លាប់របស់ទារកនិងកុមារក៏បានកើនឡើង ។ ដើម្បីដោះស្រាយបញ្ហានេះ បក្សបានរៀបចំអាពាហ៍ពិពាហ៍ទាំងបង្ខំ ។ ដោយសារតែកូនក្រមុំដែលពុំមានអាហារគ្រប់គ្រាន់ទទួលទានដូចជាជីវភាពសាច់ប្រូតេអ៊ីននោះ ស្ត្រីពុំអាចមានផ្ទៃពោះបាន ។ នេះបញ្ជាក់ថា កម្មាភិបាលខ្មែរក្រហមដែលមានមុខនាទីប្រតិបត្តិនិងប្តូរគោលការណ៍របបអាហារបានដឹងថាប្រជាជនកំពុងតែខ្វះខាតអាហារ ។ សំខាន់ជាងនេះទៀតវាបញ្ជាក់ថាការផ្តល់បន្ថែមធ្វើឡើងដើម្បីឲ្យស្ថានភាពធូរស្រាលនៅពេលដែលសមស្របចំពោះបក្ស ។

## សរុបសេចក្តី

ព្រះរាជអាជ្ញានៅអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជាហាក់ដូចជាមិនមានការពិបាកធ្វើការបង្ហាញថាកង្វះអាហារបានកើតមានឬក៏អាចបង្ហាញថានេះជាលទ្ធផលរបស់សកម្មភាពឧក្រិដ្ឋកម្ម ។ ប៉ុន្តែការជាប់ទាក់ទងមេដឹកនាំជាន់ខ្ពស់របស់ខ្មែរក្រហមចំពោះបទឧក្រិដ្ឋនេះនឹងអាចជាជម្លោះដ៏ខ្លាំងមួយ ។ យ៉ាងណាក៏ដោយ ដោយសារតែកង្វះអាហារជាបទឧក្រិដ្ឋដែលអ្នកនៅរស់ជាច្រើនយល់ពីបទពិសោធន៍របស់ខ្លួននៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យការកាត់ទោសគួរតែប្រឹងប្រែងដើម្បីដោះស្រាយបញ្ហានេះ ។ **ស្ទឹមម៉ុន ដាស៊ី**

# ខ្ញុំចង់រំឭក ខ្ញុំចង់ឃើញ ខ្ញុំចាំមើល

ក្នុងភាពជាកុមារអាយុ ១១ឆ្នាំក្នុងជំនាន់ប៉ុលពត ខ្ញុំរស់នៅភូមិទួរ៉ុលើ ឃុំព្រែកពោធិ៍ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ។ ស្ថិតនៅកងកុមារក្នុងភូមិខ្ញុំមានភារកិច្ចជីជីជំបូក កាប់ដើមទន្រ្ទានខែត្រ ដើរកើបនិងប្រមូលលាមកសត្វសម្រាប់ធ្វើជីដាក់ស្រែនិងពេលខ្លះត្រូវរៀនក្នុងថ្នាក់ ។

ខ្ញុំត្រូវអ្នកគ្រូដាក់ទណ្ឌកម្មឲ្យស្រាតខោនិងដោះអាវចេញ លុតក្បាលជង្គង់លើសំបកខ្នុរ ស្រែកអាក្រោសទិតៀនខ្លួនឯងកុំឲ្យកុមារដទៃទៀតយកតម្រាប់តាម ដោយសារតែខ្ញុំកើបលាមកគោមិនគ្រប់ផែនការអង្គការ ។ ខ្ញុំចាំបានថា កាលណោះក្បាលជង្គង់របស់ខ្ញុំចេញឈាមរឹមៗ ឈឺពើតផ្សាទនិងហើមមួយរយៈ ម្តាយរបស់ខ្ញុំជាចុងភៅនៅរោងបាយរួមនិងជាប្រជាជនមូលដ្ឋានចាស់ ហេតុនេះខ្ញុំមានសំណាងជាងកុមារជាច្រើនដែលមានគ្រួសារជាប្រជាជនថ្មី ដោយបានបាយក្តាំងហូបខ្លះៗដែលម្តាយខ្ញុំលួចលាក់ទុកឲ្យ ហើយកុមារជាច្រើនគ្មានឱកាសនិងសំណាងបានហូបដូចខ្ញុំឡើយ ។

ខ្ញុំបានឃើញពីភាពខុសគ្នាក្នុងការរស់នៅការបញ្ចេញពលកម្មរវាងប្រជាជនចាស់និងប្រជាជនថ្មី ខ្ញុំបានឃើញផ្ទាល់ភ្នែកអ្នកទោសត្រូវគេទឹមដូចសត្វគោក្របី ។ អ្នកទោសរូបរាងស្គមស្គាំងស្លេកស្លាំង ស្លៀកខោខ្លីលែងខ្លួនទទេកំពុងតែអូសរទេះគោដែលមានដាក់ជុំឥដ្ឋពេញ អ្នកឯទៀតរុញរទេះ ហើយឈ្លបកាន់កាំភ្លើងនិងខ្សែតីដើរឃ្លាំមើលពីក្រោយ ។ អ្នកទោសម្នាក់បានដើររើសស្លឹកល្ហុងទុំដែលជ្រុះពីដើមតាមផ្លូវមុខផ្ទះខ្ញុំ គាត់មូលចូលចង្កេះខោយ៉ាងប្រញាប់ប្រញាល់ បុរសម្នាក់ដែលកាន់ខ្សែតីឃើញទាន់វាយអ្នកទោសរូបនោះនឹងខ្សែតីដូចគេវាត់សេះ អ្នកទោសគ្មានស្រែកមួយម៉ាត់ ។ ខ្ញុំឃើញខ្នងគាត់បែកឈាមរឹមៗ ប៉ុន្តែគាត់មិនខ្វល់ស្មុះរុញបន្តទៅមុខទៀត ។ ក្រោយមកទើបខ្ញុំដឹងថា គាត់យកស្លឹកល្ហុងទុំទៅមូរជក់ដូចបារី ។ សមមិត្ត នួន ជា និងសមមិត្ត ខៀវ សំផន អើយ មនុស្សសោះហេតុអ្វីក៏សាច់កម្មដូចតិរច្ឆាន ។ នេះគឺជាទិដ្ឋភាពរន្ធត់មួយដែលបានដិតជាប់ក្នុងខួរក្បាលរបស់ខ្ញុំដល់សព្វថ្ងៃនេះ ។

ខ្ញុំមានចំណាប់អារម្មណ៍ចូលចិត្តអានតាមដានរឿងខ្មែរក្រហម និងបញ្ចេញទស្សនៈរបស់ខ្ញុំជារបៀបសាមញ្ញត្រង់ៗទាក់ទងនឹងថ្នាក់ដឹកនាំខ្មែរក្រហម ។ ជាយូរមកហើយខ្ញុំប្រាថ្នាចង់ឃើញរូបសំណាក់របស់អតីតមេដឹកនាំខ្មែរក្រហមសំខាន់ៗត្រូវបានគេកសាងឡើងដាក់ទីសាធារណៈ និងតាមវាលពិឃាតសំខាន់ៗដោយមានសរសេរដាក់ក្នុងន័យពេបជ្រាយ ដែលនេះអាចជាសំណងផ្លូវចិត្តដែលខ្ញុំបានពុថាជនរងគ្រោះអាចទទួលសំណងជំងឺចិត្តជាវត្តអនុស្សាវរីយ៍ ។

ខ្ញុំសែនសប្បាយចិត្តនៅពេលឃើញរួចហើយនូវក្បាលរបស់មេដឹកនាំខ្មែរក្រហមសំខាន់ៗត្រូវបានគេសូនជាចានគោះបារី ។ ខ្ញុំចង់ឃើញគេធ្វើជាកន្ទោរ ទ្រនាប់ជូតជើង ចានបន្តន់ជាបន្ថែមទៀត ។ ខ្ញុំស្រមៃនឹងមានមនុស្សជាក្រុម ជាបុគ្គលនិងរូបខ្ញុំដែលមានការតាំងចិត្តទុកជាមុននាំគ្នាទៅខាកស្តោះប្តុបន្ទោរបង់ដាក់ផ្នូរមេដឹកនាំខ្មែរក្រហមនៅថ្ងៃណាមួយ ។

ខ្ញុំឆ្ងល់នឹងសួរខ្លួនឯងថា ហេតុអ្វីបានជាមេដឹកនាំខ្មែរក្រហមកំពូលៗដែលនៅរស់រានមានជីវិតដូចជាសមមិត្ត នួន ជា និងសមមិត្ត ខៀវ សំផន ជាដើមមិនហ៊ានត្រឡប់ទៅរស់នៅឯស្រុកភូមិកំណើតរបស់ខ្លួនវិញ នៅពេលស្រុកសាន្តត្រាណបែរជាទៅរស់នៅទីចុងកាត់មាត់ញកភ្លេចអស់រដូវទៅលេងស្រុក ជួបជុំបងប្អូនដូចជាៈពេលចូលឆ្នាំខ្មែរ បុណ្យភ្ជុំបិណ្ឌ រដូវសែនដូនតា ។ ចម្លើយគឺមានតែសមមិត្តទាំងនោះទេដែលដឹងច្បាស់ ។

ខ្ញុំដូចជាមិនស្ងប់ចិត្តពេលអានកាសែតពុថា នៅសាលាក្តីខ្មែរក្រហមមានអ្នកយំនិងអ្នកសើច ។ អ្នកយំគឺអ្នកមកប្តឹង អ្នកសើចគឺសមមិត្ត នួន ជា និងក្រុមគ្រួសារដោយសារលក្ខខណ្ឌរស់នៅដ៏ប្រសើរ ។ ខ្ញុំរង់ចាំមើលថាតើនៅពេលដែលសាលាក្តីខ្មែរក្រហមបញ្ចប់ទៅ តើវាសនាសមមិត្តទាំងនោះនឹងក្លាយទៅជាយ៉ាងណា?

តើពេលនោះ នឹងមានមូលនិធិសម្រាប់ទ្រទ្រង់លក្ខខណ្ឌរស់នៅដ៏មហាប្រសើររបស់អតីតមេដឹកនាំទាំងនេះបន្តទៅទៀតទេ? តើនឹងមានភាពខុសគ្នាយ៉ាងណារវាងអ្នកទោសឧក្រិដ្ឋនៅគុកព្រៃសនិងបណ្ដាអតីតសមមិត្តទាំងនោះ? តើការផ្សះផ្សានិងបង្រួបបង្រួមជាតិនឹងត្រូវបញ្ចប់ឬ? នៅពេលសាលាក្ដីនេះបញ្ចប់ទៅឬក៏យ៉ាងណា? នេះជាអ្វីដែលខ្ញុំកំពុងតែទន្ទឹងរង់ចាំមើលវាសនាចុងក្រោយរបស់បណ្ដាអតីតសមមិត្តមេដឹកនាំខ្មែរក្រហម ។

ជាពុទ្ធសាសនិកជនខ្ញុំជឿលើកម្មផល ខ្ញុំជឿថាសព្វថ្ងៃនេះបណ្ដាអតីតសមមិត្តដឹកនាំកំពូលៗនៃរបបខ្មែរក្រហមប្រហែលជាគេងមិនសូវលក់ស្រួលទេដោយមន្ទិលទៅលើវាសនាចុងក្រោយរបស់ខ្លួន មិនដឹងជាត្រូវឡើងសវនាការនៅថ្ងៃណា កាត់សេចក្ដីយ៉ាងដូចម្ដេច ប៉ុន្ដែការភ័យព្រួយទាំងនោះមានទំហំតូចជាងការភ័យភិតរបស់ប្រជាជនខ្មែរដែលរស់នៅក្រោមរបបខ្មែរក្រហមឆ្ងាយណាស់ ។ ខ្ញុំជឿជាក់ថា អតីតមេដឹកនាំខ្មែរក្រហមមិនគ្រាន់តែទទួលនូវភាពអាម៉ាស់និងវិប្បដិសារីចំពោះពូជពង្សវង្សត្រកូលមិត្តភក្ដិនិងស្រុកកំណើតរបស់ខ្លួនប៉ុណ្ណោះទេ ថែមទាំងកំពុងតែទទួលបាននូវការស្អប់ខ្ពើមនិងការអាម៉ាស់មុខជាលក្ខណៈអន្តរជាតិទៀតផង ។

ខ្ញុំសូមកោតសរសើរនិងគោរពចំពោះការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាដែលបានខិតខំស្រាវជ្រាវចងក្រងទុករាល់ឯកសារនិងរូបថតទាំងឡាយដែលបង្ហាញពីអតីតកាលដ៏រន្ធត់ក្នុងសម័យកាលរបបកម្ពុជាប្រជាធិបតេយ្យ ។

ស្រីសន្ធរ, ថ្ងៃទី៣០ ខែ១០ ឆ្នាំ២០០៧

**អតីតកុមាររងគ្រោះនៃរបបកម្ពុជាប្រជាធិបតេយ្យ**

## លិខិតពីមិត្តអ្នកអាន

### *សូមគោរពលោកនាយកមជ្ឈមណ្ឌលឯកសារស្វែងរកការពិតពីចម្ងាយ!*

ខ្ញុំបាទមានកិត្តិយសសូមប្រកាសជូនដំណឹងអំពីការស្រាវជ្រាវរកជនរងគ្រោះ!

នៅសម័យខ្មែរក្រហម ខ្ញុំរស់នៅភូមិតាឥន្ទ (បច្ចុប្បន្នហៅភូមិត្រពាំងវែងខាងលិច) ឃុំត្រពាំងរាំង ស្រុកជុំគីរី ខេត្តកំពត ។ កាលនោះខ្ញុំនៅកុមារតូចនៅឡើយ ។ ថ្ងៃមួយខ្ញុំបានជួបបុរសម្នាក់មាឌក្រអាញសាច់ដុំធំៗ សម្បុរស្រអែម គាត់ឈ្មោះ ឡុង អានជាអ្នកប្រដាល់កាលពីសង្គមចាស់ ។ ពេលខ្ញុំបានជួបនិងឃើញគាត់ អ្នកស្រុកខ្ញុំបានសុំឲ្យគាត់សាកបញ្ចេញក្បាច់ប្រដាល់មើល គាត់ក៏បានធ្វើឲ្យមើលដូចជាក្បាច់ចាប់ទាត់ធាក់យ៉ាងស្ទាត់ជំនាញគួរឲ្យចង់មើលនិងស្ងើចសរសើរពីវិជ្ជារបស់គាត់ ។ គាត់ជាប្រជាជនថ្មីមិនដឹងគាត់ជម្លៀសមកពីភូមិឃុំស្រុកខេត្តណាទេ មកនៅភូមិតារាជ្យជាប់នឹងភូមិរបស់ខ្ញុំ ។ ក្រោយមកខ្ញុំបានសាកសួររកឈ្មោះគាត់អ្នកភូមិបានប្រាប់ខ្ញុំថា គាត់ត្រូវគេយកទៅសម្លាប់បាត់ហើយ តែខ្ញុំមិនបានសួរថាតើគេយកគាត់ទៅសម្លាប់នៅកន្លែងណាទេ ។ រហូតមកដល់ពេលនេះ ខ្ញុំនៅតែនឹកឃើញគាត់និងសែនស្រណោះអំពីជីវិតរបស់គាត់ក៏ដូចបងប្អូនពូមីងខ្ញុំនិងជនរួមជាតិដែលទទួលរងគ្រោះត្រូវឈ្លបសម្លាប់ដូចសត្វធាតុ ។

ព័ត៌មានដែលខ្ញុំបានដឹងខាងលើចាត់ទុកជាការជូនដំណឹងដល់បងប្អូន សាច់ញាតិ ឪពុកម្ដាយរបស់គាត់បានជ្រាបនឹងដឹងព្រួខ្លះៗតែប៉ុណ្ណោះ ។ ប្រសិនបើបងប្អូនមិនទាន់បានដំណឹងនេះ ហើយចង់ដឹងព័ត៌មានលម្អិតសូមអញ្ជើញទៅជួបអ្នកភូមិខាងលើប្រហែលនឹងបានដំណឹងបន្ថែមទៀតជាពុំខាន ។

សូមអរគុណក្នុងការចុះផ្សាយនូវដំណឹងនេះទុកជាប្រយោជន៍ដល់គ្រួសារទៅតាមផ្លូវធម៌ ឬជាប្រវត្តិសាស្ត្រផងដែរ ។

**គុនវ៉ា**




ឧបត្ថម្ភការបោះពុម្ពផ្សាយដោយរដ្ឋាភិបាល ដេនម៉ាក ន័រវេ ស៊ុីតដេន និងសហរដ្ឋអាមេរិក
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម/៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា : ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ : (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 97, January 2008 ◆ Funded by Denmark, Norway, Sweden, and USA.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.